លោកអាចារ្យ **ចាប ពិន** សុវណ្ណជោតោ

# ឱវាទបាតិមោក្ខ



ព.ស. ២៤៧៩ - គ.ស. ១៩៣៧

**ចម្លងតាមច្បាប់ដើម**

ព.ស. ២៥៥៥ - គ.ស. ២០១២

ក្រុងម៉ុងរអាល - កេបិក - កាណាដា

**សម្រាប់ជាធម្មទាន**

# និទានជាតិហេតុ


លោកអាចារ្យ **ចាប ពិន** សុវណ្ណជោតោ

វត្តឧណ្ណាលោម ក្រុងភ្នំពេញ

ក្រុមជំនុំព្រះត្រៃបិដក នៃពុទ្ធសាសនបណ្ឌិត្យ


រៀបរៀង

**ព.ស. ២៤៧៩ - គ.ស. ១៩៣៧**

ចម្លងឡើងវិញតាមច្បាប់ដើមដោយ

ខ្ញុំព្រះករុណា ខ្ញុំបាទ **វ៉ាត តិរក្ស**


ក្រុងម៉ុងរេអាល - កេបិក - កាណាដា

**ព.ស. ២៥៥៥ - គ.ស. ២០១២**


**សម្រាប់ជាធម្មទាន**

# សៀវភៅចាស់ដែលបានចម្លងជាថ្មី ៖

១. ស្នាព្រះហស្តក្រោយបង្អស់នៃសម្តេចព្រះមហាសុមេធាធិបតី **ជួន ណាត**

២. ធម៌នមស្ការព្រះរតនត្រ័យ ពិស្តារ - សង្ខេប

៣. ប្រស្នា គិហិប្រតិបត្តិពិស្តារ ( ឈឹម ទូច, សុង ស៊ីវ )

៤. ប្រជុំនានាធម៌សង្វេគ ( ជ័យ ម៉ៃ )

៥. អានាបានស្សតិកម្មដ្ឋាន វិបស្សនាបញ្ហាធម្មបរិយាយ ( គង់ ឌឹប )

៦. ធម្មនិយាម ៣០ និងកំណាព្យផ្សេង ៗ ( ប៊ុត សាវង្ស, ភិក្ខុ សាន សុជា )

៧. ជីវិតកថា ( ម៉ុញ សារ៉ាន ) ថ្មី

៨. ធម្មប្រទីប ( ប្រជុំកងធម៌ ឃិន វន់ )

៩. រឿង ព្រះភិក្ខុពនេចរ ( ឱម ណាគ្រី )

១០. រឿង នគរកាយ ( ចាប ពិន )

១១. ច្បាប់គោរពមាតាបិតា ( អ៊ូ ចុង )

១២. នត្ថិធម្មាធិប្បាយ ( ព្រះបិដកធម្ម អ៊ុម ស៊ុម )

១៣. ត្រៃក្ងួដធម៌ ( សុង ស៊ីវ )

# ពាក្យប្រារព្ធ

សៀវភៅ " **ឱវាទបាតិមោក្ខ** " ជាស្នាដៃរបស់លោកអាចារ្យ " **ចាប ពិន** " ដែលលោកបានរៀបរៀងឡើងនៅក្នុង ព. ស. ២៤៧៩ ត្រូវនឹង គ. ស. ១៩៣៧ ហើយបានបោះពុម្ពជាសៀវភៅនៅឆ្នាំ ១៩៤១។

ព្រះគ្រូ **សុំ ប៊ុនធឿម** (**សុវណ្ណត្ថេរោ**) គង់នៅវត្ត **ពុទ្ធសុទ្ធារាម** លោកបានយល់ថាជាសៀវភៅធម៌មានប្រយោជន៍ច្រើន ព្រះតេជព្រះ-គុណក៏បានយកសៀវភៅនេះមកពិគ្រោះជាមួយនឹងខ្ញុំព្រះករុណា ខ្ញុំបាទ ដើម្បីចម្លងបោះពុម្ពសាជាថ្មីឡើងវិញ ព្រោះសៀវភៅនេះចាស់ពេក ណាស់ទៅហើយ បាត់ក្រប រលប់អក្សរខ្លះ ៗ និងត្រូវសត្វកណ្ដៀរស៊ី ជុំវិញអស់ខ្លះទៅហើយ ...

ហេតុបច្ច័យ និងដោយមានឧបនិស្ស័យខ្លះៗ ព្រមទាំងការស្រេក ឃ្លាននូវបុណ្យ កុសលនិងមានសទ្ធាទៅលើព្រះពុទ្ធវចនៈ ថា ៖ **ធម្មទាន ឈ្នះអស់ទានទាំងពួង** ជាពិសេសគឺចង់ឲ្យសប្បុរសជនជាពុទ្ធសានិក បានជ្រួតជ្រាបនូវទស្សនៈ ទ្រឹស្ដីសំខាន់ៗ នៃព្រះពុទ្ធសាសនាផងខ្ញុំព្រះ ករុណា ខ្ញុំបាទ ក៏ទទួលយល់ព្រមពីការស្នើរបស់ព្រះគ្រូដោយឥតរុញរា ហើយខឹតខំព្យាយាមចម្លងឡើងវិញនូវសៀវភៅ " **ឱវាទបាតិមោក្ខ** " នេះទុកជាធម្មទាន លុះត្រាតែបានសម្រេចជាស្ថាពរ ។

ខ្ញុំសូមលើកហត្ថទាំងទ្វេលំអោនកាយ វាចា ចិត្តគោរពដល់ លោកគ្រូអាចារ្យ ដែលជាអ្នកប្រាជ្ញ ជាបណ្ឌិត ដែលជាម្ចាស់សៀវភៅ " **ឱវាទបាតិមោក្ខ** " នេះ សូមលោកអនុញ្ញាតដល់ខ្ញុំដើម្បីសរសេរ ចម្លង និង រៀបរៀងនូវសៀវភៅ " **ឱវាទបាតិមោក្ខ** " របស់លោក សាជាថ្មីឡើងវិញ ។

ក្នុងការចម្លងឡើងវិញនេះ ខ្ញុំព្រះករុណា ខ្ញុំបាទ បានរៀបរៀងទំព័រជាថ្មី ព្រមទាំងបានកែអក្ខរាវិរុទ្ធខ្លះផង ដោយយោងទៅតាមវចនានុក្រមខ្មែរ (២០០៨) ដែលជាស្នាព្រះហស្តរបស់សម្តេចព្រះសង្ឃរាជ **ជួន ណាត ជោតញ្ញាណោ** ប៉ុន្តែខ្លឹមសារនិងសំនួនវោហាររបស់អ្នកនិពន្ធនៅរក្សាទុកដូចដើម ។

ខ្ញុំព្រះករុណា ខ្ញុំបាទ សូមថ្លែងអំណរអរព្រះគុណ និងអំណរគុណដ៏ជ្រាលជ្រៅចំពោះ ៖

- ព្រះគ្រូចៅអធិការ **ធីវ ធីម (ចន្ទត្ថេរ)** ដែលព្រះអង្គបានជួយខ្នះខ្នែងជ្រោមជ្រែង ដោយផ្តល់នូវសៀវភៅថ្មី និងជួយពិនិត្យឡើងវិញនូវអក្ខរាវិរុទ្ធដើម្បីការពារនូវសេចក្តីត្លាំងត្លាត់ ។
- ព្រះគ្រូ **សុំ ម៉ុនធៀម (សុវណ្ណត្ថេរោ)** និង
- ឧបាសក **ម៉ិញ សាវ៉ាន** ដែលព្រះអង្គ និងលោកបានចំណាយពេលវេលាជួយត្រួតពិនិត្យ ពាក្យពេចន៍ ដើម្បីធ្វើឲ្យសៀវភៅនេះបានល្អត្រឹមត្រូវតាមច្បាប់ដើម ។

សូមឧទ្ទិសស្នាដៃថ្មីនៃសៀវភៅ " **ឱវាទបាតិមោក្ខ** " នេះ ថ្វាយ ប្រគេន ជូនដល់ ៖

❖ **សម្តេចព្រះសង្ឃរាជ ជួន ណាត ជោតញ្ញាណោ**
**ប.អ.ស - អ.ម.វ** (១)

❖ **លោកអាចារ្យ ចាប ពិន សុវណ្ណជោតោ**

ដែលលោកបានបន្សល់ទុកនៅមរតកអក្សរសាស្ត្រសម្រាប់កូនចៅខ្មែរជំនាន់ក្រោយ ។ សូមព្រះអង្គ លោកគ្រូអាចារ្យ ទទួលជ្រាបគោលបំណងល្អរបស់ខ្ញុំព្រះករុណា ខ្ញុំបាទ ហើយអនុមោទនានិងបានសោយសុខតាមសមគួរដល់គតិភពកុំបីឃ្លៀងឃ្លាតឡើយ ។

ទន្ទឹមនេះដែរ ខ្ញុំព្រះករុណា, ខ្ញុំ សូមទានមេត្តាខន្តីអភ័យទោស រាល់កំហុសឆ្គង ដែលកើតឡើងដោយ " **អវិជ្ជា** " គ្របសង្កត់ខ្ញុំ ឲ្យភ្លាំងភ្លាត់ដោយប្រការណា សូមទានព្រះករុណាម្ចាស់ព្រម ទាំងលោកអ្នកអានទាំងឡាយមេត្តាអនុគ្រោះហើយជួយជួសជុល កែ បំពេញថែកជូនដល់ខ្ញុំព្រះករុណា ខ្ញុំបាទ ផងដើម្បីជាកិច្ចអនុគ្រោះចំពោះព្រះពុទ្ធសាសនាតរៀងទៅ ។

ដោយអំណាចកុសលចិត្តជ្រះថ្លា ក្នុងព្រះពុទ្ធសាសនាបានផ្តល់ជាពលានុភាព ឲ្យអាត្មាភាព យើងខ្ញុំព្រះករុណា ខ្ញុំបាទស្រុះស្រួលមូលមតិគ្នា បរិច្ចាគបច្ច័យតាមកម្លាំងសទ្ធា សង្វាតខិតខំរៀបចំចាត់ចែងបោះពុម្ពជាសៀវភៅថ្មីនេះឡើងវិញដើម្បីប្រគេនចែកជូនជាធម្មទាន សូមអំណាចផលានិសង្ស នៃអាមិសទាន និងធម្មទាននេះ ជួយឧបត្ថម្ភដល់ពួកសត្វទាំងឡាយក្នុងចតុឱឃាជលាលោកទាំងអស់ បានទទួលឥដ្ឋមនុញ្ញផលគ្រប់ ៗ គ្នា ព្រមទាំងមានប្រាជ្ញាថ្លាគំនិត បដិបត្តិព្រះធម៌បានសម្រេចមគ្គផលដល់ទីបំផុតទុក្ខកុំបីខានឡើយ ។

**សូមអនុមោទនា** !!!

ក្រុងម៉ុងរេអាល, ថ្ងៃ ៥ ១៥ ១២ ឆ្នាំថោះ ត្រីស័ក ព.ស. ២៥៥៥[២]
ត្រូវនឹងថ្ងៃ ព្រហស្បតិ៍ ទី ១០ ខែ វិច្ឆិកា គ.ស. ២០១១

**អ្នកសរសេរចម្លង**

**ម៉ាត តិរក្ស**

---

(១) អានថា បណ្ឌិតអក្សរសាស្ត្រ - អភិធជមហារដ្ឋគុរុ (អ:ភិ:ធ:ជ: ម:ហារ៉ៃ-ឋ:គុរុ)
(២) អានថា ថ្ងៃព្រហស្បតិ៍ ១៥ កើត ខែកត្តិក ឆ្នាំថោះ ត្រីស័ក ព.ស. ២៥៥៥

# បញ្ជីមាតិកានៃឱវាទបាតិមោក្ខ

មាតិកានុក្រម ទំព័រ


ឧទ្ទិសកថា ........................................................................

អារម្ភកថា ........................................................................

ចតុរង្គសន្និបាត ................................................................ ១៥


# កណ្ឌទី ១


សំដែងបទ **សព្វបាបស្ស អករណំ** ការមិនធ្វើអំពើបាបទាំងពួង.. ២៣

ពណ៌នាសេចក្ដីក្នុងកាយកម្ម .................................................. ២៤

បាណាតិបាត ........................................................................ ២៤

រឿង ចុន្ទសូករិកៈ ............................................................... ២៥

រឿង គោឃាតកៈ ................................................................. ២៦

អទិន្នាទាន ......................................................................... ២៧

រឿង កុហកតាបស ................................................................ ២៨

កាមេសុមិច្ឆារ ..................................................................... ៣០

រឿង ព្រះនាងមល្លិកា ............................................................ ៣១

ពណ៌នាសេចក្ដីក្នុងវចីកម្ម ..................................................... ៣៣

មុសាវាទ ............................................................................ ៣៣

រឿង នាងចិញ្ចមាណវិកា ........................................................ ៣៤

បិសុណាវាទ ........................................................................ ៣៥

រឿង សូករប្រេត .................................................................. ៣៦

ផរុសវាទ ............................................................................ ៣៧

រឿង កោកាលិកភិក្ខុ ............................................................. ៣៨

សម្ផប្បលាបវាទ .................................................................. ៤០

ពណ៌នាសេចក្ដីក្នុងមនោកម្ម .................................................. ៤១

អភិជ្ឈា ........................................................................ ៤២
រឿង ព្រះបាទបសេនទិកោសល .......................................... ៤៣
ព្យាបាទ ........................................................................ ៤៤
រឿង ស្ត្រីពីរនាក់រួមប្តីចងពៀរនឹងគ្នា ................................ ៤៥
មិច្ឆាទិដ្ឋិ ...................................................................... ៤៧
មិច្ឆាទិដ្ឋិ ១០ យ៉ាង ......................................................... ៤៧
មិច្ឆាទិដ្ឋិ ៣ យ៉ាង ........................................................... ៤៨
មិច្ឆាទិដ្ឋិ ២ យ៉ាង ........................................................... ៤៨
រឿង សុនក្ខត្តលិច្ឆវី ......................................................... ៥០
សរុបសេចក្តីកាយកម្ម, វចីកម្ម, មនោកម្ម ............................ ៥៣
ទោសទុច្ចិត ៥ យ៉ាង ........................................................ ៥៤
វិរតិ ៣ យ៉ាង ................................................................. ៥៥

# គណ្ឋាទី ២

សំដែងបទ **កុសលស្សូបសម្បទា** ការបំពេញកុសលឲ្យបរិបូណ៌.. ៥៧
កុសលប្រព្រឹត្តទៅក្នុងភូមិ ៤ ................................................ ៥៨
អធិប្បាយចិត្តជាកាមាវចរកុសល .......................................... ៥៩
ចិត្តជាកាមាវចរកុសល ...................................................... ៥៩
បុញ្ញកិរិយាវត្ថុ ១០ ......................................................... ៦០
សេចក្តីមិនប្រមាទជាកំពូលកុសល ......................................៦៣
អធិប្បាយសេចក្តីមិនប្រមាទ ............................................... ៦៤
មិនប្រមាទក្នុងការលះនិងការចម្រើន .................................... ៦៥
រឿង ភិក្ខុមិនប្រយ័ត្នបរិក្ខារ ................................................. ៦៦
រឿង ពិលាលបទកសេដ្ឋី ..................................................... ៦៧

មិនប្រមាទក្នុងទី ៤ ស្ថាន .................................................. ៦៨
ធម៌ជាឧបការៈនៃសេចក្តីមិនប្រមាទ .................................... ៧០
ឧបាយឲ្យកើតអប្បមាទធម៌ ............................................... ៧១

# កណ្ឌទី ៣

សំដែងបទ **សចិត្តបរិយោទបនំ** ការញុំាងចិត្តរបស់ខ្លួនឲ្យផូរផង់.. ៧៧
បានទុក្ខ ឬសុខ ក៏ព្រោះចិត្ត ............................................... ៧៨
ទៅទុគ្គតិ ឬសុគតិ ក៏ព្រោះចិត្ត .......................................... ៨០
ប្រៀបកម្មនឹងការបណ្តុះពូជវត្ថុទាំងឡាយ ............................. ៨០
រឿង តិរ្ថិយជួលចោរឲ្យវាយព្រះមោគ្គល្លាន ........................... ៨១
រឿង អសោកមហារាជ ...................................................... ៨២
រឿង អជាតសត្តុរាជកុមារ ................................................. ៨២
រឿង ពេជ្ឈឃាតឈ្មោះតម្ពទាឋិក ........................................ ៨៣
រឿង ធម្មិកឧបាសក ......................................................... ៨៣
រឿង នន្ទិយឧបាសក ......................................................... ៨៤
សម្រេចព្រះនិព្វានក៏ព្រោះចិត្ត ............................................ ៨៥
ឧបក្កិលេស ១៦ ............................................................. ៨៨
លក្ខណៈបុគ្គលមានសតិសម្បជញ្ញៈ .................................... ៩១
សតិបដ្ឋាន ៤ ................................................................. ៩៣
សម្បជញ្ញៈ ៤ ................................................................. ៩៥
រឿង សាមណេរ និងភិក្ខុឃើញអសុភ ................................. ៩៩
រឿង ព្រាហ្មណ៍ធ្វើបុណ្យជាលំដាប់ .................................... ១០៤

# កណ្ឌទី ៤

សំដែងបទ **ខន្តិ បរមំ តបោ តីតិក្ខា** អធិវាសនក្ខន្តី ពោលគឺ
សេចក្តីអត់ធន់ជាតបធម៌ដ៏ឧត្តម ........................................ ១០៧
អធិប្បាយខន្តី ................................................................ ១០៧
រឿង ព្រះសម្ពុទ្ធទ្រង់ស្តេចទៅក្រុងកោសម្ពី ........................ ១០៩
ឧបាយរំលត់សេចក្តីក្រោធ ............................................... ១១០
អានិសង្សអធិវាសនក្ខន្តី .................................................. ១១៣
អធិប្បាយចំពោះខន្តីជាតបធម៌ .......................................... ១១៥
យោបល់ឲ្យកើតអធិវាសនក្ខន្តី .......................................... ១១៧
ឈ្នះសេចក្តីក្រោធដោយសេចក្តីមិនក្រោធ ......................... ១១៨
រឿង នាងឧត្តរា ............................................................. ១១៨
ទោសនៃសេចក្តីក្រោធ ..................................................... ១២០
រឿង ព្រានសុនខឈ្មោះកោកៈ .......................................... ១២១
អានិសង្សអធិវាសនក្ខន្តី ៥ យ៉ាង ...................................... ១២៣
អធិប្បាយពាក្យថា ពៀរ .................................................. ១២៤
ហេតុជាគ្រឿងតពៀរ និងរម្ងាប់ពៀរ .................................. ១២៤
គុណានិសង្សនៃខន្តីយ៉ាងអស្ចារ្យ ....................................... ១២៦
រឿង ទីឃាវុកុមារ ........................................................... ១២៦

# កណ្ឌទី ៥

សំដែងបទ **និព្វានំ បរមំ វទន្តិ ពុទ្ធា** ព្រះពុទ្ធទាំងឡាយតែង
សំដែងថា ព្រះនិព្វានជាធម៌ដ៏ឧត្តម .................................. ១២៩
អធិប្បាយពាក្យថា និព្វាន ............................................... ១៣០
អធិប្បាយអំពីភ្លើងកិលេស ............................................... ១៣០
អធិប្បាយអំពីភ្លើងទុក្ខ .................................................... ១៣២

ព្រះនិព្វាន ២ យ៉ាង ........................................................ ១៣៤
គុណនៃព្រះនិព្វាន ........................................................ ១៣៥
អប្បមាទធម៌ជាផ្លូវព្រះនិព្វាន ............................................ ១៣៧
អរិយមគ្គជាឯកសមង្គី ...................................................... ១៣៨
សង្គ្រោះអដ្ឋង្គិកមគ្គក្នុងត្រៃសិក្ខា .................................... ១៤០

## កណ្ឌទី ៦

សំដែងបទ **ន ហិ បព្វជិតោ បរូបឃាតី សមណោ ហោតិ បរំ វិហេឋយន្តោ** បុគ្គលដែលសម្លាប់សត្វដទៃ មិនឈ្មោះថា បព្វជិត បុគ្គលដែលបៀតបៀនសត្វដទៃ មិនឈ្មោះថា សមណៈ ...................................................................... ១៤៣
អធិប្បាយពាក្យថា បព្វជិត ................................................ ១៤៣
មន្ទិល ៩ ប្រការ .............................................................. ១៤៤
អធិប្បាយពាក្យថា សមណៈ ............................................... ១៤៦
ធម៌ធ្វើបុគ្គលឲ្យជាសមណៈ ................................................ ១៤៨
ឧបាយឲ្យកើតធម៌របស់បព្វជិត ឬសមណៈ .......................... ១៥២
ទោសរបស់បព្វជិតប្រព្រឹត្តមិនល្អ ....................................... ១៥៣
យោបល់នាំបព្វជិតឲ្យប្រព្រឹត្តល្អ ....................................... ១៥៥

## កណ្ឌទី ៧

សំដែងបទ **អនូបវាទោ អនូបឃាតោ** ការមិនពោលតិះដៀលអ្នកដទៃ ការមិនបៀតបៀនអ្នកដទៃ ....................................... ១៥៧
អធិប្បាយអំពីឧបវាទកម្ម .................................................... ១៥៨
រឿង ព្រះថេរៈ និងភិក្ខុកម្លោះ ............................................ ១៥៩

ការសូមស្មាលាទោសនឹងព្រះអរិយៈ .................................... ១៦០
រឿង ជម្ពុកាជីវក ........................................................... ១៦២
អធិប្បាយអំពីឧបឃាតកម្ម ................................................ ១៦៥
រឿង ព្រះបាទអជាតសត្តុ ................................................ ១៦៥
រឿង ព្រះតិស្សត្ថេរ ........................................................ ១៦៨

## កណ្ឌទី ៨

សំដែងបទ **បាតិមោក្ខេ ច សំវរោ** ការសង្រួមក្នុងបាតិមោក្ខ.. ១៧១
ឧបាយឲ្យកើតការសង្រួមក្នុងបាតិមោក្ខ .............................. ១៧៤
សីលឧត្តមជាងជីវិត ........................................................ ១៧៥
បាតិមោក្ខសំវរសីលបរិសុទ្ធដោយសទ្ធា .............................. ១៧៥
ត្រូវបង្អោនចិត្តគិតតាមអង្គនៃកណ្ដៀរ ................................ ១៧៦
សីលជាខាងដើមនៃធម៌ទាំងពួង ......................................... ១៧៧
សីលជាឯកធម៌តែងមានក្នុងនានាស្ថាន .............................. ១៧៨
អានិសង្សសីល .............................................................. ១៧៩

## កណ្ឌទី ៩

សំដែងបទ **មត្តញ្ញុតា ច ភត្តស្មឹ** ភាវៈជាអ្នកដឹងប្រមាណក្នុង
ភត្ត ........................................................................... ១៨៣
ការដឹងប្រមាណ ៣ យ៉ាង .................................................. ១៨៤
ទោស និងគុណនៃការបរិភោគ ......................................... ១៨៧

## កណ្ឌទី ១០

សំដែងបទ **បន្តញ្ច សយនាសនំ** ទីដេកទីអង្គុយដ៏ស្ងាត់ ........ ១៩១

អង្គនៃព្រៃធំ ៥ ........ ១៩២
អានិសង្សនៃការនៅក្នុងព្រៃ ........ ១៩៤
គុណនៃរុក្ខមូល ១០ យ៉ាង ........ ១៩៥
អានិសង្សនៃការនៅទៀបគល់ឈើ ........ ១៩៧
រឿង ភិក្ខុ ១ រូបចម្រើនធម៌ក្នុងព្រៃ ........ ២០០
សេចក្ដីឧបមា ៣ យ៉ាង ........ ២០១
នៅព្រៃតែមិនស្ងាត់ចាកកាម ........ ២០៣
រឿង ព្រះមេឃិយត្ថេរ ........ ២០៤

# គាថាទី ១១

សំដែងបទ **អធិចិត្តេ ច អាយោគោ** ការបំពេញព្យាយាមក្នុង
អធិចិត្ត ........ ២០៧
នីវរណធម៌ ៥ ........ ២០៨
កំណើតនីវរណៈ ៥ ........ ២០៨
ធម៌ជាគ្រឿងកំចាត់នីវរណៈ ៥ ........ ២០៩
ប្រៀបនីវរណៈ ៥ នឹងទឹក ៥ យ៉ាង ........ ២១៣
រូបសមាបត្តិ ឬរូបជ្ឈាន ........ ២១៣
អធិប្បាយអំពីរូបជ្ឈាន ........ ២១៤
លក្ខណៈដួងចិត្តរបស់មនុស្សធម្មតា ........ ២១៥
ផែនទីចិត្តមនុស្សធម្មតា និងអ្នកបានឈាន ........ ២១៨
អរូបសមាបត្តិ ឬអរូបជ្ឈាន ........ ២២០
សំដែងបញ្ជាក់អំពីរូបជ្ឈាន និងអរូបជ្ឈាន ........ ២២២
អធិប្បាយអំពីបញ្ញា ........ ២២៤
នាមពុទ្ធបរិស័ទមានសទ្ធា ........ ២២៩

# អារម្ភកថា

ក្នុងឱកាសដែលខ្ញុំមើលព្រះសុត្តន្តបិដកបាលី បានឃើញសេចក្ដីធម៌ក្នុងឱវាទបាតិមោក្ខគាថា ក៏មានសេចក្ដីពេញចិត្តជាអនេក, បានស្រង់យកបាលីមកប្រែហើយរៀបរៀងជាពាក្យទេសនា សន្មតនាមថា **ឱវាទបាតិមោក្ខ** តាមនាមដើមដែលព្រះសម្មាសម្ពុទ្ធទ្រង់កំណត់ទុកក្នុងព្រះសុត្តន្តបិដកនោះ រួចស្រេចជាយូរមកហើយ, បម្រុងនឹងបោះពុម្ពផ្សាយជាធម្មទានក្នុងឱកាសដ៏គួរ ; តែមិនទាន់សម្រេចព្រោះមិនមានអ្នកជួយឧបត្ថម្ភ ។

លុះដល់ពុទ្ធសករាជ ២៤៧៩ ឧបាសក **តាន់ សៀងស៊ុយ** ឧបាសិកា **ម៉េងវ័ត** នៅកំពង់ឆ្នាំងប្រាថ្នានឹងធ្វើធម្មទានដើម្បីឧទ្ទិសផលជូនដល់មាតាបិតា, ក៏ផ្ដើមបោះពុម្ពឡើង ។

ឱវាទបាតិមោក្ខគាថានេះ, មានក្នុងគម្ពីរជាច្រើន គឺទីឃនិកាយ មហាវគ្គ មហាបទានសូត្រ ១, ខុទ្ទកនិកាយ ធម្មបទ ១, បឋមសមន្តបាសាទិកា វិនយដ្ឋកថា ១ ។ គម្ពីរទាំង ៣ នេះ មានន័យប្លែកគ្នាខ្លះ ដូចគ្នាខ្លះ, ដែលថាប្លែកគ្នានោះ មិនមែនខុសគ្នាណាស់ណាទេ គ្រាន់តែផ្លាស់ប្ដូរកងធម៌មុនជាក្រោយប៉ុណ្ណោះ គឺទីឃនិកាយ និងបឋមសមន្ត . . . លោករៀង **ខន្តី បរមំ តបោ តីតិក្ខា** មុន ខុទ្ទកនិកាយលោករៀង **សព្វបាបស្ស អករណំ** មុន ។ ដែលខ្ញុំរៀបរៀងនេះ តាមខុទ្ទកនិកាយ តម្រូវឲ្យត្រូវតាមរបៀបភាណវារៈ និងធម្មបទដ្ឋកថា ដែលកុលបុត្រធ្លាប់សិក្សានិងស្វាធ្យាយទូទៅទាំងកម្ពុជរដ្ឋទាំងមូល ជាយូរអង្វែងមកហើយ ។ ឯរបៀប

ដែលរៀបរៀងនោះ ខ្ញុំបានចែកព្រះឱវាទក្នុងផ្ទៃនៃគាថាដោយសង្កាត់ ៗ ជា ១១ កណ្ឌ ហើយអធិប្បាយសេចក្តីត្រង់តាមន័យក្នុងអដ្ឋកថា, តែឧទាហរណ៍ដែលប្រកបសេចក្តីអធិប្បាយនិងវត្ថុនិទានដែលប្រារព្ធព្រះឱវាទក្នុងកណ្ឌនោះ ៗ ខ្ញុំស្រង់យកអំពីគម្ពីរជាច្រើន មានធម្មបទដ្ឋកថាជាដើម មករៀបរៀង ។ កាលដែលរៀបរៀងចប់សព្វគ្រប់ ខ្ញុំបានយកទៅប្រគេនព្រះតេជព្រះគុណព្រះឧត្តមមុនី អធិបតីរងក្រុមជំនុំព្រះត្រៃបិដក នៅពុទ្ធ-សាសនបណ្ឌិត្យ ឲ្យជួយពិនិត្យថែមដើម្បីការពារសេចក្តីភ្លាំងភ្លាត់ ។ ព្រះតេជព្រះគុណព្រះឧត្តមមុនីក៏មេត្តាពិនិត្យឲ្យ យល់ឃើញថាត្រឹមត្រូវល្អ ជាធម៌មានប្រយោជន៍ច្រើន ។

ដោយអំណាចកម្លាំងព្យាយាម ដែលខ្ញុំរៀបរៀង **ឱវាទ-បដិមោក្ខ** នេះ, សូមឲ្យព្រះពុទ្ធសាសនារុងរឿងឡើងវិញ ដូចកាលដែលព្រះសម្មាសម្ពុទ្ធបរមគ្រូគង់ព្រះជន្មនៅ ; ទាំងពុទ្ធសាសនិកជនដែលបានសិក្សា និងប្រតិបត្តិតាមធម៌នេះ ក៏សូមឲ្យសម្បូណ៌ដោយសតិបញ្ញា និងសេចក្តីសុខសេចក្តីចំរើនគ្រប់ប្រការ អស់កាលជាអង្វែង ។

ឧណ្ណាលោមារាម ក្រុងភ្នំពេញ នៅថ្ងៃ ១៥ កើត ខែ ផល្គុន ឆ្នាំជូតអដ្ឋស័ក ពុទ្ធសករាជ ២៤៧៩ ត្រូវនឹងថ្ងៃ ២៥ ខែ ហ្វេវរីយេ គ្រិស្តសករាជ ១៩៣៧ ។

លោកអាចារ្យ **ចាប ពិន** សុវណ្ណជោតោ
ក្រុមជំនុំព្រះត្រៃបិដក នៃពុទ្ធសាសនបណ្ឌិត្យ
នៅព្រះរាជបណ្ណាល័យ កម្ពុជា

# នមត្ថុ រតនត្តយស្ស

# ចតុរង្គសន្និបាត

## ឱវាទបាតិមោក្ខគាថា

សព្វបាបស្ស អករណំ
កុសលស្សូបសម្បទា
សចិត្តបរិយោទបនំ
ឯតំ ពុទ្ធានសាសនំ
ខន្តិ បរមំ តបោ តីតិក្ខា
និព្វានំ បរមំ វទន្តិ ពុទ្ធា
ន ហិ បព្វជិតោ បរូបឃាតី
សមណោ ហោតិ បរំ វិហេឋយន្តោ
អនូបវាទោ អនូបឃាតោ
បាតិមោក្ខេ ច សំវរោ
មត្តញ្ញុតា ច ភត្តស្មឹ
បន្តញ្ច សយនាសនំ
អធិចិត្តេ ច អាយោគោ
ឯតំ ពុទ្ធានសាសនំ ។

ព្រះបរមពុទ្ធោវាទ ៣ គាថា[១]នេះ ឈ្មោះថា **ឱវាទបាតិមោក្ខ** ជាព្រះឱវាទមានសេចក្តីវិសេស ១១ ប្រការ ដូចន័យដែលចែកជាកណ្ឌ ៗ តទៅនេះ គឺ ៖

១. **សព្វបាបស្ស អករណំ** ការមិនធ្វើអំពើបាបទាំងពួង ;

២. **កុសលស្សូបសម្បទា** ការបំពេញកុសលឲ្យបរិបូណ៌ ;

៣. **សចិត្តបរិយោទបនំ** ការញុំាងចិត្តរបស់ខ្លួនឲ្យផូរផង់ នេះជាពាក្យប្រដៅរបស់ព្រះពុទ្ធទាំងឡាយ ។

៤. **ខន្តិ បរមំ តបោ តីតិក្ខា** អធិវាសនខន្តី ពោល គឺសេចក្តីអត់ធន ជាតបធម៌ដ៏ឧត្តម ;

៥. **និព្វានំ បរមំ វទន្តិ ពុទ្ធា** ព្រះពុទ្ធទាំងឡាយតែងសម្តែងថា ព្រះនិព្វានជាធម៌ឧត្តម ;

៦. **ន ហិ បព្វជិតោ បរូបឃាតី សមណោ ហោតិ បរំ វិហេឋយន្តោ** បុគ្គលដែលសម្លាប់សត្វដទៃមិនឈ្មោះថា បព្វជិត, បុគ្គលដែលបៀតបៀនសត្វដទៃមិនឈ្មោះថា សមណៈឡើយ ;

៧. **អនូបវាទោ អនូបឃាតោ** ការមិនពោលតិះ-ដៀល ( អ្នកដទៃ ) ការមិនបៀតបៀន ( អ្នកដទៃ ) ;

៨. **បាតិមោក្ខេ ច សំវរោ** ការសង្រួមក្នុងបាតិមោក្ខ ;

---

( ១ ) បើរាប់តាមបាទនៃគាថានេះ ឃើញ ៣ គាថាកន្លះតែត្រង់ពាក្យថា ឯតំពុទ្ធានសាសនំទាំងពីរបាទនុ៎ះ មិនមែនជាព្រះឱវាទទេ, គ្រាន់តែជាចំណងជើងនៃព្រះឱវាទប៉ុណ្ណោះ, បានជាលោកពោលថាតែ ៣ គាថាគត់ដូច្នេះ ។

៩. **មត្តញ្ញុតា ច ភត្តស្មឹ** ភាវៈជាអ្នកដឹងប្រមាណក្នុងភត្ត ;

១០. **បន្តញ្ច សយនាសនំ** ទីដេកទីអង្គុយដ៏ស្ងាត់ ;

១១. **អធិចិត្តេ ច អាយោគោ** ការបំពេញព្យាយាមក្នុងអធិចិត្ត ។

នេះជាពាក្យប្រដៅរបស់ព្រះពុទ្ធទាំងឡាយ ។

ឱវាទបាតិមោក្ខនេះ ជាសាសនធម៌ផ្លូវប្រតិបត្តិរបស់ពុទ្ធបរិស័ទគ្រប់ចំពូកទូទៅទាំងសាសនមណ្ឌល ។ ព្រះបោរាណាចារ្យបានសម្ដែងទុកថា ៖ ធម្មតាព្រះអរហន្តសម្មាសម្ពុទ្ធទាំងឡាយដែលបានត្រាស់ក្នុងអតីតកាលកន្លងទៅហើយ តាំងពីព្រះវិបស្សីសម្មាសម្ពុទ្ធជាដើមក្ដី, ព្រះអរហន្តសម្មាសម្ពុទ្ធដែលនឹងបានត្រាស់ក្នុងអនាគតកាលខាងមុខក្ដី, ព្រះអរហន្តសម្មាសម្ពុទ្ធជាបរមគ្រូរបស់យើងទាំងឡាយ ដែលមានសាសនោវាទរុងរឿងនៅសព្វថ្ងៃនេះក្ដី, ព្រះសម្មាសម្ពុទ្ធក្នុងកាលទាំង ៣ តែងទ្រង់ធ្វើវិសុទ្ធិឧបោសថសម្ដែងឱវាទបាតិមោក្ខ ៣ គាថានេះក្នុងទីប្រជុំនៃព្រះសង្ឃសាវ័កដ៏ប្រសើរ ដែលហៅថា " ចតុរង្គសន្និបាត ( ការប្រជុំសាវ័កប្រកបដោយអង្គ ៤ ) " ដូចគ្នាគ្រប់ ៗ ព្រះអង្គ, ផ្សេងតែវារៈដែលទ្រង់សម្ដែង, ព្រះអង្គខ្លះច្រើនដង ព្រះអង្គខ្លះតិច និងផ្សេងចំនួនភិក្ខុដែលមកប្រជុំ ច្រើនតិចជាងគ្នាតាមកាល ; ព្រះវិបស្សីសម្មាសម្ពុទ្ធ មានចតុរង្គសន្និបាត ៣ ដង គឺមានភិក្ខុ ៦ លាន ៨ សែនរូបម្ដង, ១ សែនរូបម្ដង, ៨ ហ្មឺនរូបម្ដង ;

ព្រះសិខីសម្មាសម្ពុទ្ធ មានចតុរង្គសន្និបាត ៣ ដង គឺមានភិក្ខុ ១ សែនរូបម្តង, ៨ ហ្មឺនរូបម្តង, ៧ ហ្មឺនរូបម្តង ; ព្រះវេស្សភូសម្មាសម្ពុទ្ធមានចតុរង្គសន្និបាត ៣ ដង គឺមានភិក្ខុ ៨ ហ្មឺនរូបម្តង, ៧ ហ្មឺនរូបម្តង, ៦ ហ្មឺនរូបម្តង ; ព្រះសម្មាសម្ពុទ្ធជាបរមសាស្តារបស់យើងមានចតុរង្គសន្និបាតតែម្តង, ព្រះអរហន្តសាវ័កដែលមកប្រជុំគ្នាក្នុងគ្រានោះតែ ១ ២៥០ រូប[១] តិចជាងព្រះសម្មាសម្ពុទ្ធពីបុរាណ ។

ចតុរង្គសន្និបាតរបស់ព្រះសម្មាសម្ពុទ្ធពីបុរាណនោះដូច្នេះគឺៈ

១. **សព្វេ ឯហិភិក្ខូ** ភិក្ខុទាំងអស់សុទ្ធតែជាឯហិភិក្ខុ ;

២. **សព្វេ ឥទ្ធិយា និព្វត្តបត្តចីវរា** ភិក្ខុទាំងអស់សុទ្ធតែមានបាត្រនិងចីវរកើតឡើងដោយឫទ្ធិ ;

៣. **សព្វេ អនាមន្តិតាវ អាគតា** ភិក្ខុទាំងអស់សុទ្ធតែមកឥតនរណានិមន្ត ;

៤. **បណ្ណរសេ ឧបោសថទិវសេ** មកក្នុងថ្ងៃឧបោសថ ១៥ កើត ។

ចតុរង្គសន្និបាត របស់ព្រះសម្មាសម្ពុទ្ធជាបរមគ្រូនៃយើងនេះដូច្នេះ គឺ ៖

១. **មាឃនក្ខត្តេន យុត្តោ បុណ្ណមីឧបោសថទិវសោ** ថ្ងៃឧបោសថព្រះចន្ទពេញវង់ប្រកបដោយ

(១) ក្រុមបុរាណជដិល ១០០០ ក្រុមអគ្គសាវ័ក ២៥០ ត្រូវជា ១២៥០ ។

ផ្កាយប្រចាំខែមាឃ : គឺថ្ងៃ ១៥ កើតខែមាឃ ;

២. **តេនចិ អនាមន្តិតានិ ហុត្វា អត្តនោយេវ ធម្មតាយ សន្និបតិតានិ អឌ្ឍតេរសានិ ភិក្ខុសតានិ** ភិក្ខុ ១២៥០ រូប ឥតមាននរណានិមន្តឡើយ ស្រាប់តែមកប្រជុំគ្នាតាមធម្មតារបស់លោក ;

៣. **តេសុ ឯកោ បុថុជ្ជនោ វា សោតាបន្នសកទាគាមិអនាគាមិសុក្ខវិបស្សកអរហន្តេសុ វា អញ្ញតរោ នត្ថិ សព្វេ ឆ អភិញ្ញាវ** ភិក្ខុអម្បាលនោះជាបុថុជ្ជន ឬសោតាបន្ន សកទាគាមី អនាគាមី ឬព្រះអរហន្តសុក្ខវិបស្សកៈ សូម្បីតែ ១ រូប ក៏មិនមាន, សុទ្ធតែជាព្រះអរហន្ត បានអភិញ្ញាណ ៦ គ្រប់រូប ;

៤. **ឯកោបិ ចេត្ថ សត្ថកេន កេសេ ឆិន្ទិត្វា បព្វជិតោ នាម នត្ថិ សព្វេ ឯហិភិក្ខុយេវ** សូម្បីតែ ១ រូបដែលកោរសក់ដោយកាំបិតហើយបួស ក៏មិនមាន សុទ្ធតែជាឯហិភិក្ខុទាំងអស់ ។

ចតុរង្គសន្និបាតនេះ ព្រះសម្មាសម្ពុទ្ធជាបរមគ្រូរបស់យើង ទ្រង់ធ្វើក្នុងវត្តវេឡុវ័ន ។ មានដំណាលថា ៖ កាលដែលអគ្គសាវ័កទាំងពីរបួសហើយ ព្រះមហាមោគ្គល្លានបានសម្រេចអរហត្តក្នុងថ្ងៃទី ៧ ។ ព្រះធម្មសេនាបតីសារីបុត្ត បានសម្រេចសាវ័កបារមីញាណក្នុងថ្ងៃទី ១៥ នៅវេលាដែលបញ្ជូនញាណទៅតាមខ្សែធម្មទេសនា ដែលព្រះដ៏មានព្រះភាគទ្រង់សម្តែង

វេទនាបរិគ្គហសូត្រ ប្រោសទីឃនខបរិព្វាជកជាក្មួយរបស់លោក ក្នុងញកគុហាឈ្មោះ សូករខាតលេណៈ នាពាក់កណ្ដាលភ្នំ គិជ្ឈកូដ ។ កាលដែលព្រះដ៏មានព្រះភាគទ្រង់ជ្រាបថាព្រះថេរៈ បានសម្រេចអរហត្តហើយ, ព្រះអង្គទ្រង់ហោះទៅតាមអាកាស ប្រតិស្ឋានឯវត្តវេឡុវ័ន ។ ព្រះថេរៈបានជ្រាបដូច្នោះ ក៏ហោះ ទៅតាមអាកាសប្រតិស្ឋានក្នុងវត្តវេឡុវ័នដែរ ។ សម័យនោះជា វេលាជួបជុំប្រកបដោយអង្គ ៤ ដែលហៅថា " **ចតុរង្គសន្និបាត** " ព្រះដ៏មានព្រះភាគក៏ទ្រង់សម្ដែងឱវាទបាតិមោក្ខ[១] ក្នុងទីប្រជុំនោះ

(១) បាតិមោក្ខមាន ២ គឺឱវាទបតិមោក្ខ ទ្រង់សម្ដែងជាពាក្យទូន្មាន ដូចក្នុងគាថាថា ៖ **សព្វបាបស្ស អករណំ** ជាដើម ដែលពោលហើយខាងដើមនេះ ១, អាណាបាតិមោក្ខ ទ្រង់បញ្ញត្តជាដាច់ខាត ដូចក្នុងសិក្ខាបទ ២២៧ ដែលទ្រង់បង្គាប់ឲ្យភិក្ខុសម្ដែងរាល់កន្លះ ខែ មានបាលីថា **សុណាតុ មេ ភន្តេ សង្ឃោ** ជាដើម ១ ។ ព្រះពុទ្ធរាល់ព្រះអង្គវេលា ដែលធ្វើឧបោសថជាមួយនឹងភិក្ខុសង្ឃ ទ្រង់សម្ដែងតែឱវាទបាតិមោក្ខដោយព្រះអង្គឯង មិនទ្រង់សម្ដែងអាណាបាតិមោក្ខទេ ។ កាលដែលទ្រង់សម្ដែងនោះសោត ក៏មិនមែន សុទ្ធតែកន្លះខែម្ដង ៗ ដូចគ្នាទេ ព្រះវិបស្សីសម្មាសម្ពុទ្ធ ៦ ឆ្នាំទើបសម្ដែងម្ដង, ព្រះ សម្មាសម្ពុទ្ធជាម្ចាស់យើងកន្លះខែម្ដង ។ ព្រះពុទ្ធដែលមានព្រះជន្មវែង ៗ ទ្រង់សម្ដែង ដរាបដល់ផុតសាសនា, ដែលព្រះជន្មខ្លី ៗ ទ្រង់សម្ដែងតែក្នុងបឋមពោធិកាល ។ ព្រះ បរមគ្រូរបស់យើង ទ្រង់សម្ដែងតែចំនួន ២០វស្សា ក្នុងបឋមពោធិកាល ។ វេលាដែល ព្រះសម្មាសម្ពុទ្ធជាម្ចាស់យើងព្រះអង្គនឹងឈប់សម្ដែងឱវាទបាតិមោក្ខនោះ ទ្រង់គង់ក្នុង បុព្វារាម លើមិគារមាតុប្រាសាទ ទ្រង់ត្រាស់នឹងភិក្ខុថា ៖ " ម្នាលភិក្ខុទាំងឡាយ ! តពីនេះ ទៅមុខទៀត តថាគតឈប់ធ្វើឧបោសថសំដែងឱវាទបាតិមោក្ខហើយ, អ្នកទាំងឡាយ គប្បីធ្វើឧបោសថ សម្ដែងអាណាបាតិមោក្ខចុះ, ព្រោះតថាគតធ្វើឧបោសថសម្ដែង បាតិមោក្ខជាមួយនឹងបរិស័ទដែលមិនបរិសុទ្ធនោះ មិនបានជាការទេ " ។ តាំងពីកាល នោះមក ភិក្ខុទាំងឡាយក៏សម្ដែងតែអាណាបាតិមោក្ខដរាបដល់សព្វថ្ងៃនេះ ។

ហេតុដូច្នោះបានជាចតុរង្គសន្និបាតនេះ ជាទីនិយមរាប់អាន របស់អ្នកប្រាជ្ញថាជាមហាអស្ចារ្យ និងជាមហាមង្គលដ៏ប្រសើរ, កាលបើដល់ថ្ងៃពេញបូណ៌មីខែមាឃ ដែលជាថ្ងៃអភិលក្ខិតកាល ដូច្នោះ សប្បុរសក៏នាំគ្នាចាត់ចែងគ្រឿងសក្ការៈដ៏ផ្ចិតផ្ចង់ មាន ប្រទីបធូបទៀននិងកម្រងផ្កាជាដើម យកទៅបូជាចំពោះ ព្រះស្តូបជាទីបញ្ចុះព្រះសារីរិកធាតុ និងឧទ្ទេសិកចេតិយ គឺព្រះ ពុទ្ធប្បដិមា ដែលប្រតិស្ឋានទុកជាគ្រឿងសំគាល់នៅក្នុងអារាម ផ្សេង ៗ ឧទ្ទិសចំពោះព្រះសម្មាសម្ពុទ្ធនិងព្រះអរហន្តទាំងឡាយ ដែលបរិនិព្វានទៅជាយូរអង្វែងហើយ ប្រជុំគ្នាស្តាប់ព្រះសង្ឃ សូត្រស្វាធ្យាយ និងស្តាប់ព្រះសទ្ធម្មទេសនាជាទីរលឹកដល់ថ្ងៃ ដែលព្រះសម្មាសម្ពុទ្ធពីបុរាណ និងព្រះសម្មាសម្ពុទ្ធបរមគ្រូរបស់ យើងទ្រង់ធ្វើ " **ចតុរង្គសន្និបាត** " នោះឯងតាមសេចក្តីជឿនិង សេចក្តីជ្រះថ្លារបស់ខ្លួន ៗ ជាប់ជាប្រវេណីត ៗ មកដរាបដល់សព្វ ថ្ងៃនេះ ។

# ចប់ ចតុរង្គសន្និបាត



# ឱវាទបាតិមោក្ខ កណ្ឌទី ១

**វេលានេះ** នឹងអធិប្បាយសេចក្តីនៃព្រះបរមពុទ្ធោវាទក្នុង ឱវាទបាតិមោក្ខ ត្រង់បទថា **សព្វបាបស្ស អករណំ ការមិនធ្វើអំពើបាបទាំងពួង** នោះ ឲ្យមានសេចក្តីពិស្តារដើម្បីជាគ្រឿងប្រដាប់សតិបញ្ញា និងជាវត្តប្រតិបត្តិរបស់សាធុជនពុទ្ធបរិស័ទ ដូចតទៅនេះ ៖

កម្មដ៏លាមក, កម្មដែលជាហេតុទៅកាន់អបាយ, កម្មដែលញ៉ាំងសត្វឲ្យដល់ទុគ្គតិ ហៅថា **បាប** ការដែលព្យាយាមកំចាត់បាបទាំងអស់មិនឲ្យកើត មិនមាននៅក្នុងកាយវាចាចិត្ត ហៅថា **មិនធ្វើអំពើបាបទាំងពួង** ។

បាបនោះបើសម្តែងដោយឫសគល់ ក៏បានខាង **លោភៈ** ( សេចក្តីជាប់ជំពាក់ក្នុងកាមារម្មណ៍ ) **ទោសៈ** ( សេចក្តីក្រោធខឹងប្រទូស្តក្នុងសត្វនិងសង្ខារ [១] ) **មោហៈ** ( សេចក្តីវង្វេងភាន់ច្រឡំមិនដឹងសេចក្តីពិត ) ។ **លោភៈ, ទោសៈ, មោហៈ** ទាំង ៣ នេះ

---

(១) ពាក្យថា " **សត្វ** " សំដៅដល់ មាតាបិតា ស្វាមី ភរិយា បុត្រធីតា បងប្អូន ញាតិមិត្ត និង ទ្រព្យសម្បត្តិដែលមានវិញ្ញាណដូចជា គោ ក្របី សេះ...។ល។
ឯពាក្យថា " **សង្ខារ** " សំដៅដល់ទ្រព្យសម្បត្តិ វត្ថុដែលគ្មានវិញ្ញាណដូចជា ផ្ទះ ដីស្រែចម្ការ ចំការ យន្តយាន គ្រឿងអលង្ការ...។ល។

ជាតួបាបផង ជាមូលហេតុ គឺជាដើមចមនាំឲ្យធ្វើអំពើបាបផង ដូចជាបុគ្គលធ្វើវេរាទាំង ៥ គឺសម្លាប់សត្វ, លួចទ្រព្យគេ, ប្រព្រឹត្តខុសក្នុងកាម, និយាយកុហក និងផឹកសុរានោះក៏ព្រោះតែសេចក្តីលោភ, សេចក្តីក្រោធខឹង និងសេចក្តីវង្វេងនេះឯង ។

បើសម្តែងតាមកម្មគឺអំពើដែលធ្វើបាបឬទ្វារ គឺកន្លែងដែលកើតបាបនោះ មាន ៣ គឺ ៖

**១. កាយកម្ម**
**២. វចីកម្ម**
**៣. មនោកម្ម**

# ពណ៌នាសេចក្តីក្នុងកាយកម្ម

១. កាយកម្មនោះ បានខាងអំពើដែលសម្រេចដោយកាយ មាន ៣ គឺ ៖

**ក). បាណាតិបាត**
**ខ). អទិន្នាទាន**
**គ). កាមេសុមិច្ឆាចារ**

## ❖ បាណាតិបាត

ក). បាណាតិបាតនោះ បានខាងអំពើដែលសម្លាប់សត្វមានជីវិតឲ្យស្លាប់ ដោយកាយរបស់ខ្លួន ឬប្រើគេឲ្យសម្លាប់ ។

# សម្តែងទោសបាណាតិបាត

បណ្តាមនុស្សនិងសត្វដែលកើតមកក្នុងលោកនេះ សុទ្ធតែស្រឡាញ់អាយុជីវិតរបស់ខ្លួន ជាងវត្ថុដទៃ ៗ ខ្លាចសេចក្តីស្លាប់ក្រៃពេក, សេចក្តីស្លាប់នេះ មិនជាទីស្រឡាញ់ពេញចិត្តនរណាម្នាក់ឡើយ ។ ព្រោះហេតុដូច្នោះ អំពើដែលសម្លាប់គេ ទើបឈ្មោះថាធ្វើឲ្យគេមិនត្រូវចិត្ត, បើនរណាធ្វើឲ្យគេមិនត្រូវចិត្តហើយ អ្នកនោះមុខជានឹងបានទទួលទោសទុក្ខព្រួយលំបាកដូចគេវិញមិនខាន ។ អំពើសម្លាប់សត្វនេះ អាចឲ្យទោសឃើញច្បាស់ទាន់ភ្នែកក្នុងជាតិនេះក៏មាន, ដូចសម្លាប់មនុស្ស ; សូម្បីសម្លាប់សត្វតិរច្ឆាន តែសម្លាប់យូរខែយូរឆ្នាំ ក៏អាចឲ្យឃើញទោសក្នុងជាតិនេះបាន ដូច **ចុន្ទសូករិកៈ** និង **គោឃាតកៈ** ។ សូមនាំរឿងទាំងនោះមកសម្តែងជាឧទាហរណ៍ដោយសង្ខេបដូចតទៅនេះ ៖

# រឿង ចុន្ទសូករិកៈ

**ចុ**ន្ទសូករិកៈនោះ ជាអ្នកសម្លាប់តែជ្រូកយកសាច់លក់ចិញ្ចឹមជីវិតពេញ ៥៥ ឆ្នាំ ។ កាលដែលសម្លាប់ម្តង ៗ នោះ គាត់យកទឹកកំពុងពុះក្តៅទៅចាក់បង្អកក្នុងមាត់ជ្រូក លុះជ្រូកនោះស្លាប់ហើយ គាត់យកដំបង ៤ ជ្រុងទៅវាយដំឲ្យណែនសាច់ដើម្បីថ្លឹងឲ្យមានទម្ងន់ លក់បានថ្លៃ ។ ដល់សម័យគាត់មានជម្ងឺ អំពើនោះក៏បណ្តាលឲ្យភ្លើងអំពីអវីចិមហានរកឆេះឡើងមក ដុតរោល

គាត់ឲ្យក្ដៅអន្ទះអន្ទែង ស្ទុះបម្រះនៀលឆ្លេឆ្លាវារទៅមកដោយក្បាលជង្គង់ ស្រែកយំមានសម្លេងដូចជ្រូក រងទុក្ខវេទនាអស់ ៧ ថ្ងៃទើបស្លាប់ ៗ ហើយទៅកើតក្នុងអវីចិមហានរក ។

# រឿង គោឃាតកៈ

ឯគោឃាតកៈនោះ ជាអ្នកសម្លាប់គោយកសាច់ចិញ្ចឹមជីវិត ថ្ងៃណាដែលគ្មានសាច់គោ ថ្ងៃនោះគាត់មិនបរិភោគអាហារ ។ វេលាថ្ងៃមួយ មិនមានសាច់គោនឹងបរិភោគ គាត់ក៏ដើរទៅខាងក្រោយផ្ទះកាត់អណ្ដាតគោទាំងរស់យកមកអាំងហើយបរិភោគជាមួយនឹងបាយ ។ ក្នុងវេលាមួយរំពេចនោះ ផលកម្មក៏បណ្ដាលឲ្យអណ្ដាតរបស់គាត់ដាច់ធ្លាក់ចុះទៅក្នុងចានបាយ ឃើញច្បាស់ទាន់ភ្នែក ស្រែករោទ៍ដូចគោមិនយូរប៉ុន្មានក៏ស្លាប់ទៅ ៗ កើតក្នុងអវីចិមហានរក សោយទុក្ខវេទនារកអ្វីប្រៀបពុំបាន ។

ន័យមួយវិញទៀត អំពើដែលសម្លាប់សត្វ បើទុកជាមិនមានទោសក្នុងជាតិនេះ ក៏គង់តែមានទោសក្នុងជាតិខាងមុខឲ្យរងទុក្ខក្នុងអបាយមាននរកជាដើមមិនខានឡើយ, លុះស្ដោះអំពីនោះមក ៗ កើតជាមនុស្សមានអាយុខ្លី និងមានរោគច្រើន ។

ព្រោះហេតុនេះបានជាអំពើដែលសម្លាប់សត្វនោះ លោកឲ្យឈ្មោះថា **បាប** ជាអំពើអាក្រក់មិនគួរធ្វើ ។ អ្នកប្រាជ្ញទាំងឡាយ

ដែលជឿកម្ម និងផលរបស់កម្មលោកមិនសម្លាប់សត្វដោយខ្លួនឯង និងមិនប្រើគេឲ្យសម្លាប់ឡើយ ។ មិនតែប៉ុណ្ណោះលោកបានទាំងបបួលអ្នកដទៃ ដែលជឿតាមពាក្យសម្ដីរបស់លោកឲ្យឈប់សម្លាប់ និងនិយាយទូន្មានគេឲ្យមានចិត្តមេត្តាប្រណីសត្វនិងមនុស្សថែមទៀតផង ។ មិនគ្រាន់តែមានចិត្តមេត្តាប៉ុណ្ណោះ, បានទាំងឲ្យទានចតុប្បច្ច័យ មានបាយនិងទឹកជាដើមដើម្បីជួយស្រោចស្រង់ជីវិតរបស់មនុស្សនិងសត្វឥតរើសមុខ ឲ្យបានសុខដោយសារទាននោះឡើងទៀត ។

## ❖ អទិន្នាទាន

២). អទិន្នាទាននោះ បានខាងអំពើដែលលួចលាក់ឆក់ដណ្ដើមបំបាត់ប្រវ័ញ្ចទ្រព្យគេ ដែលគេមិនបានអនុញ្ញាតឲ្យដោយកាយ ឬវាចា ។

បណ្ដាទ្រព្យសម្បត្តិទាំងអស់ដែលមាននៅក្នុងលោកនេះ ទោះបីល្អក្ដី អាក្រក់ក្ដី ឲ្យតែគេសំគាល់ថាស្រេចជារបស់គេហើយ គេមិនចង់ឲ្យនរណាមកលួចលាក់ឆក់ដណ្ដើមបំបាត់ប្រវ័ញ្ចយកទៅទេ ។ ព្រោះហេតុនេះបានជា អំពើដែលលួចទ្រព្យរបស់គេ លោកឲ្យឈ្មោះថាបៀតបៀនគេ ធ្វើឲ្យគេលំបាកចិត្ត, បើនរណាធ្វើឲ្យគេលំបាកចិត្តហើយ ខ្លួនអ្នកដែលធ្វើនោះក៏នឹងត្រឡប់បានទទួលទោសទុក្ខលំបាកដូចគេវិញមិនលែង ។ អំពើលួចទ្រព្យរបស់អ្នកដទៃនេះឯងច្រើនឃើញទោសប្រាកដក្នុងជាតិ

នេះ ដូចអ្នកទោសដែលជាប់គុកច្រវាក់ គេប្រើឲ្យធ្វើការដោយបង្ខំ វាយដំច្រំធាក់ឲ្យលំបាកនោះ ក៏ច្រើនតែជាប់ទោសព្រោះលួចប្លន់ ឆក់ដណ្ដើមយកទ្រព្យរបស់គេ ។ ឯអំពើលួចទ្រព្យរបស់គេនេះ បើម្ចាស់គេទាន់ហើយ ទុកជាមិនមានទោសដល់ទៅជាប់គុកច្រវាក់ ក៏គង់តែគេទះតប់វាយដំច្រំធាក់ស្ទើរតែនឹងស្លាប់មិនខាន ដូច **កុហកតាបស** ; សូមនាំរឿងនោះមកសម្ដែងជាឧទាហរណ៍ ដូចតទៅនេះ ៖

# រឿង កុហកតាបស

**មា**នតាបសកុហកម្នាក់ អាស្រ័យនៅនឹងសាលា ១ ទៀបក្រុងពារាណសី, មានកុដុម្ពីម្នាក់និមន្តឆាន់រាល់ ៗ ថ្ងៃ ។ ដល់មានភ័យនឹងចោរ កុដុម្ពីយកមាសទៅកប់ក្រោមសាលាផ្ញើនឹងតាបស ៗ ក៏លួចយកទៅទុកក្នុងទីមួយ ហើយទៅបញ្ឆោតគេថា ៖

- " អាត្មានៅក្នុងទីនេះច្រឡូកច្រឡំនឹងមនុស្សច្រើន មានសេចក្ដីធុញទ្រាន់ពន់ពេក ឥឡូវអាត្មាសូមលាញោមទៅនៅទីឯទៀតហើយ " ។

ទោះបីគេឃាត់យ៉ាងណា តាបសក៏មិនព្រមនៅ, លុះទៅបន្តិចត្រឡប់មកវិញ យកស្បូវពីរបីសរសៃមកសៀតនឹងផ្នួងសក់ហើយប្រាប់កុដុម្ពីថា ៖

- " ស្បូវនេះធ្លាក់អំពីដម្បូលផ្ទះញោមមកជាប់នឹងផ្នួងសក់អាត្មា ៗ ក្រែងជាអទិន្នាទាន បានជាយកមកជូនញោមវិញ " ។

សម្តីនេះ ជាសម្តីបង្វែងដានដើម្បីកុំឲ្យគេសង្ស័យក្នុងថ្ងៃក្រោយ ។

គ្រានោះ ព្រះបរមពោធិសត្វបានឮសម្តីតាបស ក៏ជ្រាបថាសម្តីបង្វែងដានហើយសួរកុដុម្ពីថា ៖

- " អ្នកមានយកអ្វីទៅផ្ញើនឹងតាបសដែរឬទេ ? "

កុដុម្ពីក៏ឆ្លើយថា ៖

- " មានមាស ១ ដុំដែរ " ។

ពោធិសត្វប្រាប់ថា ៖

- " បើដូច្នោះ ច្បាស់ជាតាបសនេះគាត់លួចយកហើយបានជាគាត់និយាយយ៉ាងហ្នឹង " ។

ថាហើយក៏នាំគ្នាទៅមើលឯសាលា ឃើញថាមាសនោះបាត់មែនក៏នាំគ្នារត់តាមទៅ ។ លុះទាន់ក៏ទះតប់វាយដំច្រំធាក់ទៀបនឹងស្លាប់ ហើយយកទ្រព្យត្រឡប់មកផ្ទះវិញ ។

នាំរឿងនេះមក, ដើម្បីពន្យល់ឲ្យឃើញថា អំពើដែលលួចលាក់ឆក់ដណ្តើមយកទ្រព្យរបស់គេ បើម្ចាស់គេទាន់ គេក៏នឹងធ្វើទោសមួយរំពេច មិនបាច់យូរ, បើយ៉ាងស្រាលបំផុតត្រឹមគេវាយទៀបស្លាប់ដូចកុហកតាបសនោះឯង ។ មិនតែប៉ុណ្ណោះឡើយ, ការលួចទ្រព្យគេ បើទុកជាចេះបំបិទបំបាំងឲ្យរួចទោសក្នុងជាតិនេះ ក៏គង់តែត្រូវទោសក្នុងជាតិខាងមុខ គឺទៅរងទុក្ខក្នុងអបាយមាននរកជាដើមមិនខាន ។ លុះរួចអំពីនោះមក ៗ កើតជាមនុស្សខ្ញុំគេឬ ក្រីក្រលំបាកតោកយ៉ាកឥតទីពឹង និងច្រើនប្រកបដោយ

សេចក្តីអន្តរាយផ្សេង ៗ ។

ព្រោះហេតុនេះ អំពើដែលលួចលាក់ឆក់ដណ្តើមទ្រព្យគេ ទើបហៅថា **បាប** ជាអំពើអាក្រក់មិនគួរធ្វើ ។ អ្នកប្រាជ្ញទាំងឡាយដែលជឿកម្ម និងផលរបស់កម្ម លោកមិនលួចលាក់ឆក់ដណ្តើមទ្រព្យរបស់គេឡើយ ។ មិនតែប៉ុណ្ណោះ, លោកថែមទាំងនិយាយទូន្មាន អ្នកដែលជឿស្តាប់តាមពាក្យសម្តីរបស់លោក ឲ្យឈប់ធ្វើអំពើលួចលាក់ឆក់ដណ្តើមទ្រព្យរបស់គេដូចលោកផង ; ហើយបានទាំងបរិច្ចាគធនធានឲ្យទានដល់មនុស្ស និងសត្វ ដោយចិត្តមេត្តាប្រាថ្នាឲ្យគេបានសេចក្តីសុខថែមឡើងទៀត ។

## ❖ កាមេសុមិច្ឆាចារ

គ). ឯកាមេសុមិច្ឆាចារនោះ បានខាងអំពើដែលប្រព្រឹត្តខុសក្នុងកាមទាំងឡាយ, បើជាបុរសបានខាងអំពើដែលលបលាក់ប្រព្រឹត្តមោះមិនគាប់នឹងភរិយារបស់អ្នកដទៃ, បើជាស្ត្រីបានខាងអំពើដែលកន្លងចិត្តស្វាមីរបស់ខ្លួន ទៅប្រព្រឹត្តមោះមិនគាប់នឹងបុរសឯទៀត ។

បណ្តាមនុស្សក្នុងលោក រមែងហួងហែងក្នុងផ្លូវកាមជាធម្មតា, បើបានអាស្រ័យនៅនឹងស្ត្រីឯណានីមួយដែលដាច់ស្រេចថាជាប្រពន្ធរបស់គេហើយ, គេតែងស្រឡាញ់ហួងហែងរក្សាទុកមិនចង់ឲ្យប្រុសដទៃមកប្រព្រឹត្តល្មើសនឹងស្ត្រីនោះទេ ។ ម្យ៉ាង

ទៀត បើគេស្លួនគ្រងរក្សាស្ត្រីឯណាដែលជាកូនរបស់គេដោយប៉ងថា នឹងរៀបចំទុកដាក់ឲ្យបុរសណាម្នាក់ដែលគេស្រឡាញ់ពេញចិត្តមកដណ្តឹងតាមច្បាប់ប្រវេណី, គេមិនចង់ឲ្យបុរសដទៃទៅប្រព្រឹត្តល្មើសកន្លងប្រវេណីនោះឡើយ ។ បើមានបុរសណាម្នាក់ទៅលបលួចប្រព្រឹត្តល្មើសកន្លងប្រវេណីនឹងស្ត្រីនោះ, បុរសនោះបានឈ្មោះថាធ្វើឲ្យគេពិបាកចិត្ត ជាហេតុនាំឲ្យខូចសាមគ្គីធម៌ គឺសេចក្តីព្រមព្រៀងរបស់គេ ដរាបដល់ឈ្លោះប្រកែកជេរប្រទេចវាយដំច្រំធាក់ ឬចាក់កាប់សម្លាប់គ្នាក៏មាន ។ ទោសដែលមើលឃើញនិងស្តាប់ឮក្នុងបច្ចុប្បន្នក៏មានច្រើន បើទុកជាចេះលាក់បំបិទបំបាំងមិនឲ្យឃើញទោសក្នុងជាតិនេះ ក៏គង់តែឃើញទៅក្នុងជាតិខាងមុខ គឺទៅរងទុក្ខក្នុងអបាយភូមិមាននរកជាដើមមិនខាន, ដូច **ព្រះនាងមល្លិកា**, សូមនាំរឿងនោះមកសម្តែងជាឧទាហរណ៍ដូចតទៅនេះ ៖

# រឿង ព្រះនាងមល្លិកា

**ព្រះ**នាងមល្លិកានោះជាព្រះទេពីព្រះបាទបសេនទិកោសលមហាក្សត្រិយ៍ក្រុងសាវត្ថី ព្រះនាងទ្រង់ប្រព្រឹត្តមោះមិនគាប់នឹងសុនខដែលស្និទ្ធស្នាល ។ កាលបើព្រះមហាក្សត្រិយ៍ទ្រង់ជ្រាបហើយត្រាស់សួរ, ព្រះនាងក៏ក្រាបបង្គំទូលកែបំភ្លៃសេចក្តីនោះត្រឡប់ឲ្យមហាក្សត្រិយ៍ទ្រង់ជឿថា ព្រះនាងស្មោះត្រង់ពិតឥត

ប្រព្រឹត្តខុសទៅវិញបាន ។ ព្រះនាងនោះ ជាស្ត្រីមានសទ្ធាជឿព្រះពុទ្ធសាសនា បានធ្វើការកុសលជាច្រើនដែរ, តែក្នុងវេលាដែលព្រះនាងទៀបអស់ព្រះជន្ម មិនបាននឹកដល់ការកុសលទាំងនោះ នឹកតែអំពើដែលប្រព្រឹត្តល្មើស ; អំពើនោះក៏នាំឲ្យព្រះនាងធ្លាក់ទៅកើតក្នុងនរកឈ្មោះអវីចិអស់ ៧ ថ្ងៃ គិតតាមថ្ងៃមនុស្សលោក ។ លុះល្ពោះចាកទីនោះមក បានទៅកើតក្នុងឋានតុសិតសួគ៌ដោយអំណាចកុសលដែលព្រះនាងបានធ្វើច្រើន ។

នាំរឿងនេះមក, ដើម្បីពន្យល់ឲ្យឃើញថា អំពើដែលប្រព្រឹត្តកាមេសុមិច្ឆាចារនោះ ទោះបីចេះលាក់បំបិទបំបាំង ឬកែខ្លួនឲ្យរួចទោសក្នុងជាតិនេះ ក៏គង់តែត្រូវទទួលទោសទៅក្នុងជាតិឯមុខមិនខាន ។ លុះល្ពោះអំពីនរកមក ៗ កើតជាសត្វតិរច្ឆានឲ្យគេក្រៀវពូជ ឬកើតជាមនុស្សខ្ទើយជាច្រើនជាតិ ។

ព្រោះហេតុដូច្នេះ អំពើដែលប្រព្រឹត្តកន្លងប្រវេណីនឹងស្ត្រីដែលគេហួងហែងរក្សា ទើបឈ្មោះថា **បាប** ជាអំពើអាក្រក់មិនគួរធ្វើទេ ។ អ្នកប្រាជ្ញទាំងឡាយដែលជឿកម្ម និងផលរបស់កម្មលោកមិនប្រព្រឹត្តកន្លងប្រវេណីនឹងស្ត្រីដែលគេហួងហែងរក្សានោះឡើយ, លោកប្រព្រឹត្តសន្តោសត្រេកអរតែនឹងភរិយាស្វាមីរបស់ខ្លួន ។ មិនតែប៉ុណ្ណោះ, អ្នកប្រាជ្ញខ្លះក៏លះបង់កាមគុណចេញទៅបួសក៏មាន ។

**សម្តែងមកនេះជាចំណែកកាយកម្ម ។**

# ពណ៌នាសេចក្តីក្នុងវចីកម្ម

២. ឯវចីកម្មនោះ បានខាងអំពើដែលសម្រេចដោយវាចាពាក្យសម្តីមាន ៤ យ៉ាង គឺ ៖

**ក). មុសាវាទ**

**ខ). បិសុណាវាទ**

**គ). ផរុសវាទ**

**ឃ). សម្ផប្បលាបវាទ**

## ❖ មុសាវាទ

**ក).** មុសាវាទនោះ បានខាងអំពើដែលនិយាយវៀច គឺខ្លួនមិនឃើញថាឃើញ មិនឮថាឮ មិនដឹងថាដឹង ដោយគំនិតគិតប្រុងនឹងឲ្យគេចូលចិត្តខុស, ទោះបីអ្នកដែលស្តាប់នោះគេជឿក្តីមិនជឿក្តី ក៏ហៅថាសំដីវៀចទាំងអស់ ។

សម្តីខ្លះធ្វើអ្នកដទៃឲ្យវិនាសជីវិតក៏មាន ឲ្យវិនាសទ្រព្យសម្បត្តិក៏មាន ឲ្យកើតសេចក្តីលំបាកផ្សេង ៗ ក៏មាន ។ សម្តីមុសាវាទនេះ ទុកជាអ្នកស្តាប់មិនជឿ មិនធ្វើតាម, ខ្លួនឯងក៏ឈ្មោះថានិយាយវៀចហើយ ជាហេតុនាំឲ្យអ្នកដទៃគេមិនជឿពាក្យសម្តីរបស់ខ្លួនទៅទាំងអស់ គឺបើគេដឹងថាអ្នកនោះធ្លាប់និយាយមុសាហើយ ថ្ងៃក្រោយសូម្បីនិយាយត្រង់ក៏គេមិនសូវជឿទោះបីនិយាយកុហកដើម្បីនឹងឲ្យរួចភ័យ ឬដើម្បីនឹងរួបរួមអ្នក

ដទៃឲ្យសាមគ្គីព្រមព្រៀងគ្នា ដែលខ្លួនយល់ឃើញថាគួរនឹងនិយាយភូតផ្សំខ្លះក៏បាននោះ ក៏មិនគួរដែរ, តាមសេចក្តីពិតត្រូវកុំភូតឲ្យសោះ, ព្រោះសម្តីដែលជាសំនួនគួរនឹងនិយាយឲ្យគេស្តាប់បាន ក៏មានច្រើនល្មមប្រើមិនខ្វះឡើយ, សូម្បីភូតលេងក៏មិនគួរដែរ, ព្រោះជាហេតុឲ្យគេស្និទ្ធស្នាលនឹងខ្លួនហើយ នាំគ្នានិយាយភូតត ៗ ទៅ ។ អំពើភូតកុហកនេះ បើមានកម្លាំងច្រើនក៏អាចឃើញទោសក្នុងបច្ចុប្បន្ន, ដូច **នាងចិញ្ចមាណវិកា** ដែលពោលបង្កាច់ព្រះបរមសាស្តា ហើយធរណីស្រូបឲ្យធ្លាក់ទៅកើតក្នុងអវីចិមហានរក; សូមនាំរឿងនោះមកសម្តែងជាឧទាហរណ៍ដូចតទៅនេះ ៖

# រឿង នាងចិញ្ចមាណវិកា

**កាល**ដែលព្រះសម្មាសម្ពុទ្ធបរមគ្រូ ទ្រង់គង់នៅក្នុងវត្តជេតពន, ពួកតិរ្ថិយបង្គាប់ឲ្យនាងចិញ្ចមាណវិកាទៅនិយាយកុហកបង្កាច់ព្រះអង្គ ដោយមេថុនធម្ម ។ តែដោយអំណាចព្រះអង្គមានព្រះឥន្ទ្រជួយទំនុកបម្រុងក្នុងរឿងនោះ, នាងចិញ្ចមាណវិកាក៏ក្លែងចោទបង្កាច់មិនបាន; ត្រឡប់ទៅជាមានទោស គឺពួកមហាជនគេវាយដំច្រំធាក់ទៀបនឹងស្លាប់ ក្នុងវេលាមួយរំពេចនោះឯង ។ លុះគេចចេញអំពីទីនោះទៅ ទើបតែនឹងផុតកន្ទុយព្រះនេត្រព្រះភគវន្តមុនី ក៏ធរណីស្រូបទម្លាក់ឲ្យទៅកើតក្នុងអវីចិមហានរករងទុក្ខវេទនារកអ្វីនឹងឧបមាពុំបានឡើយ ។

ម្យ៉ាងទៀត អំពើមុសាវាទនេះ បើមានកម្លាំងតិចក៏ឲ្យទោសតែក្នុងជាតិខាងមុខ, លោកសម្ដែងថា បើអ្នកណាធ្វើហើយ អ្នកនោះទៅកើតក្នុងជាតិណា ៗ ច្រើនកើតជាមនុស្សរៀចមាត់ ឆែបមាត់ និងច្រើនមានអ្នកដទៃមកចោទបង្កាច់ដោយពាក្យមិនពិតផ្សេង ៗ ។

ព្រោះហេតុដូច្នោះ អំពើភូតកុហកនេះ ទើបហៅថា **បាប** ជាអំពើអាក្រក់មិនគួរធ្វើឡើយ ។ អ្នកប្រាជ្ញទាំងឡាយ លោកសម្លឹងឃើញទោសភូតកុហកដូចសម្ដែងមកនេះហើយ បានជាលោកមិននិយាយភូតកុហកសោះ ។ មិនតែប៉ុណ្ណោះ, ថែមទាំងមានពាក្យសត្យស្មោះត្រង់ទៀតផង; ព្រោះពាក្យសត្យស្មោះត្រង់ជាពាក្យមានរសជាតិ អាចនាំឲ្យអ្នកដែលប្រព្រឹត្តឲ្យរួចចាកភ័យអន្តរាយបាន ។

## ❖ បិសុណាវាទ

**ខ).** បិសុណាវាទនោះ បានខាងពាក្យសម្ដីដែលនិយាយស៊កសៀត គឺរើសយករឿងខាងម្ខាង ទៅប្រាប់ដល់ម្ខាងដោយចេតនាប្រាថ្នានឹងឲ្យគេស្អប់ខ្ពើមមនុស្ស ដែលខ្លួនមិនត្រូវចិត្ត បើរឿងនោះជាពាក្យស៊កសៀតមែន តែជារឿងពិត ក៏គ្រាន់តែជាបិសុណាវាទម្យ៉ាងប៉ុណ្ណោះ បើរឿងនោះជារឿងមិនពិតផង ក៏ជាមុសាវាទថែមទៀត ។

អំពើដែលនិយាយស៊កសៀត នេះជាដើមចមនាំឲ្យអ្នកស្ដាប់បែកចេញពីគ្នា ឈ្លោះវិវាទចងពៀរនឹងគ្នា ។ មិនតែប៉ុណ្ណោះ, ធ្វើទាំងអ្នកនិយាយនោះឲ្យកើតក្ដៅក្រហាយដល់ខ្លួនឯងវិញ ក្នុងជាតិនេះក៏មាន និងសោយទុក្ខក្នុងជាតិខាងមុខក៏មាន, ដូច **សូករប្រេត** ដែលរងទុក្ខយ៉ាងខ្លាំងនោះក៏ព្រោះតែទោសដែលញុះញង់ ឲ្យភិក្ខុពីររូបបែកបាក់គ្នា, សូមនាំរឿងនោះមកសម្ដែងជាឧទាហរណ៍ដូចតទៅនេះ ៖

# រឿង សូករប្រេត

**ក្នុង**សាសនាព្រះពុទ្ធទ្រង់ព្រះនាមកស្សប, មានភិក្ខុ ១ រូបនិយាយញុះញង់ព្រះថេរៈពីរអង្គ ដែលមានសីលាទិគុណល្អ ឲ្យបែកសាមគ្គីអំពីគ្នា ។ ដោយកម្មនោះ, ភិក្ខុនោះឯងក៏ធ្លាក់ទៅឆេះក្នុងអវីចិមហានរកអស់ ១ ពុទ្ធន្តរ ។ ដល់មកសាសនាព្រះពុទ្ធជាម្ចាស់យើងនេះ បានឡើងមកកើតជាប្រេតមានខ្លួនដូចមនុស្សក្បាលដូចជ្រូក នៅលើភ្នំគិជ្ឈកូដ សោយទុក្ខវេទនាមានដង្កូវធំ ៗ ប៉ុន ៗ អណ្ដើក ចាក់រុករើកក្នុងមាត់ និងវារដេរដាសពេញទាំងខ្លួន ។

ឯសូករប្រេតដែលរងទុក្ខ ដូចសម្ដែងមកហើយនេះ ក៏ព្រោះតែទោសដែលនិយាយញុះញង់ព្រះថេរៈពីរអង្គឲ្យបែកសាមគ្គីអំពីគ្នានោះឯង ។

ព្រោះហេតុដូច្នោះបានជា អំពើដែលពោលញុះញង់គេឲ្យបែកគ្នានោះ លោកឲ្យឈ្មោះថា **បាប** ជាអំពើអាក្រក់មិនគួរធ្វើឡើយ ។ បណ្ឌិតទាំងឡាយលោកពិចារណាឃើញទោសនៃពាក្យស៊កសៀតយ៉ាងនេះហើយ បានជាលោកមិននិយាយស៊កសៀតនោះឯង ត្រឡប់ជានិយាយលួងលោមប្រមូលអ្នកដទៃដែលបែកបាក់គ្នាឲ្យត្រឡប់ទៅជាសាមគ្គីព្រមគ្នាឡើងវិញ ។

## ❖ ផរុសវាទ

**គ).** ផរុសវាទនោះ បានខាងសម្ដីដែលនិយាយអាក្រក់បោកបោះ ខ្មោះខ្មួរ មិនគួរស្ដាប់ ដូចជេរប្រទេចផ្ដាសាផ្សេង ៗ ដោយអក្កោសវត្ថុទាំងឡាយមានត្មះតិះដៀលដល់ជាតិ ឬពូជអម្បូរជាដើម ។

បុគ្គលដែលមានបំណងនឹងឲ្យអ្នកដទៃអ័ប្បយស ហើយនិយាយបន្ទុះបង្អាប់ថា " អាឯងជាជាតិពាល " ឬនិយាយចំអកថា " អើបាឯងជាជាតិបណ្ឌិតហើយ " ដូច្នេះជាដើម ហៅថាសម្ដីទ្រគោះ ៗ នេះឯង តែងធ្វើអ្នកដែលស្ដាប់ឲ្យច្រឡោតខឹង ហើយក៏និយាយសម្ដីទ្រគោះបោកបោះតបមកវិញ, កាលបើតបតគ្នាទៅវិញទៅមកហើយ ក៏រាលដាលធំថ្លោសឡើង ដរាបដល់ចងពៀរដល់គ្នានឹងគ្នាតទៅបាន ។ គួរឃើញដូចអ្នកដែលឈ្លោះវិវាទទាស់ទែងខ្វែងគំនិតគ្នា ដែលធ្លាប់ឃើញមកហើយនោះចុះ ។ ម្យ៉ាងទៀត សម្ដីដែលស្ដីទ្រគោះខ្ជីខ្ជាដរាបដល់ជេរប្រទេចនេះ

ឯង, បើជេរប្រទេចផ្ដាសាចំពោះបុគ្គលមានគុណវិសេសតិចក្នុងខ្លួន ទោសនោះក៏ស្រាល, បើមានគុណវិសេសច្រើនក្នុងខ្លួន ទោសនោះក៏ធ្ងន់; ដូច **កោកាលិកភិក្ខុ** ដែលធរណីស្រូបធ្លាក់ទៅកើតក្នុងបទុមនរកនោះ ក៏ព្រោះតែទោសដែលជេរប្រទេចផ្ដាសាព្រះសារីបុត្ត និងព្រះមោគ្គល្លាន សូមនាំនិទាននោះមកសម្ដែងជាឧទាហរណ៍ដូចតទៅនេះ ៖

# រឿង កោកាលិកភិក្ខុ

**កាល**បើព្រះសម្ពុទ្ធបរមគ្រូទ្រង់ជ្រាបថា ទេវទត្តមកនៅក្នុងគយាសីសប្រទេសហើយ ក៏ទ្រង់ប្រើព្រះសារីបុត្ត និងព្រះមោគ្គល្លានឲ្យទៅនាំភិក្ខុទាំងឡាយដែលទេវទត្តនាំយកទៅនោះត្រឡប់មកវិញ ។ ព្រះសាវ័កទាំងពីរក៏ទៅទេសនាទូន្មានភិក្ខុទាំងនោះ ឲ្យបានសម្រេចមគ្គផលហើយនាំគ្នាហោះតាមអាកាសមកឯវត្តជេតពន ។ សម័យនោះ ទេវទត្តកំពុងសិងលក់មិនដឹងខ្លួន, កោកាលិកភិក្ខុជាមិត្តភ័ក្ដិនឹងទេវទត្ត បានឃើញក៏ក្រេវក្រោធស្ទុះលោតទៅធាក់ថងទេវទត្តត្រង់ដើមទ្រូង ហើយក៏ជេរប្រទេចផ្ដាសាព្រះសាវ័កទាំងពីរ ។ កំពុងតែជេរប្រទេច, ធរណីក៏ស្រូបទម្លាក់ចុះទៅសោយទុក្ខក្នុងបទុមនរក ។ ព្រះបរមគ្រូទ្រង់ត្រាស់ថា ៖

- " កោកាលិកភិក្ខុនេះ មិនវិនាសខ្លួនព្រោះខ្ជូចមាត់តែក្នុង

ជាតិនេះទេ, ពីដើមក៏វិនាសដូច្នេះដែរ ˝ ។

ទ្រង់ត្រាស់ហើយក៏សម្ដែងរឿងកច្ឆបជាតក ថា ៖

- ˵ ពីដើមគាត់កើតជាអណ្ដើកជាសម្លាញ់នឹងហង្ស ១ គូ, អណ្ដើកនោះចង់ទៅនៅក្បែរភ្នំចិត្តកូដ ក៏ឲ្យហង្សទាំងគូពាំចុងឈើ ១ ម្ខាង ខ្លួនឯងពាំត្រង់កណ្ដាល ហើយក៏ហើរទៅតាមអាកាស ។ ពួកក្មេង ៗ មើល ឃើញក៏នាំគ្នាស្រែកថា ៖

- ˵ នុ៎ះហ្ន៎មើលអណ្ដើកហោះ ! ˝,

អណ្ដើកបានឮដូច្នោះចង់និយាយត ទើបតែនឹងហាមាត់ឡើង ក៏របូតធ្លាក់ចុះមកទង្គិចនឹងផែនដីបែកស្នូកខ្ទេចខ្ទីស្លាប់វិនាសទៅ ។

នាំរឿងនេះមក, ដើម្បីពន្យល់ឲ្យឃើញថា អំពើដែលនិយាយទ្រគោះខ្ទីខ្ទា ឬជេរប្រទេចអ្នកដទៃនេះ, បើជេរប្រទេចលោកអ្នកមានគុណវិសេសច្រើនក្នុងខ្លួន ទោសក៏ធ្ងន់ ដូចកោកាលិកភិក្ខុនោះឯង ។

ម្យ៉ាងទៀត បុគ្គលខ្លះជាមនុស្សមាត់រអិល សម្ដីណាមិនគួរនិយាយក៏និយាយ, ទោះបីសម្ដីណាដែលគួរនិយាយ ក៏ច្រើនតែប្រែសម្ដីទ្រគោះខ្ទីខ្ទារឿយ ៗ ពេក ជាមនុស្សមិនសូវចេះនិយាយពាក្យថ្នមឲ្យល្មមនឹងចិត្តអ្នកដទៃក៏មាន ។ មនុស្សបែបនេះ ច្រើនតែជួបប្រទះនឹងសេចក្ដីទាស់ទែងរឿយ ៗ ឬច្រើនជួបប្រទះនឹងសេចក្ដីវិនាសដល់ខ្លួន មានខូចយសនិងបង់ទ្រព្យជាដើម, ដូចអណ្ដើកដែលមិនត្រូវទំនងនិយាយក៏និយាយ ហើយវិនាសខ្លួន

ដូច្នោះឯង ។

ព្រោះហេតុនេះ អំពើដែលនិយាយសម្ដីទ្រគោះ ទើបឈ្មោះថា **បាប** ជាអំពើអាក្រក់មិនគួរនិយាយឡើយ ។ អ្នកប្រាជ្ញលោកពិចារណាឃើញច្បាស់លាស់យ៉ាងនេះ បានជាលោកមិននិយាយពាក្យទ្រគោះដែលឈ្មោះថាផរុសវាទនេះទេ; លោកនិយាយតែពាក្យសម្ដីពីរោះគួរឲ្យស្រណោះដល់ត្រចៀករបស់អ្នកស្ដាប់ ដែលរាប់បញ្ចូលថាជាសង្គហវត្ថុ(១) គ្រឿងភ្ជាប់ចិត្តប្រជុំជននោះវិញ ។

## ❖ សម្ផប្បលាបវាទ

**ឃ).** ឯសម្ផប្បលាបវាទនោះ បានខាងពាក្យដែលនិយាយឡេះឡោះ ឬពាក្យដែលរោយរាយ ឥតប្រយោជន៍ខ្លួននិងអ្នកដទៃ, ដូចនិយាយរឿងចំពូកខ្លះ; លោកលើករឿងនាងសិតាជាដើម ថាជារឿងរោយរាយមិនមានប្រយោជន៍ ។ ក្នុងន័យខ្លះលោកឃាត់អ្នកប្រតិបត្តិធម៌មិនឲ្យនិយាយពាក្យតិរច្ឆានកថា ៣២ យ៉ាង មានរាជកថា និងមហាមត្តកថាជាដើម ឲ្យនិយាយតែពាក្យជាវត្ថុកថា ១០ យ៉ាង មានអប្បិច្ឆកថា និងសន្តុដ្ឋីកថា ជាដើម ។

---

(១) សង្គហវត្ថុ ប្រែថា គ្រឿងសង្គ្រោះ ឬគ្រឿងភ្ជាប់ចិត្តប្រជុំជនមាន ៤ យ៉ាងគឺ ៖
១. ទាន ការឲ្យទ្រព្យរបស់ ;
២.បេយ្យវជ្ជ ចរចាពាក្យពីរោះគួរស្រណោះក្នុងចិត្ត ;
៣. អត្ថចរិយា ប្រព្រឹត្តឲ្យជាប្រយោជន៍ដល់ជនដែលត្រូវការ ;
៤. សមានត្តតា សភាពជាអ្នកមានចិត្តស្មោះស្មើ ;

សម្ផប្បលាបវាទនេះ ជាសម្ដីរោយរាយធ្វើទាំងអ្នកនិយាយទាំងអ្នកស្ដាប់ឲ្យរាយមាយចិត្តមិនស្ងប់រម្ងាប់, អ្នកណានិយាយសម្ដីឡេះឡោះ អ្នកនោះក៏សម្ដែងអាការៈឲ្យអ្នកដទៃឃើញថាជាមនុស្សឡេះឡោះដែរ, សម្ដីរបស់មនុស្សដែលនិយាយឡេះឡោះនោះ ជាសម្ដីមិនស័ក្តិសិទ្ធិ ឥតប្រយោជន៍ ។

ព្រោះហេតុដូច្នោះបានជា ឈ្មោះថា **បាប** ជាអំពើអាក្រក់មិនគួរនិយាយឡើយ ។ បណ្ឌិតទាំងឡាយ លោកឃើញទោសនៃសម្ផប្បលាបវាទ ដូចសម្ដែងមកហើយនេះ បានជាលោកនិយាយតែពាក្យសុភាសិត ដែលជាពាក្យមានប្រយោជន៍ដល់ខ្លួននិងអ្នកដទៃ ។

**សម្ដែងមកនេះជាចំណែកវចីកម្ម ។**

# ពណ៌នាសេចក្ដីក្នុងមនោកម្ម

៣. ឯមនោកម្មនោះ បានខាងអំពើដែលសម្រេចដោយចិត្តមាន ៣ យ៉ាង គឺ ៖

**ក). អភិជ្ឈា**

**ខ). ព្យាបាទៈ**

**គ). មិច្ឆាទិដ្ឋិ**

## ❖ អភិជ្ឈា[១]

**ក).** អភិជ្ឈានោះ បានខាងសេចក្ដីលោភសម្លឹងរំពៃគយគន់ប្រុងនឹងយកទ្រព្យរបស់អ្នកដទៃមកជារបស់ខ្លួន ដោយឧបាយដែលមិនត្រូវតាមគន្លងធម៌ គឺប្រុងនឹងឆក់ដណ្ដើម ឬលួចលាក់ឆបោកបំបាត់ប្រវ័ញ្ច និងបញ្ឆោតលល្បួងដោយពិធីផ្សេង ៗ បម្រុងតែនឹងឲ្យបានមកជារបស់ខ្លួន ។

ពួកចោរដែលសម្លាប់ម្ចាស់ទ្រព្យ យកទ្រព្យរបស់គេហើយត្រូវទោសទណ្ឌកម្មផ្សេង ៗ មានគុកច្រវាក់ជាដើមនោះក្ដី, ឬក៏ដូចព្រះបាទ **បសេនទិកោសល** ដែលប្រាថ្នាយករាជសម្បត្តិរបស់អជាតសត្តុរាជកុមារក្ដី, ក៏ព្រោះតែចិត្តលោភសម្លឹងរំពៃចំពោះទ្រព្យរបស់គេ; សូមនាំយករឿងនោះមកសម្ដែងជាឧទាហរណ៍ដូចតទៅនេះ ៖

---

( ១ ) អភិជ្ឈា មានកិរិយាសម្លឹងរំពៃចំពោះទ្រព្យរបស់អ្នកដទៃ ថា " ឱហ្ន៎ ! ទ្រព្យនុ៎ះចូរបានមកជាទ្រព្យរបស់អញ " យ៉ាងនេះ ជាលក្ខណៈ គ្រឿងសម្គាល់ ។ មានអង្គ ២ គឺ បរភណ្ឌំ ទ្រព្យជារបស់អ្នកដទៃ ១, អត្តនោ បរិណាមនំ គិតចង់បង្អោនទ្រព្យរបស់អ្នកដទៃនោះឲ្យបានមកជាទ្រព្យរបស់ខ្លួនដោយកលឧបាយផ្សេង ៗ ១ ។ ទោះបីសេចក្ដីលោភក្នុងទ្រព្យជារបស់អ្នកដទៃកើតឡើងហើយ តែមិនទាន់គិតបង្អោនដើម្បីខ្លួនថា" ឱហ្ន៎ ! ទ្រព្យនុ៎ះចូរបានមកជាទ្រព្យរបស់អញ " ដូច្នេះដរាបណា មិនទាន់បានឈ្មោះថា ធ្លាយកម្មបថដរាបនោះ ។ មានបាលីថា បរភណ្ឌវត្ថុកេហិ លោភេ ឧប្បន្នេបិ ន តាវ កម្មបថ-ភេទោ ហោតិ យាវ អរហាវតេតំ មមស្សាតិ អត្តនោ ន បរិណាមេតិ ដូច្នេះ ។

# រឿង ព្រះបាទបសេនទិកោសល

**ព្រះ**រាជាទ្រង់ព្រះនាមបសេនទិកោសល ព្រះចៅក្រុងសាវត្ថី ទ្រង់ប៉ងចង់បានរាជសម្បត្តិរបស់អជាតសត្តុរាជកុមារដែលជាព្រះភាគិណេយ្យ[១]របស់ព្រះអង្គ, ក៏លើកចតុរង្គសេនាទៅច្បាំងដណ្ដើមយក; ប៉ុន្តែអជាតសត្តុរាជកុមារមានជោគជ័យជាង ក៏ទ្រង់បរាជ័យចាញ់ដៃអជាតសត្តុរាជកុមារនោះដល់បីដង ។ សេចក្ដីនេះសមដូចបុរាណសុភាសិតលោកពោលទុកថា " **ចចើងចង់លាភ វែងបាត់ធនទៅ** " ។

ម្យ៉ាងទៀត ចិត្តដែលប៉ុនប៉ងចង់បានទ្រព្យរបស់គេនេះ មិនមែនជាចិត្តត្រជាក់ទេ ជាចិត្តក្ដៅក្រហាយ, អម្បាលប៉ងចង់បានទ្រព្យរបស់អ្វីមួយដែលត្រូវតាមផ្លូវធម៌ ម្ដេចក៏គង់មានចិត្តក្ដៅខ្លះដែរ ចំណង់បើប៉ងចង់បានទ្រព្យគេដែលមិនត្រូវតាមផ្លូវធម៌ គឺរបស់ដែលគេមិនព្រមឲ្យដល់ខ្លួន នឹងឲ្យមានចិត្តត្រជាក់មកពីណាផតត្រជាក់បន្តិចបន្តួចសោះឡើយ ។

ព្រោះហេតុដូច្នោះបានជា គំនិតដែលគិតសម្លឹងរំពៃចង់បានទ្រព្យគេនោះ ទើបឈ្មោះថា **បាប** ជាអំពើអាក្រក់មិនគួរនឹកនាទេ

---

(១) ពាក្យបាលីថា ភាគិណេយ្យ ប្រែថា ក្មួយ គឺអជាតសត្តុកុមារត្រូវជាក្មួយ ព្រះបាទបសេនទិកោសល ។

បណ្ឌិតទាំងឡាយលោកពិចារណាឃើញទោសយ៉ាងនេះ បានជាលោកព្យាយាមលះអភិជ្ឈានេះចោលចេញ, មានចិត្តសន្តោសត្រេកអរតែនឹងទ្រព្យរបស់ ៗ ខ្លួន ។ មិនតែប៉ុណ្ណោះ, ថែមទាំងមានចិត្តមេត្តាប្រណីមនុស្សនិងសត្វ ហើយបរិច្ចាគទាន ដើម្បីជួយស្រោចស្រង់អាយុជីវិតរបស់មនុស្សនិងសត្វ ឥតស្តាយទ្រព្យសម្បត្តិឡើយ ។

## ❖ ព្យាបាទ

**ខ).** ឯព្យាបាទនោះ បានខាងចិត្តដែលគិតបំផ្លាញអ្នកដទៃឲ្យវិនាសយសស័ក្តិទ្រព្យសម្បត្តិ ដោយសេចក្តីក្រោធខឹងស្អប់ថា ៖ " អ្នកនោះបានធ្វើអំពើយ៉ាងនេះ ៗ ឲ្យអញទាស់ចិត្ត " ។

ព្យាបាទចិត្តនេះ ជាចិត្តក្តៅ, ដូចទឹកក្តៅដែលកំពុងពុះកញ្ជ្រោល ធ្វើខ្លួនឯងឲ្យក្តៅក្រហល់ក្រហាយជាមុន ហើយទើបធ្វើអ្នកដទៃឲ្យក្តៅជាក្រោយ ។ ព្យាបាទនេះឯង តែងកឲ្យកើតជាកម្មពៀរតគ្នាទៅខាងមុខអស់កាលជាអង្វែង, ដូចទេវទត្តដែលព្យាបាទចងពៀរនឹងព្រះដ៏មានព្រះភាគជាម្ចាស់ តាំងអំពីអនេកជាតិមកដោយលំដាប់ តែទេវទត្តចាញ់ព្រះអង្គរាល់ ៗ គ្រា ព្រោះព្រះអង្គមិនចងពៀរតបវិញឡើយ ។ ពុំនោះសោត ដូចរឿងស្ត្រីពីរនាក់ ម្នាក់ជាប្រពន្ធដើម ម្នាក់ជាប្រពន្ធចុង រួមស្វាមីជាមួយគ្នាដែលចងពៀរនឹងគ្នាជាច្រើនជាតិ; សូមនាំរឿងនោះមកសម្តែងជាឧទាហរណ៍ដូចតទៅនេះ ៖

# រឿង ស្ត្រីពីរនាក់រួមប្តីចងពៀរនឹងគ្នា

**មា**នស្ត្រីម្នាក់ជាស្រីអារឥតកូន ខ្លាចក្រែងប្តីយកប្រពន្ធមួយទៀតនឹងត្រួតត្រាលើខ្លួន ក៏ទៅដណ្តឹងស្ត្រីម្នាក់មកឲ្យជាប្រពន្ធរបស់ប្តីដោយខ្លួនឯង ដើម្បីឲ្យប្រពន្ធក្រោយនៅក្រោមអំណាចខ្លួន លុះគេមានគភ៌ក៏ផ្សំថ្នាំឲ្យគេស៊ី រលូតគភ៌ដល់ពីរដង, ម្តងក្រោយទៀតជាគម្រប់បី ប្រពន្ធចុងក៏ស្លាប់ទាំងកូនក្នុងពោះ ។ វេលាទៀបនឹងស្លាប់នោះ បានចងពៀរនឹងគ្នាថា ៖ " បើអញទៅកើតជាអ្វី ៗ សូមឲ្យបានស៊ីកូនវាវិញកុំខាន " ។ លុះប្រពន្ធចុងស្លាប់ហើយ, ប្តីបានដឹងហេតុនោះ ក៏វាយប្រពន្ធដើមជាដំណំ មិនយូរប៉ុន្មានក៏ស្លាប់ទៅ, ទៀបនឹងស្លាប់បានចងពៀរដូចគ្នា ។ ឯកិរិយាដែលជាប់ជាពៀរនឹងគ្នាតទៅមុខទៀតនោះ យ៉ាងនេះគឺ ៖

ជាតិទី ១ ប្រពន្ធចុងជាមេឆ្មា ប្រពន្ធដើមជាមេមាន់ ។

ជាតិទី ២ ប្រពន្ធចុងជាមេម្រឹគ ប្រពន្ធដើមជាមេខ្លាដំបង

ជាតិទី ៣ ប្រពន្ធចុងជាមេយក្ខិនី ប្រពន្ធដើមជានាងកុលធីតា ។

ស៊ីតែកូនគ្នាទៅវិញទៅមករាល់ ៗ ជាតិ ។ ក្នុងជាតិទី ៣ ប្រពន្ធចុងដែលកើតជាយក្ខិនីស៊ីកូនប្រពន្ធដើម ដែលកើតជានាងកុលធីតាដល់ពីរដង, វេលាដែលប្រារព្ធនឹងស៊ីជាគម្រប់បី នាងកុលធីតាក៏នាំកូនខ្ចីរត់ចូលទៅឯវត្តជេតពន ក្នុងវេលាដែលព្រះសម្មាសម្ពុទ្ធជាម្ចាស់ កំពុងសម្តែងធម៌កណ្តាលប្រជុំពុទ្ធបរិស័ទ

នាងកុលធីតា ក៏យកកូនទៅដាក់ក្បែរព្រះបាទថ្វាយព្រះអង្គ ។ ក្នុងខណៈនោះ នាងយក្ខិនីរត់តាមមកទាន់ ។ ព្រះអង្គមានព្រះពុទ្ធដីកាថា ៖

- " នៃនាងទាំងឡាយ ! ត្រូវឈប់ចងពៀរនឹងគ្នាទៅ, ដ្បិតអំពើដែលនាងឯងចងពៀរនឹងគ្នានេះ បើប្រសិនណាជាមិនបានជួបនឹងតថាគតទេ ពៀរនេះមុខជានឹងចេះតែចងគ្នាដរាបដល់អស់ ១ កប្បនេះមិនខាន; ប៉ុន្តែឥឡូវនេះ នាងទាំងពីរនាក់បានមកជួបនឹងតថាគតហើយឈប់ចងពៀរនឹងគ្នាតទៅ ពៀរនេះនឹងរលត់អស់ត្រឹមនេះហើយ " ។ ស្ត្រីទាំងពីរនាក់នោះ ក៏លែងចងពៀរនឹងគ្នាតាំងតែអំពីថ្ងៃនោះមក ត្រឡប់ជាមានចិត្តស្នេហាស្រឡាញ់គ្នាតទៅ ។

នាំរឿងនេះមក ដើម្បីបញ្ជាក់សេចក្តីឲ្យឃើញច្បាស់ថា សេចក្តីព្យាបាទបំផ្លាញគ្នាឲ្យវិនាសនេះឯង តែងកឲ្យកើតជាពៀរនឹងគ្នា កម្រនឹងលុបលាងឲ្យជាសះស្បើយទៅបាន, ដូចនិទានស្ត្រីទាំងពីរនាក់ដែលសម្តែងមកនេះ ។

អំពើដែលព្យាបាទបំផ្លាញអ្នកដទៃឲ្យវិនាសនេះឯង ជាអំពើលាមកអាក្រក់ពេកណាស់ ។ ព្រោះហេតុដូច្នោះបានជាលោកឲ្យឈ្មោះថា **បាប** ជាអំពើអាក្រក់មិនគួរធ្វើទេ ។ បណ្ឌិតទាំងឡាយលោកពិចារណាឃើញទោសនៃព្យាបាទដូចពោលមកហើយនេះ , ទើបលោកលះបង់ចេញ ហើយមានចិត្តមេត្តាប្រណីសព្វសត្វឥត

រើសមុខឡើយ ។

## ❖ មិច្ឆាទិដ្ឋិ

**គ).** ឯមិច្ឆាទិដ្ឋិនោះ បានខាងអំពើដែលយល់ខុស ចាកគន្លងធម៌ពិតធម៌មែន ។

## មិច្ឆាទិដ្ឋិចែកជា ១០ យ៉ាង ៖

១. **នត្ថិ ទិន្នំ** យល់ថាទានដែលបុគ្គលឲ្យ មិនមានផល ;

២. **នត្ថិ យិដ្ឋំ** យល់ថារបស់ដែលបុគ្គលបូជាមិនមានផល ;

៣. **នត្ថិ ហុតំ** យល់ថាសក្ការៈដែលបុគ្គលធ្វើមិនមានផល ;

៤. **នត្ថិ សុកដទុក្កដានំ កម្មានំ ផលវិបាកោ** យល់ថាផលវិបាករបស់កម្មដែលសត្វធ្វើល្អ និងអាក្រក់មិនមាន ;

៥. **នត្ថិ អយំ លោកោ** យល់ថាលោកនេះមិនមាន ;

៦. **នត្ថិ បរោ លោកោ** យល់ថាលោកខាងមុខមិនមាន ;

៧. **នត្ថិ មាតា** យល់ថាមាតាមិនមានគុណ ;

៨. **នត្ថិ បិតា** យល់ថាបិតាមិនមានគុណ ;

៩. **នត្ថិ សត្តា ឧបបាតិកា** យល់ថាសត្វជាឧបបាតិកមិនមាន ;

១០. **នត្ថិ លោកេ សមណព្រាហ្មណា** យល់ថាពួកសមណៈ និងព្រាហ្មណ៍ក្នុងលោកដែលព្រមព្រៀងគ្នាប្រតិបត្តិធម៌ ហើយពោលថា បានធ្វើឲ្យជាក់ច្បាស់នូវលោកនេះ និងលោកខាងមុខមិនមាន ។

## មិច្ឆាទិដ្ឋិ ១០ រួមចូលគ្នាជា ៣

១. **អកិរិយទិដ្ឋិ** យល់ថាកម្មដែលធ្វើមិនមាន គឺមិនជឿកម្ម ;

២. **នត្ថិកទិដ្ឋិ** យល់ថាផលរបស់កម្មមិនមាន គឺមិនជឿផល ;

៣. **អហេតុកទិដ្ឋិ** យល់ថាហេតុបច្ច័យដែលតាក់តែងឲ្យសត្វល្អឬអាក្រក់មិនមានគឺមិនជឿទាំងកម្មទាំងផល ។

## មិច្ឆាទិដ្ឋិបំព្រួញដោយតិចត្រឹម ២ យ៉ាង

១. **សស្សតទិដ្ឋិ** យល់ថាទៀងទាត់បិតបេរ គឺជាតិនេះធ្លាប់កើតជាសត្វ ទៅលោកខាងមុខក៏កើតជាសត្វទៀតមិនប្រែប្រួល ;

២. **ឧច្ឆេទទិដ្ឋិ** យល់ថាដាច់សូន្យសោះ គឺស្លាប់

ហើយមិនកើតទៀត ។

ពាក្យថា **ទិដ្ឋិ** ប្រែថា " **សេចក្តីយល់** " បើយល់ត្រូវ លោកហៅថា " **សម្មាទិដ្ឋិ** " យល់ខុសហៅថា " **មិច្ឆាទិដ្ឋិ** " ។ សេចក្តីយល់ទាំងប៉ុន្មានយ៉ាង ដែលសម្តែងមកហើយខាងលើនេះសុទ្ធតែខុសទាំងអស់ បានជាលោកឲ្យឈ្មោះថា " **មិច្ឆាទិដ្ឋិ** " ។

បើជាមិច្ឆាទិដ្ឋិហើយ ទោះនិយាយ ឬធ្វើ និងគិតអ្វី ៗ ក៏សុទ្ធតែខុស ៗ ទាំងអស់ ។ មិច្ឆាទិដ្ឋិនេះឯង ជាឫសគល់នៃបាបអកុសលគ្រប់ចំពូក ។ ហេតុនេះបានជា ព្រះដ៏មានព្រះភាគជាម្ចាស់ទ្រង់សម្តែងថា " **នាហំ ភិក្ខវេ អញ្ញំ ឯកធម្មំ សមនុបស្សាមិ ម្នាលភិក្ខុទាំងឡាយ ! តថាគតមិនឃើញមានធម៌ដទៃណាមួយជាហេតុ ជាឫសគល់នាំអកុសលដែលមិនទាន់កើតឲ្យកើតឡើង នាំអកុសលដែលកើតឡើងហើយឲ្យរឹងរឹតតែកើតចម្រើនឡើង, ដូចមិច្ឆាទិដ្ឋិនេះឡើយ មិច្ឆាទិដ្ឋិកស្ស ភិក្ខវេ ម្នាលភិក្ខុទាំងឡាយ ! អកុសលធម៌ដែលមិនទាន់កើតឡើង ឬដែលកើតឡើងហើយ រមែងកើតច្រើន ៗ ឡើង ដល់អ្នកដែលយល់ខុសនោះឯង " ដូច្នេះ** ។

ឯសេចក្តីយល់ខុសនេះ បើសម្តែងចំពោះសេចក្តីយល់ខុសចាកព្រះពុទ្ធសាសនា, កុំបាច់និយាយដល់អ្នកដែលមិនទាន់ចូលមកកាន់ព្រះពុទ្ធសាសនានេះឡើយ ទោះបីអ្នកដែលធ្លាប់កាន់ហើយ ក៏គង់នឹងឃ្លាតចេញដោយឆាប់មិនខាន ដូចសុនក្ខត្តលិច្ឆវី

សូមនាំរឿងនោះមកសម្តែងជាឧទាហរណ៍ដូចតទៅនេះ ៖

# រឿង សុនក្ខត្តលិច្ឆវី

**សុ**នក្ខត្តលិច្ឆវីនោះ ជាបុត្តរបស់ស្តេចលិច្ឆវី នៅក្រុងវេសាលី បានចូលមកបួសក្នុងសាសនានៃព្រះបរមគ្រូជាម្ចាស់របស់យើងទាំងឡាយនេះ ។ លុះបួសហើយខំយកចិត្តទុកដាក់បម្រើព្រះដ៏មានព្រះភាគ សូមរៀនទិព្វចក្ខុបរិកម្មដើម្បីឲ្យបានទិព្វចក្ខុវិជ្ជា គឺភ្នែកទិព្វ ។ ព្រះទសពលញ្ញាណក៏ទ្រង់មានសេចក្តីអនុគ្រោះបង្ហាញវិធីឲ្យភាវនា ។ កាលបើសុនក្ខត្តភិក្ខុនោះព្យាយាមប្រតិបត្តិធ្វើបរិកម្មសមគួរតាមពុទ្ធឱវាទទៅហើយ ក៏បានទិព្វចក្ខុមែន មើលឃើញរូបទេវតាទាំងឡាយ, តែស្តាប់សម្លេងមិនឮក៏កើតគំនិតលោភឡើងថា " អាត្មាអញបានឃើញសរីរសណ្ឋានដ៏ជាទិព្វមានលំអរយ៉ាងនេះហើយ, ទាស់តែមិនបានឮសម្លេង បើប្រសិនជាបានឮផងតើនឹងពីរោះពិសាយ៉ាងណាទៅ; ឱហ្ន៎ ! ធ្វើម្តេចនឹងបានឮសម្លេងទិព្វនោះទៀត " ។ លុះគិតដូច្នោះហើយក៏ចូលទៅគាល់ព្រះដ៏មានបុណ្យក្រាបបង្គំសូមរៀនបរិកម្មក្នុងទិព្វសោតវិជ្ជាតទៅ ។

ព្រះបរមលោកនាថជាម្ចាស់ មិនបានត្រាស់ពន្យល់ដូចមុនឡើយ, ព្រោះទ្រង់ជ្រាបថា ក្នុងកាលកន្លងទៅហើយសុនក្ខត្តភិក្ខុនោះ បានប្រហារគុម្ពត្រចៀកភិក្ខុមានសីល ១ រូបឲ្យថ្លង់ស្តាប់អ្វី

មិនឮសោះ ។ ព្រោះសេសបាបនោះ ទោះបីព្យាយាមយ៉ាងណា ក៏មិនបានទិព្វសោតទេ, បានជាព្រះបរមគ្រូមិនទ្រង់ពន្យល់សូម្បី សុនក្ខត្តភិក្ខុខំធ្វើបរិកម្មភាវនាដោយខ្លួនឯងអស់បីឆ្នាំ ក៏ឥតបាន ទិព្វសោតវិជ្ជានោះឡើយ ។ កាលបើមិនបានទិព្វសោតវិជ្ជា ដូច្នោះ, សុនក្ខត្តភិក្ខុក៏គិតថា ៖

- " ច្បាស់ជាព្រះសមណគោតមយល់ថា លោកក៏ជាតិ ក្សត្រិយ៍អញក៏ជាតិក្សត្រិយ៍ស្មើគ្នា " បើប្រសិនជាបណ្ដោយឲ្យ អញបានទិព្វសោតវិជ្ជាទៅ ក្រែងលោអញបានត្រាស់ដឹងព្រះ សព្វញ្ញុតញ្ញាណស្មើនឹងលោក បានជាលោកមិនខ្វល់ខ្វាយប្រាប់ វិធីចម្រើនឲ្យកើតទិព្វសោតវិជ្ជាដល់អញឡើយ, គឺលោកប្រាថ្នា នឹងរារាំងញាណវិស័យនៃអញជាប្រាកដ " ។

កាលបើសុនក្ខត្តភិក្ខុគិតជ្រុលយល់ជ្រួស ដោយគំនិតខូច ដូច្នោះហើយ ក៏ចងគំនុំនឹងព្រះបរមគ្រូតទៅ ។ លុះកាលកន្លង ទៅដោយលំដាប់, សុនក្ខត្តភិក្ខុនោះក៏សឹកចេញទៅជាគ្រហាវាស វិនាសចាកពុទ្ធសាសនា ។

ឯគំនិតដែលសុនក្ខត្តភិក្ខុគិត ថ្កោលទោសព្រះសម្មាសម្ពុទ្ធ ដូច្នោះ ជាគំនិតឆ្វេងខុសទទេ មិនត្រូវតាមសេចក្ដីពិតឡើយ ព្រោះធម្មតាព្រះពុទ្ធទាំងឡាយ មិនមានព្រះហឫទ័យញាប់ញ័រ ដោយលោកធម៌[១]ទេ ។ ដូចកាលដែលសុភទ្ទបរិព្វាជកចូលទៅ

(១) លោកធម៌មាន ៨ គឺ ៖ ១. បានលាភ, ២. សូន្យលាភ, ៣. បានយស, ៤. សូន្យយស, ៥. និន្ទា, ៦. សរសើរ, ៧. សុខ, ៨. ទុក្ខ ។

ក្រាបបង្គំទូលសួរព្រះដ៏មានព្រះភាគជាម្ចាស់យើង អំពីរឿងសមណៈ អំពីសង្ខារ និងអំពីព្រះហឫទ័យនៃព្រះពុទ្ធទាំង - ឡាយ ។ ព្រះអង្គក៏ទ្រង់ទេសនាប្រៀបធៀបគតិលោកនិងគតិធម៌តាមសេចក្តីពិតថា ៖

**អាកាសេវ បទំ នត្ថិ សមណោ នត្ថិ ពាហិរេ**
**សង្ខារា សស្សតា នត្ថិ នត្ថិ ពុទ្ធានមិញ្ជិតំ ។**

សេចក្តីថា ៖ **ខាងក្រៅពីពុទ្ធសាសនាមិនមានសមណៈទេ, សង្ខារទាំងឡាយមិនដែលទៀងទេ, ព្រះពុទ្ធទាំងឡាយមិនមានសេចក្តីញាប់ញ័រទេ, ដូចជាស្នាមជើងដែលមិនមានឮដ៏អាកាសដូច្នោះឯង ។**

ព្រោះអាស្រ័យពុទ្ធភាសិតនេះជាសំអាង, បានជាឃើញថាគំនិតដែលសុនក្ខត្តភិក្ខុគិតដូច្នោះ ជាគំនិតយល់ខុសគួររាប់ថា ជាមិច្ឆាទិដ្ឋិពេញទីបាន, ព្រោះគិតថ្កោលព្រះហឫទ័យរបស់ព្រះសម្មាសម្ពុទ្ធ មិនត្រូវតាមទំនងដែលពិតមែន ។

ហេតុនេះបានជា មិច្ឆាទិដ្ឋិគំនិតយល់ឆ្វេង យល់ខុសដូចសុនក្ខត្តលិច្ឆវីនេះជាដើម លោកឲ្យឈ្មោះថា **បាប** ជាអំពើអាក្រក់ដែលបុគ្គលមិនគួរឲ្យមកប៉ះពាល់ក្នុងចិត្តឡើយ ។ បណ្ឌិតទាំងឡាយ លោកឃើញទោសមិច្ឆាទិដ្ឋិដូចពោលមកនេះ បានជាលោកលះបង់, ហើយព្យាយាមធ្វើសម្មាទិដ្ឋិឲ្យកើតឡើង ។

## អធិប្បាយមកនេះជាចំណែកមនោកម្ម

# សរុបសេចក្ដីកាយកម្ម, វចីកម្ម, មនោកម្ម

**កាយកម្ម ៣, វចីកម្ម ៤, មនោកម្ម ៣** នេះ សុទ្ធតែចាត់ជា **បាប** ទាំងអស់ ។ ក្នុងបាលីមានសម្ដែងអំពីបាប ៣ ពួកនេះច្រើនជាងចំណែកដទៃ ៗ ព្រោះបាបអម្បាលនេះជាប្រធានរបស់បាបទាំងពួង, សូម្បីបណ្ដាបាបដទៃក៏រួមចូលក្នុងបាប ៣ ពួកនេះដែរ; បាបទាំងនេះ ចួនកាលលោកហៅថា **បាប** ដដែល ចួនកាលលោកហៅថា **ទុច្ចរិត** ចួនកាលលោកហៅថា **អកុសល** ចួនកាលលោកហៅថា **អករណីយកិច្ច** ចួនកាលលោកហៅថា **អធម្ម-ចរិយៈ វិសមចរិយៈ** ។ ដែលហៅថា **បាប** នោះប្រែថា កម្មដ៏លាមក, ហៅថា **ទុច្ចរិត** ប្រែថាសេចក្ដីប្រព្រឹត្តអាក្រក់, ហៅថា **អកុសល** ប្រែថាការមិនល្អ, ហៅថា **អករណីយកិច្ច** ប្រែថាកិច្ចមិនគួរធ្វើ, ហៅថា **អធម្មចរិយៈ វិសមចរិយៈ** ប្រែថាសេចក្ដីប្រព្រឹត្តមិនជាធម៌ សេចក្ដីប្រព្រឹត្តមិនសម ។

បណ្ដាបាបទាំងប៉ុន្មានដែលបានពោលមកហើយនេះ, ឥតមានចំណែកណាមួយដែលជារបស់គួរធ្វើសោះឡើយ; សុទ្ធតែជាកិច្ចមិនគួរធ្វើទាំងអស់ ។ ព្រះភគវន្តមុនីបរមគ្រូជាម្ចាស់បានត្រាស់នឹងព្រះអានន្ទថា ៖

## ឯកំសេនាហំ អានន្ទ អករណីយំ វទាមិ

ម្នាលអានន្ទ ! តថាគតហៅ កាយទុច្ចរិត, វចីទុច្ចរិត និង មនោទុច្ចរិត ថាជាកិច្ចដែលបុគ្គលមិនគួរធ្វើដោយដាច់ខាត, កាល បើបុគ្គលណាមួយជ្រុលកាយ វាចា ចិត្ត ធ្វើអករណីយកិច្ចនោះ ហើយ ត្រូវដឹងខ្លួនចុះថា មុខជានឹងមានទោស បើយ៉ាងតិចត្រឹម ៥ យ៉ាង ដូចពោលខាងមុខ ៖

## ទោសទុច្ចរិត ៥ យ៉ាង

១. **អត្តាបិ អត្តានំ ឧបវទតិ** សូម្បីខ្លួនឯងតិះដៀល ខ្លួនឯងបាន ;

២. **អនុវិច្ច វិញ្ញូ គរហន្តិ** លោកអ្នកចេះដឹងរិះគន់ មើលរមែងតិះដៀលបាន ;

៣. **បាបកោ កិត្តិសទ្ទោ អព្ភុគច្ឆតិ** កេរ្តិ៍ឈ្មោះអាក្រក់ រមែងខ្ចរខ្ចាយឡើង ;

៤. **សម្មូឡ្ហោ កាលំ ករោតិ** វង្វេងស្មារតីក្នុងវេលាទៀប ស្លាប់ ;

៥. **កាយស្ស ភេទា បរម្មរណា ទុគ្គតឹ ឧបបជ្ជតិ** ខាងមុខអំពីទំលាយខ័ន្ធទៅ រមែងទៅកើតក្នុងទុគ្គតិ ។

បាបរមែងឲ្យទោសក្នុងលោកទាំងពីរ, អ្នកធ្វើបាបក៏រមែង ក្តៅក្រហាយក្នុងលោកទាំងពីរ គឺ ៖

១. ក្នុងលោកនេះ រមែងក្ដៅក្រហាយដោយគិតថា អាត្មាអញបានធ្វើបាបដូច្នោះ ៗ ;
២. លុះច្យុតចាកលោកនេះទៅហើយ រឹងរឹតតែក្ដៅក្រហាយជាងនេះទៅទៀត ។

ព្រោះហេតុដូច្នោះ ទើបលោកពោលថា **បាប** នោះ ជាកិច្ចមិនគួរធ្វើឡើយ ។ ការដែលមិនធ្វើបាបនោះ ក៏គឺការសង្រួមក្នុងសីល ឬការលះវៀរចាកទុច្ចរិត ដែលលោកហៅថា **វិរតិ** នោះឯង ។

## វិរតិមាន ៣ យ៉ាង

១. សម្បត្តវិរតិ, ២. សមាទានវិរតិ, ៣. សមុច្ឆេទវិរតិ ។

- **សម្បត្តវិរតិ** នោះ ប្រែថា ការវៀរចាកវត្ថុដែលដល់ព្រម គឺមិនទាន់តាំងចិត្តមកពីដើមទេ ស្រាប់តែប្រទះនឹងវត្ថុដែលគួរនឹងប្រព្រឹត្តល្មើស, គួរធ្វើខុស ក៏មិនប្រព្រឹត្តល្មើស មិនធ្វើខុស ការវៀរបែបនេះ បានខាងការវៀររបស់មនុស្សសាមញ្ញដែលមិនទាន់សមាទានសីល ។
- **សមាទានវិរតិ** ប្រែថា ការវៀរដោយអំណាចសមាទាន គឺបានប្ដេជ្ញាថាវៀរមកពីដំបូង ។ ការវៀរបែបនេះ បានខាងការវៀររបស់សាធុជនដែលសមាទានសីល ដូចឧបាសក, ឧបាសិកា និងភិក្ខុសាមណេរ ។

- **សមុច្ឆេទវិរតិ** ប្រែថា ការវៀរដោយអំណាចកាត់ផ្តាច់ឫសគល់អកុសលដោយល្អ ។ ការវៀរបែបនេះ បានខាងការវៀររបស់ព្រះអរិយបុគ្គល ដែលមិនប្រព្រឹត្តកន្លងសេចក្តីបញ្ញត្តិនោះ ៗ ចាប់ដើមតាំងពីលោកបានជាព្រះអរិយហើយ ។

**ពាក្យ**ដែលហាមប្រាមមិនឲ្យធ្វើបាបគ្រប់យ៉ាង គឺឲ្យលះវៀរចាកបាបដោយការសង្រួមក្នុងសីល ឬដោយវិរតិទាំងបីដូចន័យដែលសម្តែងមកនេះ រាប់ថាជា **ពុទ្ធសាសនា** ពាក្យប្រៀនប្រដៅរបស់ព្រះពុទ្ធទាំងឡាយ គឺព្រះពុទ្ធគ្រប់ព្រះអង្គដែលបានត្រាស់ក្នុងកាលទាំងពួង តែងទ្រង់ប្រដៅដូច្នេះ ។

# ចប់កណ្ឌទី ១



# ឱវាទបាតិមោក្ខ កណ្ឌទី ២

**លំដាប់នេះ** នឹងអធិប្បាយសេចក្តីនៃព្រះបរមពុទ្ធោវាទក្នុងឱវាទបាតិមោក្ខ ត្រង់បទថា **កុសលស្សូបសម្បទា ការបំពេញកុសលឲ្យបរិបូណ៌** នោះឲ្យមានសេចក្តីពិស្តារ ដើម្បីជាគ្រឿងប្រដាប់សតិបញ្ញានិងជាវត្តប្រតិបត្តិរបស់សាធុសប្បុរសពុទ្ធបរិស័ទ ដូចតទៅនេះ ៖

កម្មដែលកំចាត់បង់សេចក្តីអាក្រក់ ហៅថា **កុសល** ការដែលព្យាយាមធ្វើកុសលឲ្យកើតឲ្យមានឡើងក្នុងកាយ វាចា ចិត្ត ហៅថា **បំពេញកុសលឲ្យបរិបូណ៌** ។ ឯកុសលនោះ បើសម្តែងដោយឫសគល់ ក៏បានខាង **អលោភៈ** ( សេចក្តីមិនលោភ ) **អទោសៈ** ( សេចក្តីមិនប្រទូស្ត ) **អមោហៈ** ( សេចក្តីមិនវង្វេង ) ។ **អលោភៈ, អទោសៈ, អមោហៈ** ទាំង ៣ នេះ ជាតួកុសលផង ជាឫសគល់របស់កុសលផង ។ កាលបើសម្តែងតាមកម្មឬទ្វារ ក៏ជា ៣ យ៉ាងគឺ ៖

១. **កាយសុចរិត** ;
២. **វចីសុចរិត** ;
៣. **មនោសុចរិត** ។

កាលបើសម្តែងតាមភូមិ ក៏ជា ៤ យ៉ាងគឺ ៖

១. **កាមាវចរភូមិ** ;
២. **រូបាវចរភូមិ** ;
៣. **អរូបាវចរភូមិ** ;
៤. **លោកុត្តរភូមិ** ។

# កុសលប្រព្រឹត្តទៅក្នុងភូមិ ៤

១. កុសលពួកណា ដែលជាវិស័យរបស់អ្នកនៅត្រេកអរដោយកាម នឹងឲ្យផលដល់អ្នកនោះឲ្យកើតជាមនុស្សវិសេស ឬ ជាទេវតាក្នុងឆកាមាវចរសួគ៌, កុសលអម្បាលនោះ ហៅថា **កាមាវចរភូមិ** ។

២. កុសលពួកណាដែលជាវិស័យរបស់អ្នកត្រេកអរដោយរូបជ្ឈាន នឹងឲ្យផលដល់អ្នកនោះឲ្យកើតជាព្រហ្មមានរូប, កុសលអម្បាលនោះ ហៅថា **រូបាវចរភូមិ** ។

៣. កុសលពួកណាដែលជាវិស័យរបស់អ្នកត្រេកអរដោយអរូបជ្ឈាន នឹងឲ្យផលដល់អ្នកនោះឲ្យកើតជាព្រហ្មមិនមានរូប, កុសលអម្បាលនោះ ហៅថា **អរូបាវចរភូមិ** ។

៤. កុសលពួកណាដែលជាវិស័យរបស់អ្នកនឿយណាយចំពោះលោកិយវិស័យ នឹងឲ្យផលដល់អ្នកនោះឲ្យដល់លោកុត្តរៈ, កុសលអម្បាលនោះ ហៅថា **លោកុត្តរភូមិ** ។

# អធិប្បាយចិត្តជាកាមាវចរកុសល

កាមាវចរកុសល កាលបើអធិប្បាយតាមចិត្តុប្បាទ គឺខណៈចិត្តដែលផ្ដួចផ្ដើមដំបូងនោះ ដូចតទៅនេះ ៖

ចិត្តអ្នកធ្វើកាមាវចរកុសល ចួនកាលក៏ប្រកបដោយសោមនស្សត្រេកអររីករាយហៅថា **សោមនស្សសហគត** ចួនកាលក៏ប្រកបដោយឧបេក្ខា ព្រងើយ ៗ ហៅថា **ឧបេក្ខាសហគត**, សហគតទាំង ២ នេះ លោកសរសើរសោមនស្សសហគតជាងឧបេក្ខាសហគត ។ ចួនកាលក៏ចេះពិចារណាលៃលកដោយប្រាជ្ញាជាមុនហើយទើបធ្វើ ហៅថា **ញាណសម្បយុត្ត**, ចួនកាលក៏មិនចេះពិចារណាលៃលកដោយប្រាជ្ញាទេ ឃើញគេធ្វើយ៉ាងណាក៏ធ្វើតាមគេយ៉ាងនោះទៅ ហៅថា **ញាណវិប្បយុត្ត** ។ បយុត្តទាំង ២ នេះ លោកសរសើរញាណសម្បយុត្តជាងញាណវិប្បយុត្ត ។ ចួនកាលក៏កើតឡើងឯង មិនបាច់នរណាបបួលហៅថា **អសង្ខារិក**, ចួនកាលក៏អាស្រ័យនឹងអ្នកដទៃបបួលទើបធ្វើបាន ហៅថា **សសង្ខារិក**, សង្ខារិក ទាំង ២ នេះ លោកសរសើរអសង្ខារិកជាងសសង្ខារិក ។

**កាមាវចរកុសលចិត្ត** នោះចែកជា ៨ ដូចមានខាងមុខ ៖

# ចិត្តជាកាមាវចរកុសល ៨

១. ចិត្តជាសោមនស្សសហគត ញាណសម្បយុត្ត

អសង្ខារិក ;

២. ចិត្តជាសោមនស្សសហគត ញាណសម្បយុត្ត សសង្ខារិក ;

៣. ចិត្តជាសោមនស្សសហគត ញាណវិប្បយុត្ត អសង្ខារិក ;

៤. ចិត្តជាសោមនស្សសហគត ញាណវិប្បយុត្ត សសង្ខារិក ;

៥. ចិត្តជាឧបេក្ខាសហគត ញាណសម្បយុត្ត អសង្ខារិក;

៦. ចិត្តជាឧបេក្ខាសហគត ញាណសម្បយុត្ត សសង្ខារិក;

៧. ចិត្តជាឧបេក្ខាសហគត ញាណវិប្បយុត្ត អសង្ខារិក;

៨. ចិត្តជាឧបេក្ខាសហគត ញាណវិប្បយុត្ត សសង្ខារិក;

ចែកកាមាវចរកុសលតាមបុញ្ញកិរិយាវត្ថុ ១០ តទៅ ។

កាមាវចរកុសលនេះ កាលបើនិយាយដោយកិរិយាធ្វើ លោកចែកជា ១០ យ៉ាងហៅថា **បុញ្ញកិរិយាវត្ថុ** ។

## បុញ្ញកិរិយាវត្ថុ ១០ យ៉ាង

១. កិរិយាឲ្យនូវវត្ថុដ៏គួរដល់បុគ្គលដែលគួរឲ្យ ដោយសេចក្ដីសង្គ្រោះឬបូជាគុណ មានឲ្យដល់មនុស្សកំសត់ ឬបូជាដល់លោកអ្នកដ៏មានសីល និងមាតាបិតាជាដើម ហៅថា **ទាន** ;

២. កិរិយាវៀរចាកអំពើអាក្រក់ ដែលកើតអំពីកាយឬវាចា

មានវៀរចាកបញ្ចវេរាទាំង ៥ ជាដើម ហៅថា **សីល** ;

៣. កិរិយាធ្វើចិត្តឲ្យស្ងប់រម្ងាប់ ដោយសមថវិធីត្រឹមឧបចារ វិបស្សនាវិធីត្រឹមអនុលោម ហៅថា **ភាវនា** ;

៤. កិរិយាបន្ទន់អស្មិមានះ ដែលមានក្នុងចិត្តដោយសេចក្តីកោតក្រែងដល់បុគ្គលដែលគួរកោតក្រែង គឺជនដែលចម្រើនដោយជាតិ ដោយវ័យ និងដោយគុណ ហៅថា **អបចាយនៈ** ;

៥. កិរិយាជួយខ្វល់ខ្វាយក្នុងកិច្ចរបស់អ្នកដទៃ ដែលគួរធ្វើដោយកាយ ឬវាចា ហៅថា **វេយ្យាវច្ចៈ** ;

៦. កិរិយាឲ្យនូវចំណែកបុណ្យ ដែលខ្លួនបានធ្វើហើយដល់អ្នកដទៃដោយចិត្តមេត្រី ដើម្បីឲ្យគេប្រព្រឹត្តត្រេកអរតាមហៅថា **បត្តិទានៈ** ;

៧. កិរិយាអនុមោទនាត្រេកអរ តាមសេចក្តីល្អរបស់អ្នកដទៃ ដោយចិត្តដែលប្រាសចាកសេចក្តីឫស្យា ឈ្នានីសហៅថា **បត្តានុមោទនា** ;

៨. កិរិយាណែនាំប្រៀនប្រដៅអ្នកដទៃ ឲ្យចេះចំណេះដែលឥតទោស ឬពន្យល់ក្នុងផ្លូវធម៌ឲ្យស្គាល់កិច្ចគួរធ្វើ និងមិនគួរធ្វើ ដែលប្រព្រឹត្តទៅដើម្បីសម្បត្តិសួគ៌និងព្រះនិព្វាន ហៅថា **ធម្មទេសនា** ;

៩. កិរិយាតាំងចិត្តស្តាប់ធម៌ដោយប្រុង ឲ្យចេះចាំធម៌អាចបាន ហៅថា **ធម្មស្សវន** ;

១០. កិរិយាធ្វើទិដ្ឋិ សេចក្តីយល់ឃើញរបស់ខ្លួនឲ្យត្រង់

តាមគន្លងធម៌ដែលពិតមែន ហៅថា **ទិដ្ឋុជុកម្ម** ។

ទាំង ១០ ប្រការនេះ បានជាហៅថា **បុញ្ញកិរិយាវត្ថុ** ព្រោះសុទ្ធតែជាការបុណ្យ ការកុសលទាំងអស់, ការកុសលបែបនេះ ចាត់ជា **កាមាវចរភូមិ** ។

ឯ **រូបាវចរកុសល** នោះ បានខាងរូបជ្ឈានទាំង ៤ គឺ ៖

១. បឋមជ្ឈាន ;

២. ទុតិយជ្ឈាន ;

៣. តតិយជ្ឈាន ;

៤. ចតុត្ថជ្ឈាន ។

កុសលបែបនេះ ចាត់ជា **រូបាវចរភូមិ** ។

ឯ **អរូបាវចរកុសល** នោះ បានខាងអរូបជ្ឈានទាំង ៤ គឺ ៖

១. អាកាសានញ្ចាយតនជ្ឈាន ;

២. វិញ្ញាណញ្ចាយតនជ្ឈាន ;

៣. អាកិញ្ចញ្ញាយតនជ្ឈាន ;

៤. នេវសញ្ញានាសញ្ញាយតនជ្ឈាន ។

កុសលបែបនេះ ចាត់ជា **អរូបាវចរភូមិ** ។

ឯ **លោកុត្តរកុសល** នោះ បានខាងមគ្គ ៤ ផល ៤ គឺ ៖

១. សោតាបត្តិមគ្គ សោតាបត្តិផល

២. សកទាគាមិមគ្គ សកទាគាមិផល

៣. អនាគាមិមគ្គ អនាគាមិផល

៤. អរហត្តមគ្គ អរហត្តផល ។

កុសលបែបនេះ ចាត់ជា **លោកុត្តរភូមិ** ។

កុសលទាំង ៤ ភូមិនុ៎ះ រួមចុះជា ២ គឺលោកិយកុសល ១, លោកកុត្តរកុសល ១ ។ កាមាវចរកុសល, រូបាវចរកុសល និង អរូបាវចរកុសល ចាត់ជា **លោកិយកុសល** ។ លោកុត្តរ-កុសល នៅជាលោកុត្តរកុសលដដែល ។ លោកិយកុសល ចាត់ជាវដ្តគាមិនីកុសល កុសលប្រព្រឹត្តទៅក្នុងវដ្តៈ ។ លោកុត្ត-កុសល ចាត់ជាវិវដ្តគាមិនីកុសល កុសលផុតចាកវដ្តៈ ។

# សេចក្តីមិនប្រមាទជាកំពូលកុសល

កាលបើលើកយកកំពូលនៃកុសលឡើងសម្តែង ក៏បាន ខាងសេចក្តីមិនប្រមាទ, ព្រោះព្រះបរមលោកនាថជាម្ចាស់ទ្រង់ត្រាស់ថា ៖

**យេកេចិ កុសលា ធម្មា សព្វេ តេ អប្បមាទមូលកា**
**អប្បមាទសមោសរណា អប្បមាទោ តេសំ អគ្គមក្ខាយតិ**

**កុសលធម៌ទាំងឡាយឯណានីមួយ កុសលធម៌ទាំងអស់នោះ មានសេចក្តីមិនប្រមាទជាមូល គឺជាឫសគល់រួមចុះក្នុងសេចក្តីមិន ប្រមាទទាំងអស់, បណ្ឌិតទាំងឡាយរមែងពោលសរសើរសេចក្តីមិន ប្រមាទថា ជាកំពូលរបស់កុសលធម៌ទាំងនោះ ។**

# អធិប្បាយសេចក្តីមិនប្រមាទ

សេចក្តីមិនប្រមាទ គឺសេចក្តីមិនប្រហែស ។ សេចក្តីមិនប្រមាទនេះ បានជាហៅថាជាកំពូលនៃកុសល, ព្រោះបណ្តាកុសលធម៌ទាំងអស់ កុសលធម៌ឯណាមួយ ដែលនឹងកើតឡើងបាន ក៏ព្រោះតែសេចក្តីមិនប្រមាទកើតឡើងជាមុនទាំងអស់, ឬក៏មានសេចក្តីមិនប្រមាទ នៅពីមុនខ្លះមកហើយទើបកើតឡើងបាន; ដូចមេដំបូលប្រាសាទ ដែលជាទីរួបរួមនៃគ្រឿងទព្វសម្ភារៈទាំង-ឡាយមានផ្ទោង ផ្លានជាដើម ។ ព្រោះហេតុនេះទើបព្រះដ៏មានព្រះភាគជាម្ចាស់ ទ្រង់សម្តែងសេចក្តីមិនប្រមាទដោយបរិយាយផ្សេង ៗ មានដើមថា ៖

**នាហំ ភិក្ខវេ អញ្ញំ ឯកធម្មំ សមនុបស្សាមិ**

**ម្នាលភិក្ខុទាំងឡាយ ! តថាគតមិនឃើញមានធម៌ដទៃណាមួយ ដែលជាហេតុញ៉ាំងកុសលមិនទាន់កើតឲ្យកើតឡើង, ញ៉ាំងកុសលដែលកើតឡើងហើយ ឲ្យរឹងរឹតតែចម្រើនឡើង, ដូចសេចក្តីមិនប្រមាទនេះឡើយ ។**

សូម្បីកាលដែលព្រះអង្គ រៀបនឹងទ្រង់រំលត់ខន្ធបរិនិព្វានទ្រង់បានសម្តែងដាស់តឿនថា ៖

**ហន្ទទានិ ភិក្ខវេ អាមន្តយាមិ វោ**

**ម្នាលភិក្ខុទាំងឡាយ ! តថាគតដាស់តឿនអ្នកទាំងអស់គ្នា**

**វយធម្មា សង្ខារា**
**សង្ខារទាំងឡាយមានសេចក្តីសូន្យជាធម្មតា**

**អប្បមាទេន សម្បាទេថ**
**អ្នកទាំងឡាយចូរញុំាងប្រយោជន៍ឲ្យសម្រេច**
**ដោយសេចក្តីមិនប្រមាទចុះ ។**

# មិនប្រមាទក្នុងការលះ និងការចម្រើន

កាលបើសម្តែងដល់អំពើនៃសេចក្តីមិនប្រមាទ ដោយសង្ខេប ក៏មានតែ ២ យ៉ាងគឺ ៖

១. មិនប្រមាទក្នុងការលះ ;

២. មិនប្រមាទក្នុងការចម្រើន ។

# អធិប្បាយសេចក្តីមិនប្រមាទក្នុងការលះតទៅ

១. ឯមិនប្រមាទក្នុងការលះនោះ មានអធិប្បាយថាអំពើណា ៗ ប្រព្រឹត្តទៅដើម្បីខូចប្រយោជន៍ខ្លួននិងអ្នកដទៃ អំពើនោះ ៗ ជាអំពើគួរលះ ទោះបីបន្តិចបន្តួចក៏មិនត្រូវប្រថុយប្រមាទឡើយ ។ ដ្បិតព្រះដ៏មានបុណ្យជាម្ចាស់ទ្រង់ត្រាស់ប្រដៅថា ៖

**មាវមញ្ញេថ បាបស្ស ន មត្តំ អាគមិស្សតិ**
**ឧទពិន្ទុនិបាតេន ឧទកុម្ភោបិ បូរតិ**
**អាបូរតិ ពាលោ បាបស្ស ថោកំ ថោកំបិ អាចិនំ ។**

សេចក្ដីថា **បុគ្គលមិនគួរមើលងាយបាបថា " បាបមានប្រមាណតិច និងមិនឲ្យផលឡើយ " សូម្បីក្អមទឹកដែលគេបើកមាត់ចំហរទុកក្នុងទីវាល ក៏រមែងពេញដោយតំណក់ទឹកភ្លៀងដែលធ្លាក់ពីលើអាកាសចុះមកម្ដងបន្តិច ៗ បាន យ៉ាងណាមិញ, មនុស្សពាល កាលបើសន្សំបាប សូម្បីតែបន្តិចម្ដង ៗ ក៏អាចពេញដោយបាបបាន យ៉ាងនោះដែរ ។**

# រឿង ភិក្ខុមិនប្រយ័ត្នបរិក្ខារ

ព្រះឱវាទានុសាសនីនេះ ព្រះអរហំសម្មាសម្ពុទ្ធទ្រង់ប្រារព្ធនឹងភិក្ខុ ១ រូបដែលមិនប្រយ័ត្នគ្រឿងបរិក្ខា មានគ្រែជាដើមយកទៅប្រើក្នុងទីណាៗ ក៏បោះបង់ចោលក្នុងទីនោះ ៗ មិនយកមកទុកវិញ ។ កាលបើមានពួកភិក្ខុមកដាស់តឿន លោកក៏ពោលពាក្យមើលងាយថា ៖ " អំពើបន្តិចបន្តួចប៉ុណ្ណឹង នឹងទៅជាអ្វីទៅបើគ្រឿងបរិក្ខារនោះវាគ្មានចិត្តទេ " ។ ព្រះបរមសាស្ដាទ្រង់ជ្រាបទ្រង់បង្គាប់ឲ្យហៅភិក្ខុនោះមក ហើយទ្រង់បញ្ញត្តបាចិត្តិយសិក្ខាបទ រួចទ្រង់ប្រទានព្រះឱវាទទុកជាគ្រឿងដាស់តឿនពុទ្ធបរិស័ទដោយព្រះពុទ្ធដីកា ដូចបានពោលមកហើយ ។

២. ចំណែកខាងមិនប្រមាទក្នុងការចម្រើននោះ មានអធិប្បាយថា អំពើណា ៗ ដែលប្រព្រឹត្តទៅដើម្បីជាប្រយោជន៍ខ្លួននិងអ្នកដទៃ, អំពើនោះ ៗ ជាអំពើគួរចម្រើន, ទោះបីបន្តិចបន្តួចក៏

មិនត្រូវប្រមាទឡើយ, ដ្បិតព្រះដ៏មានព្រះភាគទ្រង់ប្រដៅថា ៖

**មាវមញ្ញេថ បុញ្ញស្ស ន មត្តំ អាគមិស្សតិ**
**ឧទពិន្ទុនិបាតេន ឧទកុម្ភោបិ បូរតិ**
**អាបូរតិ ធីរោ បុញ្ញស្ស ថោកំ ថោកំបិ អាចិនំ ។**

សេចក្តីថា **បុគ្គលមិនគួរមើលងាយបុណ្យថា " បុណ្យមានប្រមាណតិច និងមិនឲ្យផលឡើយ " សូម្បីក្អមទឹកដែលគេបើកមាត់ចំហរទុកក្នុងទីវាល ក៏អាចពេញទៅដោយតំណក់ទឹកភ្លៀងដែលធ្លាក់ពីលើអាកាសចុះមកបន្តិចម្តង ៗ បាន យ៉ាងណាមិញ, អ្នកមានប្រាជ្ញាកាលបើសន្សំបុណ្យសូម្បីម្តងបន្តិច ៗ ក៏អាចពេញដោយបុណ្យបាន យ៉ាងនោះដែរ ។**

# រឿង ពិលាលបទកសេដ្ឋី

ព្រះឱវាទានុសាសនីនេះ ព្រះសក្យមុនីបរមគ្រូជាម្ចាស់ទ្រង់ប្រារព្ធនឹងសេដ្ឋីម្នាក់ ដែលឃើញបុរសអ្នកចាត់ការទានមកក្រើនឲ្យធ្វើទាន មកដល់ផ្ទះរបស់ខ្លួន ក៏នឹកក្តាញ់ក្នុងចិត្តថា ៖ " ម្តេចក៏មិនធ្វើតែល្មមនឹងកម្លាំងខ្លួន ចាំបាច់ដើររៃគេ " គិតហើយក៏ចិបអង្ករខ្លះ សណ្តែករាជមាសខ្លះ មួយមុខបន្តិច ៗ ដូចជាឆ្មាកកាយឲ្យទៅបុរសនោះ, ព្រោះហេតុដូច្នោះ បានជាអ្នកស្រុកគេហៅថា **ពិលាលបទកសដ្ឋី** ( សេដ្ឋីជើងឆ្មា ) តទៅ ។ បុរសអ្នក

ចាត់ការ ក៏នាំយកវត្ថុទាំងនោះទៅរួបរួម ហើយតាក់តែងធ្វើជាចង្ហាន់បម្រុងប្រគេនសង្ឃក្នុងវេលាព្រឹក ។ លុះព្រឹកឡើងវេលាព្រះសង្ឃកំពុងឆាន់ សេដ្ឋីក៏សៀតក្រឹស[១]ដើរទៅក្នុងទីប្រជុំនោះដោយគិតថា ៖ " បើបុរសអ្នកចាត់ការនិយាយដើមខ្លួនប្រាប់គេនឹងប្រហារដោយក្រឹសនោះ " ។ លុះព្រះសង្ឃនិងព្រះពុទ្ធជាម្ចាស់ឆាន់ហើយ បុរសអ្នកចាត់ការបានក្រាបបង្គំទូលព្រះអង្គថា ៖ " សូមទ្រង់ព្រះមេត្តាប្រោស ! ខ្ញុំព្រះអង្គបានដើរបបួលមហាជនឲ្យបរិច្ចាគទានតាមកម្លាំងរបស់ខ្លួន ៗ ច្រើនខ្លះ តិចខ្លះ សូមឲ្យបានផលដល់ម្ចាស់ទានគ្រប់ ៗ គ្នាចុះ ។ កាលបើសេដ្ឋីបានឮដូច្នោះ, ក៏ត្រឡប់ជាកើតគំនិតល្អដឹងទោសរបស់ខ្លួន ហើយសូមស្មាលាទោសនឹងបុរសអ្នកចាត់ការក្នុងវេលានោះវិញ ។ ព្រោះហេតុនេះបានជា ព្រះបរមសាស្តាទ្រង់ប្រទានព្រះសទ្ធម្មទេសនាប្រដៅពុទ្ធបរិស័ទកុំឲ្យមើលងាយបុណ្យ ដូចន័យដែលបានពោលមកហើយ ។

## មិនប្រមាទក្នុងទី ៤ ស្ថាន

ន័យមួយវិញទៀត ព្រះសយម្ភូញាណជាម្ចាស់ទ្រង់ត្រាស់ប្រដៅឲ្យលះ កាយទុច្ចរិត, វចីទុច្ចរិត, មនោទុច្ចរិត និងកុំឲ្យ

(១) ក្រឹស ( ន. ) គ្រឿងសស្ត្រាខ្លីស្រួច មានមុខទាំងពីរខាងសម្រាប់ស៊កក្នុងស្រោមសៀតចង្កេះដូចកាំបិតស្នៀត ។

ប្រមាទក្នុងការលះទុច្ចរិតទាំងនោះ ឲ្យធ្វើកាយសុចរិត វចីសុចរិត មនោសុចរិត ឲ្យកើតមានឡើង និងកុំឲ្យប្រមាទក្នុងការចម្រើនសុចរិតទាំងនោះ ។ ក៏ឯសេចក្ដីមិនប្រមាទនេះ បើនឹងពោលតាមសេចក្ដី ក៏គឺសតិ, សតិនិងសេចក្ដីមិនប្រមាទមានសេចក្ដីជាមួយគ្នា, ដ្បិតព្រះដ៏មានព្រះភាគជាម្ចាស់បានត្រាស់ថា ៖

**ចតូសុ ភិក្ខវេ ឋានេសុ អត្តរូបេន អប្បមាទោ សតិ ចេតសោ អារក្ខោ ករណីយោ ។**

ម្នាលភិក្ខុទាំងឡាយ ! សេចក្ដីមិនប្រមាទ គឺសតិ ជាធម៌រក្សាទុកនូវចិត្ត ជាធម្មជាតិដែលអ្នកទាំងឡាយត្រូវធ្វើក្នុងទី ៤ ស្ថានតាមសមគួរដល់ខ្លួន, សេចក្ដីមិនប្រមាទដែលអ្នកទាំងឡាយត្រូវធ្វើក្នុងទី ៤ ស្ថាននោះ គឺតាំងចិត្តថា ៖

១. ចិត្តរបស់អាត្មាអញកុំត្រេកត្រអាល ក្នុងធម៌ដែលជាហេតុឲ្យកើតសេចក្ដីត្រេកត្រអាល ;

២. ចិត្តរបស់អាត្មាអញកុំប្រទូស្ត ក្នុងធម៌ដែលជាហេតុឲ្យកើតសេចក្ដីប្រទូស្ត ;

៣. ចិត្តរបស់អាត្មាអញកុំវង្វេង ក្នុងធម៌ដែលជាហេតុឲ្យកើតសេចក្ដីវង្វេង ;

៤. ចិត្តរបស់អាត្មាអញកុំស្រវឹង ក្នុងធម៌ដែលជាហេតុឲ្យកើតសេចក្ដីស្រវឹង ។

# ធម៌ជាឧបការៈនៃសេចក្ដីមិនប្រមាទ

កាលបើពោលដោយសេចក្ដីប្រតិបត្តិ ដែលជាឧបការៈដល់សេចក្ដីមិនប្រមាទនោះ ក៏គឺមនសិការៈ ធ្វើទុកក្នុងចិត្តដល់ខយវយធម៌សេចក្ដីអស់សេចក្ដីសូន្យ ។ បុគ្គលនឹករំពឹងដល់សេចក្ដីសូន្យនៃសង្ខារ ដោយអំណាចសេចក្ដីចាស់ សេចក្ដីឈឺ សេចក្ដីស្លាប់ក្ដី, នឹករំពឹងថា ៖ " **ឱ ! សេចក្ដីចាស់, ឈឺ, ស្លាប់ជាភ័យធំរុករានទន្ទ្រានកាយចូលកាន់តែជិត ៗ មកហើយ** " ដូច្នេះក្ដី; តអំពីនោះទៅ ទើបមិនប្រមាទ ខំខ្មីឃ្មាតបំពេញកុសលឲ្យកើតមានឡើងក្នុងសន្ដាន ។ ព្រោះហេតុនោះបានជា ព្រះបរមសាស្ដាជាម្ចាស់ កាលនឹងត្រាស់ដាស់តឿនពុទ្ធបរិស័ទឲ្យមិនប្រមាទ ក៏ទ្រង់លើកយកសេចក្ដីអស់ សេចក្ដីសូន្យ ឡើងសម្ដែងជាមុនថា ៖

**វយធម្មា សង្ខារា**

**សង្ខារទាំងឡាយ មានសេចក្ដីសូន្យទៅជាធម្មតា ។**

ហើយទើបត្រាស់ទេសនាមិនឲ្យប្រមាទជាខាងក្រោយថា ៖

**អប្បមាទេន សម្បាទេថ**

**អ្នកទាំងឡាយ ! ចូរញុំាងប្រយោជន៍ឲ្យសម្រេចដោយសេចក្ដីមិនប្រមាទចុះ;** ដូច្នេះ ។

# ឧបាយឲ្យកើតអប្បមាទធម៌

ឯមនសិការៈដល់សេចក្តីអស់, សេចក្តីសូន្យ ដោយអំណាចសេចក្តីចាស់, សេចក្តីឈឺ, សេចក្តីស្លាប់ ដែលជាឧបាយឲ្យកើតអប្បមាទធម៌នោះ, ដូចក្នុងអភិណ្ហបច្ចវេក្ខណៈ ដែលទ្រង់ប្រដៅឲ្យស្ត្រី, បុរស, គ្រហស្ថ, បព្វជិត គិតរំពឹងពិចារណាថា៖

**ជរាធម្មោម្ហិ ជរំ អនតីតោ**

**អាត្មាអញមានសេចក្តីចាស់ជាធម្មតា នឹងកន្លងសេចក្តីចាស់ទៅមិនបាន ។**

**ព្យាធិធម្មោម្ហិ ព្យាធឹ អនតីតោ**

**អាត្មាអញមានសេចក្តីឈឺថ្កាត់ជាធម្មតា នឹងកន្លងសេចក្តីឈឺថ្កាត់ទៅមិនបាន ។**

**មរណធម្មោម្ហិ មរណំ អនតីតោ**

**អាត្មាអញមានសេចក្តីស្លាប់ជាធម្មតា នឹងកន្លងសេចក្តីស្លាប់ទៅមិនបាន ។**

**សព្វេហិ មេ បិយេហិ មនាបេហិ នានាភាវោ វិនាភាវោ ។**

**អាត្មាអញគង់តែព្រាត់ប្រាសចាកសត្វនិងសង្ខារ ដែលជាទីស្រឡាញ់ ជាទីពេញចិត្តទៅទាំងអស់ ។**

**កម្មស្សកោម្ហិ កម្មទាយាទោ កម្មយោនិកម្មពន្ធុ**

**កម្មបដិស្សរណោ យំ កម្មំ ករិស្សាមិ កល្យាណំ វា បាបកំ វា តស្ស ទាយាទោ ភវិស្សាមិ ។**

**អាត្មាអញមានកម្មជារបស់ខ្លួន មានកម្មជាអ្នកឲ្យនូវផល មានកម្មជាកំណើត មានកម្មជាផៅពង្ស មានកម្មជាទីពឹងអាស្រ័យ, អាត្មាអញនឹងធ្វើកម្មឯណា ជាកម្មល្អក្តី អាក្រក់ក្តី អាត្មាអញត្រូវជាអ្នកទទួលនូវផលនៃកម្មនោះ;** ដូច្នេះ ។

ន័យមួយទៀត គប្បីពិចារណាឲ្យវិសេសឡើងទៅជាងនេះថា ៖ សេចក្តីចាស់ សេចក្តីឈឺ សេចក្តីស្លាប់ដែលមានជាធម្មតា កន្លងទៅមិនបាននេះ នឹងមានតែអាត្មាអញម្នាក់ឯងក៏ទេ, ទោះបីសត្វទាំងឡាយទាំងពួង ដែលកំពុងមក កំពុងទៅ កំពុងច្យុត កំពុងកើត ក៏សុទ្ធតែជាអ្នកមានសេចក្តីចាស់ សេចក្តីឈឺ សេចក្តីស្លាប់ជាធម្មតា កន្លងទៅមិនបានដូចគ្នា, សេចក្តីព្រាត់ប្រាសចាករបស់ជាទីស្រឡាញ់ ជាទីពេញចិត្តនោះសោត ក៏មិនមែនមានតែអាត្មាអញម្នាក់ឯង, ទោះបីសត្វទាំងឡាយទាំងពួង ដែលកំពុងមក កំពុងទៅ កំពុងច្យុត កំពុងកើត ក៏សុទ្ធតែព្រាត់ប្រាសចាករបស់ជាទីស្រឡាញ់ ជាទីពេញចិត្តដូចគ្នាដែរ, ទាំងកម្មដែលជារបស់នៃខ្លួន កម្មជាអ្នកឲ្យនូវផល កម្មជាកំណើត កម្មជាផៅ-ពង្ស កម្មជាទីពឹងអាស្រ័យនឹងធ្វើកម្មឯណា ទោះល្អក្តី អាក្រក់ក្តី ត្រូវតែទទួលយកផលនៃកម្មនោះ ក៏មិនមែនតែអាត្មាអញម្នាក់ឯងឡើយ, ទោះបីសត្វទាំងឡាយទាំងពួង ដែលកំពុងមក កំពុងទៅ កំពុងច្យុត កំពុងកើត ក៏សុទ្ធតែជាអ្នកមានកម្មជា

របស់ខ្លួន មានកម្មជាអ្នកឲ្យនូវផល មានកម្មជាកំណើត មានកម្មជាផៅពង្ស មានកម្មជាទីពឹងអាស្រ័យ បើសត្វទាំងនោះធ្វើកម្មឯណា ទោះល្អក្តី អាក្រក់ក្តី ក៏ត្រូវតែទទួលយកផលនៃកម្មនោះ ខានមិនបានដូចគ្នាដែរ ។

ការដែលពិចារណាក្នុងអភិណ្ហបច្ចវេក្ខណៈទាំង ៥ នេះជាឧបាយបំបាត់សេចក្តីប្រមាទ សេចក្តីស្រវឹងថា ៖ " អាត្មាអញនៅកម្លោះក្រមុំ, មិនមានរោគ, មិនទាន់ស្លាប់ " បាន និងជាឧបាយរំកៀកខ្លួនឲ្យផុតចាកបាប, បែរមុខឆ្ពោះទៅរកបុណ្យកុសល, ចម្រើនចំណែកដែលជា **ភាវនាកិច្ច** ( កិច្ចដែលត្រូវចម្រើន ) លះបង់ចំណែកដែលជា **បហានកិច្ច** ( កិច្ចដែលត្រូវលះបង់ ) ចោលចេញបាន ។

អភិណ្ហប្បច្ចវេក្ខណៈទាំង ៥ នេះជាឧបការៈឲ្យឃើញសេចក្តីអស់ សេចក្តីសូន្យ ជាហេតុឲ្យកើតអប្បមាទធម៌ ។

ឯផ្លូវដែលរំពឹងពិចារណាឲ្យឃើញ សេចក្តីអស់ និងសេចក្តីសូន្យ របស់សង្ខារនោះ មិនមែនមានតែប៉ុណ្ណោះឡើយ, មានច្រើនជាអនេក; បណ្ឌិតបាននាំយកធម៌ទាំងឡាយដែលជាហេតុឲ្យកើតអប្បមាទធម៌ ហៅថា **វិបស្សនា** មកឲ្យពិចារណាថា ៖

**រូបំ អតីតានាគតប្បច្ចុប្បន្នំ**

**រូបទាំងអតីត អនាគត បច្ចុប្បន្ន ដែលមានបច្ច័យតាក់តែងអាស្រ័យបច្ច័យហើយក៏កើតឡើង សុទ្ធតែជារបស់មិនទៀងមាន**

កិរិយាអស់ទៅ សូន្យទៅ ប្រែប្រួលទៅ រលត់ទៅជាធម្មតា, សូម្បីវេទនាខន្ធ សញ្ញាខន្ធ សង្ខារក្ខន្ធ វិញ្ញាណក្ខន្ធ ក៏ដូចគ្នា,

**សព្វេ សង្ខារា អនិច្ចា**

សង្ខារទាំងឡាយ គឺបញ្ចក្ខន្ធ មិនទៀង ជាទុក្ខ មានកិរិយាប្រែប្រួលទៅជាធម្មតា; សេចក្ដីទៀង សេចក្ដីសុខ សេចក្ដីប្រែប្រួលនោះ បុគ្គលនឹងបានមកពីណា ,

**យន្តំ ជាតំ**

របស់ណាដែលកើតឡើង ដែលបច្ច័យតាក់តែងឡើង សុទ្ធតែមានកិរិយាបែកធ្លាយទៅវិញជាធម្មតាទាំងអស់, សូម្បីបុគ្គលនិយាយអង្វរថា ៖ " សូមកុំឲ្យរបស់នោះវិនាសឡើយ " ដូច្នេះក៏ឥតអំពើ ,

**អហោ ចត មេ ឥមិនា ជីវិតេន រត្តិន្ទិវេន**

ឱ! ថ្ងៃនិងយប់ចេះតែកន្លងទៅ ៗ សូម្បីអាយុរបស់អាត្មាអញក៏អស់ទៅតាមថ្ងៃនិងយប់ដែរ ទាំងជីវិតរបស់អាត្មាអញសោតក៏កាន់តែរុករានទន្ទ្រានចូលទៅជិតកាន់សេចក្ដីស្លាប់ហើយ,

**ពហុកា ខោ មេ បច្ចយា មរណស្ស**

បច្ច័យនៃសេចក្ដីស្លាប់របស់អាត្មាអញច្រើនក្រៃពេក, មានទាំងខាងក្នុងខាងក្រៅ អាត្មាអញមុខជានឹងធ្វើកាលកិរិយាដោយហេតុនោះ ៗ ដោយអន្តរាយនោះ ៗ , ភ័យនឹងអន្តរាយនោះ ៗ មុខជានឹងមានដល់អាត្មាអញជាប្រាកដមិនខាន ។

កាលបើបុគ្គលបានរំពឹងដល់ **អភិណ្ហប្បច្ចវេក្ខណៈ** និង **វិបស្សនា** ន័យដូចនាំមកសម្ដែងនេះហើយ, សូម្បីតែយ៉ាងណានីមួយក៏សុទ្ធតែជាឧបាយឲ្យកើតអប្បមាទធម៌ទាំងអស់ ។

បណ្ឌិតគួរស្ងួនគ្រងរក្សាអប្បមាទធម៌ ទុកឲ្យដូចជាអ្នកដែលសម្លឹងឃើញប្រយោជន៍នៃទ្រព្យ ហើយបីបាច់រក្សាទ្រព្យមិនឲ្យអន្តរាយដូច្នោះ ។

សេចក្ដីដែលសម្ដែងមកនេះ ជាសេចក្ដីអធិប្បាយអំពី **កុសល**, កុសលនេះ ជាកិច្ចគួរធ្វើ គឺគួរញុំាងកុសលដែលមិនទាន់បានធ្វើឲ្យមានឡើង ដែលធ្វើហើយឲ្យរឹតតែចម្រើនឡើង កុំឲ្យសាបសូន្យទៅឡើយ, ព្រោះកុសលនេះ កាលបើបុគ្គលបានធ្វើឲ្យបរិបូណ៌ហើយ រមែងប្រព្រឹត្តទៅដើម្បីជាគុណប្រយោជន៍សមគួរតាមអំពើរបស់ខ្លួន ។ ព្រោះហេតុដូច្នោះបានជាព្រះដ៏មានព្រះភាគអរហន្តសម្មាសម្ពុទ្ធជាម្ចាស់ ទ្រង់ត្រាស់ប្រដៅឲ្យបំ - ពេញកុសលដោយព្រះពុទ្ធដីកាថា ៖

**កុសលំ ភិក្ខវេ ភាវេថ**

**ម្នាលភិក្ខុទាំងឡាយ ! អ្នកទាំងឡាយចូរញុំាងកុសលឲ្យចម្រើន កុសលនេះជាធម្មជាតិគឺអ្នកទាំងឡាយអាចឲ្យចម្រើនបាន, បើមិនអាចឲ្យចម្រើនបានទេ តថាគតក៏មិនគួរនឹងពោលថា ៖ " អ្នកទាំងឡាយចូរញុំាងកុសលឲ្យចម្រើន " ដូច្នេះឡើយ; ព្រោះតែអ្នកទាំងឡាយចូរញុំាងកុសលឲ្យចម្រើនបាន, បានជាតថាគត**

**ហៅនពោលថា " អ្នកទាំងឡាយចូរញ៉ាំងកុសលឲ្យចម្រើន " នេះឯង ។ មួយទៀត បើកុសលដែលអ្នកទាំងឡាយធ្វើឲ្យចម្រើនហើយនោះត្រឡប់ជាទោសប្រព្រឹត្តទៅដើម្បីឥតប្រយោជន៍ ដើម្បីសេចក្តីទុក្ខវិញ ក៏តថាគតមិនគួរនឹងពោលថា ៖ " អ្នកទាំងឡាយចូរញ៉ាំងកុសលឲ្យចម្រើន " ដូច្នេះទេ, ព្រោះតែកុសលដែលបុគ្គលបានធ្វើឲ្យចម្រើនហើយ តែងប្រព្រឹត្តទៅដើម្បីប្រយោជន៍ ដើម្បីសេចក្តីសុខ បានជាតថាគតពោលថា ៖ " អ្នកទាំងឡាយចូរញ៉ាំងកុសលឲ្យចម្រើន " ដូច្នេះឯង ។**

**ពាក្យ**ដែលប្រដៅឲ្យបំពេញកុសលឲ្យបរិបូណ៌ គឺឲ្យធ្វើសេចក្តីល្អឲ្យកើតមានឡើងក្នុងខន្ធសន្តាន ដោយបុញ្ញកិរិយាវត្ថុឬដោយសមថៈនិងវិបស្សនា ដូចន័យដែលពោលមកនេះរាប់ថាជា **ពុទ្ធសាសនា** ពាក្យប្រដៅរបស់ព្រះពុទ្ធទាំងឡាយ ក៏ព្រះពុទ្ធរាល់ព្រះអង្គដែលបានត្រាស់ក្នុងកាលទាំងពួង តែងទ្រង់ប្រដៅដូច្នេះ ។

# ចប់កណ្ឌទី ២

# ឱវាទបាតិមោក្ខ កណ្ឌទី ៣

**លំដាប់នេះ** នឹងអធិប្បាយសេចក្តីនៃព្រះបរមពុទ្ធោវាទក្នុងឱវាទបាតិមោក្ខ ត្រង់បទថា ៖ **សចិត្តបរិយោទបនំ ការញ៉ាំងចិត្តរបស់ខ្លួនឲ្យផូរផង់** នោះ, ឲ្យមានសេចក្តីពិស្តារ ដើម្បីជាគ្រឿងប្រដាប់សតិបញ្ញា និងជាវត្តប្រតិបត្តិរបស់សាធុជនពុទ្ធ - បរិស័ទ ដូចតទៅនេះ ៖

ធម្មជាតិដែលគិតដឹងនូវអារម្មណ៍ ហៅថា **ចិត្ត**, ការដែលធ្វើចិត្តរបស់ខ្លួនឲ្យល្អបរិសុទ្ធដោយសព្វគ្រប់ ដរាបដល់បានសម្រេចមគ្គផល មានអរហត្តជាទីបំផុត ហៅថា **ការញ៉ាំងចិត្តរបស់ខ្លួនឲ្យផូរផង់** ។ **ចិត្ត** ជាធម្មជាតិដ៏ល្អិតឥតមានរូបរាងសណ្ឋានទ្រង់ទ្រាយពណ៌យ៉ាងណាទេ គ្រាន់តែជា **នាមធម៌** ម៉្យាង, បើនិយាយតាមបញ្ចក្ខន្ធ ក៏គឺវិញ្ញាណនោះឯង; ជារបស់ប្រែប្រួលឃ្លេងឃ្លោងក្រឡាប់ក្រឡុកទៅមកបាន, ចួនកាលជាយ៉ាងនោះ ចួនកាលជាយ៉ាងនេះ ។ ព្រោះហេតុដូច្នោះ បានជាក្នុងគម្ពីរព្រះអភិធម្មសម្តែងប្រភេទរបស់ចិត្តដោយពិស្តារថា ៖ មាន ១២១ ចិត្ត ដោយសង្ខេប ៨៩ ចិត្ត ។ តែតាមសេចក្តីពិតចិត្តនេះជាធម្មជាតិតែមួយ, ដែលបានជាច្រើនដូច្នោះ ព្រោះចែកតាមប្រភេទនៃសេចក្តីប្រព្រឹត្តទៅ, កាលបើប្រព្រឹត្តទៅយ៉ាងណាក៏ហៅឈ្មោះតាមអាការដែលប្រព្រឹត្តទៅយ៉ាងនោះ ។ **ចិត្ត** ជា

ធម្មជាតិសំខាន់បំផុត បុគ្គលនឹងបានទុក្ខឬសុខក៏ព្រោះចិត្ត, ទៅទុគ្គតិឬសុគតិក៏ព្រោះចិត្ត, សម្រេចព្រះនិព្វាន ក៏ព្រោះតែចិត្តនេះឯង ។ ព្រោះហេតុដូច្នោះបានជាព្រះដ៏មានព្រះភាគជាម្ចាស់ទ្រង់ត្រាស់ថា ៖

**នាហំ ភិក្ខវេ អញ្ញំ ឯកធម្មំ សមនុបស្សាមិ**

**ម្នាលភិក្ខុទាំងឡាយ ! តថាគតមិនឃើញធម៌ណាមួយដទៃ ដូចចិត្តនេះឡើយ**

**ចិត្តំ ភិក្ខវេ អទន្តំ**

**ម្នាលភិក្ខុទាំងឡាយ ! ចិត្ត ដែលបុគ្គលមិនបានទូន្មាន មិនបានគ្រប់គ្រង មិនបានបីបាច់រក្សា មិនបានសង្រួម មិនបានរវាំង មិនបានប្រយ័ត្ន រមែងប្រព្រឹត្តទៅដើម្បីសេចក្តីវិនាសយ៉ាងធំ**

**ចិត្តំ ភិក្ខវេ ទន្តំ**

**ម្នាលភិក្ខុទាំងឡាយ ! ចិត្តនេះបើបុគ្គលបានទូន្មាន បានគ្រប់គ្រង បានថែទាំរក្សា បានសង្រួម បានរវាំង បានប្រយ័ត្នហើយ តែងប្រព្រឹត្តទៅដើម្បីប្រយោជន៍យ៉ាងធំ ។**

## បានទុក្ខ ឬសុខ ក៏ព្រោះចិត្ត

ត្រង់ពាក្យថា បានទុក្ខ ឬសុខ ក៏ព្រោះចិត្តនោះមានអធិប្បាយថា ៖ បុគ្គលនឹងធ្វើកិច្ចការអ្វី ៗ ដោយកាយក្តី ដោយវាចាក្តី ក៏ព្រោះចិត្តរិះគិតផ្តើមឡើងជាមុនទើបធ្វើបាន, កាលបើ

ចិត្តគិតខុសហើយ កិច្ចការនោះ ៗ ក៏មិនល្អ, ថែមទាំងមានទោសទុក្ខកើតឡើងផង; បើចិត្តរិះគិតត្រូវ ទើបមានផលល្អនិងជាគុណឲ្យបានសេចក្តីសុខ សេចក្តីចម្រើនដល់ខ្លួន ។ ម្យ៉ាងទៀត ចិត្តដែលលោភចង់បានក្តី, ចិត្តដែលត្រេកត្រអាលក្នុងកាមគុណក្តី, ចិត្តដែលក្រោធខឹងប្រទូស្តក្តី, ចិត្តដែលវង្វេងមិនដឹងខុសត្រូវក្តី, សូម្បីតែម៉្យាង ៗ ក៏សុទ្ធតែជាភ្លើងដុតរោលឲ្យក្តៅក្រហាយឲ្យកើតទុក្ខព្រួយលំបាកទាំងអស់ ។ ចិត្តនេះបើប្រាសចាកសេចក្តីលោភ, សេចក្តីត្រេកត្រអាល, សេចក្តីក្រោធខឹងប្រទូស្តនិងសេចក្តីវង្វេងហើយ ទើបអស់សេចក្តីក្តៅក្រហាយជាសុខសប្បាយទៅបាន, ទោះបីមិនអស់ជាសមុច្ឆេទប្បហានផ្តាច់ផ្តិលព្រមទាំងឫសគល់ក៏ដោយ ឲ្យតែបានត្រឹមតទង្គប្បហានស្ងប់រម្ងាប់ដោយខណៈ ៗ ក៏គង់ជាសុខស្រួលក្នុងចន្លោះ ៗ ដែរ ព្រោះហេតុនោះបានជាព្រះដ៏មានបុណ្យជាម្ចាស់ ទ្រង់ព្រះមេត្តាប្រោសសម្តែងប្រាប់វិធីច្រើនយ៉ាងជាវិធីប្រដៅចិត្តឲ្យប្រព្រឹត្តទៅដើម្បីសេចក្តីសុខសេចក្តីចម្រើន មានទ្រង់ប្រដៅមិនឲ្យលុះអំណាចសេចក្តីលោភដែលកើតឡើង ឲ្យសន្តោសតាមមានតាមបាន ឲ្យលះបង់សេចក្តីក្រោធ និងសេចក្តីវង្វេងជាដើម ។ ឯព្រះពុទ្ធដីកាដែលទ្រង់ប្រដៅឲ្យលះសេចក្តីលោភជាដើមនេះ សូម្បីតែម៉្យាង ៗ ក៏សុទ្ធតែជាផ្លូវសុខ ផ្លូវចម្រើនទាំងអស់ ។ សេចក្តីដែលបានអធិប្បាយមកនេះ ដើម្បីបង្ហាញឲ្យឃើញថា បានទុក្ខឬសុខក៏ព្រោះតែចិត្ត ។

# ទៅទុគ្គតិ ឬសុគតិក៏ព្រោះចិត្ត

ត្រង់ពាក្យថា ទៅទុគ្គតិ ឬសុគតិ ក៏ព្រោះតែចិត្តនោះមាន សេចក្ដីអធិប្បាយថា ៖ " **កម្មគឺអំពើដែលសត្វធ្វើគ្រប់យ៉ាងដែលនឹងមានផលក្ដៅត្រជាក់ ក៏អាស្រ័យនឹងចេតនា ដ្បិតចេតនាជាតួកម្ម** " ។ ព្រោះហេតុនេះ បានជាព្រះដ៏មានព្រះភាគទ្រង់ សម្ដែងថា ៖

**ចេតនាហំ ភិក្ខវេ កម្មំ វទាមិ**
**ម្នាលភិក្ខុទាំងឡាយ! តថាគតហៅចេតនា**
**សេចក្ដីដែលតាំងចិត្តធ្វើថាជាតួកម្ម ។**

កាលបើតាំងចិត្តធ្វើដោយសេចក្ដីលោភ, សេចក្ដីក្រោធ, សេចក្ដីវង្វេង, ចាត់ជាអកុសលកម្ម, បើតាំងចិត្តធ្វើដោយសេចក្ដីមិនលោភ, មិនក្រោធ, មិនវង្វេង, ចាត់ជាកុសលកម្ម ។

# ប្រៀបកម្មនឹងការបណ្ដុះពូជវត្ថុទាំងពួង

លោកប្រៀបធៀបកិរិយាប្រព្រឹត្តទៅរបស់កម្មជាកុសល និងអកុសលដែលឲ្យផលផ្សេងគ្នា ថា ៖

**យាទិសំ វបតេ ពីជំ តាទិសំ លភតេ ផលំ**
**កល្យាណការី កល្យាណំ បាបការី ច បាបកំ ។**

សេចក្ដីថា **មនុស្សក្នុងលោក គេសាបព្រោះបណ្ដុះពូជបែបណា តែងបានផ្លែផ្កាមកជាបែបនោះវិញ, សេចក្ដីនេះមាន**

**ឧបមាដូចម្ដេចមិញ; កល្យាណជនអ្នកធ្វើអំពើល្អ តែងបានល្អ, បាបជនអ្នកធ្វើអំពើអាក្រក់ ក៏តែងបានអាក្រក់; មានឧបមេយ្យដូច្នោះដែរ ។**

អធិប្បាយថា បើសត្វឯណាបានធ្វើអំពើល្អឬអាក្រក់, អំពើនោះឯង ក៏បែងចែករំលែកឲ្យសត្វនោះ ៗ បានល្អឬអាក្រក់តាមបែបដែលធ្វើ; អំពើអាក្រក់ក៏នាំទៅកាន់ទុគ្គតិ, អំពើល្អក៏នឹងនាំទៅកាន់សុគតិ ។ ទាំងនេះ ក៏សម្រេចមកតែអំពីចិត្តជាហេតុទាំងអស់ ។

សូមលើកឧទាហរណ៍ឡើងសម្ដែងដូចតទៅនេះ ៖

# រឿង តិរ្ថិយជួលចោរវាយព្រះមោគ្គលាន

កាលបើពុទ្ធសាសនារុងរឿងឡើង, ពួកតិរ្ថិយក៏ឱនអាប់មិនសូវមានគេរាប់អាន; ព្រោះហេតុនេះ ទើបពួកតិរ្ថិយជួលពួកចោរឲ្យសម្លាប់ព្រះមោគ្គលាន ដោយយល់ថា ពុទ្ធសាសនារុងរឿងព្រោះតែព្រះថេរៈនោះ ។ ព្រះបាទអជាតសត្រូវឲ្យស៊ើបដំណឹងរកឃើញតាមពិត ទ្រង់ឲ្យចាប់ពួកតិរ្ថិយ និងពួកចោរមកឲ្យជីករណ្ដៅត្រឹមផ្ចិត គ្របចំបើងដុតភ្លើងហើយទ្រង់បង្គាប់ឲ្យភ្ជួរដោយនង្គ័លដែក ដាច់ជាកំណាត់ធំកំណាត់តូច ស្លាប់អស់មិនមានសល់ ។

ទាំងនេះ ក៏ព្រោះចិត្តលោភលាភសក្ការៈនឹងថ្លៃឈ្នួល ។

# រឿង អសោកមហារាជ

ព្រះបាទអសោកមហារាជនោះ ទ្រង់មានព្រះរាជសទ្ធា ទោះបីទ្រង់ធ្វើព្រះរាជកុសលជាច្រើន ក៏ទ្រង់មិនស្កប់ព្រះហឫទ័យ, កាលទៀបទ្រង់ព្រះទិវង្គត ទ្រង់បង្គាប់ឲ្យពួករាជសេវកាមាត្យយកព្រះរាជទ្រព្យ ទៅប្រគេនព្រះសង្ឃឯវត្តកុក្កុដារាម ។ ពួករាជសេវកាមាត្យមិនព្រមប្រគេនតាមព្រះរាជហឫទ័យ ក៏ទ្រង់ព្រះកន្សែងស្រក់ទឹកព្រះនេត្រជោកព្រះភក្ត្រ ទ្រង់ព្រះពិរោធជាពន្លឹក, កំពុងតែទ្រង់ព្រះពិរោធដូច្នោះ ក៏ទ្រង់ព្រះទិវង្គតទៅ ទៅកើតក្នុងទុគ្គតិភព សមគួរតាមយថាកម្ម ។

ទាំងនេះ ក៏ព្រោះចិត្តក្រោធនឹងសេវកាមាត្យ ។

# រឿង អជាតសត្តុរាជកុមារ

អជាតសត្តុរាជកុមារនោះ កាលបើសេពគប់នឹងទេវទត្ត ក៏កាត់ព្រះទ័យយល់ខុសតាម, ទោះបីទេវទត្តបបួលឲ្យធ្វើយ៉ាងណា ក៏ធ្វើយ៉ាងនោះ ដរាបដល់ចាប់ព្រះបាទពិម្ពិសារជាព្រះបិតាទៅបង្ខាំងទុកក្នុងទ្រុងបង្អត់ក្រយាស្ងោយ ហើយឲ្យពួកពេជ្ឈឃាតពុះព្រះបាទព្រះវរបិតាឲ្យទ្រង់ព្រះទិវង្គតទៅ ។ បើតាមកម្មដែលសម្លាប់ព្រះវរបិតា ដែលហៅថាអានន្តរិយកម្មនេះ កាលបើទ្រង់ព្រះទិវង្គតទៅ ត្រូវទៅកើតក្នុងអវីចិមហានរក, ប៉ុន្តែដោយសារ

គុណដែលទ្រង់បានជួយឧបត្ថម្ភព្រះពុទ្ធសាសនា ច្រើនយ៉ាង មានទ្រង់ឧបត្ថម្ភក្នុងការធ្វើបឋមសង្គាយនាជាដើម ក៏ថយទោស បន្តិចមក ទ្រង់ធ្លាក់ទៅកើតត្រឹមលោហកុម្ភីនរកវិញ ។

ទាំងនេះ ក៏ព្រោះចិត្តវង្វេងទៅជឿតាមទេវទត្ត ។

# រឿង ពេជ្ឈឃាតតម្ពទាឋិក

ពេជ្ឈឃាតតម្ពទាឋិកនោះ ជាអ្នកសម្លាប់ចោររបស់រាជការ តាំងពីក្មេងដល់ចាស់ លុះចាស់ជរាក៏លាចេញចាកក្រសួងនោះ។ ថ្ងៃមួយកំពុងតាក់តែងកាយប្រារព្ធនឹងបរិភោគអាហារ បានជួប នឹងព្រះសារីបុត្តដែលទើបចេញចាកសមាបត្តិថ្មី ៗ ក៏កើតសេចក្ដី ជ្រះថ្លា បានប្រគេនចង្ហាន់ដោយគោរព, លុះសម្រេចភត្តកិច្ច បានស្ដាប់ធម៌អនុមោទនាដោយសង្ខេប បានសម្រេចសោតា-បត្តិផល ។ ក្នុងខណៈដែលជូនព្រះថេរៈទៅហើយត្រឡប់មក វិញដល់ពាក់កណ្ដាលផ្លូវ មានមេគោមួយបុះស្លាប់ លុះស្លាប់ទៅ ហើយបានទៅកើតក្នុងតុសិតសួគ៌ ។

# រឿង ធម្មិកឧបាសក

ធម្មិកឧបាសកនោះ ជាអ្នកបរិបូណ៌ដោយកល្យាណធម៌ ច្រើនយ៉ាង វេលាមានជម្ងឺទៀបនឹងអស់សង្ខារឲ្យកូនទៅអារាធនា

ភិក្ខុទាំងឡាយមកសូត្រសតិបដ្ឋាន; កំពុងតែស្តាប់ធម៌បានឃើញទេវតាក្នុងឆកាមាវចរសួគ៌ទាំង ៦ ជាន់យកទេវរថ ៦ មកអញ្ជើញឲ្យទៅកើតក្នុងពិភពរបស់ខ្លួន ៗ ។ លុះច្យុតពីមនុស្សលោកនេះទៅ បានទៅកើតក្នុងតុសិតសួគ៌ ។

# រឿង នន្ទិយឧបាសក

នន្ទិយឧបាសកនោះ ជាអ្នកមានសទ្ធាក្នុងព្រះពុទ្ធសាសនាជាមហាទានាធិបតី បានថ្វាយទានដល់ព្រះភិក្ខុសង្ឃ ឲ្យទានដល់មនុស្សអនាថា បានសាងសាលា ១ មានមុខ ៤ បួនល្វែងព្រមទាំងគ្រឿងសេនាសនៈសម្រាប់សាលានោះជាច្រើនទុកក្នុងឥសិបតនមិគទាយវន ថ្វាយចំពោះព្រះសង្ឃមានព្រះពុទ្ធជាប្រធាន; ខណៈដែលថ្វាយព្រះវិហារនោះ មានប្រាសាទទិព្វប្រកបដោយកែវ ៧ ប្រការ ទំហំ ១២ យោជន៍ កំពស់ ១៧ យោជន៍ ព្រមទាំងទេពអប្សរកើតឡើងក្នុងទេវលោក ។ លុះនន្ទិយឧបាសកធ្វើមរណកាលទៅ បានទៅកើតក្នុងប្រាសាទនោះឯង ។

ដែលស្រង់យកឧទាហរណ៍អម្បាលនេះមកសម្តែង ក៏ដើម្បីបង្ហាញសេចក្តីឲ្យឃើញច្បាស់ថា ទៅទុគ្គតិឬសុគតិ ក៏ព្រោះតែចិត្ត ។ ត្រង់បទនេះសមនឹងពុទ្ធភាសិតដែលសម្តែងថា ៖

**ចិត្តេ សង្កិលិដ្ឋេ ទុគ្គតិបាដិកង្ខា**
**កាលបើចិត្តសៅហ្មងហើយ ប្រាកដជាបានទុគ្គតិ**

**ចិត្តេ បរិសុទ្ធេ សុគតិបាដិកង្ខា**
**កាលបើចិត្តបរិសុទ្ធហើយ ឲ្យសង្ឃឹមចុះថា**
**មុខជានឹងបានសុគតិជាប្រាកដ ដូច្នេះឯង ។**

ព្រោះហេតុនេះ ទើបលោកពោលថា ទៅទុគ្គតិឬសុគតិក៏ព្រោះ **ចិត្ត** ។

## សម្រេចព្រះនិព្វាន ក៏ព្រោះចិត្ត

ពាក្យថា សម្រេចព្រះនិព្វានក៏ព្រោះចិត្តនោះ, មានសេចក្ដីថា ៖ បុគ្គលដែលបង្ហាត់ចិត្តដោយសមថវិធី និងវិបស្សនាវិធីដរាបដល់កើតបញ្ញាឃើញសភាវធម៌តាមពិត មានចិត្តមិនបានប្រកាន់ខ្ជាប់តាម **តណ្ហា មានះ ទិដ្ឋិ** ធ្វើចិត្តឲ្យស្រុតស្រកចាកកិលេសទាំងតូចទាំងធំ រំលត់កិលេសព្រមទាំងកងទុក្ខទាំងអស់លោកឲ្យឈ្មោះថាដល់ព្រះនិព្វាន, ទាំងនេះក៏សម្រេចមកអំពីការប្រតិបត្តិផ្លូវចិត្តទាំងអស់ ។ ហេតុដូច្នោះបានជាព្រះដ៏មានព្រះភាគទ្រង់សម្ដែងថា ៖

**ទូរង្គមំ ឯកចរំ អសរីរំ គុហាសយំ**
**យេ ចិត្តំ សញ្ញមេស្សន្តិ មោក្ខន្តិ មារពន្ធនា ។**

សេចក្តីថា ៖ " **ពួកជនឯណាសង្រួមចិត្ត ដែលមិនមានសរីរៈ ដែលត្រាច់ទៅតែម្នាក់ឯង តែងទទួលអារម្មណ៍ក្នុងទីឆ្ងាយ មានគុហាគឺមហាភូតរូប ៤ ( ដី, ទឹក, ភ្លើង, ខ្យល់ ) ជាទីអាស្រ័យនៅបាន, ពួកជននោះឯងតែងផុតចាកចំណងនៃមារ** " ។

សេចក្តីប្រតិបត្តិក្នុងផ្លូវព្រះនិព្វាន ក៏សុទ្ធតែសម្តែងជាប់ដោយការប្រតិបត្តិផ្លូវចិត្តទាំងអស់ ។ ហេតុដូច្នោះបានជាលោកពោលថា សម្រេចព្រះនិព្វានក៏ព្រោះតែចិត្ត ។

ម្យ៉ាងទៀត ចិត្តនេះ ជាធម្មជាតិសំខាន់បំផុតក្នុងរាងកាយដូចពុទ្ធភាសិតថា ៖

**មនោបុព្វង្គមា ធម្មា មនោសេដ្ឋា មនោមយា**
**មនសា ចេ បទុដ្ឋេន ភាសតិ វា ករោតិ វា**
**តតោ នំ ទុក្ខមន្វេតិ ចក្កំវ វហតោ បទំ ។**

សេចក្តីថា ៖ " **ធម៌ទាំងឡាយ មានចិត្តជាប្រធាន មានចិត្តជាធំ សម្រេចតែអំពីចិត្ត, បើបុគ្គលណាមួយនិយាយពាក្យសម្តី ឬធ្វើការអ្វី តាមចិត្តដែលអាក្រក់; ចិត្តអាក្រក់នោះឯងតែងកឲ្យកើតសេចក្តីទុក្ខលំបាកជាប់តាមគេទៅ, ដូចជាកង់រទេះដែលវិលជាប់តាមស្នាមជើងគោ** " ។

**មនោបុព្វង្គមា ធម្មា មនោសេដ្ឋា មនោមយា**
**មនសា ចេ បសន្នេន ភាសតិ វា ករោតិ វា**

**តតោ នំ សុខមន្វេតិ ឆាយាវ អនុបាយិនី ។**

សេចក្តីថា ៖ " **ធម៌ទាំងឡាយ មានចិត្តជាប្រធាន មានចិត្តជាធំ សម្រេចតែអំពីចិត្ត, បើបុគ្គលណានិយាយពាក្យសម្តីឬធ្វើការអ្វី តាមចិត្តជ្រះថ្លា; ចិត្តជ្រះថ្លានោះឯងតែងកឲ្យកើតជាសេចក្តីសុខ ជាប់តាមគេទៅ, ដូចជាស្រមោលអន្ទោលតាមប្រាណជាប្រក្រតី នោះឯង** ។ សេចក្តីនេះ សមនឹងបុរាណសុភាសិតថា ៖

**វីបុណ្យនិងបាប អំពើសុភាព នោះវាតែងតាម**
**ប្រដូចស្រមោល អន្ទោលតាមប្រាណ ពុំដែលចៀសបាន**
**ត្រង់ក្តីទុក្ខសោក ។**

កាលបើចិត្តជាធម្មជាតិសំខាន់បំផុតដូច្នេះហើយ, សាធុជនដែលប្រាថ្នាសេចក្តីសុខសេចក្តីចម្រើន គួរតែរក្សាចិត្តតាមពុទ្ធភាសិតដែលទ្រង់ដាស់តឿនថា ៖

**សុទុទ្ទសំ សុនិបុណំ យត្ថកាមនិបាតិនំ**
**ចិត្តំ រក្ខេថ មេធាវី ចិត្តំ គុត្តំ សុខាវហំ ។**

សេចក្តីថា ៖ " **បុគ្គលជាបណ្ឌិតមានប្រាជ្ញាគួរតែខំបីបាច់រក្សាចិត្ត ដែលឃើញបានដោយកម្រ ដែលល្អិតពន់ពេក ដែលលង់ទៅក្នុងអារម្មណ៍ឯណានីមួយហើយ មិនងាយនឹងទាញឲ្យងាកចេញមកវិញបាន, ចិត្ត ដែលអ្នកមានប្រាជ្ញាបានថែរក្សាហើយ តែងនាំសុខមកឲ្យជាអនេក ។**

ឯការរក្សាចិត្តនោះ ក៏គឺប្រយ័ត្នចិត្តមិនឲ្យប្រទ្បាក់ប្រឡូស ដោយគ្រឿងសៅហ្មង, ឲ្យស្អាតផូរផង់នៅជាប្រក្រតីនោះឯង ។

ចិត្តនេះ ព្រះដ៏មានបុណ្យជាម្ចាស់ត្រាស់ទេសនាថា ៖

**បភស្សរមិទំ ភិក្ខវេ ចិត្តំ តញ្ច ខោ**
**អាគន្តុកេហិ ឧបក្កិលេសេហិ ឧបក្កិលិដ្ឋំ**

**ម្នាលភិក្ខុទាំងឡាយ ! ចិត្តនេះ ជាធម្មជាតិដ៏ស្អាតផូរផង់, ប៉ុន្តែរមែងសៅហ្មងដោយឧបក្កិលេស ទាំងឡាយដែលចូលមកថ្មី; គួរនាដូចវត្ថុគ្រឿងប្រើប្រាស់ទាំងពួងមានសំពត់ជាដើម ដែលនៅថ្មីនៅឡើយ សុទ្ធតែជារបស់ស្អាតល្អទាំងអស់, ប៉ុន្តែវត្ថុទាំងនោះរមែងសៅហ្មងដោយគ្រឿងមិនស្អាតទាំងឡាយ មានធូលីជាដើម ដែលចូលមកប៉ះពាល់ជាខាងក្រោយ ។**

ឯឧបក្កិលេសនោះសោត ក៏ជាអកុសលជាតិដែលកើតមកអំពីចិត្ត ហើយត្រឡប់ប្រទូស្តចិត្តឲ្យសៅហ្មង ឲ្យខូចវិញ, ដូចច្រែសដែលកើតអំពីដែក ហើយត្រឡប់ស៊ីដែកឲ្យខូចទៅដូច្នោះ ។ ឧបក្កិលេសគ្រឿងសៅហ្មងចិត្តនោះ ព្រះដ៏មានព្រះភាគជាម្ចាស់ត្រាស់ទេសនាថា មាន ១៦ យ៉ាង ។

## ឧបក្កិលេស ១៦ យ៉ាង

១. **អភិជ្ឈាវិសមលោភ** ល្មោភរំពៃចង់បានទ្រព្យគេ ;
២. **ទោស** ប្រទូស្ត ;

៣. **ក្រោធ** ក្រោធ ;
៤. **ឧបនាហ** ចងក្រោធទុក្ខ ;
៥. **មក្ខ** លុបគុណគេ ;
៦. **បលាស** វ៉ៃប្ញកប្រប ;
៧. **ឥស្សា** ប្ញស្យា ;
៨. **មច្ឆរិយ** កំណាញ់ ;
៩. **មាយា** លាក់ពុត ;
១០. **សាថេយ្យ** អួតអាង ;
១១. **ថម្ភ** រឹងត្អឹង ;
១២. **សារម្ភ** ប្រជែងវាសនា ;
១៣. **មាន** ប្រកាន់ខ្លួន ;
១៤. **អតិមាន** មើលងាយគេ ;
១៥. **មទ** ស្រវឹង ;
១៦. **បមាទ** ប្រហែសធ្វេស ។

អកុសលធម៌ទាំង ១៦ ប្រការនោះ សូម្បីឯណានីមួយកាលបើបណ្ដោយឲ្យរុករានចូលមកក្នុងចិត្តហើយ, សុទ្ធតែធ្វើចិត្តឲ្យសៅហ្មង មិនថ្លាស្អាតទាំងអស់ ។ ព្រោះហេតុដូច្នោះបានជាលោកហៅថា **ឧបក្កិលេស** ។ ឧបក្កិលេសនោះទោះបីមានច្រើនដល់ទៅ ១៦ ក៏ពិតហើយ, ប៉ុន្តែមិនកើតក្នុងវេលាមួយជាមួយគ្នាទេ រមែងផ្លាស់ប្ដូរគ្នាកើត ។ មួយវិញទៀត ចិត្តតែមួយទេ តែកាលបើមានកុសលធម៌ណាមួយមកសណ្ឋិតនៅ

ដូចជាម្ចាស់ផ្ទះហើយ, ឧបក្កិលេសដែលជាអកុសលធម៌ក៏មិនអាចលុកលុយចូលមកបាន, កាលបើមានអកុសលធម៌ណាមួយចូលមកសម្ងំនៅដូចជាម្ចាស់ផ្ទះហើយ, កុសលធម៌ក៏រកឱកាសចូលមកមិនបាន ។ តាមធម្មតារបស់ចិត្ត ជាកណ្ដាល ៗ កាលបើខាងណាចូលមកនៅបានមុន ក៏មានអំណាចអាចរារាំងខាងចំណែកថ្មីដែលមានកម្លាំងតិច មិនឲ្យចូលមកបាន ។ ព្រោះហេតុនោះ សាធុជនដែលមានបំណងនឹងធ្វើចិត្តរបស់ខ្លួនឲ្យជ្រះថ្លាប្រាថ្នាសុខ, គួរតែខំញុំាងកុសលធម៌ឲ្យកើត ឲ្យមានឡើងជាប់នៅក្នុងចិត្តជានិច្ចជាកាលចុះ ។

ឯកុសលធម៌នោះ កាលបើលើកយកតែកុសលធម៌ដែលគួរឲ្យកើតមានក្នុងចិត្តខានមិនបាន ហើយមានឧបការៈច្រើនផងមកសម្ដែង ក៏គឺ **សតិសម្បជញ្ញៈ** ព្រោះលោកសរសើរថាធម៌ ២ ប្រការគឺ **សតិ** និង **សម្បជញ្ញៈ** ជាធម៌មានឧបការៈច្រើន ។ សតិគឺសេចក្ដីរឭក, សម្បជញ្ញៈគឺសេចក្ដីដឹងខ្លួន; គុណធម៌ទាំង ២ នេះប្រព្រឹត្តទៅក្នុងកិច្ចជាមួយគ្នា ផ្សេងតែអាការៈ គឺសតិនោះជាភ្នាក់ងារខាងឯនឹកឃើញក្នុងវេលាដែលធ្វើហើយ និយាយហើយ គិតហើយ, សូម្បីយូរ ៗ ក៏នឹកឃើញបាន, សម្បជញ្ញៈនោះជាភ្នាក់ងារខាងដឹងខ្លួនក្នុងវេលា ដែលកំពុងធ្វើ កំពុងនិយាយ កំពុងគិត ។ ចិត្តដែលឥតសម្បជញ្ញៈគ្រប់គ្រងតែងស្ទុះបម្រះននៀលទៅរកវិសភាគារម្មណ៍ផ្សេង ៗ តាមតែប្រទះស្រេចតែនឹងប្រាថ្នា, មិនរើសថា ដូចម្ដេចគួរ ដូចម្ដេចមិនគួរ

ឡើយ ។ ចំណែកចិត្តដែលមានសតិសម្បជញ្ញៈគ្រប់គ្រង រមែងចេះរើសរកតែចំណែកដែលល្អ ៗ ។ ធម្មតារថទឹមសេះដែលគ្មាននាយសារថីបរ សេះតែងនាំពង្រត់ទៅតាមទំនើងចិត្តរបស់វា រមែងស្ទុះទៅផ្តេសផ្តាស ជល់នេះជល់នោះហែទៅតាមផ្លូវ ធ្វើឲ្យកើតសេចក្តីអន្តរាយដល់គេដល់ឯង មិនបានស្រួលឡើយ; ចំណែករថដែលមាននាយសារថី ដ៏ឈ្លាសវៃនៅគ្រប់គ្រងរក្សា រមែងលឿនត្រង់ទៅតាមរបៀបរៀបរយ មិនធ្វើឲ្យកើតសេចក្តីអន្តរាយដល់នរណាឡើយ, ញ៉ាំងប្រយោជន៍នៃការប្រើរថឲ្យសម្រេចដោយល្អ, សេចក្តីនេះមានឧបមាយ៉ាងណាមិញ; ឯសេចក្តីប្រព្រឹត្តទៅរបស់មនុស្ស ក៏យ៉ាងនោះដែរ, គឺបុគ្គលដែលគ្មានសតិសម្បជញ្ញៈ រមែងប្រព្រឹត្តកាយវាចាខុស ៗ ភ្លាត់ ៗ ធ្វើឲ្យកើតសេចក្តីអន្តរាយដល់ខ្លួននិងអ្នកដទៃ ។ ចំណែកបុគ្គលដែលមានសតិសម្បជញ្ញៈ រមែងប្រព្រឹត្តកាយ វាចា ត្រង់ត្រូវតាមផ្លូវដែលល្អ ៗ ជាហេតុឲ្យបានសេចក្តីសុខដល់ខ្លួននិងអ្នកដទៃ ។

## លក្ខណៈបុគ្គលមានសតិសម្បជញ្ញៈ

ឯលក្ខណៈនៃបុគ្គលដែលប្រកបដោយសតិសម្បជញ្ញៈនោះ ដូច្នេះគឺ ៖

ភិក្ខុដែលប្រកបដោយសតិសម្បជញ្ញៈនោះ កាលដែលនឹងឈានទៅខាងមុខខាងក្រោយ ក៏មានស្មារតីដឹងខ្លួនថា ៖ " ឥឡូវនេះ អាត្មាអញកំពុងឈានទៅខាងមុខថយទៅខាងក្រោយ " ។

កាលនឹងឱនកាយទៅមុខក្តី ផ្ងារកាយទៅក្រោយក្តី ក្រឡេកមើលទៅមុខក្តី ទៅឆ្វេងក្តី ទៅស្តាំក្តី ក៏មានស្មារតីដឹងខ្លួនថា ៖ " ឥឡូវនេះ អាត្មាអញកំពុងឱនកាយទៅមុខ ផ្ងារកាយទៅក្រោយ ក្រឡេកមើលទៅមុខទៅក្រោយ ឬទៅឆ្វេង ទៅស្តាំ " ។ កាលដែលនឹងបត់ដៃឆ្វេង-ស្តាំចូលក្តី បត់ជើងឆ្វេង-ស្តាំចូលក្តី ក៏មានស្មារតីដឹងខ្លួនថា ៖ " ឥឡូវនេះ អាត្មាអញកំពុងបត់ដៃឆ្វេង-ស្តាំចូល បត់ជើងឆ្វេង-ស្តាំចូល " ។ កាលដែលនឹងលាដៃឆ្វេង-ស្តាំចេញក្តី លាជើងឆ្វេង-ស្តាំចេញក្តី ក៏មានស្មារតីដឹងខ្លួនថា ៖ " ឥឡូវនេះ អាត្មាអញកំពុងលាដៃឆ្វេង-ស្តាំចេញ លាជើងឆ្វេង-ស្តាំចេញ " ។ កាលដែលនឹងប្រើប្រាស់សង្ឃាដី ឬបាត្រ ចីវរ ក៏មានស្មារតីដឹងខ្លួនថា ៖ " ឥឡូវនេះ អាត្មាអញកំពុងប្រើសង្ឃាដី បាត្រ ចីវរ " ។ កាលដែលនឹងឆាន់ចង្ហាន់ឬឆាន់ទឹកនឹងទំពា ឬស្រូប ហិត លិទ្ធ ភ្លក្សរបស់អ្វីៗ ក៏មានស្មារតីដឹងខ្លួនថា ៖ " ឥឡូវនេះ អាត្មាអញកំពុងឆាន់ចង្ហាន់ ឆាន់ទឹក ទំពា ស្រូប ហិត លិទ្ធ ភ្លក្សរបស់នោះៗ " ។ កាលដែលបន្ទោបង់ឧច្ចារៈ បស្សាវៈ ក៏មានស្មារតីដឹងខ្លួនថា ៖ " ឥឡូវនេះ អាត្មាអញកំពុងបន្ទោបង់ឧច្ចារៈ បស្សាវៈ " ។ កាលនឹងដើរ ឈរ ដេក អង្គុយ ភ្ញាក់ និយាយស្តី ស្ងៀម ក៏មានស្មារតីដឹងខ្លួនថា ៖ " ឥឡូវនេះ អាត្មាអញកំពុងដើរ ឈរ ដេក អង្គុយ ភ្ញាក់ និយាយស្តី ស្ងៀម " ។

ភិក្ខុដែលឃើញភ័យក្នុងវដ្តសង្សារ រមែងជាអ្នកប្រកប

ដោយសតិសម្បជញ្ញៈ ដូចថាមកនេះ ។

## អធិប្បាយ សតិ

សតិ ជាធម៌សំខាន់បំផុតខាងឯធ្វើចិត្តឲ្យបរិសុទ្ធហ្មត់ចត់ល្អ, ព្រះបរមសាស្តាជាម្ចាស់ទ្រង់ត្រាស់ទេសនាថា ៖

**ឯកាយនោ អយំ ភិក្ខវេ មគ្គោ សត្តានំ**
**វិសុទ្ធិយា សោកបរិទេវានំ សមតិក្កមាយ**
**ទុក្ខទោមនស្សានំ អត្ថង្គមាយ ញាយស្ស**
**អធិគមាយ និព្វានស្ស សច្ឆិកិរិយាយ**

សេចក្តីថា ៖ " **នែ៎ភិក្ខុទាំងឡាយ ! ផ្លូវនេះជាផ្លូវជាទីទៅតែម្នាក់ឯង ដើម្បីសេចក្តីបរិសុទ្ធរបស់សត្វទាំងឡាយ ដើម្បីកន្លងបង់នូវសេចក្តីសោកស្រណោះអាឡោះអាល័យ និងសេចក្តីខ្សឹកខ្សួលទាំងឡាយ ដើម្បីរំលត់នូវទុក្ខនិងទោមនស្សទាំងឡាយ ដើម្បីត្រាស់ដឹងនូវធម៌ដែលគួរត្រាស់ដឹង ដើម្បីធ្វើឲ្យជាក់ច្បាស់នូវព្រះនិព្វាន,**

**យទិទំ ចត្តារោ សតិបដ្ឋានា**
**ផ្លូវនោះគឺ សតិបដ្ឋាន ៤ ។**

## សតិបដ្ឋាន ៤

**១. កាយានុបស្សនាសតិបដ្ឋាន** តម្កល់សតិពិចារណា កាយ

ជាអារម្មណ៍ ;

**២. វេទនានុបស្សនាសតិបដ្ឋាន** តម្កល់សតិពិចារណា វេទនាជាអារម្មណ៍ ;

**៣. ចិត្តានុបស្សនាសតិបដ្ឋាន** តម្កល់សតិពិចារណា ចិត្តជាអារម្មណ៍ ;

**៤. ធម្មានុបស្សនាសតិបដ្ឋាន** តម្កល់សតិពិចារណា ធម៌ជាអារម្មណ៍ ។

ឯវិធីដែលព្រះសម្មាសម្ពុទ្ធទ្រង់ប្រដៅឲ្យពិចារណានោះមានន័យច្រើនជាអនេក, តែបើស្រង់យកតែចំណែកដែលដូចគ្នាទាំង ៤ យ៉ាងនោះមកសម្តែង ក៏គឺពិចារណាឲ្យឃើញថា ៖ " **កាយនេះគ្រាន់តែជាកាយ, វេទនាគ្រាន់តែជាវេទនា, ចិត្តគ្រាន់តែជាចិត្ត, ធម៌គ្រាន់តែជាធម៌, មិនមែនជាសត្វ ជាបុគ្គលជាតួខ្លួនទេ; គួរកុំប្រកាន់ កុំស្អប់ កុំស្រឡាញ់សោះឡើយ** " ដូច្នេះជាដើម ។

កាលបើកំពុងតាំងសតិកំណត់អារម្មណ៍ទាំង ៤ ប្រការដូចថាមកនេះ ចិត្តក៏នឹងជាប់នៅតែក្នុងកុសលធម៌ម្យ៉ាង; បើចិត្តជាប់នៅក្នុងកុសលធម៌ហើយ ឧបក្កិលេសដែលជាអកុសលក៏រកឱកាសនឹងកើតឡើងគ្មាន; កាលបើដូច្នោះ ចិត្តក៏នឹងប្រាសចាកគ្រឿងសៅហ្មង ដល់នូវសេចក្តីជ្រះថ្លាជាខណៈ ៗ ដោយលំដាប់ទៅ ។

នេះជាសេចក្តីសង្ខេបក្នុងរឿងសតិ ។

# សម្បជញ្ញៈ ៤

ឯសម្បជញ្ញៈនោះ ចែកជា ៤ ប្រការ គឺ ៖

១. **សាត្ថកសម្បជញ្ញៈ** ដឹងបានមានប្រយោជន៍ ;

២. **សប្បាយសម្បជញ្ញៈ** ដឹងបានជាទីសប្បាយ ;

៣. **គោចរសម្បជញ្ញៈ** ដឹងបានជាទីគោចរ ;

៤. **អសម្មោហសម្បជញ្ញៈ** ដឹងបានមានសេចក្ដីមិនវង្វេង ។

# អធិប្បាយសម្បជញ្ញៈ

១. **សាត្ថកសម្បជញ្ញៈ** ដឹងបានមានប្រយោជន៍នោះ, មានអធិប្បាយថា ភិក្ខុក្នុងព្រះពុទ្ធសាសនានេះដែលប្រកបដោយសម្បជញ្ញៈ គឺសេចក្ដីពិចារណាឃើញនិងដឹងខ្លួនដោយសព្វគ្រប់នោះ, កាលបើគិតថានឹងទៅប្រទេសឯណានីមួយ នឹងបានទៅដោយប្រញាប់ប្រញាល់តាមអំណាចចិត្តដែលគិតនោះក៏ទេ ពិចារណាឲ្យឃើញថាមានប្រយោជន៍ឬឥតប្រយោជន៍ជាមុនថា ៖ " ដែលអាត្មាអញទៅក្នុងទីនោះ តើនឹងមានប្រយោជន៍ឬទេ ? ", បើឃើញថា ទៅក្នុងទីនោះនឹងមានប្រយោជន៍ គឺនឹងបានទស្សនាការឃើញព្រះចេតិយ ឃើញពោធិព្រឹក្ស ឃើញព្រះសង្ឃ ឃើញមហាថេរ ឬឃើញអសុភដែលមានទំនងឲ្យកើតព្រះត្រៃលក្ខណ៍, ពិចារណាឃើញប្រយោជន៍យ៉ាងនេះហើយទើបទៅ ។ បើពិចារណាទៅហើយឃើញថាមិនមានប្រយោជន៍

ក៏កាត់គមិកចិត្តនោះចេញ មិនបានទៅក្នុងទីដែលប្រាសចាកប្រយោជន៍នោះឡើយ ។ ព្រោះការដែលបានទស្សនាការឃើញព្រះចេតិយ ឃើញពោធិព្រឹក្ស ឃើញមហាថេរ ឃើញអសុភនោះឯង តែងជាបច្ច័យឲ្យចម្រើនសីលគុណ សមាធិគុណ បញ្ញាគុណ ។ ព្រះយោគាវចរអង្គខ្លះដែលមានឧបនិស្ស័យ បានកសាងសន្សំមកអំពីបុព្វជាតិ, កាលបើបានឃើញព្រះចេតិយ ឃើញពោធិព្រឹក្ស ក៏កើតបីតិប្រាមោទ្យមានពុទ្ធគុណជាអារម្មណ៍, លុះពិចារណាបីតិប្រាមោទ្យនោះដោយខយវយៈ គឺកិរិយាអស់ទៅនិងសូន្យទៅហើយ, ក៏បានសម្រេចព្រះអរិយមគ្គ អរិយផលដោយលំដាប់ ៗ ដរាបដល់ព្រះអរហត្តដោយសារតែបានឃើញ បានថ្វាយបង្គំបានបូជា ព្រះចេតិយនិងពោធិព្រឹក្សជាបច្ច័យនោះក៏មាន ។ ព្រះយោគាវចរអង្គខ្លះបានទស្សនាការឃើញព្រះសង្ឃ ហើយកើតបីតិប្រាមោទ្យដែលមានសង្ឃរតនៈជាអារម្មណ៍ ហើយពិចារណាបីតិប្រាមោទ្យនោះដោយខយវយៈ ក៏បានសម្រេចព្រះអរិយមគ្គ អរិយផលដោយលំដាប់ ៗ ដរាបដល់ព្រះអរហត្តដោយសារតែបានឃើញព្រះសង្ឃជាបច្ច័យនោះ ក៏មាន ។ ព្រះយោគាវចរអង្គខ្លះបានឃើញមហាថេរ ហើយបានធ្វើសេចក្តីគោរពនិងឋិតនៅក្នុងឱវាទរបស់លោក បានសម្រេចព្រះអរហត្តក៏មាន ។ ព្រះយោគាវចរអង្គខ្លះបានទស្សនាឃើញអសុភហើយ ចម្រើនព្រះកម្មដ្ឋាន បានសម្រេចបឋមជ្ឈាន ក៏ពិចារណាអង្គឈានគឺ វិតក្កៈ វិចារៈ បីតិ សុខៈ ឯកគ្គតានោះ

ដោយខយវយៈបានសម្រេចព្រះអរហត្តក៏មាន ។ កិរិយាដែលបានឃើញព្រះចេតិយ ឃើញពោធិព្រឹក្ស ឃើញព្រះសង្ឃ ឃើញមហាថេរ និងឃើញអសុភនោះឯង រមែងនាំមកនូវប្រយោជន៍ដូចសម្តែងមកហើយនេះ ។ ហេតុដូច្នោះបានជាភិក្ខុដែលមានសេចក្តីប្រាថ្នានឹងត្រាច់ទៅស្វែងរកប្រយោជន៍ មានថ្វាយបង្គំព្រះចេតិយ ឬពោធិព្រឹក្សជាដើមនេះ បានឈ្មោះថា **សាត្ថកសម្បជញ្ញៈ** ។

**២.** ៦ **សប្បាយសម្បជញ្ញៈ** ដឹងឋានជាទីសប្បាយនោះ មានអធិប្បាយថា ៖ ភិក្ខុអ្នកប្រកបដោយសម្បជញ្ញៈរមែងពិចារណារកដំណើរជាទីសប្បាយ និងមិនសប្បាយជាមុនថា " វេលាដែលអាត្មាអញទៅក្នុងទីនោះ ៗ តើនឹងបានអារម្មណ៍ជាទីសប្បាយឬទេ ? " បើឃើញថានឹងយកអារម្មណ៍ឲ្យជាទីសប្បាយមិនបាន ក៏ឈប់បង្អង់; លុះបានពេលដែលកើតអារម្មណ៍ជាទីសប្បាយទើបទៅ យ៉ាងនេះជាដើម ឈ្មោះថា **សប្បាយ-សម្បជញ្ញៈ** ។

ដូចម្តេចដែលហៅថា ដំណើរប្រកបដោយប្រយោជន៍ឲ្យកើតសេចក្តីសប្បាយ ?

ដំណើរដែលទៅមើលព្រះចេតិយឬពោធិព្រឹក្ស, ហៅថា ដំណើរប្រកបដោយប្រយោជន៍ឲ្យកើតសេចក្តីសប្បាយដោយពិត ប៉ុន្តែ បើព្រះចេតិយឬមហាពោធិព្រឹក្សនោះមានបរិស័ទទៅប្រជុំ

គ្នាដើម្បីធ្វើមហាបូជា, អស់ពួកមហាជនទាំងស្ត្រីទាំងបុរស ក៏សុទ្ធតែតាក់តែងរាងកាយដោយគ្រឿងប្រដាប់សមគួរតាមទ្រព្យ រៀងខ្លួន ល្អល្អះ ដូចរូបគំនូរ ដើរត្រាច់ចរច្រវាត់ទៅមក ។ ចិត្តរបស់ភិក្ខុដែលទៅក្នុងទីមានសភាពដូច្នោះ រមែងកើតសេចក្តីជំពាក់ក្នុងឥដ្ឋារម្មណ៍, កើតសេចក្តីថ្នាំងថ្នាក់ក្នុងអនិដ្ឋារម្មណ៍, កើតសេចក្តីភាន់ច្រឡំក្នុងកិរិយាក្រឡេកឃើញអារម្មណ៍ ដែលក្រឡេកមើលមិនស្មើ, រមែងត្រូវអាបត្តិកាយសំសគ្គៈព្រោះការប៉ះពាល់ផង រមែងកើតសេចក្តីអន្តរាយដល់ជីវិតព្រហ្មចរិយៈផង ។ ទីដែលមានសភាពដូច្នោះ, ឈ្មោះថា ជាទីមិនសប្បាយ ។ លុះតែទីដែលមិនមានសេចក្តីអន្តរាយដូច្នោះ, ទើបឈ្មោះថា ជាទីសប្បាយ ។

ព្រោះហេតុដូច្នោះ ភិក្ខុដែលនឹងទៅថ្វាយបង្គំព្រះចេតិយឬមហាពោធិព្រឹក្សនោះ ត្រូវប្រតិបត្តិក្នុងសប្បាយសម្បជញ្ញៈ គឺពិចារណាឲ្យឃើញទីសប្បាយ និងមិនសប្បាយនេះឲ្យច្រើននៅក្នុងសន្តានជាមុនសិនហើយសឹមទៅ, ដ្បិតសប្បាយសម្បជញ្ញៈនេះ ជាធម៌ដ៏សំខាន់ក្រៃពេកក្នុងការដែលធ្វើចិត្តឲ្យស្ថិតនៅក្នុងសាសនធម៌មិនឲ្យរេកម្រើក; ទោះបីនឹងទៅទស្សនាការព្រះសង្ឃក៏គប្បីឲ្យមានសប្បាយសម្បជញ្ញៈទាំងអស់ ។ បើមនុស្សទាំងឡាយធ្វើមហាមណ្ឌបក្នុងស្រុក ហើយគេស្តាប់ធម៌អស់ ១ យប់ទាល់ភ្លឺក្នុងទីណា, ទីនោះតែងមានមហាជនប្រជុំគ្នាច្រើនផង, តែងមានសេចក្តីអន្តរាយ ដូចន័យដែលពោលមកហើយផង,

ទីណាមានសភាពដូច្នោះ ទីនោះក៏ឈ្មោះថា ជាទីមិនសប្បាយ លុះតែទីដែលមិនមានសេចក្តីអន្តរាយ ទើបឈ្មោះថាទីសប្បាយ ទោះបីនឹងទៅទស្សនាការព្រះមហាថេរៈដែលមានបរិស័ទជាបរិវារច្រើន មានញាតិញោមច្រើនក៏មានន័យដូច្នោះដែរ ។

ហេតុនេះ ភិក្ខុក្នុងព្រះពុទ្ធសាសនាដែលជាអ្នកឃើញភ័យក្នុងវដ្តៈ គប្បីប្រតិបត្តិក្នុងសប្បាយសម្បជញ្ញៈនេះឲ្យច្រើននៅក្នុងខន្ធសន្តាន, បើនឹងទៅនមស្ការព្រះសង្ឃឬព្រះមហាថេរៈដូច្នោះក៏ត្រូវទៅតាមទំនងដែលគួរឲ្យកើតអារម្មណ៍ជាទីសប្បាយចុះ; បើឃើញថាមិនស្រួលក៏កុំគប្បីទៅឡើយ ។ ទោះបីនឹងទៅមើលអសុភក៏សឹងដូចគ្នា គប្បីទៅក្នុងការគួរ គប្បីតាំងសប្បាយសម្បជញ្ញៈទុកជាត្រីមុខ, ព្រោះកិរិយាដែលទៅពិចារណាអសុភក្នុងកាលដ៏គួរនោះ រមែងនាំមកនូវផលានិសង្សជាច្រើន ។ ព្រះអដ្ឋកថាចារ្យនាំយកនិទានមកតាំងទុក ៖

# រឿង សាមណេរ និងភិក្ខុឃើញអសុភ

ដូចបានឮមកថា មានភិក្ខុកម្លោះ ១ រូបនាំសាមណេរ ១ រូបចូលទៅក្នុងព្រៃដើម្បីរកឈើស្ទន្ត, សាមណេរចៀសចេញពីផ្លូវដើរទៅខាងមុខបន្តិចបានឃើញអសុភ បានពិចារណាយកជាអសុភកម្មដ្ឋាន ក៏កើតបឋមជ្ឈាន ហើយធ្វើបឋមជ្ឈាននោះជាទីតាំង ពិចារណាសង្ខារជាវិបស្សនា ក៏ធ្វើឲ្យជាក់ច្បាស់

នូវផល ៣ គឺ ៖ សោតាបត្តិផល, សកទាគាមិផល និង អនាគាមិផល, កំពុងតែពិចារណាកម្មដ្ឋានដើម្បីឲ្យបានមគ្គនិងផលខាងលើគឺព្រះអរហត្តផលតទៅ ។ ឯភិក្ខុកម្លោះនោះកាលបើមិនឃើញសាមណេរក៏ស្រែកហៅ ។

សាមណេរនោះគិតថា ៖

- " តាំងពីអាត្មាអញបួសមកដល់ឥឡូវនេះ មិនដែលឲ្យភិក្ខុស្រែកហៅធ្ងន់មាត់ដល់ពីរម៉ាត់ឡើយ, ណ្ហើយចុះចាំថ្ងៃក្រោយសឹមចម្រើនព្រះកម្មដ្ឋានទៀតធ្វើលោកុត្តរញ្ញាណដែលជាខាងលើឲ្យកើតឡើង ។

លុះសាមណេរនោះគិតដូច្នោះហើយ ក៏សួរភិក្ខុថា ៖

- " មានការអ្វីលោកម្ចាស់ ? " ។

ភិក្ខុកម្លោះនោះប្រាប់ថា ៖

- " ចូរមកអាយ ! " ។

ភិក្ខុហៅតែមួយម៉ាត់ សាមណេរក៏ទៅភ្លាមហើយប្រាប់ភិក្ខុនោះថា ៖

- " សូមលោកម្ចាស់និមន្តទៅតាមផ្លូវនេះ ទៅឈរក្នុងទីដែលខ្ញុំព្រះករុណាឈរអម្បាញ់មិញនោះ បែរមុខទៅទិសខាងកើតហើយនិមន្តសម្លឹងមើលមួយស្របក់ចុះ នឹងបានឃើញរបស់អ្វីមួយដែលពេញចិត្តមិនខាន " ។

កាលភិក្ខុកម្លោះធ្វើតាមពាក្យសាមណេរហើយទៅពិចារណាអសុភកម្មដ្ឋាននោះ ក៏បានសម្រេចអនាគាមិផលដូចសាមណេរ

នោះដែរ ។ គួរអស្ចារ្យណាស់ហ្ន៎ ! អសុភតែមួយអាចឲ្យប្រយោជន៍ដល់សាធុជន ២ រូប គឺសាមណេរនិងភិក្ខុដោយប្រការដូច្នេះ ។ ហេតុនេះ អ្នកប្រាជ្ញគួរសន្និដ្ឋានថា ការដែលទៅថ្វាយបង្គំព្រះចេតិយ និងមហាពោធិព្រឹក្ស ឬទៅថ្វាយបង្គំព្រះសង្ឃថេរៈនោះ បើបានទៅក្នុងកាលដ៏គួរនឹងទៅហើយ តែងនាំមកនូវប្រយោជន៍ដល់ខ្លួនជាច្រើន ដូចពោលមកនេះ ។ កិរិយាពិចារណា រកកាលដ៏សប្បាយក្នុងវេលាដែលនឹងទៅថ្វាយបង្គំព្រះចេតិយ និងមហាពោធិព្រឹក្ស ទៅថ្វាយបង្គំព្រះសង្ឃនិងព្រះសង្ឃថេរៈ ឬទៅមើលអសុភនោះឯង បានឈ្មោះថា **សប្បាយសម្បជញ្ញៈ** ។

**៣. ៦ គោចរសម្បជញ្ញៈ** ដឹងឋានជាទីគោចរនោះ, មានអធិប្បាយថា ៖ បណ្ដាកម្មដ្ឋានទាំង ៣៨ ប្រការ [១] នោះ កាលបើយោគាវចរភិក្ខុអ្នកពិចារណាព្រះកម្មដ្ឋាន បានរៀនកម្មដ្ឋានណាមួយដែលមានអារម្មណ៍ជាទីគាប់ចិត្ត គឺសមគួរតាមចរិត ហើយក៏បានយកព្រះកម្មដ្ឋាននោះជាអារម្មណ៍គ្រប់វេលាដែលគោចរទៅរកចង្ហាន់ មិនបានឲ្យចិត្តនោះប្រាសចាកកម្មដ្ឋានដំណើរដែលត្រាច់ទៅនោះហៅថា **គោចរសម្បជញ្ញៈ** ។ ដើម្បីសម្ដែងឲ្យជាក់ច្បាស់នូវគោចរសម្បជញ្ញៈនោះ អ្នកប្រាជ្ញគួរជ្រាបតាមន័យដែលលោកចែកជា ៤ ដូច្នេះគឺ ៖

(១) កម្មដ្ឋាន ១០ លើកអាកាសកសិណ និងអាលោកកសិណចេញ នៅ ៣៨ ។

**ក**). **ឯកច្ចោ ហរតិ ន បច្ចាហរតិ** ព្រះយោគាវចរចំពូកខ្លះ កាន់យកពុទ្ធានុស្សតិកម្មដ្ឋានជាអារម្មណ៍បានតែពេលដែលត្រាច់ទៅបិណ្ឌបាត ត្រឡប់មកវិញមិនបាន ;

**ខ**). **ឯកច្ចោ បច្ចាហរតិ ន ហរតិ** ព្រះយោគាវចរចំពូកខ្លះ បានតែក្នុងពេលត្រឡប់មក ពេលដែលត្រាច់ទៅមិនបាន ;

**គ**). **ឯកច្ចោ បន នេវ ហរតិ ន បច្ចាហរតិ** ព្រះយោគាវចរចំពូកខ្លះ មិនបានទាំងទៅទាំងមក ;

**ឃ**). **ឯកច្ចោ ហរតិ ច បច្ចាហរតិ ច** ព្រះយោគាវចរចំពូកខ្លះ បានទាំងទៅទាំងមក ។

កាលបើព្រះយោគាវចរ កាន់យកពុទ្ធានុស្សតិកម្មដ្ឋានជាទីសប្បាយហើយ ក៏ចម្រើនគ្រប់វេលាដែលគោចរទៅរកចង្ហាន់នុ៎ះឯង ហៅថា **គោចរសម្បជញ្ញៈ** ។

**៤.** ឯ **អសម្មោហសម្បជញ្ញៈ** ដឹងឋានមានសេចក្ដីមិនវង្វេងនោះ, មានសេចក្ដីអធិប្បាយថា ៖ សេចក្ដីមិនវង្វេងក្នុងឥរិយាបថទាំងឡាយ មានឈានទៅមុខ ថយទៅក្រោយជាដើម ហៅថា **អសម្មោហសម្បជញ្ញៈ** ។ បណ្ឌិតគួរជ្រាបសេចក្ដីនោះយ៉ាងនេះថា ធម្មតាពួកអន្ធពាលបុថុជ្ជនរមែងវង្វេងក្នុងឥរិយាបថទាំងឡាយមានឈានទៅមុខជាដើម គឺគ្រាន់តែដឹងថា " ខ្លួនឈានទៅមុខ, ជំហានទៅមុខខ្លួនបានឈានទៅហើយ "

ដូច្នេះឬថា " អញឈានទៅមុខ, ជំហានទៅមុខអញបានឈាន ទៅហើយ " ដូច្នេះប៉ុណ្ណោះ មិនដឹងវិសេសជាងនេះឡើយ ។ ឯយោគាវចរភិក្ខុក្នុងពុទ្ធសាសនានេះ មិនវង្វេងដូច្នោះទេ គឺ កាលបើមានចិត្តគិតថា " អាត្មាអញនឹងឈានទៅមុខ " ដូច្នេះ ហើយ ក៏នឹកឃើញថា " ឱ ! ឥឡូវនេះវាយោធាតុញ៉ាំងវិញ្ញត្តិឲ្យ កើតឡើង គឺខ្យល់កម្រើកហើយតើ " ដូច្នេះ ជាមួយនិងចិត្ត ដែលគិតថា " អញឈានទៅមុខ " នោះឯង; ហើយគិតតទៅ ទៀតថា " ឱ ! ឥឡូវនេះ, រាងឆ្អឹងដែលលោកសន្មតថាកាយ នេះ កំពុងឈានទៅមុខដោយអំណាចកម្រើកវាយោធាតុ និង កិរិយាចិត្តហើយ " ។ គិតយ៉ាងនេះគ្រប់ឥរិយាបថ និងធាតុទាំង ៤ ។ តាមសេចក្តីក្នុងបរមត្ថថា ការដើរក៏ជារបស់ពួកធាតុ, ការឈរក៏ជារបស់ពួកធាតុទាំងអស់ ។ ចិត្តដែលប្រព្រឹត្តទៅ ជាមួយនឹងរូបក្នុងចំណែកនោះ ៗ ជាប់គ្នាដូចខ្សែទឹក ។ សេចក្តី នេះ សមដូចន័យគាថាដែលលោកពោលថា ៖

**អញ្ញំ ឧប្បជ្ជតេ ចិត្តំ អញ្ញំ ចិត្តំ និរុជ្ឈតិ**
**អវីចិមនុសម្ពន្ធោ នទីសោតោវ វត្តតិ ។**

សេចក្តីថា ៖ **ចិត្តដទៃកើតឡើង ចិត្តដទៃក៏រលត់ទៅ ប្រហែលគ្នានឹងខ្សែទឹកទន្លេដែលប្រព្រឹត្តជាប់ទៅតាមរលក ។**

សេចក្តីមិនវង្វេងក្នុងឥរិយាបថទាំងឡាយមានឈានទៅខាង មុខជាដើម ដូចពណ៌នាមកហើយនេះ បានឈ្មោះថា **អសម្មោ-ហសម្បជញ្ញៈ** ។

អ្នកដែលប្រកបដោយសម្បជញ្ញៈដូច្នេះ ចិត្តក៏រមែងជ្រះថ្លា មិនមានឱកាសឲ្យឧបក្កិលេសរុករានចូលមកបាន ។

សតិនិងសម្បជញ្ញៈទាំង ២ នេះ បើកើតឡើងព្រមគ្នាក្នុងវេលាមួយ ក៏រឹងរឹតតែទ្វេកម្លាំងច្រើនឡើង អាចកំចាត់សត្រូវគឺកិលេសដែលជាមេកងធំ គឺ **រាគៈ ទោសៈ មោហៈ** ឲ្យអស់ទៅបាន, តែកិលេសទាំងនេះអស់ទៅហើយ ចិត្តរមែងបរិសុទ្ធជ្រះថ្លាផូរផង់; ទុកជាមិនដាច់អស់ជាសមុច្ឆេទប្បហាន ក៏គង់ជាតទង្គប្បហាន; កាលបើជាតទង្គប្បហានរឿយ ៗ ក៏រមែងក្លាយជាសមុច្ឆេទប្បហានទៅបាន ។ សន្តានចិត្តនៃជនដែលបានដុសខាត់រឿយ ៗ រមែងស្អាតផូរផង់ទៅដោយលំដាប់តាមទំនងនៃកុសលធម៌ដែលជាគ្រឿងដុសខាត់នោះ ៗ, ដូចព្រាហ្មណ៍ម្នាក់ដែលធ្វើការកុសលបន្តិចម្តង ៗ ជាលំដាប់ ដរាបដល់បានសម្រេចមគ្គផល, សូមនាំរឿងនោះមកសម្តែងជាឧទាហរណ៍ដូចតទៅនេះ ៖

# រឿង ព្រាហ្មណ៍ធ្វើបុណ្យជាលំដាប់

ព្រាហ្មណ៍នោះ បានធ្វើបុណ្យជាលំដាប់ ៗ តាំងពីតិច ៗ ដរាបដល់បានសម្រេចមគ្គផលជាទីបំផុត ។ មុនដំបូងបានឃើញទីដែលភិក្ខុ ១ រូបឈរឃ្លុំចីពរ, ទីនោះមិនស្អាតប្រឡាក់ដោយភក់និងស្មៅ; ក៏ធ្វើឲ្យស្អាតល្អឡើង បានជញ្ជូនដីខ្សាច់

យកមកពោយរាយ រួចធ្វើបារាំបាំងកំដៅថ្ងៃ, ខាងក្រោយបំផុត បានសាងសាលា ១ ត្រង់ទីនោះ ។ វេលាសម្ពោធឆ្លងសាលានោះ បាននិមន្តព្រះភិក្ខុសង្ឃមានព្រះសម្មាសម្ពុទ្ធជាប្រធានមកឆាន់; លុះទ្រង់ឆាន់ហើយ, ក៏ក្រាបបង្គំទូលប្រវត្តិហេតុនៃការសាងសាលានោះឲ្យទ្រង់ជ្រាបតាំងពីខាងដើមជាលំដាប់មក រួចហើយវេរសាលានោះថ្វាយចំពោះសង្ឃ មានព្រះសម្ពុទ្ធជាប្រធាន កាលដែលព្រះបរមគ្រូនឹងទ្រង់អនុមោទនា ក៏ទ្រង់សម្ដែងបទព្រះគាថានេះថា ៖

**អនុបុព្វេន មេធាវី ថោកំ ថោកំ ខណេ ខណេ**
**កម្មារោ រជតស្សេវ និទ្ធមេ មលមត្តនោ ។**

សេចក្ដីថា **អ្នកមានប្រាជ្ញាគួរកំចាត់មន្ទិលរបស់ខ្លួនក្នុងខណៈ ៗ បន្តិចម្ដង ៗ ដោយលំដាប់ទៅ, ដូចជាងមាសដែលជម្រះស្នឹមនៃមាសប្រាក់ ដូច្នោះ ។**

**ពាក្យ**ដែលទូន្មានឲ្យធ្វើចិត្តរបស់ខ្លួនផូរផង់ ជាលំដាប់ដរាបដល់បានសម្រេចអរហត្តជាទីបំផុត ដូចពោលមកនេះរាប់ថាជា **ពុទ្ធសាសនា** ពាក្យប្រដៅរបស់ព្រះពុទ្ធទាំងឡាយ គឺព្រះពុទ្ធរាល់ព្រះអង្គដែលបានត្រាស់ក្នុងកាលទាំងពួង តែងទ្រង់ប្រដៅដូច្នេះ ។

# ចប់កណ្ឌទី ៣



# ឱវាទបាតិមោក្ខ កណ្ឌទី ៤

**លំដាប់នេះ** នឹងអធិប្បាយសេចក្តីនៃព្រះបរមពុទ្ធោវាទក្នុង ឱវាទបាតិមោក្ខ ត្រង់បទថា ៖

**ខន្តិ បរមំ តបោ តីតិក្ខា**
**អធិវាសនក្ខន្តិ ពោលគឺសេចក្តីអត់ធន់ ជាតបធម៌ដ៏ឧត្តម**
នោះ, ឲ្យមានសេចក្តីពិស្តារ ដើម្បីជាគ្រឿងប្រដាប់សតិបញ្ញា
និងជាវត្តប្រតិបត្តិរបស់សាធុសប្បុរសពុទ្ធបរស័ទដូចតទៅនេះ ៖

**ខន្តិ** ប្រែថា "**សេចក្តីអត់**" **តីតិក្ខា** ប្រែថា "**សេចក្តីធន់**" ស័ព្ទទាំង ២ នេះ មានសេចក្តីជាមួយគ្នា ទើបរួមចូលគ្នាហៅថា "**សេចក្តីអត់ធន់**" សេចក្តីអត់ធន់នេះលោកចែកជា ៣ យ៉ាងគឺ ៖

១. អត់ធន់ចំពោះសេចក្តីទុក្ខដែលជាហេតុឲ្យកើតលោភៈ
២. អត់ធន់ចំពោះសេចក្តីទុក្ខដែលជាហេតុឲ្យកើតទោសៈ
៣. អត់ធន់ចំពោះសេចក្តីទុក្ខដែលជាហេតុឲ្យកើតមោហៈ

## អធិប្បាយខន្តី

១. ឯសេចក្តីអត់ធន់ចំពោះសេចក្តីទុក្ខ ដែលជាហេតុឲ្យកើត **លោភៈ** នោះបានខាងអត់ទ្រាំនឹងចំណង់ផ្សេង ៗ ដែលកើតឡើងក្នុងទ្វារទាំង ៦ ។ ពាក្យថា អត់ទ្រាំគឺមិនប្រព្រឹត្ត

ទុច្ចរិតតាមចំណង់ឬសេចក្ដីស្រេកឃ្លាននោះ ៗ ។ បុគ្គលចំពូកខ្លះព្រោះតែមិនចេះអត់ទ្រាំនឹងចំណង់ឬសេចក្ដីស្រេកឃ្លាន បានជាលួចឆក់ដណ្ដើមបំបាត់ប្រវ័ញ្ចទ្រព្យសម្បត្តិរបស់គេ, កាលបើប្រព្រឹត្តទុច្ចរិតដូច្នោះ រមែងជួបប្រទះនឹងសេចក្ដីទុក្ខព្រួយដែលជាផលរបស់ទុច្ចរិតនោះ ៗ មានត្រូវទោសជាប់គុកជាប់ច្រវាក់ជាដើម ។ បុគ្គលឯណាជាមនុស្សមិនសូវរវេះរវាមពេក ចេះអត់ទ្រាំបាន, បុគ្គលនោះឯងតែងប្រកបដោយសេចក្ដីសុខសេចក្ដីចម្រើន ។ **ខន្តី** សេចក្ដីអត់ធន់បែបនេះ ហៅថា អត់ធន់ចំពោះសេចក្ដីទុក្ខដែលជាហេតុឲ្យកើត **លោភៈ** សូម្បីអត់ធន់ចំពោះសេចក្ដីទុក្ខដែលជាហេតុឲ្យកើត **រាគៈ** ក៏គួរសង្គ្រោះចូលក្នុងខន្តីនេះដែរ ។

២. ឯសេចក្ដីអត់ធន់ចំពោះសេចក្ដីទុក្ខ ដែលជាហេតុឲ្យកើត **ទោសៈ** នោះ បានខាងសេចក្ដីអត់ធន់នឹងពាក្យបរប្បវាទដែលបុគ្គលដទៃស្ដីថាត្មះតិះដៀល ឬអត់ធន់នឹងអំពើដែលបុគ្គលដទៃបៀតបៀនដែលជាហេតុឲ្យកើតទោសៈ ។ ធម្មតាមនុស្សដែលកើតមកក្នុងលោកសន្និវាសនេះ ដែលថាមិនឲ្យមានគេស្ដីថា ត្មះតិះដៀលសោះនោះគ្មានទេ, ទោះបីគេត្មះតិះដៀលស្ដីថាដោយត្រង់ ៗ មិនបាន ក៏គង់ត្មះតិះដៀលស្ដីថាដោយពាក្យបញ្ឆិតបញ្ឆៀងផ្សេង ៗ, បើគេតិះដៀលស្ដីថាចំពោះមុខមិនបាន គេក៏គង់តិះដៀលស្ដីថាជាកំបាំង ៗ អម្បាលព្រះអាទិត្យព្រះចន្ទដែលដើរវិលផ្លុះបំភ្លឺលោកជាប្រក្រតី ម្ដេចក៏គង់តែមានគេតិះ

ដៀលខ្លះដែរ, ចំណាង់បើមនុស្សក្នុងលោក នឹងរកនរណាឲ្យជាមនុស្សឥតគេតិះដៀលនោះមិនមានឡើយ; ទុកជាព្រះសាស្ដាបរមគ្រូជាម្ចាស់ដែលប្រកបដោយព្រះមហាករុណាទិគុណ ក៏គង់មានគេតិះដៀលដែរ, ដូចកាលទ្រង់ស្ដេចទៅគង់ក្នុងក្រុងកោសម្ពីសូមនាំរឿងនោះមកសម្ដែងជាឧទាហរណ៍ដូចតទៅនេះ ៖

# រឿង ព្រះសម្ពុទ្ធទ្រង់ស្ដេចទៅក្រុងកោសម្ពី

កាលដែលព្រះភគវន្ដមុនី ទ្រង់ស្ដេចទៅក្រុងកោសម្ពីនោះនាងមាគណ្ឌិយជាទេពីព្រះបាទឧទេន ប្រើមនុស្សឲ្យជេរប្រទេចផ្ដាសាព្រះអង្គដោយពាក្យអាក្រក់ផ្សេង ៗ ដរាបដល់ព្រះអានន្ទធុញទ្រាន់អត់ទ្រាំមិនបាន ចូលទៅក្រាបបង្គំទូលនិមន្ដព្រះអង្គឲ្យទ្រង់ស្ដេចទៅនគរឯទៀត, តែព្រះអង្គមិនញាប់ញ័រនឹងហេតុនោះបន្ដិចបន្ដួចឡើយ ។ ក្នុងវេលានោះ ពួកជនដែលបានមើលឃើញនិងស្ដាប់ឮ កម្រនឹងចៀសវាងសេចក្ដីក្រេវក្រោធបាន, បើនឹងបានខ្លះក៏ដោយសារតែប្រឹងអត់សង្កត់ចិត្តតាមព្រះអង្គប៉ុណ្ណោះលុះចំណេរមកខាងក្រោយ ពួកស្រីទាំងនោះក៏ដល់នូវសេចក្ដីស្លាប់ដោយព្រះមហាក្សត្រិយ៍ឲ្យចាប់យកមកឲ្យជីកកប់ក្នុងរណ្ដៅឲ្យនៅត្រឹម ១ ក ហើយឲ្យរាស់ដោយរនាស់ដែក និងដុតរោលដោយភ្លើង, លុះស្លាប់ទៅហើយក៏ទៅកើតក្នុងនរករងទុក្ខវេទនាជាពន្លឹកគួរខ្លាចក្រៃពេក ។

# ឧបាយរំលត់សេចក្ដីក្រោធ

ព្រះបោរាណាចារ្យលោកសម្ដែងប្រាប់ឧបាយគឺ យោបល់ជាគ្រឿងរំលត់សេចក្ដីក្រោធខឹងថា ៖

**" ទុកជាមានភ្នែកភ្លឺក៏ត្រូវធ្វើដូចជាងងឹត,**
**មានត្រចៀកស្ដាប់ឮក៏ត្រូវធ្វើថ្លង់ "**

ដូច្នេះទើបអត់ទ្រាំសេចក្ដីក្រោធខឹងនោះបាន ។ បើធ្វើជាមនុស្សភ្នែកទិព្វត្រចៀកទិព្វ នឹងរក្សាខន្តីសេចក្ដីអត់ធន់នោះបានដោយកម្រណាស់; ដូចយ៉ាងមនុស្សដែលមិនចេះអត់ធន់ចំពោះសេចក្ដីទុក្ខលំបាកដែលជាហេតុឲ្យកើតទោសៈនោះ ច្រើនតែធ្វើការអ្វី ៗ ដោយសេចក្ដីខឹងតូងតាង, អ្នកដែលធ្វើដូច្នោះ ច្រើនតែប្រទះនឹងសេចក្ដីអន្តរាយផ្សេង ៗ; កាលបើជួបប្រទះនឹងគ្រោះថ្នាក់ណាមួយ ព្រោះតែសេចក្ដីខឹងតូងតាងនោះហើយ ច្រើនតែគិតស្ដាយក្រោយថា ៖ " **ឱ ! អញធ្វើនេះខុសហើយ មិនគួរសោះ** " បណ្ដាកិច្ចការអ្វី ៗ ទោះបីយ៉ាងណាក៏ដោយ ឲ្យតែធ្វើដោយសេចក្ដីក្រេវក្រោធហើយ, កិច្ចការនោះ ៗ សុទ្ធតែជារបស់មិនស្រួលមិនល្អទាំងអស់ ។ ព្រោះហេតុដូច្នេះបានជាអ្នកប្រាជ្ញដែលសម្បូណ៌ដោយប្រាជ្ញា គួរតែពិចារណាឃើញទោសនៃសេចក្ដីក្រោធខឹង ហើយខំប្រឹងអត់ធន់ ដូចសម្ដែងមកនេះចុះ ។

៣. ឯសេចក្ដីអត់ធន់ចំពោះសេចក្ដីទុក្ខ ដែលជាហេតុឲ្យ

កើត **មោហៈ** នោះ បានខាងសេចក្ដីអត់ទ្រាំនឹងទុក្ខវេទនាផ្សេង ៗ ដែលកើតឡើងក្នុងកាយនិងចិត្ត មិនលុះអំណាចទុក្ខវេទនា ហើយទៅប្រព្រឹត្តទុច្ចរិតឡើយ ។ សូម្បីការដែលអត់ទ្រាំនឹងទុក្ខវេទនាក្នុងវេលាឈឺថ្កាត់នោះសោត ក៏ជាហេតុជួយឧបត្ថម្ភឲ្យមានសតិសម្បជញ្ញៈ គឺសេចក្ដីរឭកនិងសេចក្ដីដឹងខ្លួនដែលជាគុណវិសេសគួរឲ្យមានក្នុងចិត្តគ្រប់កាលទាំងពួង, ពុំនោះសោតក្នុងវេលាមានព្យាធិដែលជាហេតុឲ្យដល់មរណៈ ក៏ត្រូវតែមានខន្តីយ៉ាងមាំមួនខានមិនបានឡើយ; ឧបាយដែលនឹងឲ្យកើតខន្តីក្នុងវេលានោះ គឺត្រូវគិតឲ្យឃើញតាមសេចក្ដីពិតថា ៖ " **ព្យាធិនិងមរណៈនុ៎ះ ជាទុក្ខដែលសត្វទាំងឡាយត្រូវតែជួបប្រទះរាល់ ៗ គ្នា គេចមិនរួចឡើយ** " ។ ក្នុងអភិណ្ហបច្ចវេក្ខណៈដែលព្រះបរមសាស្ដាទ្រង់ប្រដៅឲ្យនឹករំពឹងជារឿយ ៗ ថា ៖

**ព្យាធិធម្មោម្ហិ ព្យាធឹ អនតីតោ**
**យើងមានជម្ងឺតម្កាត់ជាធម្មតា**
**នឹងចៀសវាងជម្ងឺតម្កាត់មិនបានឡើយ**

ដូច្នេះនោះ ក៏ដើម្បីឲ្យប្រុងខ្លួនអំពីកាលដែលនៅជានៅឡើយ, បើចាំទៅនឹករំពឹងក្នុងពេលដែលជម្ងឺតម្កាត់មកដល់តែម្ដង ក៏មុខជាកម្រនឹងបាន; ព្រោះវេលាដែលឈឺនោះឯងតែងមានទុក្ខព្រួយលំបាកច្រើនយ៉ាងណាស់; កាលបើអត់ទ្រាំទុក្ខវេទនាមិនបាន, សតិសម្បជញ្ញៈ ក៏នឹងទ្រេតទ្រោតទៅមិន

តម្កល់នៅខ្ជាប់ឡើយ; ដូចជនចំពូកខ្លះដែលមិនបានហាត់ចិត្តទុកអំពីកាលនៅជានោះ លុះវេលាដែលមានជម្ងឺយ៉ាងធ្ងន់មកដល់ក៏ច្រើនតែមានចិត្តរវើរវាយផ្សេង ៗ ដរាបដល់ធ្វើអំពើទុច្ចរិតមានសម្លាប់សត្វជាដើមដើម្បីបូជាគ្រោះ ដោយចង់រស់តែខ្លួនឯងមិនគិតអាណិតដល់សត្វដទៃក៏មាន ។ ទោសទាំងនេះ មកតែអំពីមិនបានហ្វឹកហាត់ស្មារតីទុកអំពីកាលនៅជាឲ្យដឹងថា ៖

## " សត្វដែលកើតមកក្នុងលោក សុទ្ធតែត្រូវឈឺថ្កាត់រាល់ ៗ រូប "

ដូច្នេះឯងបានជារវើរវាយយ៉ាងនោះ; ពួកបុគ្គលដែលរវើ - រវាយហើយទៅប្រព្រឹត្តទុច្ចរិតដូច្នោះ លុះរំលាយខន្ធទៅហើយតែងទៅកើតក្នុងអបាយ ។ ចំណែកពួកបុគ្គលដែលមានសតិសម្បជញ្ញៈបរិបូណ៌រមែងទៅកើតក្នុងឋានសួគ៌ ។ ព្រោះហេតុដូច្នោះ ការដែលបង្ហាត់ចិត្តបង្ហាត់ស្មារតីដើម្បីឲ្យកើតខន្តីសេចក្ដីអត់ធន់នោះ ជារបស់ដែលយើងត្រូវការគ្រប់ ៗ ប្រាណសម្រាប់តយុទ្ធនឹងសត្រូវគឺព្យាធិទុក្ខ ក្នុងវេលាដែលជិតនឹងដល់មរណៈនោះ ។ កាលបើអ្នកមានប្រាជ្ញាពិចារណាឃើញទោសនៃសេចក្ដីវង្វេង ឃើញគុណនៃសតិសម្បជញ្ញៈ និងគុណនៃខន្តីដូចសម្ដែងមកនេះហើយ, គួរណាស់តែហាត់ស្មារតីទុកជាមុនតាមពីធីដែលព្រះសម្មាសម្ពុទ្ធជាបរមគ្រូទ្រង់ប្រដៅឲ្យហាត់ មានអភិណ្ហបច្ចវេក្ខណវិធីជាដើម ដើម្បីកុំឲ្យសេចក្ដីវង្វេងនោះកើតឡើងបាន ។

**ខន្តី** សេចក្តីអត់ធន់ ដែលចែកចេញជា ៣ យ៉ាង មានសេចក្តីដូចសម្តែងមកនេះ ។

ឯសេចក្តីអត់ធន់ចំពោះសេចក្តីទុក្ខ ដែលជាហេតុឲ្យកើត **លោភៈ** និង **មោហៈ** ទាំងពីរដែលពណ៌នាមកនេះ ជាខន្តីដោយបរិយាយ ឬដោយអម, មិនមែនជាខន្តីដោយត្រង់; ចំណែកឯសេចក្តីអត់ធន់ចំពោះសេចក្តីទុក្ខដែលជាហេតុឲ្យកើត **ទោសៈ** សេចក្តីប្រទូស្តនោះឯង ទើបជាខន្តីដោយត្រង់, លោកហៅថា **អធិវាសនខន្តី** ។

## អានិសង្សអធិវាសនខន្តី

ឯអធិវាសនខន្តីនេះ លោកសរសើរដោយអនេកបរិយាយ មានដើមថា ៖

**សីលសមាធិគុណានំ ខន្តិ បធានការណំ**
**សព្វេបិ កុសលាធម្មា ខន្ត្យាយេវ វឌ្ឍន្តិ តេ**

**សេចក្តីអត់ធន់ ជាហេតុជាទីតាំងនៃគុណ គឺសីលនិងសមាធិទាំងឡាយ, ធម៌ទាំងឡាយជាកុសលទាំងអស់នោះ តែងចម្រើនដោយសេចក្តីអត់ធន់មែនពិត ។**

**កេវលានំបិ បាបានំ ខន្តិ មូលំ និកន្តតិ**
**គរហកលហាទីនំ មូលំ ខនតិ ខន្តិកោ**

សេចក្តីអត់ធន់ តែងកាត់បង់បាននូវឫសនៃបាបទាំងឡាយទាំងអស់, បុគ្គលអ្នកអត់ធន់ ឈ្មោះថាជីករំលើងនូវឫសនៃទោសទាំងឡាយ មានពាក្យតិះដៀល និងការឈ្លោះប្រកែកជាដើម ។

**ខន្តិ ធីរស្សលង្ការោ ខន្តិ តបោ តបស្សិនោ**
**ខន្តិ ពលំ ច យតីនំ ខន្តិ ហិតសុខាវហា**

សេចក្តីអត់ធន់ ជាគ្រឿងអលង្ការរបស់អ្នកប្រាជ្ញ សេចក្តីអត់ធន់ ជាគ្រឿងដុតបង់នូវបាបរបស់អ្នកដែលមានតបធម៌, សេចក្តីអត់ធន់ជាកម្លាំងរបស់អ្នកប្រព្រឹត្តធម៌, សេចក្តីអត់ធន់ ជាគុណជាតិនាំមកនូវប្រយោជន៍ និងសេចក្តីសុខ ។

**ខន្តិកោ មេត្តវា លាភី យសស្សី សុខសីលវា**
**បិយោ ទេវមនុស្សានំ មនាបោ ហោតិ ខន្តិកោ**

អ្នកអត់ធន់ ជាអ្នកមានមិត្តសម្លាញ់ ជាអ្នកមានលាភ ជាអ្នកមានយស ជាអ្នកមានសេចក្តីសុខជាប្រក្រតី, អ្នកអត់ធន់ រមែងជាទីស្រឡាញ់ជាទីគាប់ចិត្តនៃទេវតា និងមនុស្សទាំងឡាយ។

**អត្តនោបិ បរេសញ្ច អត្ថាវហោ ច ខន្តិកោ**
**សគ្គមោក្ខគមំ មគ្គំ អារូឡ្ហោ ហោតិ ខន្តិកោ**

អ្នកអត់ធន់ ជាអ្នកនាំមកនូវប្រយោជន៍ដល់ខ្លួនផង ដល់ជនទាំងឡាយឯទៀតផង, អ្នកអត់ធន់ ជាអ្នកឡើងកាន់ផ្លូវជាទីទៅស្ថានសួគ៌ និងព្រះនិព្វាន ។

**សត្ថុនោ វចនោវាទំ ករោតិយេវ ខន្តិកោ**

**បរូបឃាតី ច បូជាយ ជិនំ បូជេតិ ខន្តិកោ**

**អ្នកអត់ធន់ ឈ្មោះថាធ្វើតាមនូវព្រះពុទ្ធដីកាជាឱវាទនៃព្រះសាស្តាមែនពិត, អ្នកអត់ធន់ ឈ្មោះថាបូជានូវព្រះពិជិតមារដោយការបូជាដ៏ឧត្តម ។**

លោកសរសើរខន្តីមានន័យផ្សេង ៗ ច្រើនយ៉ាងដោយប្រការដូច្នេះ; តែក្នុងឱវាទបាតិមោក្ខគាថានេះ ព្រះសម្មាសម្ពុទ្ធរាល់ព្រះអង្គទ្រង់សម្តែងសរសើរគុណរបស់ខន្តីថា **បរមំ តបោ តីតិក្ខា ជាតបធម៌ដ៏ឧត្តម** តែ ១ បទប៉ុណ្ណោះ ។

## អធិប្បាយចំពោះខន្តីជាតបធម៌

ពួកធម៌ឯណា ដែលកើតឡើងហើយដុតបំផ្លាញបាបធម៌ដ៏ជាសត្រូវដល់ខ្លួនបាន, ធម៌អម្បាលនោះ បានឈ្មោះថាជាតបធម៌ទាំងអស់, ដូចកុសលកម្មបថ ក៏ជាតបធម៌របស់អកុសលកម្មបថ ព្រោះកាលកុសលកម្មបថកើតឡើង ក៏កំចាត់បង់អកុសលកម្មបថឲ្យអន្តរធានទៅបាន, **វីរិយៈ** ( សេចក្តីប្រឹងប្រែង ) ជាតបធម៌របស់ **កោសជ្ជៈ** ( សេចក្តីខ្ជិលច្រអូស ) ព្រោះសេចក្តីប្រឹងប្រែងកើតឡើង ក៏អាចកំចាត់បង់សេចក្តីខ្ជិលច្រអូសឲ្យអន្តរធានទៅបាន, ដូច្នេះជាដើម ។

ឯខន្តីនោះ បានជាហៅថាតបធម៌ ព្រោះដុតបាបធម៌ទាំងឡាយមាន **ទោសៈ** ( សេចក្តីប្រទូស្ត ) **កោធ** ( សេចក្តីក្រោធ )

**ព្យាបាទ** ( សេចក្តីបំផ្លាញគេឲ្យវិនាស ) **វិហឹសា** ( សេចក្តីបៀតបៀនគេ ) **អរតិ** ( សេចក្តីឈ្នានីសគេ ) **បដិឃៈ** ( សេចក្តីថ្នាំងថ្នាក់ ) ជាដើម ដែលជាសាខារបស់ទោសៈ ឲ្យរីងស្ងួតទៅ; ឯទោសៈដែលចម្រើនធំថ្លោសឡើងបាន ក៏អាស្រ័យសេចក្តីមិនអត់ធន់, គប្បីមើលអ្នកដែលឈ្លោះវិវាទគ្នា ដូចពួកភិក្ខុក្នុងស្រុកកោសម្ពីដែលអាស្រ័យនឹងហេតុបន្តិចបន្តួច សមបើទឹកដែលសល់អំពីការជម្រះលាមកប៉ុណ្ណោះ ក៏មិនប្រឹងអត់ធន់, ផ្តួចផ្តើមឲ្យកើតជាវិវាទទាស់ទែងរោលរាលធំធាត់ឡើង ដរាបដល់បែកសាមគ្គីអំពីគ្នា, បើប្រសិនជាខាងណាម្ខាងអត់ធន់បាន រឿងរ៉ាវនោះក៏នឹងស្ងប់រម្ងាប់ទៅមិនខានឡើយ ។ សេចក្តីអត់ធន់នេះមិនមែនមានគុណចំពោះតែខ្លួនឯងទេ រមែងមានគុណប្រ - យោជន៍ដល់អ្នកដទៃផង, ហេតុដូច្នោះបានជាលោកសរសើរថាជាតបធម៌ដ៏សំខាន់ក្រៃពេក ។ ម្យ៉ាងទៀត បណ្តាអារម្មណ៍ដែលមកនាំឲ្យកើតទោសៈនោះ នឹងមានមកប៉ះពាល់ជានិច្ចទាំងយប់ទាំងថ្ងៃគ្រប់ពេលទៅក៏ទេ, គង់មានចន្លោះទំនេរគ្រាន់នឹងឲ្យទប់ទល់តម្កល់ស្មារតីបានខ្លះដែរ, ចួនកាល ២-៣ ថ្ងៃមិនទាន់មកប៉ះពាល់ម្តងសោះក៏សឹងមាន; ដែលនឹងហៅអធិវាសនក្ខន្តីបាននោះ ក៏ចំពោះតែក្នុងខណៈដែលមានហេតុមកប៉ះពាល់ដល់ទង្គិចហើយអត់ទ្រាំបាននោះឯង ។ បុគ្គលដែលជាអ្នកសមាទានអធិវាសនខន្តី បើមិនទាន់មានហេតុដែលនាំឲ្យកើតទោសៈទេ ឬទៅនៅជ្រកសម្ងំក្នុងទីណាដែលមិនមានមនុស្ស ការរក្សាអធិ-

វាសនក្ខន្តីនោះ ក៏មិនទាន់ឃើញផលអស្ចារ្យ, លុះតែមានហេតុកើតឡើងហើយអត់ធន់បាន ទើបឃើញផលអស្ចារ្យមែន; ដូចពួកអ្នកច្បាំងដែលនឹងដឹងថាពូកែនោះ លុះតែបានចូលទៅប្រយុទ្ធនឹងសង្គ្រាម ហើយតយុទ្ធយកជាញជ័យបាន ទើបឈ្មោះថាពូកែមែន ។

# យោបល់ឲ្យកើតអធិវាសនក្ខន្តី

ពុទ្ធសាសនិកជន ដែលស្ម័គ្រចិត្តប្រតិបត្តិតាមអធិវាសនក្ខន្តីធម៌គួរគិតឲ្យយល់ដោយយោបល់ដូច្នេះថា ៖ " **ឱ! អ្នកដែលមកតិះដៀលអាត្មាអញដោយពាក្យសម្តីទ្រគោះ ខ្ចីខ្ចាសៀតស៊កនេះហាក់ដូចជាគេមកបំពេញខន្តីបារមីរបស់អាត្មាអញ ឲ្យរឹងរឹតតែចម្រើនឡើងទេតើ** " ព្រោះអធិវាសនក្ខន្តីនេះជាកម្លាំងនៃពោធិញ្ញាណមួយដ៏សំខាន់, ដូចកាលព្រះវេស្សន្តរបរមពោធិសត្វទ្រង់ប្រទានកណ្ហាជាលីជាបុត្តសម្លាញ់ឲ្យទៅជូជកព្រាហ្មណ៍ វេលាដែលព្រះរាជកុមារទាំងពីរកិកកុកមិនព្រមទៅ ព្រាហ្មណ៍ចាស់ក៏ទះតប់វាយដំច្រំផាក់ ចំពោះព្រះភក្ត្រព្រះបរមពោធិសត្វក្នុងគ្រានោះ ហេតុតែព្រះអង្គបិតនៅក្នុងអធិវាសនក្ខន្តីយ៉ាងខ្ជាប់ខ្ជួនបានជាមិនធ្វើអំពើអាក្រក់ឯណានីមួយដល់ព្រាហ្មណ៍នោះឡើយ ។ ដូច្នេះហៅថាព្រះអង្គមានជ័យជំនះផង ហៅថាព្រះអង្គបានបំពេញទានបារមី និងខន្តីបារមីផង ។ម្យ៉ាងទៀតគួរគិតឲ្យយល់ដោយយោបល់ថា ៖ " **ឱ! អ្នកដែលមកនិយាយស៊កសៀត**

**ទ្រគោះខ្ញីខ្ញាផ្ដេសផ្ដាសដូច្នោះ ទុកដូចជាគេយកបុណ្យមកឲ្យយើងទេតើ ”,** ព្រោះការអត់ធន់មិនក្រោធខឹងសោះអំពីដំបូងតែម្ដង ឬដំបូងឡើយក្រោធខឹងខ្លះដែរ តែបានអត់ឲ្យស្ងប់មួយរំពេចទៅវិញ មិនលុះតាមអំណាចសេចក្ដីក្រោធខឹងនេះឯង ជាតួបុណ្យកុសលយ៉ាងសំខាន់ និងជាដើមចមនាំឲ្យកើតបុណ្យកុសលឯទៀត ៗ ច្រើនយ៉ាង; ការបុណ្យកុសលចំពូកខ្លះបើនឹងធ្វើលុះតែអស់ទ្រព្យ ដាច់ប្រាក់កាស ឬនឿយហត់ពិបាកខ្លួនទើបបាន; ឯសេចក្ដីអត់ធន់ចំពោះសម្ដីដែលអ្នកដទៃមកនិយាយអាក្រក់គ្រោតគ្រាតខ្ញីខ្ញានេះ ជាបុណ្យកុសលយ៉ាងងាយ ៗ មិនបាច់ដាច់ទ្រព្យសម្បត្តិឡើយ ហើយមិនបាច់នឿយព្រួយលំបាកផង ទាំងមានសេចក្ដីស្រួលសប្បាយដូចធម្មតា ។

## ឈ្នះសេចក្ដីក្រោធ ដោយសេចក្ដីមិនក្រោធ

អ្នកដែលមានអធិវាសនក្ខន្តិខ្ជាប់ខ្ជួនល្អ រមែងឈ្នះអ្នកដែលមានសេចក្ដីក្រេវក្រោធ ដូចនាង **ឧត្តរា** ដែលឈ្នះនាង **សិរិមា** ។ សូមនាំរឿងនោះមកសម្ដែងជាឧទាហរណ៍ដូចតទៅនេះ ៖

## រឿង នាងឧត្តរា

នាងឧត្តរា ជាឧបាសិកានោះ ជាអ្នកបានសម្រេចសោតាតាំងពីក្មេង ជាធីតារបស់បុណ្ណសេដ្ឋី ជាភរិយារបស់រាជគហ-

សេដ្ឋីដែលជាមនុស្សមិច្ឆាទិដ្ឋិ ។ តាំងពីថ្ងៃដែលនាងទៅនៅក្នុងផ្ទះស្វាមី មិនមានឱកាសនឹងបរិច្ចាគទាន, នាងក៏បានជួលនាងសិរិមា ដែលជាស្ត្រីពេស្យាផ្កាមាសឲ្យមកនៅបម្រើស្វាមីរបស់នាង ហើយនាងចៀសចេញទៅធ្វើការកុសលតាមប្រាថ្នា ។ ឯនាងសិរិមានោះ កាលបើបានមកនៅជាមួយនឹងស្វាមីរបស់គេតែត្រឹមកន្លះខែ ក៏កម្រើកចិត្តគិតចង់ដណ្ដើមយកទីជាមេផ្ទះ បានប្រទូស្តដល់នាងឧត្តរាមានប្រការផ្សេង ៗ ដរាបដល់ប្រើគេឲ្យយកទឹកក្ដៅកំពុងពុះស្រោចចុះលើនាងឧត្តរាជាទីបំផុត, តែនាងឧត្តរាមិនក្រេវក្រោធសោះ ទឹកក្ដៅនោះត្រឡប់ជាត្រជាក់ដូចទឹកធម្មតា ។ ឯនាងសិរិមាដឹងថាខ្លួនមានទោស ទើបចូលទៅសូមស្មាលាទោសនឹងនាងឧត្តរា ៗ ក៏នាំទៅចូលគាល់ព្រះបរមសាស្ដាក្រាបបង្គំទូលរឿងនុ៎ះឲ្យទ្រង់ជ្រាប ។ ព្រះអង្គទ្រង់ព្រះមេត្តាប្រោសប្រទានព្រះសទ្ធម្មទេសនាទូន្មានថា ៖

**អក្កោធេន ជិនេ កោធំ អសាធុំ សាធុនា ជិនេ**
**ជិនេ កទរិយំ ទានេន សច្ចេនាលិកវាទិនំ ។**

សេចក្ដីថា ៖ **បុគ្គលគប្បីឈ្នះសេចក្ដីក្រោធ ( របស់គេ ) បានដោយសារសេចក្ដីមិនក្រោធ ( របស់ខ្លួន ), គប្បីឈ្នះសេចក្ដីមិនល្អ ( របស់គេ ) បាន ដោយសេចក្ដីល្អ ( របស់ខ្លួន ), គប្បីឈ្នះសេចក្ដីកំណាញ់ស្វិត ( របស់គេ ) បាន ដោយការឲ្យ ( របស់ខ្លួន ), គប្បីឈ្នះ មនុស្សដែលហៃនិយាយឡេះឡោះបាន ដោយការនិយាយតែពាក្យពិតទៅវក ។**

ត្រង់បទថា ៖ **បុគ្គលគប្បីឈ្នះសេចក្ដីក្រោធ ( របស់គេ ) បានដោយសារសេចក្ដីមិនក្រោធ ( របស់ខ្លួន )** , នោះមានសេចក្ដីអធិប្បាយដូចតទៅ ៖

សេចក្ដីក្រេវក្រោធ ជាសង្កិលេសធម៌ម្យ៉ាង តែងដេកត្រាំនៅក្នុងខន្ធសន្ដាននៃមនុស្សបុថុជ្ជនទូទៅ កម្រនឹងលះបាន, លុះតែព្រះខីណាស្រព ទើបលះបាន ដោយអំណាចអរហត្តមគ្គ; ឯមនុស្សជាបាបបុថុជ្ជនមានសន្ដានក្រាស់ដោយបាប លះមិនបានឡើយ, លុះតែជាកល្យាណបុថុជ្ជនមានសន្ដានល្អ ទើបលះបាន ដោយអំណាចអធិវាសនក្ខន្តី ។ បុគ្គលណាមួយបើមានអ្នកដទៃមកប្រទូស្ដ ហើយខ្លួនជាមនុស្សអាចធ្វើអ្នកដែលប្រទូស្ដនោះឲ្យវិនាសបានដែរ, តែអត់ធន់ មិនក្រោធពិរោធតបឡើយចេះសម្ដែងចិត្តមេត្រី ធ្វើមុខស្រស់បស់សំណោះសំណាលទៅរកគេវិញ, បើដូច្នេះ អ្នកដែលប្រទូស្ដនោះ មិនយូរប៉ុន្មានក៏នឹងរសាយចិត្ត លែងប្រទូស្ដខ្លះមិនខាន, ហេតុនេះបានជា លោកឲ្យឈ្មោះអ្នកដែលអត់ធន់បែបនោះថា ជាមនុស្សមានជ័យជំនះឈ្នះអ្នកដែលប្រទូស្ដ ដោយពិត ដូចនាងឧត្តរានោះឯង ។

# ទោសនៃសេចក្ដីក្រោធ

ធម្មតាមនុស្សណាមួយ ដែលច្រឡោតខឹងឡើងចំពោះនរណាម្នាក់, បើអ្នកម្ខាងគេអត់ធន់បាន មិនខឹងតបវិញសោះ

ហើយអ្នកម្ខាងនោះនៅតែចចេសខឹងនឹងគេ ដរាបដល់ជេរប្រ-ទេចផ្ដាសាគេថែម ៗ ញយ ៗ ដងទៅ អ្នកដែលខឹងហើយជេរគេដោយបំពាននោះ ក៏នឹងត្រឡប់ជាភ័យខ្លួនវិញ ឬនឹងត្រឡប់ជាមានសេចក្ដីអន្តរាយដល់ខ្លួនវិញមិនខាន; ដូចព្រានសុនខឈ្មោះ **កោកៈ** ។

សូមនាំរឿងនោះមកសម្ដែងជាឧទាហរណ៍ដូចតទៅនេះ ៖

# រឿង ព្រានសុនខឈ្មោះ កោកៈ

ព្រានសុនខឈ្មោះកោកៈនោះ បណ្ដើរសុនខ ១ ហ្វូងទៅបណ្ដោញសត្វក្នុងព្រៃ ។ ថ្ងៃនោះក៏ចួនបួតសូន្យទទេ មិនបានសត្វអ្វី ១ សោះ ។ លុះប្រទះនឹងភិក្ខុ ១ រូបក៏គិតថា ៖ " ការដែលអញមិនបានសត្វក្នុងថ្ងៃនេះ មិនទាស់ពីរឿងអ្វីទេ, ច្បាស់ជាទាស់ពីព្រោះតែអញឃើញមនុស្សកាឡកិណ្ណីនេះឯង បានជាឆ្នែងអស់ " នឹកខឹងក្នាញ់ក្នុងចិត្តដូច្នោះ ក៏ពន្យុះឆ្កែឲ្យដេញខាំលោក ។ ភិក្ខុនោះស្ទុះឡើងដើមឈើ ។ ព្រានឆ្កែក៏តាមទៅចាក់បាទជើងលោកនឹងលំពែង, ទោះបីលោកអង្វរយ៉ាងណាក៏មិនស្ដាប់; ចេះតែចាក់ដរាបដល់របូតចីវររបស់លោកធ្លាក់ចុះមកគ្របលើខ្លួន ។ ឯហ្វូងឆ្កែ កាលបើឃើញដូច្នោះ, សម្គាល់ថាលោកធ្លាក់ចុះមក ហើយក៏នាំគ្នាខាំត្របាក់ជញ្ជែងព្រាននោះដរាបដល់ស្លាប់ ។ កាលបើឆ្កែទាំងអស់ចៀសចេញទៅហើយ

ភិក្ខុនោះចុះមក, កើតមានសេចក្តីសង្ស័យក្រែងខូចសីលរបស់លោក ក៏ទៅក្រាបបង្គំទូលសួរព្រះបរមសាស្តា ។ ព្រះអង្គទ្រង់ត្រាស់ថា ៖ " សីលរបស់អ្នកមិនធ្លុះធ្លាយទេ " ហើយទ្រង់សម្តែងព្រះគាថា ថា ៖

**យោ អបទុដ្ឋស្ស នរស្ស ទុស្សតិ**
**សុទ្ធស្ស បោសស្ស អនង្គណស្ស**
**តមេវ ពាលំ បច្ចេតិ បាបំ**
**សុខុមោ រជោ បដិវាតំវ ខិត្តោ ។**

សេចក្តីថា ៖ **មនុស្សល្ងង់ខ្លៅណាមួយទៅប្រទូស្តនឹងនរជនដែលឥតប្រទូស្តដល់ខ្លួន ហើយគេជាមនុស្សល្អបរិសុទ្ធ ជាមនុស្សឥតទួលពោលគឺកិលេស, អំពើបាបនោះឯងតែងត្រឡប់មកត្រូវមនុស្សល្ងង់ខ្លៅនោះវិញមិនខាន, ដូចធូលីដ៏ល្អិតដែលបុគ្គលបាចប្រាសខ្យល់ តែងត្រឡប់មកត្រូវខ្លួនវិញ ។**

អ្នកដែលមិនចេះអត់ធន់ ច្រើនមានសេចក្តីវិនាសអន្តរាយដូចរឿងព្រានដែលនិទានមកនេះ ។ ព្រោះហេតុដូច្នោះ បណ្ឌិតទាំងឡាយដែលប្រាថ្នាមិនឲ្យមានភ័យ និងពៀរដល់ខ្លួន គួរពិចារណាឲ្យឃើញទោសរបស់ **ទោសៈ** ថា ៖ " **ដូចជាភ្លើងដុតខ្លួន និងអ្នកដទៃឲ្យខ្លោចផ្សា** " ហើយគួរសមាទាននូវអធិវាសនក្ខន្តិ ថា ៖ " **ថ្ងៃនេះអញនឹងរក្សាអធិវាសនក្ខន្តិ មិនក្រោធខឹងនឹងនរណាទេ** " លុះសមាទានដូច្នេះរួចហើយ ត្រូវប្រុង

ស្មារតីរឭកដល់ការសមាទាននោះឲ្យរឿយ ៗ; បើក្រែងវង្វេងភ្លេច ត្រូវធ្វើគ្រឿងសម្គាល់យ៉ាងណាមួយទុកនឹងខ្លួន មានក្ដួចជាយសំពត់ចំណាំជាដើម, លុះក្រឡេកឃើញគ្រឿងសម្គាល់នោះ ក៏នឹងនឹកភ្នកឃើញឡើងភ្លាមមិនវង្វេងភ្លេចឡើយ; ខំហាត់ញយ ៗ ទៅក៏មុខជាធ្លាប់ទៅឯង ។

# អានិសង្សអធិវាសនក្ខន្តី ៥ យ៉ាង

ព្រះអរហន្តសម្មាសម្ពុទ្ធជាម្ចាស់ បានត្រាស់សរសើរគុណសម្បត្តិនៃការលះទោសៈថា ៖

**ទោសំ ភិក្ខវេ បជហថ**

**"ម្នាលភិក្ខុទាំងឡាយ ! បើអ្នកទាំងអស់គ្នាលះទោសៈបាន តថាគតនឹងហៅអ្នកទាំងឡាយថាជាអនាគាមិ ដូច្នេះ" ។**

ក៏ឯការលះទោសៈនេះ បើទុកជាមិនបានដាច់ជាសមុច្ឆេ - ទប្បហាន គ្រាន់តែធ្វើឲ្យស្ងប់រម្ងាប់ក្នុងចន្លោះនោះ ៗ ដោយអធិវាសនក្ខន្តី ក៏មានគុណានិសង្ស ៥ យ៉ាង គឺ ៖

១. **បិយោ មនាបោ** អ្នកអត់ធន់ តែងបានជាទីស្រឡាញ់ពេញចិត្តរបស់ជនជាច្រើន ;
២. **ន វេរពហុលោ** មិនមានពៀរច្រើន ;
៣. **ន វជ្ជពហុលោ** មិនមានទោសច្រើន ;

៤. **អសម្មូឡ្ហោ** មិនវង្វេងស្មារតីក្នុងមរណសម័យ ;
៥. **សុគតិ** ទំលាយខន្ធទៅបានទៅកើតក្នុងឋានសួគ៌ ។

បណ្ដាគុណានិសង្សទាំង ៥ យ៉ាងនេះ, ត្រង់បទទី ១, ៣, ៤, ៥ មានសេចក្ដីងាយស្ដាប់ស្រាប់ហើយ មិនបាច់អធិប្បាយ, នឹងអធិប្បាយតែត្រង់បទទី ២ ដែលមានសេចក្ដីថា " អ្នកអត់ធន់មិនមានពៀរច្រើន " នោះ ដោយសេចក្ដីសង្ខេបដូចតទៅនេះ ៖

## អធិប្បាយពាក្យថាពៀរ

ពាក្យដែលហៅថា **ពៀរ** នោះ ប្រែថា " **សេចក្ដីឈ្នានីសគ្នាទៅវិញទៅមកដោយហេតុមានសភាពផ្សេង ៗ** ", នរណាប្រកបដោយខន្ដី សេចក្ដីអត់ធន់ មិនបង្កហេតុឲ្យកើតពៀរនឹងគេមុន, គេក៏មិនចងពៀរ គេមិនឈ្នានីសដោយហេតុណាមួយដល់អ្នកនោះវិញដែរ, ទោះបីមាននរណាមកឈ្នានីសដល់អ្នកដែលឥតទោសដូច្នោះ អ្នកដែលឈ្នានីសគេនោះក៏នឹងវិនាសខ្លួនឯងវិញមិនខាន, ដូចរឿងព្រានដែលពោលមកហើយខាងដើម ។

## ហេតុដែលជាគ្រឿងតពៀរ និងរម្ងាប់ពៀរ

ព្រះសម្មាសម្ពុទ្ធជាម្ចាស់បានត្រាស់សម្ដែង ហេតុជាគ្រឿងតនៃពៀរ និងហេតុជាគ្រឿងស្ងប់រម្ងាប់នៃពៀរ ថា ៖

**ន ហិ វេរេនវេរានិ សម្មន្តីធ កុទាចនំ**
**អវេរេន ច សម្មន្តិ ឯស ធម្មោ សនន្តនោ ។**

សេចក្ដីថា ៖ **ក្នុងកាលណា ៗ ក៏ដោយ ធម្មតាពៀរទាំងឡាយក្នុងលោកសន្និវាសនេះ មិនដែលស្ងប់រម្ងាប់ដោយការចងពៀរឡើយ; ដោយពិត ពៀរទាំងឡាយតែងស្ងប់រម្ងាប់ដោយការមិនចងពៀរ, ធម៌នេះ ជាធម៌ចាស់មានយូរណាស់មកហើយ ។**

អធិប្បាយចំពោះតែបទដែលទាក់ទងគ្នា ដោយរឿងខន្តីសេចក្ដីអត់ធន់ម្យ៉ាង ដូចតទៅនេះ ៖

បណ្ដាបទទាំងឡាយ ត្រង់បទថា **អវេរេន ច សម្មន្តិ** ដូច្នេះ មានសេចក្ដីថា **ពៀរដែលនឹងស្ងប់រម្ងាប់ ឈប់ចងគ្នាទៅវិញទៅមកនោះ** លុះតែមានទឹកចិត្តយ៉ាងត្រជាក់វិសេសគឺ **ខន្តី** ( សេចក្ដីអត់ធន់ ) **មេត្តា** ( សេចក្ដីស្រឡាញ់ ) ឬមានយោនិសោមនសិការ និងបច្ចវេក្ខណញ្ញាណ គឺយកចិត្តទុកដាក់ដោយយោបល់ ពិចារណាឲ្យឃើញទោសនៃសេចក្ដីក្រោធខឹង និងគុណានិសង្សនៃសេចក្ដីអត់ធន់ ទើបពៀរនោះស្ងប់រម្ងាប់ទៅបាន; មានឧបមាដូចទីកន្លែងណាមួយ ដែលប្រឡាក់ដោយរបស់មិនស្អាតមានទឹកមាត់ជាដើម លុះតែគេយកទឹកដែលថ្លាទៅដុសលាង ទើបជ្រះស្អាត មានក្លិនល្អដូចដើមទៅវិញបាន ។

# គុណានិសង្សនៃខន្តីយ៉ាងអស្ចារ្យ

អ្នកប្រាជ្ញដ៏មានប្រាជ្ញា គួរឃើញគុណានិសង្សរបស់ខន្តីយ៉ាងអស្ចារ្យ ដូច **ទីឃាវុកុមារ** ដែលបានសោយរាជ្យជាមហាក្សត្រិយ៍ក្នុងនគរពីរ ក៏ព្រោះអានិសង្សរបស់ខន្តីនេះឯង ។ សូមនាំរឿងនោះមកសម្តែងជាឧទាហរណ៍ដូចតទៅនេះ ៖

# រឿង ទីឃាវុកុមារ

កាលព្រះបាទព្រហ្មទត្ត គ្រងរាជសម្បត្តិនៅក្រុងពារាណសី ដែនកាសី, ព្រះបាទទីឃីតិគ្រងរាជសម្បត្តិក្នុងក្រុងសាវត្ថី ដែនកោសល ។ គ្រានោះ ព្រះបាទព្រហ្មទត្តលើកពលទៅវាយក្រុងសាវត្ថីបាន ។ ព្រះបាទទីឃីតិនាំព្រះអគ្គមហេសីទៅនៅអាស្រ័យនឹងស្មូនឆ្នាំងម្នាក់ក្នុងប្រទេស ១ ជាទីបំផុតដែន ។ ចំណេរមកខាងក្រោយ ព្រះអគ្គមហេសីមានព្រះរាជបុត្រ សន្មតព្រះនាមថា " **ទីឃាវុកុមារ** " ។ វេលាមួយ ព្រះបាទព្រហ្មទត្តចាប់ព្រះបាទទីឃីតិបាន ក៏ឲ្យពេជ្ឈឃាតនាំទៅសម្លាប់, គេកំពុងបណ្តើរទៅ ទីឃាវុមកទាន់ ។ ព្រះបាទទីឃីតិទ្រង់ប្រដៅព្រះរាជបុត្រថា ៖ " នែ៎ទីឃាវុ ! អ្នកកុំឃើញកាលវែងពេក ខ្លីពេក ធម្មតាពៀរមិនដែលរម្ងាប់ដោយពៀរទេ ពៀរតែងរម្ងាប់ដោយការមិនចងពៀរ " ទ្រង់ផ្តាំស្រេចពេជ្ឈឃាតក៏សម្លាប់ទៅ ។

ថ្ងៃក្រោយ ទីឃាវុបានចូលថ្វាយខ្លួនជាខ្ញុំរាជការយ៉ាងជិតដិតនឹងព្រះបាទព្រហ្មទត្ត ។ សម័យ ១ ព្រះបាទព្រហ្មទត្តទ្រង់ស្តេចទៅប្រពាតព្រៃ ឲ្យទីឃាវុធ្វើជានាយសារថីបររាជរថ ។ ទីឃាវុបានឱកាស ក៏ប្រឹងបររាជរថបង្ហួសទៅមុនពួកពលសេនា ដោយប្រាថ្នានឹងសម្លាប់ព្រះបាទព្រហ្មទត្តនោះ ។ វេលានោះ ព្រះបាទព្រហ្មទត្តទ្រង់ផ្ទំកើយភ្លៅទីឃាវុ ដោយសេចក្ដីនឿយព្រួយព្រះកាយពល កំពុងតែផ្ទំស្កុល់, ទីឃាវុចាប់ព្រះខាន់លើកឡើងប្រាថ្នានឹងសម្លាប់ តែនឹកភ្នកដល់បណ្ដាំព្រះបិតាក៏ឈប់ទៅវិញ, គ្រាន់តែស្រែកសន្ធាប់ឲ្យព្រះបាទព្រហ្មទត្តជ្រាបថាជាបុត្រព្រះបាទទីឃីតិប៉ុណ្ណោះ ។ គ្រានោះ ក្សត្រិយ៍ទាំង ២ ព្រះអង្គទ្រង់បានឲ្យជីវិតដល់គ្នានិងគ្នា ហើយទ្រង់ស្តេចត្រឡប់ទៅព្រះនគរ ។ ព្រះបាទព្រហ្មទត្តបង្វែរក្រុងសាវត្ថីប្រទានមកទីឃាវុវិញ ព្រមទាំងប្រទានព្រះរាជធីតាឲ្យជាអគ្គមហេសី ។ លុះតមកខាងក្រោយ ព្រះបាទទីឃាវុបានគ្រងរាជ្យជាធំក្នុងដែនទាំង ២ គឺដែនកាសី និងដែនកោសល ។

**ខន្តី** សេចក្ដីអត់ធន់ មានគុណានិសង្សជាអស្ចារ្យក្រៃពេកដូចយ៉ាងទីឃាវុកុមារដែលបានសោយរាជ្យជាធំក្នុងដែនទាំង ២ នោះ ក៏មិនមកពីអ្វីឡើយ មកតែពីខន្តីសេចក្ដីអត់ធន់ប៉ុណ្ណោះ, បើប្រសិនជាទីឃាវុចងពៀរតបនឹងព្រះបាទព្រហ្មទត្តវិញ; ពៀរនោះធ្វើម្ដេចឡើយនឹងស្ងប់រម្ងាប់ទៅបាន មុខជាមានអ្នកដទៃដែលខ្ញុំរាជការរបស់ព្រះបាទព្រហ្មទត្ត គេនឹងសម្លាប់ព្រះអង្គវិញ

មិនលែង ។ ព្រោះហេតុនេះបានជា ព្រះសម្មាសម្ពុទ្ធជាម្ចាស់ត្រាស់ទេសនាថា ៖ “ **ពៀរមិនដែលស្ងប់រម្ងាប់ដោយពៀរឡើយ, ពៀរដែលនឹងស្ងប់រម្ងាប់បាន តែដោយការមិនចងពៀរ** ” ។

ព្រោះហេតុដូច្នោះ សាធុជនអ្នកប្រាថ្នាសេចក្ដីសុខ សេចក្ដីចម្រើនក្នុងលោក និងលោកខាងមុខ គប្បីមានខន្តីគ្រប់វេលាកុំបោះបង់ចោលខន្តីឡើយ ។

**ពាក្យ**ដែលប្រដៅឲ្យមានខន្តីសេចក្ដីអត់ធន់ ដូចពោលមកហើយនេះ រាប់ថាជា **ពុទ្ធសាសនា** ពាក្យប្រដៅរបស់ព្រះពុទ្ធទាំងឡាយ គឺព្រះពុទ្ធរាល់ព្រះអង្គដែលបានត្រាស់ក្នុងកាលទាំងពួង តែងទ្រង់ប្រដៅដូច្នេះ ។

# ចប់កណ្ឌទី ៤



# ឱវាទបាតិមោក្ខ កណ្ឌទី ៥

**លំដាប់នេះ** នឹងអធិប្បាយសេចក្ដីនៃព្រះបរមពុទ្ធោវាទក្នុងឱវាទបាតិមោក្ខ ត្រង់បទថា ៖

**និព្វានំ បរមំ វទន្តិ ពុទ្ធា**
**ព្រះពុទ្ធទាំងឡាយតែងសម្ដែងថា ព្រះនិព្វានជាធម៌ដ៏ឧត្តម**

នោះ, ឲ្យមានសេចក្ដីពិស្ដារដើម្បីជាគ្រឿងប្រដាប់សតិបញ្ញា និងជាវត្តប្រតិបត្តិរបស់សាធុជនពុទ្ធបរិស័ទ ដូចតទៅនេះ ៖

លោកអ្នកប្រាជ្ញទាំងឡាយ ហៅថា **ពុទ្ធៈ** ។ ពុទ្ធៈនេះមានច្រើនប្រភេទ, ន័យខ្លះចែកជា ២, ន័យខ្លះចែកជា ៣, ន័យខ្លះចែកជា ៤ ។

១. តាមន័យដែលចែកជា ២ ចំពូកនោះ គឺព្រះសព្វញ្ញុពុទ្ធលោកអ្នកត្រាស់ដឹងនូវញេយ្យធម៌ទាំងពួងឥតចន្លោះ ចំពោះព្រះអង្គ ហើយសម្ដែងប្រដៅអ្នកដទៃឲ្យត្រាស់ដឹងតាមបាន ១, ព្រះបច្ចេកពុទ្ធ លោកអ្នកត្រាស់ដឹងចំពោះព្រះអង្គដែរ តែសម្ដែងប្រដៅអ្នកដទៃឲ្យត្រាស់ដឹងតាមធម៌មិនបាន ១ ។

២. តាមន័យដែលចែកជា ៣ ចំពូកនោះ គឺព្រះសព្វញ្ញុពុទ្ធ ១, ព្រះបច្ចេកពុទ្ធ ១, ព្រះអនុពុទ្ធ លោកអ្នកត្រាស់ដឹងតាមព្រះសព្វញ្ញុពុទ្ធ ១ ។

៣. តាមន័យដែលចែកជា ៤ ចំពូកនោះ គឺព្រះសព្វញ្ញុ - ពុទ្ធ ១, ព្រះបច្ចេកពុទ្ធ ១, ព្រះសុតពុទ្ធ លោកអ្នកចេះដឹងដោយការរៀនសូត្រតាមធម៌របស់ព្រះសព្វញ្ញុពុទ្ធ ១, ព្រះសាវ័ក - ពុទ្ធ លោកអ្នកចេះដឹងដោយការស្តាប់ធម៌របស់ព្រះសព្វញ្ញុពុទ្ធដោយគោរព ដែលហៅថា សាវ័ករបស់ព្រះពុទ្ធនោះ ១ ។

ព្រះពុទ្ធមានច្រើនចំពូកដូចពោលមកនេះ, បើសម្តែងដោយបរិយាយ កំណត់យកតែត្រង់លោកអ្នកចេះដឹងធម៌វិន័យរបស់ព្រះសព្វញ្ញុពុទ្ធទាំងប៉ុន្មាន បានឈ្មោះថា **ព្រះពុទ្ធ** ទាំងអស់ ។

ព្រះពុទ្ធទាំងនោះ រមែងពោលសរសើរព្រះនិព្វានថាជាធម៌ដ៏ឧត្តម មិនត្មះតិះដៀលព្រះនិព្វានឡើយ ។

## អធិប្បាយពាក្យថា និព្វាន

ដូចម្តេចហៅថា **និព្វាន** ?

**សេចក្តីរំលត់ភ្លើងកិលេស និងភ្លើងទុក្ខ យ៉ាងស្និទ្ធឥតកម្រើកបានទៀត លោកហៅថា និព្វាន ។**

## អធិប្បាយអំពីភ្លើងកិលេស

ដូចម្តេចហៅថា **ភ្លើងកិលេស** ?

- **រាគៈ** **( សេចក្តីត្រេកត្រអាលក្នុងកាមគុណ )** ;

- **ទោសៈ ( សេចក្ដីប្រទូស្ដដល់សត្វនិងសង្ខារ )** ;
- **មោហៈ ( សេចក្ដីវង្វេង មិនដឹងតាមពិតរបស់សង្ខារ )** ។

អកុសលធម៌ ៣ យ៉ាងនេះ ជាដើមលោកហៅថា **ភ្លើងកិលេស**, ព្រោះជារបស់ដុតសត្វឲ្យក្ដៅដូចភ្លើង; កិលេសនេះកាលបើកើតឡើងក្នុងសន្ដាននៃសត្វឯណាហើយ ក៏ធ្វើសត្វនោះឲ្យក្ដៅក្រហល់ក្រហាយរសាប់រសល់នៅមិនសុខឡើយ ។ ពពួកសត្វក្នុងលោក លើកទុកតែព្រះពុទ្ធជាម្ចាស់ និងព្រះអរហន្តសាវ័កចេញ, ក្រៅពីនោះសូម្បីគ្រាន់តែដឹងថា **រាគៈ**, **ទោសៈ**, **មោហៈ** ជាភ្លើងប៉ុណ្ណោះ ក៏ចាត់ជាគ្រាន់បើ, តែមិនដូច្នោះឡើយ មានតែសម្គាល់ខុសថាជារបស់ស្រួលល្អវិសេសវិញ; ដូចសត្វមមាចដែលមិនស្គាល់ភ្លើងប្រទីបឃើញរស្មីប្រទីបក៏នាំគ្នាហើរចូលទៅឥតញញើត, ភ្លើងប្រទីបក៏ដុតឲ្យដល់សេចក្ដីស្លាប់ក៏មាន ឲ្យឆេះខ្លោចស្លាបខ្លោចកន្ទុយជាដើមក៏មាន ។

ហេតុនេះបានជា ព្រះដ៏មានបុណ្យជាម្ចាស់ត្រាស់ទេសនាថា កិលេស ៣ ពួកនេះជាភ្លើង ដោយពុទ្ធភាសិតថា ៖

**១. រាគគ្គិ ទហតិ មច្ចេ រត្តេ កាមេសុ មុច្ឆិតេ**

**ភ្លើងគឺ រាគៈ តែងដុតសត្វទាំងឡាយដែលជាអ្នកត្រេកអរជ្រុលជ្រប់ទៅក្នុងកាម ;**

**២. ទោសគ្គិ បន ព្យាបន្នេ នរេ បាណាតិបាតិនោ**

**ភ្លើងគឺ ទោសៈ តែងដុតនរជនទាំងឡាយដែលជាអ្នកព្យា-បាទ សម្លាប់សត្វ ;**

**៣. មោហគ្គិ សម្មូឡ្ហេ អរិយធម្មេ អកោវិទេ**

**ភ្លើងគឺ មោហៈ តែងដុតសត្វដែលជាអ្នកវង្វេងមិនឈ្លាសវៃក្នុងធម៌របស់ព្រះអរិយៈ ។**

ទ្រង់សម្ដែងដូច្នេះហើយ ទើបទ្រង់សម្ដែងធម៌សម្រាប់លត់ភ្លើង ៣ យ៉ាងនោះ គឺ ៖

**១. ភ្លើងគឺរាគៈ** ទ្រង់ត្រាស់បង្គាប់ឲ្យលត់ដោយអសុភ-សញ្ញា គឺចម្រើនចិត្ត ឲ្យសម្គាល់ថាមិនស្អាតមិនល្អ ;

**២. ភ្លើងគឺទោសៈ** ទ្រង់ត្រាស់បង្គាប់ឲ្យលត់ដោយមេត្តាភាវនា គឺការចម្រើនចិត្តឲ្យកើតមេត្រីទៅក្នុងពពួកសត្វទាំងអស់ ;

**៣. ភ្លើងគឺមោហៈ** ទ្រង់ត្រាស់បង្គាប់ឲ្យលត់ដោយបញ្ញា ;

# អធិប្បាយអំពីភ្លើងទុក្ខ

ដូចម្ដេចហៅថា **ភ្លើងទុក្ខ** ?

**ជាតិ, ជរា, មរណៈ** ( សេចក្ដីកើត, ចាស់, ស្លាប់ ) ជាដើម លោកហៅថា **ភ្លើងគឺកងទុក្ខ** ព្រោះដុតសត្វឲ្យក្ដៅដូចភ្លើងអត់ទ្រាំបានដោយលំបាក ។ ឯជាតិ ( សេចក្ដីកើត ) ដែលហៅថា ភ្លើងទុក្ខនោះ ពិចារណាក្រឃើញជាងមរណៈ ( សេចក្ដីស្លាប់ ) ព្រោះពពួកសត្វមានមនុស្សជាដើម វេលាដែលកើតឡើងរមែង

ត្រេកអរ ដល់វេលានឹងស្លាប់ទៅវិញរមែងតូចចិត្ត, តែជាតិនោះជាប្រធាន គឺជាដើមចមនាំឲ្យកើតទុក្ខទាំងពួង, បើមិនកើតឡើងទុក្ខទាំងពួងក៏មិនមាន ។ ព្រោះហេតុដូច្នេះបានជាបណ្ឌិតដែលមានសេចក្តីរន្ធត់នឹងទុក្ខទាំងពួង លោកត្រឡប់ជាខ្លាចកើតវិញមិនខ្លាចស្លាប់ឡើយ ។ ក្នុងទីដែលនឹងពិចារណាដល់ជាតិទុក្ខជាដើមនុ៎ះ គួរឃើញដល់កំណើតរបស់គព្ភសេយ្យកសត្វ គឺមនុស្សដែលដេកនៅក្នុងគភ៌ ថាជាភ័យដ៏ធំពន្លឹកគួរស្ញើមគួរខ្លាច, សេចក្តីវិកលវិការនៃរាងកាយ មានធ្មេញបាក់ សក់ស្កូវថ្ពាល់ផត មាត់គ្រហុប ខ្នងកោង ស្បែកជ្រួញជ្រីវយុរយារជាដើម ជារបស់ដែលយើងរាល់គ្នាមិនចង់បាន មិនមានត្រូវចិត្តសោះ តែគង់ជួបប្រទះ គេចមិនរួចឡើយ ។ សេចក្តីស្លាប់ក៏ជារបស់ដែលយើងឥតចង់បានបន្តិចបន្តួចទេ តែនឹងកន្លងឲ្យហួសទៅមិនបាន ។

ឯសេចក្តីកើត ចាស់ ស្លាប់នេះ បានជាឈ្មោះថាទុក្ខពីព្រោះពិបាកអត់ ពិបាកទ្រាំ ។ អធិប្បាយថា រាងកាយរបស់មនុស្សក្នុងលោក រកបិតបេរគ្មាន កើតឡើងមិនយូរប៉ុន្មានក៏ចាស់គ្រាំគ្រា បែកធ្លាយទៅ ដោយជម្ងឺតម្កាត់មានប្រការផ្សេង ៗ មុនដែលនឹងបែកធ្លាយស្លាប់ទៅនោះ រមែងកើតទុក្ខវេទនាក្រៃពេក រកអ្វីប្រៀបពុំបាន ។

**រាគៈ ទោសៈ មោហៈ ជាភ្លើងកិលេស, ជាតិ ជរា មរណៈ ជាភ្លើងទុក្ខ** ដូចពោលមកនេះ ។

# ព្រះនិព្វានពីរយ៉ាង

ធម៌វិសេសម្យ៉ាង ដែលអាចលត់ភ្លើងកិលេសនិងភ្លើងទុក្ខបាន លោកហៅថា " **និព្វាន** " ។ ព្រះនិព្វាននោះលោកសម្តែងថាមាន ២ យ៉ាង តាមពុទ្ធភាសិតថា ៖

**ទ្វេ ភិក្ខវេ និព្វានធាតុយោ**
**ម្នាលភិក្ខុទាំងឡាយ ! និព្វានធាតុមាន ២ យ៉ាងគឺ ៖**
**សឧបាទិសេសនិព្វាន ១, អនុបាទិសេសនិព្វាន ១ ។**

អធិប្បាយថា កិលេសទាំងឡាយរលត់អស់មិនមានសេសសល់ នៅសល់តែខន្ធដែលជាចំណែកបរិសុទ្ធហៅថា " **សឧបា-ទិសេសនិព្វាន** " កិលេសព្រមទាំងកងទុក្ខរលត់អស់មិនមានសេសសល់ សូម្បីតែខន្ធដែលជាចំណែកបរិសុទ្ធនោះក៏រលត់អស់ ហៅថា " **អនុបាទិសេសនិព្វាន** " ។ និព្វានស័ព្ទនេះប្រែបានច្រើនយ៉ាង តែក្នុងទីនេះ សូមប្រែតែត្រឹម ៣ យ៉ាង គឺ ៖

១. ប្រែថា " **មិនមាន** " **គឺមិនមានតណ្ហា** ;
២. ប្រែថា " **អស់ទៅ** " **គឺអស់កិលេស** ;
៣. ប្រែថា " **រលត់មិនសល់** " **គឺរលត់កិលេសនិងកងទុក្ខ ។**

ដែលប្រែថា " **មិនមាន និង អស់ទៅ** " សំដៅយកសឧបាទិ-សេសនិព្វានតែម្យ៉ាង ។ ដែលប្រែថា " **រលត់មិនសល់** " សំដៅយកទាំងសឧបាទិសេសនិព្វាន ទាំងអនុបាទិសេសនិព្វាន ។

# គុណនៃព្រះនិព្វាន

ព្រះពុទ្ធទាំងឡាយតែងសរសើរគុណព្រះនិព្វានថា៖ **រាគក្ខយោ អស់ទៅនៃរាគៈ**, **ទោសក្ខយោ អស់ទៅនៃទោសៈ**, **មោហក្ខយោ អស់ទៅនៃមោហៈ** ដូច្នេះ ក៏មាន; ថា **អជាតំ មិនកើត**, **អជរា មិនចាស់**, **អព្យាធិ មិនឈឺ**, **អមតំ មិនស្លាប់** ដូច្នេះ ក៏មាន, ថា **មទនិម្មទនោ ញាំញីនូវសេចក្ដីស្រវឹង**, **បិបាសវិនយោ បន្ទោបង់នូវសេចក្ដីស្រេកឃ្លានក្នុងបញ្ចកាមគុណ**, **អាលយសមុគ្ឃាតោ រំលើងបង់នូវសេចក្ដីអាល័យក្នុងបញ្ចកាមគុណ**, **វដ្ដុបច្ឆេទោ កាត់ផ្ដាច់នូវដំណើរវិលវល់ក្នុងភពទាំង ៣**, **តណ្ហាក្ខយោ អស់ទៅនៃតណ្ហា**, **វិរាគោ ប្រាសចាកតម្រេក**, **និរោធោ រំលត់បង់នូវតណ្ហា** ដូច្នេះក៏មាន, ថា ជា **អសង្ខតធម៌ ឥតបច្ច័យតាក់តែង** ដូច្នេះក៏មាន, ថា **បរមំ សុញ្ញំ សូន្យក្រៃពេក**, ( ពាក្យថា សូន្យ ៗ ប្រែថា " ទទេ " ដូចពាក្យថា " សុញ្ញាគារផ្ទះទទេ " ដែលមិនមានមនុស្សនៅអាស្រ័យ, ព្រះនិព្វានក៏ទទេចាកសត្វបុគ្គល ) ដូច្នេះក៏មាន, ថា **បរមំ សុខំ សុខយ៉ាងឆ្នើម**, បណ្ដាសេចក្ដីសុខផ្សេង ៗ ដែលសត្វបានជួបប្រទះក្នុងលោកសន្និវាសនេះ ជាសាមិសសុខ គឺនៅលាយដោយទុក្ខ មិនបានជាសុខតែម្យ៉ាងទេ; ចំណែកខាងសុខក្នុងព្រះនិព្វានជាឯកន្តសុខ គឺមានតែសេចក្ដីសុខម្យ៉ាង ឬជានិរាមិសសុខ សុខប្រាសចាកអាមិស មិនលាយដោយទុក្ខ

បន្តិចបន្តួចឡើយ ទើបឈ្មោះថា **បរមសុខ ជាសុខយ៉ាងប្រសើរ** ដូច្នេះ ក៏មាន ។

ព្រះពុទ្ធទាំងឡាយ តែងសរសើរព្រះនិព្វានដោយប្រការផ្សេង ៗ ដូចសម្ដែងមកនេះ ជាដើម ។

ម្យ៉ាងទៀត ពាក្យប្រដៅក្នុងផ្លូវព្រះនិព្វាននោះមានចំពោះតែក្នុងសាសនារបស់ព្រះពុទ្ធជាម្ចាស់នៃយើងទាំងឡាយ ម្យ៉ាងប៉ុណ្ណោះ មិនមានក្នុងសាសនារបស់គ្រូដទៃឡើយ, គ្រូឯទៀត ៗ គេប្រដៅយ៉ាងខ្ពស់បំផុតត្រឹមឋានសួគ៌ និងព្រហ្មលោក ។ បើនិយាយតាមពិត ព្រះនិព្វានមាននៅជាធម្មតា តែមិនមែនជាវិស័យរបស់បុគ្គលជាពាហិរសាស្ដាដឹងបាន, ព្រោះព្រះនិព្វានធម៌នេះ **គម្ភីរោ ជាធម៌គម្ពីរភាពជ្រាលជ្រៅពេក ទុទ្ទសោ ឃើញបានដោយកម្រ ទុរានុពោធោ ដឹងបានដោយកម្រ សន្តោ ស្ងប់រម្ងាប់ បណីតោ ឧត្តម អតក្កាវចរោ គិតគ្នាន់គ្នេរយកឯងមិនបាន និបុណោ ល្អិត បណ្ឌិតវេទនីយោ គឺបណ្ឌិតគួរដឹងច្បាស់** ។ ព្រោះហេតុដូច្នោះ កាលដែលព្រះដ៏មានបុណ្យជាម្ចាស់ទើបនឹងបានត្រាស់ថ្មី ៗ ព្រះអង្គធុញទ្រាន់ក្នុងព្រះហឫទ័យ មិនសូវចង់សំដែងធម៌ប្រៀនប្រដៅសត្វក្នុងផ្លូវព្រះនិព្វានឡើយ, តែដោយសារព្រះករុណាគុណមកបណ្ដាលដឹកនាំព្រះហឫទ័យនៃព្រះអង្គ ទើបទ្រង់ទេសនា ។

# អប្បមាទធម៌ជាផ្លូវព្រះនិព្វាន

កាលបើសំដែងសរសើរគុណព្រះនិព្វាន គួរតែសំដែងអំពីផ្លូវទៅកាន់ព្រះនិព្វានផង ។ ក៏ព្រះពុទ្ធដីកាដែលទ្រង់ប្រដៅក្នុងផ្លូវព្រះនិព្វាននោះមានច្រើនន័យ តាមនិស្ស័យរបស់សត្វ, តែបើនឹងលើកយកកំពូលធម៌ដ៏សំខាន់ឡើងសំដែង ក៏ស្រេចនៅលើសេចក្តីមិនប្រមាទ, ព្រោះព្រះសក្យមុនីបរមគ្រូទ្រង់សំដែងថា ៖

**អប្បមាទោ អមតំ បទំ**

**សេចក្តីមិនប្រមាទ ជាផ្លូវទៅកាន់ព្រះនិព្វាន ។**

ឯសេចក្តីមិនប្រមាទ ដែលថាជាផ្លូវនៃព្រះនិព្វាននោះបើសំដែងតម្រូវនឹងព្រះអរិយមគ្គ ក៏បានខាងការមិនប្រមាទក្នុងព្រះអរិយមគ្គទាំង ៨ គឺ ៖

១. មិនប្រមាទក្នុងការលះមិច្ឆាទិដ្ឋិ, ធ្វើសម្មាទិដ្ឋិឲ្យកើតមានឡើង ;

២. មិនប្រមាទក្នុងការលះមិច្ឆាសង្កប្ប, ធ្វើសម្មាសង្កប្បឲ្យកើតឲ្យមានឡើង ;

៣. មិនប្រមាទក្នុងការលះមិច្ឆាវាចា, ធ្វើសម្មាវាចាឲ្យកើតឲ្យមានឡើង ;

៤. មិនប្រមាទក្នុងការលះមិច្ឆាកម្មន្ត, ធ្វើសម្មាកម្មន្តឲ្យកើតឲ្យមានឡើង ;

៥. មិនប្រមាទក្នុងការលះមិច្ឆាអាជីវ, ធ្វើសម្មាអាជីវឲ្យកើតឲ្យមានឡើង ;

៦. មិនប្រមាទក្នុងការលះមិច្ឆាវាយាម, ធ្វើសម្មាវាយាមឲ្យកើតឲ្យមានឡើង ;

៧. មិនប្រមាទក្នុងការលះមិច្ឆាសតិ, ធ្វើសម្មាសតិឲ្យកើតឲ្យមានឡើង ;

៨. មិនប្រមាទក្នុងការលះមិច្ឆាសមាធិ, ធ្វើសម្មាសមាធិឲ្យកើតឲ្យមានឡើង ។

ឯមគ្គទាំង ៨ នេះ ដែលនឹងបរិបូណ៌បាន ក៏ព្រោះអាស្រ័យសេចក្ដីមិនប្រមាទក្នុងការលះ និងការចម្រើន ដូចសំដែងមកនេះ ។

# អរិយមគ្គជាឯកសមង្គី

មគ្គទាំង ៨ នេះ បើជាឯកសមង្គី រួមចូលជាមួយគ្នាហើយ ក៏ធ្វើបុគ្គលដែលប្រតិបត្តិនោះ ឲ្យចុះក្នុងប្រឡាយនៃព្រះនិព្វាន មាននាមតាមពុទ្ធសាសនវោហារ ហៅថា " **សោតា** រហូតដល់ **អរហត្ត** " ដូចព្រះអញ្ញាកោណ្ឌញ្ញត្ថេរ ដែលបានស្ដាប់ព្រះធម្មចក្កប្បវត្តនសូត្របឋមទេសនា កើតធម្មចក្ខុគឺភ្នែកឃើញធម៌ថា ៖

**យំកិញ្ចិ សមុទយធម្មំ សព្វន្តំ និរោធធម្មំ**

**របស់អ្វី ៗ ដែលមានកិរិយាកើតឡើងជាធម្មតា,**
**របស់ទាំងអស់នោះ ក៏មានកិរិយារលត់ទៅវិញជាធម្មតា ។**

ទាំងនេះក៏ព្រោះតែមគ្គទាំង ៨ ប្រការ ជាឯកសមង្គី ។ អធិប្បាយថា ការឃើញដូច្នោះ ឈ្មោះថា ឃើញត្រូវ ជាតួសម្មាទិដ្ឋិ, តម្រិះដូច្នោះឈ្មោះថា តម្រិះត្រូវ ជាតួសម្មាសង្កប្ប, និយាយឲ្យគេស្តាប់ដូច្នោះ ឈ្មោះថា និយាយត្រូវ ជាតួសម្មា-វាចា, ការងាររបស់ចិត្តដូច្នោះ ឈ្មោះថា ការងារត្រូវ ជាតួសម្មាកម្មន្ត, រស់នៅដោយការពិចារណាដឹងដូច្នោះ ឈ្មោះថា រស់នៅដោយប្រពៃ ជាតួសម្មាអាជីវ, ព្យាយាមដូច្នោះ ឈ្មោះថា ព្យាយាមត្រូវ ជាតួសម្មាវាយាម, រឭកដូច្នោះ ឈ្មោះថា រឭកត្រូវ ជាតួសម្មាសតិ, តម្កល់ចិត្តទុកដូច្នោះ ឈ្មោះថា តម្កល់ចិត្តទុកត្រូវ ជាតួសម្មាសមាធិ ។ សំដែងមកនេះ ដើម្បីបញ្ជាក់ឲ្យឃើញច្បាស់ថា កាលបើមគ្គទាំង ៨ រួមចូលព្រមព្រៀងគ្នាជាឯកសមង្គីហើយ តែងមានបញ្ញាចក្ខុពិចារណាឃើញថា ៖

**យំកិញ្ចិ សមុទយធម្មំ សព្វន្តំ និរោធធម្មំ**
**របស់អ្វី ៗ ដែលមានកិរិយាកើតឡើងជាធម្មតា,**
**របស់ទាំងអស់នោះ ក៏មានកិរិយារលត់ទៅវិញជាធម្មតា ។**

ដូច្នេះ ឈ្មោះថាបានដើរតាមដំណើរព្រះអរិយមគ្គទាំង ៨ បរិបូណ៌មិនខ្វះខាត និងបានឈ្មោះថាបានត្រេចតាមគន្លងពោធិ-បក្ខិយធម៌ទាំង ៣៧ ប្រការដោយបរិបូណ៌ ។

# សង្គ្រោះអដ្ឋង្គិកមគ្គក្នុងត្រៃសិក្ខា

មគ្គទាំង ៨ ប្រការនេះ លោកសង្គ្រោះចូលជាត្រៃសិក្ខាគឺ ៖

**១. សម្មាទិដ្ឋិ** សេចក្ដីឃើញត្រូវ, **សម្មាសង្កប្ប** សេចក្ដីត្រិះរិះត្រូវ, សង្គ្រោះជាបញ្ញាសិក្ខា ; ព្រោះជាគុណជាតិធ្វើបុគ្គលអ្នកសិក្សាឲ្យកើតប្រាជ្ញា សេចក្ដីដឹងច្បាស់របស់ពិត របស់មែន ;

**២. សម្មាវាចា** សំដីត្រូវ, **សម្មាកម្មន្ត** ការងារត្រូវ, **សម្មាអាជីវ** ចិញ្ចឹមជីវិតត្រូវ, សង្គ្រោះជាសីលសិក្ខា ; ព្រោះជាគុណជាតិធ្វើបុគ្គលអ្នកសិក្សាឲ្យមានសីល គឺរក្សាកាយ វាចារាបសារ ;

**៣. សម្មាវាយាម** សេចក្ដីព្យាយាមត្រូវ, **សម្មាសតិ** សេចក្ដីរឭកត្រូវ, **សម្មាសមាធិ** សេចក្ដីតម្កល់ចិត្តទុកក្នុងអារម្មណ៍ដ៏ត្រូវ, សង្គ្រោះជាចិត្តសិក្ខា ; ព្រោះជាគុណជាតិធ្វើបុគ្គលអ្នកសិក្សាឲ្យមានចិត្តស្ងប់រម្ងាប់ ។

កាលបើសង្គ្រោះយ៉ាងនេះ ក៏ឆ្លុះសេចក្ដីឲ្យឃើញច្បាស់ថាមគ្គប្រកបដោយអង្គ ៨ មានសេចក្ដីរួមចូលគ្នាជាត្រៃសិក្ខាដោយប្រការដូច្នេះ ។

អរិយមគ្គប្រកបដោយអង្គ ៨ នេះហើយ ដែលជាផ្លូវដ៏ប្រសើរអាចធ្វើដំណើរនៃយោគាវចរកុលបុត្រអ្នកប្រាថ្នា នឹងទៅកាន់ព្រះនិព្វាន ឲ្យបានសម្រេចដូចបំណង ។

**ពាក្យ**ដែលពោលសរសើរព្រះនិព្វានថា ជាធម៌ដ៏ឧត្តមដូចពោលមកហើយនេះ រាប់ថាជា **ពុទ្ធសាសនា** ពាក្យប្រដៅរបស់ព្រះពុទ្ធទាំងឡាយ គឺព្រះពុទ្ធរាល់ព្រះអង្គដែលបានត្រាស់ក្នុងកាលទាំងពួង តែងទ្រង់ប្រដៅដូច្នេះ ។

# ចប់កណ្ឌទី ៥



# ឱវាទបាតិមោក្ខ កណ្ឌទី ៦

**វេលានេះ** នឹងអធិប្បាយសេចក្តីនៃព្រះបរមពុទ្ធោវាទក្នុងឱវាទបាតិមោក្ខ ត្រង់បទថា ៖

**ន ហិ បព្វជិតោ បរូបឃាតី សមណោ**
**ហោតិ បរំ វិហេឋយន្តោ**
**បុគ្គលដែលសម្លាប់សត្វដទៃ មិនឈ្មោះថាបព្វជិត,**
**បុគ្គលដែលបៀតបៀនសត្វដទៃ មិនឈ្មោះថាសមណៈ**

នោះ, ឲ្យមានសេចក្តីពិស្តារ ដើម្បីជាគ្រឿងប្រដាប់សតិបញ្ញា និងជាវត្តប្រតិបត្តិរបស់សាធុសប្បុរសពុទ្ធបរិស័ទ ដូចតទៅនេះ ៖

បុគ្គលដែលប្តេជ្ញាខ្លួនថាជា **បព្វជិត** ឬ **សមណៈ** នោះ លុះតែមានអធិវាសនក្ខន្តី អត់ធន់ មិនប្រទូស្តអ្នកដទៃឲ្យគេវិនាសចាកជីវិត ចាកទ្រព្យសម្បត្តិ ឬមិនបៀតបៀនគេឲ្យបានសេចក្តីលំបាក, ទើបសមតាមឈ្មោះដូច្នោះ; បើនៅតែសម្លាប់ ឬបៀតបៀនអ្នកដទៃ មិនហៅថា **បព្វជិត** ឬ **សមណៈ** ទេ ។

## អធិប្បាយពាក្យថាបព្វជិត

បុគ្គលដែលសម្លាប់ឬបៀតបៀនគេតាមអំពើចិត្ត ដែលឥត

អធិវាសនក្ខន្តី នោះ ដោយហោចទៅ សូម្បីតែសម្លាប់សត្វតូច ៗ មានល្បោមនិងមូសជាដើម ឲ្យវិនាសចាកជីវិត ក៏ហៅថា **បព្វជិត** មិនកើត ។

ព្រោះហេតុអ្វីបានជាពោលដូច្នោះ ?

ព្រោះហេតុមិនទាន់បណ្តេញបំបរមន្ទិលនៅឡើយ, លុះតែជាអ្នកបណ្តេញបំបរមន្ទិលចោលចេញ ទើបហៅថា **បព្វជិត** បាន, ដូចមានពុទ្ធភាសិតថា ៖

**បព្វាជយមត្តនោ មលំ តស្មា បព្វជិតោតិ វុច្ចតិ**

សេចក្តីថា **អ្នកដែលបណ្តេញបំបរនូវមន្ទិលរបស់ខ្លួនឲ្យឃ្លាតចេញបាន ទើបតថាគតហៅថា បព្វជិត ដោយហេតុដែលគេបណ្តេញបំបរនូវមន្ទិលនោះឯង ។ ការដែលបណ្តេញនូវមន្ទិលជាលក្ខណៈគ្រឿងសម្គាល់របស់បព្វជិត ។**

អ្វីហៅថា មន្ទិល ?

**កិលេសដែលធ្វើចិត្តឲ្យសៅហ្មង** ដូចវត្ថុពណ៌ខ្មៅ មានធ្យូងជាដើម ដែលធ្វើរបស់ស្អាតឲ្យប្រឡាក់ខូចទៅ លោកហៅថា " **មន្ទិល** " ។

## មន្ទិលមាន ៩ ប្រការ

**១. កោធ** សេចក្តីក្រោធខឹង ;

**២. មក្ខ** សេចក្តីលុបគុណគេ ;

៣. **ឥស្សា** សេចក្ដីច្រណែន ;
៤. **មច្ឆរិយ** សេចក្ដីកំណាញ់ ;
៥. **មាយា** លាក់ពុតកំហូច ;
៦. **សាថេយ្យ** សេចក្ដីអួតអាង ;
៧. **មុសា** សេចក្ដីកុហក ;
៨. **បាបិច្ឆ** សេចក្ដីប្រាថ្នាលាមក ;
៩. **មិច្ឆាទិដ្ឋិ** សេចក្ដីយល់ឆ្វេងអំពីការពិត ។

បណ្ដាអកុសលទាំង ៩ នេះ, កាលបើអកុសលណាមួយកើតឡើងហើយ ក៏ធ្វើចិត្តឲ្យកករល្អក់មិនជ្រះថ្លា ; ហេតុដូច្នោះបានជាលោកហៅថា " **មន្ទិល** " ; អ្នកដែលកំចាត់បង់មន្ទិលក្នុងខ្លួនឲ្យអស់ទៅបាន ទើបគួរហៅថា **បព្វជិត** មែន; ទោះបីកំចាត់បង់មិនទាន់បានទាំងអស់ តែតាំងចិត្តប្រុងនឹងកំចាត់បង់ឲ្យអស់តទៅ ក៏គួរហៅថា **បព្វជិត** បានដែរ ។ ឯបុគ្គលដែលសម្លាប់សត្វដទៃ ឬបៀតបៀនសត្វដទៃ ក៏ព្រោះតែមន្ទិលទាំងនេះជ្រកសម្ងំនៅក្នុងសន្ដានទាំងអស់ ។

ន័យមួយទៀត បព្វជិត ប្រែថា " **អ្នកវៀរ** " គឺវៀរចាកទោសដែលព្រះសម្មាសម្ពុទ្ធជាម្ចាស់ទ្រង់ឃាត់មិនឲ្យធ្វើ តាំងអំពីវៀរចាក មេថុនធម្ម, អទិន្នាទាន, មនុស្សវិគ្គហៈ និងឧត្តរិ-មនុស្សធម្ម ជាដើមទៅ, ព្រោះអំពើ ៤ យ៉ាងនេះ ជាហេតុនាំឲ្យប្រទូស្ត និងបៀតបៀនអ្នកដទៃ ។ បុគ្គលចំពូកខ្លះ អាស្រ័យ

មេថុនធម្មជាហេតុ ក៏ប្រទូស្តនិងបៀតបៀនគ្នា ដរាបដល់ចាក់កាប់សម្លាប់គ្នាជាទីបំផុតក៏មាន ; បុគ្គលចំពូកខ្លះ ចង់បានទ្រព្យរបស់គេ ក៏ប្រទូស្តនិងបៀតបៀនម្ចាស់ទ្រព្យ ដរាបដល់ចងបាច់គ្នាជាពួក ហើយសម្លាប់ម្ចាស់ទ្រព្យយកទ្រព្យគេក៏មាន ; បុគ្គលចំពូកខ្លះ មានចេតនាលាមកអាក្រក់ចង់បានលាភសក្ការៈ និងសេចក្តីគោរពរាប់អានអំពីអ្នកដទៃ ក៏និយាយបញ្ឆោតគេដោយឧត្តរិមនុស្សធម្មក៏មាន ; អំពើអម្បាលនេះជាដើម ហៅថាប្រទូស្តថាបៀតបៀនអ្នកដទៃ, ជាអករណីយកិច្ចដែលព្រះភគវន្តមុនីបរមគ្រូជាម្ចាស់ទ្រង់ហាមប្រាមអ្នកបួសក្នុងព្រះពុទ្ធសាសនាមិនឲ្យធ្វើជាដាច់ខាត ។ ហេតុនោះ បុគ្គលដែលឋិតនៅក្នុងភេទជាបព្វជិត គួរតែវៀរចាកទោសដែលទ្រង់បញ្ញត្ត ខំប្រតិបត្តិតាមគុណដែលទ្រង់អនុញ្ញាត, បើមិនវៀរចាកទោសដែលទ្រង់បញ្ញត្តដូចសំដែងមកនេះទេ នឹងហៅថា **បព្វជិត** ដូចម្តេចបាន ។

## អធិប្បាយពាក្យថាសមណៈ

បុគ្គលដែលឥតអធិវាសនក្ខន្តិ ទោះបីមិនបានសម្លាប់អ្នកដទៃឲ្យវិនាសចាកជីវិតទេ, គ្រាន់តែបៀតបៀនដោយបហរណវត្ថុមាន ដំបងព្រនង់ជាដើម ឲ្យគេបានសេចក្តីលំបាក ក៏មិនហៅថា **សមណៈ** ដែរ ។

ព្រោះហេតុអ្វីបានជាពោលដូច្នោះ ?

ព្រោះហេតុមិនទាន់រម្ងាប់ចាកសេចក្តីបៀតបៀននៅឡើយ , លុះតែជាអ្នកប្រព្រឹត្តស្ងប់រម្ងាប់ចាកសេចក្តីបៀតបៀន ទើបហៅថា **សមណៈ** បាន, ដូចមានពុទ្ធភាសិតថា ៖

**សមិតត្តា ហិ បាបានំ សមណោតិ វុច្ចតិ**

សេចក្តីថា **អ្នកដែលរម្ងាប់នូវបាបទាំងឡាយឲ្យស្ងប់ទៅបាន ទើបតថាគតហៅថា សមណៈ ដោយហេតុដែលគេជាអ្នកស្ងប់រម្ងាប់នោះឯង ។ ការដែលរម្ងាប់នូវបាប ជាលក្ខណៈគ្រឿងសំគាល់របស់ សមណៈ ។**

ន័យមួយទៀត ដែលហៅថា **សមណៈ** នោះ មិនហៅត្រឹមតែភេទជាគ្រឿងចំណាំឡើយ គឺហៅតាមលក្ខណៈដូចពោលមកនេះឯង, ដ្បិតមានពុទ្ធភាសិតថា ៖

**ន មុណ្ឌកេន សមណោ អព្វតោ អលិកំ ភណំ**
**ឥច្ឆាលោភសមាបន្នោ សមណោ កឹ ភវិស្សតិ**
**យោ ច សមេតិ បាបានិ អណុំថូលានិ សព្វសោ**
**សមិតត្តា ហិ បាបានំ សមណោតិ វុច្ចតិ ។**

សេចក្តីថា **បុគ្គលមិនមែនបានឈ្មោះថា សមណៈ ព្រោះតែកោរសក់ប៉ុណ្ណោះទេ អ្នកដែលឥតវត្តប្រតិបត្តិ និយាយពាក្យឡេះឡោះ មិនត្រូវតាមធម៌វិន័យ ជាអ្នកសម្បូណ៌ដោយសេចក្តីប្រាថ្នា សេចក្តីលោភ នឹងឈ្មោះថា សមណៈ ដូចម្តេចបាន, ចំណែកខាងជនដែល ជាអ្នករម្ងាប់នូវបាបទាំងតូចទាំងធំបានដោយ**

សព្វគ្រប់ ទើបតថាគតហៅថា **សមណៈ** ព្រោះតែគេរម្ងាប់នូវបាបទាំងឡាយនោះឯង ។

## ធម៌ធ្វើបុគ្គលឲ្យជាសមណៈ

ព្រះសម្មាសម្ពុទ្ធជាម្ចាស់ ទ្រង់ត្រាស់ទេសនាអំពីឈ្មោះថា **សមណៈ** និងធម៌របស់សមណៈថា ៖

**សមណា សមណាតិ វោ ភិក្ខវេ ជនោ សញ្ជានាតិ**

ម្នាលភិក្ខុទាំងឡាយ ! មហាជនតែងស្គាល់ឈ្មោះអ្នកទាំង-ឡាយថាជាសមណៈ, ចំណែកឯអ្នកទាំងឡាយសោត កាលបើមានគេសួរថា " លោកជាអ្វី ? " អ្នកទាំងឡាយក៏មុខជាប្ដេជ្ញាខ្លួនថា " យើងទាំងឡាយជាសមណៈ " ដូច្នេះដែរ, កាលបើអ្នកទាំងឡាយមានឈ្មោះយ៉ាងនេះនិងប្ដេជ្ញាខ្លួនដូច្នេះហើយ ត្រូវដឹងខ្លួនថា,

**យេ ធម្មា សមណករណា ព្រាហ្មណករណា**

ធម៌ទាំងឡាយឯណាដែលធ្វើឲ្យជាសមណៈផង ដែលធ្វើជាព្រាហ្មណ៍ផង យើងទាំងឡាយនឹងសមាទាន នូវធម៌អម្បាលនោះ, ប្រព្រឹត្តយ៉ាងនេះ ទើបឈ្មោះថាសមនឹងសេចក្ដីប្ដេជ្ញារបស់យើងទាំងឡាយដោយពិត ដូចពាក្យគេហៅមែន ។ ម្យ៉ាងទៀត យើងទាំងឡាយបានបរិភោគចីវរ បិណ្ឌបាត សេនាសនៈ គិលានប្បច្ច័យភេសជ្ជបរិក្ខារ របស់ទាយកទាំងឡាយឯណា, អំពើ

**បុណ្យកុសលរបស់ទាយកអម្បាលនោះ មុខជាមានផលធំ មានអានិសង្សធំ ព្រោះអាស្រ័យយើងទាំងឡាយមិនខានឡើយ ។ មួយវិញទៀត ផ្នួសរបស់យើងទាំងឡាយ នឹងមិនជាអារឥតផលទេ, ជាផ្នួសមានផលមានកម្រៃដោយពិត ; ម្នាលភិក្ខុទាំង-ឡាយ ! អ្នកទាំងឡាយត្រូវដឹងខ្លួនយ៉ាងនេះរាល់ ៗ គ្នាចុះ កុំភ្លេចឡើយ ។**

កាលបើទ្រង់ត្រាស់ដូច្នេះហើយ ទើបទ្រង់សំដែងអំពីធម៌ដែលធ្វើឲ្យជាសមណៈតទៅ, ទ្រង់លើកហិរិឱត្តប្បៈ ឡើងជាប្រធាននៃធម៌ទាំងពួង ហើយទ្រង់សំដែងថា បរិសុទ្ធកាយសមាចារ, បរិសុទ្ធវចីសមាចារ, បរិសុទ្ធមនោសមាចារ, បរិសុទ្ធអាជីវៈ ឥន្ទ្រិយសំវរៈ, ភោជនមត្តញ្ញូ, ជាគរិយានុយោគ, សតិសម្បជញ្ញៈ, ការអាស្រ័យនៅក្នុងទីសេនាសនៈដ៏ស្ងាត់, ការជម្រះចិត្តឲ្យប្រាសចាកនីវរណធម៌ហើយតម្កល់ឲ្យខ្ជាប់ជាសមាធិ, ធ្វើបញ្ញាដែលឃើញច្បាស់ក្នុងចតុរារិយសច្ចឲ្យកើតឡើង ។ ធម៌អម្បាលនេះឯង ជាធម៌របស់សមណៈ ។

**ហិរិ** នោះ បានខាង **សេចក្តីខ្មាស** ចំពោះបាបទុច្ចរិតផ្សេង ៗ ។

**ឱត្តប្បៈ** នោះ បានខាង **សេចក្តីខ្លាច** ចំពោះបាបទុច្ចរិតផ្សេង ៗ ។

ធម៌ ២ ប្រការ គឺ **ហិរិ** និង **ឱត្តប្បៈ** នេះ ជាធម៌សំខាន់

បំផុតរបស់សមណៈ, បើមិនមានធម៌ ២ ប្រការនេះទេ មិនគួរហៅថាសមណៈឡើយ, កាលបើមានធម៌ ២ ប្រការនេះ ទើបជាដើមចមនាំឲ្យបានសម្រេចគុណវិសេសដទៃ ៗ ជាលំដាប់ទៅ ។

- **បរិសុទ្ធកាយសមាចារ** នោះ បានខាងកាយសុចរិតទាំង ៣ ;
- **បរិសុទ្ធវចីសមាចារ** នោះ បានខាងវចីសុចរិតទាំង ៤ ;
- **បរិសុទ្ធមនោសមាចារ** នោះ បានខាងមនោសុចរិតទាំង ៣ ;
- **បរិសុទ្ធអាជីវៈ** នោះ បានខាងការចិញ្ចឹមជីវិតដោយផ្លូវបរិសុទ្ធ វៀរចាកមិច្ឆាជីវៈផ្សេង ៗ មានកុលទូសកៈ អនេសនៈ[១] ជាដើម ;
- **ឥន្ទ្រិយសំវរៈ** នោះ បានខាងការសង្រួមចិត្តមិនឲ្យអភិជ្ឈាទោសមនស្សចូលមកគ្របសង្កត់ក្នុងវេលាដែលឃើញរូបជាដើម ;
- **ភោជនមត្តញ្ញូ** នោះ បានខាងការដឹងប្រមាណ គឺចេះលៃលកបរិភោគភោជនាហារតែយ៉ាងល្មម ពិចារណា ដោយឧបាយ ប្រាជ្ញាឲ្យឃើញអំណាចប្រយោជន៍ហើយ ទើបបរិភោគ ;

---

(១) អនេសនៈ ការស្វែងរកពុំត្រូវតាមធម៌ឬពុំត្រូវតាមបែបបទ : កុំចិញ្ចឹមជីវិតដោយអនេសនៈ ។ ការចិញ្ចឹមជីវិតដោយដំណើរស្វែងរកចតុប្បច្ច័យ មិនត្រូវតាមធម៌វិន័យ ។

- **ជាគរិយានុយោគ** នោះ បានខាងការប្រកបតាមក្នុងសភាពជាបុគ្គលភ្ញាក់រឭក មិនល្មោភដេកច្រើនពេក ;
- **សតិសម្បជញ្ញៈ** នោះ បានខាងសេចក្ដីរឭក និងសេចក្ដីដឹងខ្លួន ។
- ការអាស្រ័យនៅក្នុងទីសេនាសនៈដ៏ស្ងាត់នោះ បានខាងការអាស្រ័យនៅក្នុងព្រៃឬទៀបគល់ឈើ និងផ្ទះទំនេរដែលជាទំនងឲ្យកើតកាយវិវេក ។
- ការជម្រះចិត្តឲ្យប្រាសចាកនីវរណធម៌ ហើយតម្កល់ចិត្តឲ្យខ្ជាប់ជាសមាធិនោះ បានខាងការដែលធ្វើចិត្តឲ្យតាំងនៅខ្ជាប់ជាចិត្តវិវេក ។

ធ្វើបញ្ញាដែលឃើញច្បាស់ក្នុងចតុរារិយសច្ច ឲ្យកើតឡើងនោះ បានខាងការដែលធ្វើសេចក្ដីដឹង សេចក្ដីឃើញក្នុង **ទុក្ខសច្ច, សមុទយសច្ច, និរោធសច្ច, មគ្គសច្ច** ឲ្យកើតឡើង ។

ធម៌អម្បាលនេះជាធម៌របស់សមណៈ, អ្នកដែលប្ដេជ្ញាខ្លួនថាជាសមណៈ ត្រូវមានធម៌ទាំងនេះ, បើខ្សត់ធម៌របស់សមណៈហើយ មុខជានឹងប្រទូស្តឬបៀតបៀនអ្នកដទៃមិនខាន ។ ព្រះដ៏មានព្រះភាគទ្រង់ត្រាស់ទេសនាអំពីបុគ្គលដែលជាសមណៈនិងធម៌ដែលធ្វើបុគ្គលឲ្យជាសមណៈ ដោយប្រការដូច្នេះ ។

# ឧបាយឲ្យកើតធម៌របស់បព្វជិត ឬសមណៈ

អ្នកដែលបានប្តេជ្ញាខ្លួនថាជាបព្វជិត ឬសមណៈ គួរតាំងចិត្តថា ៖ " **អាត្មាអញជាបព្វជិត ជាសមណៈហើយ ត្រូវតែទ្រទ្រង់គុណធម៌ឲ្យល្អសមគួរតាមភេទបព្វជិតនិងសមណៈទើបគួរ** " ឬពិចារណាតាមន័យដែលព្រះសម្មាសម្ពុទ្ធទ្រង់ដាស់តឿនឲ្យពិចារណាថា ៖ " **ឥឡូវនេះ អាត្មាអញមានភេទផ្សេងអំពីគ្រហស្ថហើយ, អាការមារយាទណា ៗ ដែលជារបស់សមណៈ អាត្មាអញត្រូវធ្វើអាការមារយាទនោះ ៗ** " ដូច្នេះជាដើមទៅ, មិនគួរប្រព្រឹត្តឲ្យល្មើសខុសប្លែកអំពីធម៌របស់បព្វជិត និងសមណៈឡើយ ; គួរនាដូចឈ្មួញដែលធ្វើការជំនួញ ចង់បានចំណេញ បើធ្វើត្រូវទំនងទើបបានកម្រៃច្រើន, បើធ្វើខុស ក៏ខាតទុន ; ព្រោះហេតុនេះបានជា ព្រះសម្មាសម្ពុទ្ធជាម្ចាស់ទ្រង់ត្រាស់ទេសនាធម៌ដែលជាគ្រឿងសង្កត់ចិត្តរបស់បព្វជិត ដោយពុទ្ធភាសិតថា ៖

**កុសោយថា ទុគ្គហិតោ ហត្ថមេវានុកន្តតិ**
**សាមញ្ញំ ទុប្បរាមដ្ឋំ និរយាយុបកឌ្ឍតិ ។**
**យំកិញ្ចិ សិថិលំ កម្មំ សំកិលិដ្ឋញ្ច យំ វតំ**
**សង្កស្សរំ ព្រហ្មចរិយំ ន តំ ហោតិ មហប្ផលំ ។**
**កយិរា ចេ កយិរាថេនំ ទឡ្ហមេនំ បរក្កមេ**
**សិថិលោ ហិ បរិព្វាជោ ភិយ្យោ អាកិរតេ រជំ ។**

សេចក្តីថា ៖ **ធម្មតាស្បូវភ្លាំងដែលបុគ្គលចាប់កាន់មិនល្អ ទាញភើចកន្ត្រាក់មក តែងមុតដៃ មានឧបមាដូចម្តេចមិញ, ផ្នួស ដែលអ្នកបួសណាមួយកាន់មិនល្អ គឺប្រព្រឹត្តខុសច្បាប់របស់បព្វជិត រមែងប្រទាញអ្នកបួសនោះឲ្យចូលទៅក្នុងនរកដូច្នោះដែរ ; ការងារ ឯណាមួយដែលធូរថយក្តី វត្តគឺសេចក្តីប្រព្រឹត្តឯណានីមួយដែល សៅហ្មងក្តី ព្រហ្មចរិយឯណានីមួយដែលបុគ្គលរឰកដោយសេចក្តី រង្កៀសក្តី ទាំង ៣ យ៉ាងនោះជាការមិនមានផលច្រើនឡើយ ; បើបុគ្គលនឹងធ្វើកិច្ចអ្វី ៗ ដែលជាកិច្ចគួរធ្វើ ក៏គប្បីធ្វើកិច្ចនោះចុះ, តែត្រូវខំខ្នះខ្នែងធ្វើកិច្ចការនោះឲ្យមែនទែន កុំគ្រាន់តែថា ព្រោះ ធម៌ជាគ្រឿងវៀរដែលបុគ្គលប្រព្រឹត្តធូរថយ តែងរោយរាយនូវ ទោសដូចធូលី គឺត្រឡប់ជាទោសវិញ ។**

# ទោសរបស់បព្វជិតប្រព្រឹត្តមិនល្អ

បុគ្គលដែលស្លៀកពាក់សំពត់លឿង តែមិនសង្រួមតាមធម៌ របស់សមណៈ ក៏មិនរួចពីនរកឡើយ ; ដូចមានពុទ្ធភាសិតជា គ្រឿងទូន្មានចិត្តរបស់បព្វជិត ម្យ៉ាងទៀតថា ៖

**កាសាវកណ្ឋា ពហវោ បាបធម្មា អសញ្ញតា**
**បាបា បាបេហិ កម្មេហិ និរយំ តេ ឧបបជ្ជរេ ។**

សេចក្តីថា ៖ **មនុស្សទាំងឡាយជាច្រើននាក់ ដែលមាន**

**សំពត់កាសាវៈជាប់នឹងក គឺស្លៀកដណ្តប់សំពត់លឿង តែជាអ្នកមានធម៌លាមកអម្បាលនោះ តែងធ្លាក់ទៅកើតក្នុងនរកដោយអំពើលាមកទាំងឡាយដែលគេបានធ្វើហើយ ។**

ន័យមួយទៀត ៖ **អ្នកបួសដែលទ្រុស្តសីលហើយបរិភោគអាហាររបស់ទាយកដែលគេប្រគេនដោយសទ្ធានោះមិនស្រួលទេ, សូវបរិភោគដុំដែកដែលកំពុងក្តៅវិញ ស្រួលជាង ;**

ដូចមានពុទ្ធភាសិតជាគ្រឿង សង្កត់ចិត្តរបស់អ្នកបួសម្យ៉ាងទៀតថា ៖

**សេយ្យោ អយោគុឡោ ភុត្តោ តត្តោ អគ្គិសិខូបមោ**
**យញ្ចេ ភុញ្ជេយ្យ ទុស្សីលោ រដ្ឋបិណ្ឌំ អសញ្ញតោ ។**

សេចក្តីថា ៖ **បព្វជិតដែលទ្រុស្តសីល ជាអ្នកមិនសង្រួម ក៏បរិភោគដុំបាយរបស់ជនានុជនអ្នកនៅក្នុងដែន ( នោះ ) មិនមែនស្រួលទេ, សូវបរិភោគដុំដែកដែលក្តៅដូចរងើកភ្លើងវិញជាជាង ។**

ព្រះលោកុត្តមាចារ្យជាម្ចាស់ បានសម្តែងបង្ហាញទោសទុក្ខរបស់បុគ្គលជាបព្វជិតនិងសមណៈ មានន័យផ្សេង ៗ ដូចសំដែងមកនេះ ។

# យោបល់នាំឲ្យបព្វជិតប្រព្រឹត្តល្អ

បព្វជិតទាំងឡាយគួរជ្រាបថា ការដែលកើតមកជាមនុស្ស ក៏ក្រ, កើតមកជាមនុស្សហើយមិនវិកលវិការ ជាអ្នករួចចាក បព្វជ្ជាទោសក៏ក្រ, ការដែលរក្សាជីវិតឲ្យរស់នៅ រហូតទល់នឹង បានបព្វជាឧបសម្បទា ក៏ហៅសែនក្រ, បួសហើយនឹងចេះដឹង យល់ធម៌វិន័យថា នេះគួរ នេះមិនគួរ ក៏មិនមែនងាយទេ ; កាលបើបានផុតស្រឡះអំពីសេចក្តីក្រីក្រ ដូចពោលមកនេះ ហើយគួរតែពេញចិត្តថាជាលាភដ៏ប្រសើររបស់អាត្មា មិនគួរធុញ ទ្រាន់រអានឹងពុទ្ធោវាទឡើយ គួរត្រេកអរឲ្យណាស់ហើយខំរៀន សូត្រធម៌វិន័យក្នុងពុទ្ធសាសនាឲ្យមធ្យ័ត និងប្រតិបត្តិតាមឲ្យ ពេញកម្លាំងចុះ ទើបបព្វជ្ជាឧបសម្បទានោះ មានផលច្រើន ធ្វើឲ្យឆាប់ដល់ព្រះនិព្វាន; ទោះបីមិនសម្រេចក្នុងជាតិនេះ, សេចក្តីដែលប្រតិបត្តិល្អ ប្រតិបត្តិត្រូវនោះ ក៏នឹងតាមជាប់ជា និស្ស័យទៅក្នុងជាតិខាងមុខ ។ ម្យ៉ាងទៀត បព្វជិតឬសមណៈ ដែលចង់ សម្រេចព្រះនិព្វានឆាប់ត្រូវមានខន្តីអត់ទ្រាំឲ្យច្រើន, កុំលុះអំណាច កិលេសដ៏អាក្រក់គ្រោតគ្រាតដែលកើតឡើង ដរាបដល់ប្រទូស្តអ្នកដទៃ ឬបៀតបៀនអ្នកដទៃនោះឡើយ ; គួរមានខន្តីជាត្រីមុខ, បើមិនមានខន្តីទេ ចេះតែព្យាបាទឬ បៀតបៀនអ្នកដទៃ នោះព្រះបរមគ្រូជាម្ចាស់មិនត្រាស់ហៅថា " **បព្វជិត ឬសមណៈ សក្យបុត្រពុទ្ធជិនោរសឡើយ** " ។

**ពាក្យ**ដែលពន្យល់ឲ្យស្គាល់ធម៌របស់បព្វជិត និងសមណៈ ដូចពោលមកហើយនេះ រាប់ថាជា **ពុទ្ធសាសនា** ពាក្យប្រដៅរបស់ព្រះពុទ្ធទាំងឡាយ គឺព្រះពុទ្ធរាល់ព្រះអង្គដែលបានត្រាស់ក្នុងកាលទាំងពួងតែងទ្រង់ប្រដៅដូច្នេះ ។

# ចប់កណ្ឌទី ៦



# ឱវាទបាតិមោក្ខ កណ្ឌទី ៧

**លំដាប់នេះ** នឹងអធិប្បាយសេចក្ដីនៃព្រះបរមពុទ្ធោវាទ ក្នុងឱវាទបាតិមោក្ខ ត្រង់បទថា ៖

**អនូបវាទោ អនូបឃាតោ**
**ការមិនពោលតិះដៀល ( អ្នកដទៃ )**
**ការមិនបៀតបៀន ( អ្នកដទៃ )**

នោះ, ឲ្យមានសេចក្ដីពិស្ដារ ដើម្បីជាគ្រឿងប្រដាប់សតិបញ្ញា និងជាវត្តប្រតិបត្តិរបស់សាធុជនពុទ្ធបរិស័ទដូចតទៅនេះ ៖

ការមិនពោលតិះដៀលអ្នកដទៃ គឺការមិនពោលបន្ដុះបង្អាប់ បន្ទាបបន្ថោក បុគ្គលណាមួយ ដោយវាចារបស់ខ្លួន ឬមិនប្រើគេឲ្យពោល ហៅថា **អនូបវាទកម្ម**, ការមិនបៀតបៀនអ្នកដទៃ គឺការមិនធ្វើបុគ្គលណាមួយឲ្យបានសេចក្ដីលំបាកដោយកាយ ឬដោយចិត្ត ហៅថា **អនូបឃាតកម្ម** ; កម្មទាំង ២ នេះ ជា **អនវជ្ជកម្ម** មិនប្រកបដោយទោស ; មានគុណានិសង្ស ។ ការពោលតិះដៀលអ្នកដទៃ ហៅថា **ឧបវាទកម្ម**, ការបៀតបៀនអ្នកដទៃ ហៅថា **ឧបឃាតកម្ម** ; កម្មទាំង ២ នេះ ជា **សាវជ្ជកម្ម** ប្រកបដោយទោស ។

# អធិប្បាយឧបវាទកម្ម

ឧបវាទកម្មនេះ ព្រះសម្មាសម្ពុទ្ធជាបរមគ្រូទ្រង់ហាមប្រាមពុទ្ធបរិស័ទមិនឲ្យប្រព្រឹត្តធ្វើ ជាដាច់ខាត, ព្រោះជាកម្មមានទោសធ្ងន់ អាចឃាត់ផ្លូវសួគ៌និងព្រះនិព្វានដល់អ្នកដែលធ្វើក៏មាន ដូចអរិយូបវាទកម្ម ដែលជាសគ្គាវរណៈ ( ឃាត់សួគ៌ ) និងមគ្គាវរណៈ ( ឃាត់មគ្គផលព្រះនិព្វាន ) នោះឯង ។

កម្មដែលបុគ្គលមានចិត្តទុច្ចរិតចង់បង្ខូចប្រយោជន៍របស់ព្រះអរិយបុគ្គល [១] គឺព្រះពុទ្ធ ព្រះបច្ចេកពុទ្ធ ឬព្រះអរហន្តជាសាវ័ករបស់ព្រះពុទ្ធ ក៏ពោលត្មះតិះដៀល ឬជេរដោយអន្តិមវត្ថុ ឬដោយកិរិយាកំចាត់បង់នូវគុណ គឺបន្ទាប បន្ថោក ព្រះអរិយបុគ្គលទាំងនោះ ហៅថា **អរិយូបវាទកម្ម** ដោយហោចទៅសូម្បីតែពោលតិះដៀលគ្រហស្ថ ដែលបានសម្រេចសោតា ក៏ចាត់ជាអរិយូបវាទកម្មដែរ ។

ពោលថា " ជនទាំងនេះ មិនមានសមណធម៌ ឬថាជនទាំងនេះ មិនមែនជាសមណៈទេ " ដូច្នេះ ហៅថា ពោលតិះ

( ១ ). បុគ្គលជាអរិយៈ មាន ៤ ពួក គឺ ៖

១. អាចារអរិយៈ អ្នកប្រសើរដោយសេចក្ដីប្រព្រឹត្ត ;

២. លិង្គអរិយៈ អ្នកប្រសើរដោយភេទ ;

៣. ទស្សនអរិយៈ អ្នកប្រសើរដោយសេចក្ដីយល់ឃើញ ;

៤. បដិវេធអរិយៈ អ្នកប្រសើរដោយត្រាស់ដឹងមគ្គផល ។

ជៀលដោយអន្តិមវត្ថុ ។ ពោលថា " ជនទាំងនេះ មិនមានឈាន មិនមានវិមោក្ខ មិនមានមគ្គ មិនមានផល " ដូច្នេះ ហៅថា ពោលតិះដៀលដោយកិរិយាកំចាត់បង់នូវគុណ ។ ទោះបីព្រះអរិយបុគ្គលនោះ ដឹងក្តី មិនដឹងក្តី ក៏ហៅថា អរិយូបវាទកម្មដូចគ្នា, កម្មទាំងនោះ ជាកម្មដ៏ធ្ងន់ ឃាត់សួគ៌ផង ឃាត់មគ្គផលព្រះនិព្វានផង ។ ដើម្បីបញ្ជាក់សេចក្តីនេះឲ្យច្បាស់លាស់ សូមនាំរឿងព្រះថេរៈ និងភិក្ខុកម្លោះមកសំដែងជាឧទាហរណ៍ ដូចតទៅនេះ ៖

# រឿង ព្រះថេរៈ និងភិក្ខុកម្លោះ

បានឮមកថា មានព្រះថេរៈ ១ រូប និងភិក្ខុកម្លោះ ១ រូប ត្រេចទៅបិណ្ឌបាតក្នុងស្រុកមួយ ។ កាលលោកទាំងនោះទៅដល់ផ្ទះជាដំបូង បានបបរ ១ បោយ ។ ព្រះថេរៈកើតរោគខ្យល់មិនស្រួលក្នុងផ្ទៃ ក៏គិតថា ៖

- " ឱ ! បបរនេះ ជាទីសប្បាយដល់អាត្មាអញហើយ អញនឹងហុតបបរនេះទាន់នៅក្តៅ ដើម្បីឲ្យបាត់ឈឺពោះ " ។

កាលបើលោកគិតដូច្នោះ ក៏អង្គុយលើកំណាត់ឈើដែលមនុស្សទាំងឡាយគេនាំមកបម្រុងធ្វើធរណី ហើយហុតបបរនោះទៅ ។

ភិក្ខុកម្លោះឃើញដូច្នោះនឹកខ្ពើម ក៏ពោលពាក្យទ្រគោះថា ៖

- " ឱ ! តាចាស់នេះ ឃ្លានអាក្រក់ណាស់តើ, ធ្វើបែបនេះនាំឲ្យកើតអាស្រូវភាសដល់អញ " ។

លុះព្រះថេរៈ ត្រេចទៅក្នុងស្រុក ហើយវិលទៅដល់វត្តវិញ សួរភិក្ខុកម្លោះនោះថា ៖

- " អាវុសោ ! លោកបានតម្កល់នូវគុណវិសេសអ្វីក្នុងព្រះសាសនានេះដែរឬ ? " ។

ភិក្ខុកម្លោះប្រាប់ថា ៖

- " ព្រះករុណាលោកម្ចាស់ ខ្ញុំព្រះករុណាបានសម្រេចស្រោតាហើយ " ។

ព្រះថេរៈពោលថា ៖

- " អាវុសោ ! បើដូច្នោះលោកកុំធ្វើព្យាយាមដើម្បីរកមគ្គខាងលើទៀតឡើយ, មិនបានទេ ; ព្រោះលោកពោលត្មះតិះដៀលព្រះខីណាស្រពហើយ " ។

ភិក្ខុកម្លោះក៏សូមស្មាលាទោសនឹងព្រះថេរៈក្នុងខណៈនោះ ។ ដោយហេតុដែលសូមស្មាលាទោសនោះ ភិក្ខុនោះឯង ក៏នៅជាប្រក្រតី គឺនឹងព្យាយាមធ្វើមគ្គខាងលើតទៅទៀតក៏បាន មិនឃាត់សួគ៌ ឃាត់មគ្គឡើយ ។

# ការសូមស្មាលាទោសនឹងព្រះអរិយៈ

បើមានភិក្ខុដទៃណាមួយ ពោលតិះដៀលព្រះអរិយបុគ្គល, ភិក្ខុនោះ ត្រូវទៅសូមស្មាលាទោសនឹងលោក, បើខ្លួនចាស់ជាង

កុំបាច់សំពះ គ្រាន់តែនិយាយសូមស្មាលាទោសដោយពាក្យថា ៖ " ខ្ញុំបានពោលពាក្យដូច្នេះខ្លះ ដូច្នេះខ្លះ ចំពោះលោកដ៏មានអាយុ សូមលោកម្ចាស់អត់ទោសឲ្យខ្ញុំ " ។ បើខ្លួនខ្ចីជាង ត្រូវក្រាបបង្គំហើយអង្គុយច្រហោងប្រណម្យអញ្ជលី សូមស្មាលាទោសដោយពាក្យថា ៖ " ទានប្រោស ! ខ្ញុំព្រះករុណាបានពោលពាក្យដូច្នេះខ្លះ ដូច្នេះខ្លះ ចំពោះលោកម្ចាស់, សូមលោកម្ចាស់អត់ទោសឲ្យខ្ញុំព្រះករុណា " ។ បើប្រសិនជាលោកមិនអត់ទោសឲ្យ ឬក៏លោកនិមន្តបាត់ទៅ ត្រូវទៅសូមស្មាលាទោសក្នុងសំណាក់នៃភិក្ខុទាំងឡាយដែលនៅក្នុងវត្ត, បើខ្លួនចាស់ជាងលោកទាំងនោះ គ្រាន់តែឈរស្មាលាទោស ; បើខ្ចីជាង ត្រូវអង្គុយច្រហោងប្រណម្យអញ្ជលី ហើយសូមស្មាលាទោសដោយពាក្យថា ៖ " ទានប្រោស ! ខ្ញុំព្រះករុណាបានពោលពាក្យដូច្នេះខ្លះ ដូច្នេះខ្លះ ចំពោះលោកដ៏មានអាយុឈ្មោះនោះ, សូមលោកដ៏មានអាយុឈ្មោះនោះអត់ទោសឲ្យខ្ញុំព្រះករុណា " ។ បើលោកឈ្មោះនោះបរិនិព្វានទៅ ត្រូវទៅដល់គ្រែដែលជាទីបរិ - និព្វាន ដរាបដល់ទីដែលធ្វើឈាបនកិច្ចសពលោក ហើយសូមស្មាលាទោសនឹងលោកចុះ, បើបានធ្វើយ៉ាងនេះ ទើបរួចទោសមិនឃាត់សួគ៌ មិនឃាត់មគ្គផលព្រះនិព្វានទេ នៅជាប្រក្រតីដូចដែលវិញ ។

ទោសនៃឧបវាទកម្ម ការពោលតិះដៀលនេះ បើភិក្ខុណាមួយបានជាជ្រុលធ្វើទៅហើយ លុះមានសេចក្តីភិតភ័យជាខាង

ក្រោយ ត្រឡប់សូមស្មាលាទោសនឹងព្រះអរិយៈ ដែលខ្លួនតិះដៀលនោះវិញ ទើបរួចចាកទោសបាន មិនឃាត់សួគ៌ និងមគ្គផលព្រះនិព្វានឡើយ ។ បើពោលតិះដៀលហើយ មិនត្រឡប់សូមស្មាលាទោសវិញទេ, កម្មនោះ ក៏ឃាត់ទាំងសួគ៌ ទាំងមគ្គផលព្រះនិព្វាន ដូច **ជម្ពុកាជីវក** ។ សូមនាំរឿងនោះមកសំដែងជាឧទាហរណ៍ ដូចតទៅនេះ ៖

# រឿង ជម្ពុកាជីវក

នាកាលកន្លងទៅហើយ ក្នុងសាសនាព្រះសម្មាសម្ពុទ្ធទ្រង់ព្រះនាមកស្សប មានកុដុម្ពីម្នាក់ធ្វើវត្ត ១ ប្រគេនភិក្ខុជាថេរៈ ១ រូប ហើយផ្គត់ផ្គង់ចតុប្បច្ច័យ ។ លុះចំណេរមកខាងក្រោយ មានភិក្ខុ ១ រូបជាព្រះខីណាស្រព ត្រេចទៅបិណ្ឌបាតទៀបទ្វារផ្ទះនៃកុដុម្ពីនោះ កុដុម្ពីបានឃើញកើតសេចក្ដីជ្រះថ្លា ក៏ប្រគេនចង្ហាន់, ប្រគេនសំពត់សាដក, ជូលជាងមកកោរសក់ប្រគេន, ប្រគេនគ្រែសំណឹង ហើយនិមន្តលោកឲ្យគង់នៅក្នុងវត្តនោះ ។ ឯលោកចៅអធិការវត្ត កាលបើបានឃើញគេរៀបសក្ការៈដូច្នោះ មិនសប្បាយចិត្ត, ដើរចូលទៅដល់ទីសំណឹងរបស់ព្រះថេរៈនោះ ក៏ពោលតិះដៀល ជេរប្រទេចដោយពាក្យជេរ ៤ យ៉ាងដូច្នេះថា ៖

១. នែ៎ ! អាវុសោអាគន្តុកៈ ប្រសើ្ដងមិនគួរឆាន់ចង្ហាន់ក្នុងផ្ទះទេ, ស៊ីលាមកវិញជាជាង ;

២. មិនគួរឲ្យកុដុម្ពីជួលជាងមកកោរសក់ឲ្យទេ, កោរសដោយផាងត្នោតវិញជាជាង ;

៣. មិនគួរឲ្យកុដុម្ពីប្រគេនសំពត់សាដកទេ, អាក្រាតវិញជាជាង ;

៤. មិនគួរដេកលើគ្រែដែលកុដុម្ពីនាំមកឲ្យនោះទេ, ដេកផ្ទាល់នឹងផែនដីវិញជាជាង ;

ថ្ងៃក្រោយមកទៀត កុដុម្ពីនិមន្តលោកទាំងអស់ទៅឆាន់ ។ ចៅអធិការមិននិមន្តព្រះថេរៈទៅទេ, វេលារៀបនឹងទៅគ្រាន់តែគោះរគាំងដោយខ្នងក្រចកបន្តិច ៗ ហើយក៏ទៅ ។ កាលបើកុដុម្ពីសួររក ប្រាប់ថា ៖

- " កុំមានប្រសាសន៍ឡើយ ភិក្ខុដែលជាជីតុនរបស់អ្នកនោះ ជាមនុស្សខ្ជិលច្រអូសណាស់ មិនល្អទេ, ចូលទៅដេកក្នុងបន្ទប់តាំងពីព្រលប់ទាល់ភ្លឺ ដល់មកពេលនេះ មិនទាន់ក្រោកទេ អាត្មាក្រោកឡើងពីព្រលឹមគោះរគាំងហៅ ក៏មិនដឹងខ្លួនសោះ " ។

ចំណែកកុដុម្ពីមិនជឿពាក្យនោះឡើយ ។ កាលបើភិក្ខុចៅអធិការនោះឆាន់ហើយ គេក៏យកបាត្រមកលាងឲ្យស្អាតល្អ រួចដាក់ចង្ហាន់ដ៏ថ្មោងថ្មីផ្ញើទៅប្រគេនព្រះថេរៈនោះ ។ លុះភិក្ខុចៅអធិការដើរដល់ពាក់កណ្ដាលផ្លូវ ក៏គិតថា ៖

- " បើភិក្ខុនោះបានឆាន់ចង្ហាន់យ៉ាងនេះហើយ មុខជានឹងក្រាញនៅក្នុងទីនេះឯង " ។

គិតហើយក៏ចាក់ចង្ហាន់នោះចោលទៅ ។ លុះទៅដល់វត្ត ស្រាប់តែរកព្រះថេរៈនោះមិនឃើញ ។

ព្រោះតែធ្វើកម្មអាក្រក់ប៉ុណ្ណោះ សូម្បីភិក្ខុជាចៅអធិការ នោះធ្វើសមណធម៌អស់ ២ ម៉ឺនឆ្នាំ ក៏ដោះខ្លួនមិនរួច ។ លុះ អស់អាយុហើយទៅកើតក្នុងអវីចិមហានរក សោយទុក្ខយ៉ាងខ្លាំង អស់ ១ ពុទ្ធន្តរ [១] ។ ដល់មកក្នុងពុទ្ធុប្បាទនេះទើបបានឡើង មកកើតក្នុងត្រកូល ១ ក្នុងក្រុងរាជគ្រឹះ ឈ្មោះ **ជម្ពុកៈ** អាក្រាត កាយតាំងពីតូចរហូតដល់ធំ មិនស្លៀកដណ្ដប់, មិនស៊ីអាហារ ស៊ីតែលាមក, ដេកលើផែនដី, វេលាសក់វែងក៏កោសដោយធាង ត្នោត ។ មាតាបិតានាំទៅឲ្យនៅក្នុងពួកអាជីវក គេហៅថា **ជម្ពុកាជីវក** លុះពួកអាជីវកគេដឹងថាស៊ីតែលាមកដូច្នោះគេក៏ បណ្ដេញចេញចាកពួកឲ្យទៅក្នុងព្រៃតែម្នាក់ឯង ។ អស់ពួក មហាជនដែលល្ងង់ ៗ សំគាល់ថាជាព្រះអរហន្តវិសេស ក៏តាក់ តែងអាហារភោជន មកសុំអង្វរឲ្យបរិភោគ, គាត់មិនបរិភោគ ឡើយ ; គ្រាន់តែយកចុងស្បូវចាក់ភោជននោះ ៗ ហើយលិទ្ធនឹង ចុងអណ្ដាត ។ លុះវេលាស្ងាត់ពីគេក៏ទៅស៊ីលាមកដែលគេ ចោលក្នុងព្រៃ, ប្រព្រឹត្តដូច្នេះ ពេញ ៥៥ ឆ្នាំ ។ ព្រះបរមគ្រូជា ម្ចាស់ទ្រង់ជ្រាបឧបនិស្ស័យនៃជម្ពុកាជីវកនោះ ក៏ទ្រង់ស្ដេចទៅ

---

( ១ ) កាលដែលជាចន្លោះព្រះពុទ្ធត្រាស់ ១ អង្គ ៗ ដូចជាព្រះពុទ្ធទ្រង់ព្រះនាមកស្សប និព្វានទៅ ដរាបដល់ព្រះពុទ្ធជាម្ចាស់យើងបានត្រាស់ឡើងជាដើម ហៅថា ១ ពុទ្ធន្តរ ។

ប្រោស ឲ្យបានសម្រេចព្រះអរហត្តព្រមទាំងបដិសម្ភិទាដោយផលដែលធ្លាប់ចម្រើនសមណធម៌មកពីដើម ។

ឧបវាទកម្ម ការតិះដៀលគេដោយវាចា រមែងមានទោសយ៉ាងធ្ងន់ ដូចពោលមកនេះ ។ ព្រោះហេតុដូច្នេះបានជាព្រះដ៏មានព្រះភាគបរមគ្រូជាម្ចាស់ ទ្រង់ប្រដៅពុទ្ធបរិស័ទមិនឲ្យធ្វើឡើយ ។

## អធិប្បាយអំពីឧបឃាតកម្ម

ការដែលបុគ្គលមានចិត្តក្រេវក្រោធ ហើយប្រទូស្តអ្នកដទៃដោយកាយមានទះតប់វាយដំច្រំធាក់ជាដើម មានសម្លាប់ជាទីបំផុត ឬមានគំនិតគិតបំផ្លាញអ្នកដទៃឲ្យវិនាស ហៅថា **ឧប-ឃាតកម្ម** ។ កម្មនេះ ព្រះដ៏មានព្រះភាគជាម្ចាស់ត្រាស់ហាមប្រាមពុទ្ធបរិស័ទមិនឲ្យធ្វើឡើយ ព្រោះជាកម្មមានទោសដ៏ធ្ងន់អាចឃាត់សួគ៌ឃាត់មគ្គផល ដូចព្រះបាទ **អជាតសត្តុ** ។ សូមនាំរឿងនោះមកសំដែងជាឧទាហរណ៍ ដូចតទៅនេះ ៖

## រឿង ព្រះបាទអជាតសត្តុ

ព្រះបាទអជាតសត្តុ ជាព្រះរាជឱរសព្រះបាទពិម្ពិសារ និងព្រះនាងវេទេហី ជាមហាក្សត្រិយ៍គ្រប់គ្រងនគររាជគ្រឹះដែន

មគធៈ ។ ព្រះមហាក្សត្រិយ៍អង្គនេះ បានជាទ្រង់ព្រះនាមថា " អជាតសត្តុ " ព្រោះជាសត្រូវនឹងព្រះបិតា តាំងអំពីនៅក្នុងគភ៌ព្រះមាតានៅឡើយ ។

ដូចបានឮមកថា កាលដែលទើបនឹងទ្រង់ព្រះសណ្ឋិតនៅក្នុងគភ៌ បណ្តាលឲ្យព្រះនាងវេទេហី ជាព្រះមាតាចង់សោយព្រះលោហិតក្នុងព្រះពាហា [១] នៃព្រះបាទពិម្ពិសារ ជាព្រះស្វាមី, ព្រះនាងទ្រង់ខ្លាចទ្រង់ខ្មាសអៀន មិនហ៊ានក្រាបបង្គំទូលព្រះភស្តាឲ្យទ្រង់ជ្រាបឡើយ ទ្រង់អត់ទ្រាំសម្រេកគម្លាននោះដរាបដល់ស្គាំងស្គមព្រះអង្គ ។ លុះព្រះបាទពិម្ពិសារទ្រង់សួររឿយ ៗ ព្រះនាងក៏ក្រាបបង្គំទូលតាមពិត ។ ព្រះរាជាទ្រង់ចាក់ព្រះពាហាដោយព្រះខ័ន យកព្រះលោហិតឲ្យព្រះនាងសោយ ទើបសេចក្តីប្រាថ្នានោះរម្ងាប់ទៅ ។ ព្រះរាជាទ្រង់សួរហេតុនោះដល់ពួកហោរា ៗ ក្រាបបង្គំទូលថា ព្រះរាជបុត្រដែលនៅក្នុងព្រះគភ៌នោះ នឹងជាសត្រូវដល់ព្រះអង្គ ក្នុងវេលាដែលប្រសូតហើយ ។ ព្រោះមានទំនាយដូច្នោះ បានជាមានព្រះនាមថា " អជាតសត្តុ " ប្រាកដតាំងពីថ្ងៃនោះមក ។ លុះព្រះរាជឱរសនោះប្រសូតហើយ ទ្រង់មានវ័យវឌ្ឍនាការឡើង, ដោយសេពគប់នឹងទេវទត្តជាបាបមិត្ត ក៏ពិឃាតព្រះបាទពិម្ពិសារជាព្រះបិតា ហើយគ្រប់គ្រងរាជគ្រឹះមហានគរ ។ ចាប់ដើមអំពីពិឃាតព្រះបិតា ជាព្រះ

(១) ដើមដៃ, ហៅតាមរាជស័ព្ទថា ព្រះពាហា គឺដើមព្រះហស្ត ។

អរិយសាវក និងជាអគ្គឧបដ្ឋាកនៃព្រះបរមសាស្ដា ដែលជាបិតុឃាតអានន្តរិយកម្មនោះមក ក៏ទ្រង់ក្ដៅក្រហាយក្នុងព្រះហឫទ័យក្រៃពេក ផ្ទំមិនលក់ធ្មេចព្រះនេត្រាមិនបាន ដូចជាមានបន្លាឬអាវុធចាក់នៅក្នុងព្រះនេត្រទាំងរយទាំងពាន់ ។ ក្នុងវេលាមួយ ជីវកកោមារភត្យនាំព្រះអង្គទៅនមស្ការព្រះសម្មាសម្ពុទ្ធជាម្ចាស់ បានទ្រង់ព្រះសវនាការសាមញ្ញផលសូត្រ ហើយក៏សូមខមាទោសនឹងព្រះរតនត្រ័យ ។ តាមឧបនិស្ស័យនៃព្រះរាជាគួរនឹងបានសម្រេចសោតាបត្តិផលក្នុងជាតិនោះ, តែដោយទោសដែលទ្រង់ធ្វើបិតុឃាតជាអនន្តរិយកម្ម ក៏ត្រឡប់ជាបានត្រឹមអត្តសន្និយាតនសរណគមន៍វិញ ។ ក្នុងកាលដែលព្រះសម្មាសម្ពុទ្ធទ្រង់បរិនិព្វានទៅថ្មី ៗ ព្រះរាជាអង្គនេះទ្រង់បានជួយឧបត្ថម្ភក្នុងការធ្វើបឋមសង្គាយនា ។ ដោយអំណាចគុណានិសង្សទាំងនោះ លុះព្រះអង្គទ្រង់ព្រះទិវង្គតទៅ មិនទៅកើតក្នុងអវីចិមហានរកអស់ ១ កប្បតាមទោសអានន្តរិយកម្មនោះឡើយ ទៅកើតក្នុងលោហកុម្ភីនរក សោយទុក្ខវេទនា តែ ៦ ហ្មឺនឆ្នាំ ។

ឧបឃាតកម្ម ការបៀតបៀនអ្នកដទៃ ដោយកាយ ឬដោយចិត្ត រមែងមានទោសធ្ងន់ ដូចពណ៌នាមកនេះ ។ ព្រោះហេតុដូច្នោះបានជា ព្រះដ៏មានបុណ្យជាបរមគ្រូទ្រង់ហាមប្រាមពុទ្ធបរិស័ទ មិនឲ្យធ្វើឡើយ ។

ន័យមួយទៀត បុគ្គលមានចិត្តក្រេវក្រោធហើយធ្វើឧប -

ឃាតកម្ម បៀតបៀនអ្នកដទៃ ដែលគេជាមនុស្សឥតប្រទូស្តតប ដល់ខ្លួន ជាមនុស្សឥតទោស សូម្បីគ្រាន់តែបៀតបៀនគេឲ្យលំបាកមិនដល់ស្លាប់ ក៏គង់មានទោសជាទម្ងន់ដែរ, បើបៀតបៀនពានទៅលើព្រះអរិយបុគ្គល ទោះបីបៀតបៀនហើយ មានសេចក្តីភិតភ័យជាខាងក្រោយ ត្រឡប់ស្មាលាទោសវិញ ក៏មិនរួចចាកទោសនោះឡើយ; ដូចជាងកែវដែលបៀតបៀនព្រះ **តិស្សត្ថេរ** ។ សូមនាំរឿងនោះ មកសំដែងជាឧទាហរណ៍ ដូចតទៅនេះ ៖

# រឿង ព្រះតិស្សត្ថេរ

កាលដែលព្រះសម្មាសម្ពុទ្ធគង់ព្រះជន្មនៅឡើយ មានព្រះថេរៈ ១ រូបឈ្មោះ **តិស្សៈ** តែងចូលទៅឆាន់ក្នុងត្រកូលនៃជាងកែវម្នាក់អស់ ១២ ឆ្នាំ ។ ជាងកែវព្រមទាំងភរិយាក៏ប្រតិបត្តិព្រះថេរៈដូចជាមាតាបិតាទំនុកបម្រុងបុត្រ ។ ថ្ងៃ ១ ព្រះបាទបសេនទិ-កោសល ទ្រង់ព្រះរាជទានកែវមណីឲ្យទៅជាងកែវនោះច្នៃ ។ កាលដែលរាជបុរសនាំកែវទៅឲ្យជាងកែវ ៗ នោះកំពុងអង្គុយហាន់សាច់ មានដៃប្រឡាក់ដោយឈាម ក៏ទទួលកែវទុកលើជ្រញ់ ហើយចូលទៅលាងដៃខាងក្នុង ។ ខណៈនោះ សត្វក្រៀលដែលជាងកែវចិញ្ចឹម ឃើញកែវស្មានថាជាដុំសាច់ ក៏ចឹកលេបទៅ ។ ជាងកែវត្រឡប់មកវិញរកកែវមិនឃើញ សង្ស័យ

នឹងព្រះថេរៈដែលគង់ក្បែរនោះ ក្រែងលួចយក, ក៏សួរលោក ៗ ប្រាប់ថា អាត្មាមិនយកទេ ជាងកែវយកខ្សែមកចងត្របែងសីសៈនៃព្រះថេរៈ ហើយវាយដោយដំបង ដរាបដល់លៀនភ្នែក ឈាមហូរសស្រាក់តាមច្រមុះ ។ ជាងកែវកំពុងតែក្រេវក្រោធមហិមា ក្រឡេកទៅឃើញក្រៀលនោះចូលមកហួរលោហិតក៏ទាត់ស្លាប់ទៅ ។

កាលដែលក្រៀលនោះនៅរស់ ទោះបីជាងកែវវាយសំពងយ៉ាងណា ក៏ព្រះថេរៈមិនប្រាប់ថា កែវនោះក្រៀលលេបទៅឡើយ ។ លុះក្រៀលនោះស្លាប់ហើយ ទើបព្រះថេរៈប្រាប់ថា កែវនោះក្រៀលចឹកលេបទៅ ។ ជាងកែវវះពោះក្រៀលនោះមើល ក៏ឃើញកែវនោះមែន ហើយមានសេចក្ដីតក់ស្លុតក្នុងចិត្ត សូមសា្មលាទោសនឹងលោក ។ តាំងពីថ្ងៃនោះមកព្រះថេរៈសមាទានធុតង្គជានិច្ច ឥតចូលក្នុងដំបូលផ្ទះឧបាសកណាមួយឡើយ, មិនយូរប៉ុន្មាន ព្រះថេរៈក៏និព្វានទៅ ។ ក្រៀលនោះស្លាប់ទៅ ៗ កើតក្នុងគភ៌នៃភរិយារបស់ជាងកែវ ។ ជាងកែវស្លាប់ទៅ ៗ កើតក្នុងនរក ។ ភរិយារបស់ជាងកែវស្លាប់ទៅ ៗ កើតក្នុងសួគ៌ទេវលោក ដោយមិនមានចិត្តទុច្ចរិតជាមួយនឹងស្វាមី ។

ឧបឃាតកម្ម ការបៀតបៀនអ្នកដទៃ រមែងមានទោសដូចពោលមកនេះ ។ ព្រោះហេតុដូច្នេះបានជា ព្រះបរមគ្រូជាម្ចាស់ ទ្រង់ហាមប្រាមជាដាច់ខាត មិនឲ្យពុទ្ធបរិស័ទធ្វើឡើយ ។

**ពាក្យ**ដែលហាមប្រាមមិនឲ្យធ្វើឧបវាទ និងឧបឃាត ដូចពោលមកហើយនេះ រាប់ថាជា **ពុទ្ធសាសនា** ពាក្យប្រដៅរបស់ព្រះពុទ្ធទាំងឡាយ គឺព្រះពុទ្ធជាម្ចាស់រាល់ព្រះអង្គដែលបានត្រាស់ក្នុងកាលទាំងពួង តែងទ្រង់ប្រដៅដូច្នេះ ។

# ចប់កណ្ឌទី ៧

# ឱវាទបាតិមោក្ខ កណ្ឌទី ៨

**លំដាប់នេះ** នឹងអធិប្បាយសេចក្តីនៃព្រះបរមពុទ្ធោវាទ ក្នុងឱវាទបាតិមោក្ខ ត្រង់បទថា ៖

**បាតិមោក្ខេ ច សំវរោ**
**ការសង្រួមក្នុងបាតិមោក្ខ**

នោះ, ឲ្យមានសេចក្តីពិស្តារ ដើម្បីជាគ្រឿងប្រដាប់ សតិបញ្ញា និងជាវត្តប្រតិបត្តិរបស់សាធុសប្បុរសពុទ្ធបរិស័ទ ដូចតទៅនេះ ៖

ធម៌ដែលជាដើម ជាប្រធាន របស់ភិក្ខុ ជាគ្រឿងហាមឃាត់ គ្រឿងការពារ នូវមារយាទអាក្រក់ ដែលកើតឡើងដោយកាយ ឬវាចា, អាចញុំាងបុគ្គលអ្នករក្សាឲ្យរួចចាកអបាយទុក្ខបាន ហៅថា **បាតិមោក្ខ** ; សេចក្តីសង្រួម, សេចក្តីរវាំង, សេចក្តីប្រុងប្រយ័ត្ន មិនហ៊ានកន្លងល្មើសនូវអាបត្តិទាំង ៧ កង ហៅថា **សំវរៈ** ; រួមពាក្យទាំង ២ ម៉ាត់ចូលគ្នាជា **បាតិមោក្ខសំវរៈ** ប្រែថា ការសង្រួមក្នុង **បាតិមោក្ខ** ។ បាតិមោក្ខនេះ បើសំដែងដោយសេចក្តី ក៏គឺជាឈ្មោះបាលីដែលរួបរួមសិក្ខាបទពុទ្ធប្បញ្ញត្តិ ដែលព្រះសម្មាសម្ពុទ្ធទ្រង់តែងតាំងឡើង សម្រាប់ឲ្យភិក្ខុសិក្សាជាខាងដើមនៃការប្រព្រឹត្តព្រហ្មចរិយៈ មានពុទ្ធានុញ្ញាតឲ្យសូត្រក្នុងទីប្រជុំសង្ឃគ្រប់ ១ កន្លះខែ, បើសំដែងដោយ

សម្លឹងយកបុគ្គលអ្នករក្សា ក៏បានជា ២ យ៉ាង គឺ ភិក្ខុប្បាតិមោក្ខ ១, ភិក្ខុនីបាតិមោក្ខ ១, ភិក្ខុប្បាតិមោក្ខមានសិក្ខាបទ ២២៧, ភិក្ខុនីបាតិមោក្ខមានសិក្ខាបទ ៣១១ ។ សេចក្ដីល្មើស ឬទោស ដែលកើតព្រោះសេចក្ដីល្មើសនឹងវិនយប្បញ្ញត្តិ ដែលព្រះសម្ពុទ្ធទ្រង់ហាម ហៅថា **អាបត្តិ**, អាបត្តិនេះ បើសំដែងតាមន័យដែលមកក្នុងបាតិមោក្ខ មាន ៥ កង គឺ ៖

**១. បារាជិក ;**
**២. សង្ឃាទិសេស ;**
**៣. បាចិត្តិយៈ ;**
**៤. បាដិទេសនីយៈ ;**
**៥. ទុក្កដ ។**

តាមន័យក្រៅពីបាតិមោក្ខ មាន ៧ កងគឺ ៖

**១. បារាជិក ;**
**២. សង្ឃាទិសេស ;**
**៣. ថុល្លច្ច័យ ;**
**៤. បាចិត្តិយៈ ;**
**៥. បាដិទេសនីយៈ ;**
**៦. ទុក្កដ ;**
**៧. ទុព្ភាសិត ។**

បារាជិកនោះ បើភិក្ខុត្រូវហើយ រមែងដាច់ចាកភាវៈជាភិក្ខុ មិនមែនជាសមណៈ មិនមែនជាសក្យបុត្រ ចាលចាញ់ព្រះពុទ្ធសាសនា មិនមានសំវាស គឺរួមធ្វើសង្ឃកម្មជាមួយនឹងសង្ឃតទៅមិនបាន ឥតផ្លូវកែខ្លួនឲ្យត្រឡប់ជាភិក្ខុឡើងវិញបានឡើយ ។

- **បឋមបារាជិក** បើភិក្ខុត្រូវហើយ ប្រៀបដូចបុរសកំបុតក្បាល មិនអាចនឹងរស់នៅដោយការភ្ជាប់សរីរៈឡើងវិញបាន ។
- **ទុតិយបារាជិក** ដូចស្លឹកឈើទុំជ្រុះចាកទង មិនត្រឡប់លូតលាស់ខៀវខ្ចីឡើងវិញបាន ។
- **តតិយបារាជិក** ដូចថ្មតាន់បែកចេញជាពីរភាគ នឹងតឲ្យជិតស្និទ្ធដូចដើមឡើងវិញមិនបាន ។
- **ចតុត្ថបារាជិក** ដូចដើមត្នោតកំបុតក មិនគួរនឹងដុះល្អឡើងវិញបាន ។

ចំណែកអាបត្តិដទៃក្រៅពីបារាជិក នៅមានផ្លូវកែខៃបាន ដូចអាបត្តិសង្ឃាទិសេស បើភិក្ខុត្រូវហើយ ត្រូវធ្វើបរិវាសកម្មទើបរួចទោសនោះ ។ អាបត្តិ ៥ កងទៀត បើភិក្ខុត្រូវហើយត្រូវសំដែងចំពោះមុខសង្ឃ គឺភិក្ខុតាំងពី ៤ រូបឡើងទៅ, ចំពោះគណៈ គឺភិក្ខុ ២ រូបឬ ៣ រូប, ចំពោះបុគ្គល គឺភិក្ខុ ១ រូប ទើបរួចចាកទោសនោះបាន ។

# ឧបាយឲ្យកើតការសង្រួមក្នុងបាតិមោក្ខ

ភិក្ខុដែលប្រាថ្នានឹងសង្រួមក្នុងបាតិមោក្ខ ត្រូវអាស្រ័យដោយការបង្អោនចិត្តគិតដល់ព្រះឱវាទដែលព្រះបរមសាស្តាទ្រង់ប្រទានទុកឲ្យពិចារណារឿយ ៗ ថា ៖

**កច្ចិ នុ ខោ មេ អត្តា សីលតោ ន ឧបវទតិ**
**ខ្លួនអញនឹងតិះដៀលខ្លួនអញដោយសីលបានឬទេ ?**

**កច្ចិ នុ ខោ មំ អនុវិច្ច វិញ្ញូ**
**សព្រហ្មចារី សីលតោ ន ឧបវទន្តិ**
**បើសព្រហ្មចារីបុគ្គលអ្នកប្រព្រឹត្តធម៌ដូចគ្នាដែលជាអ្នកចេះដឹង គេនឹករំពឹងរិះគន់មើល តើនឹងតិះដៀលខ្លួនអញដោយសីលបានខ្លះដែរឬទេ ?**

ដូច្នេះជាដើម ទើបអាចញ៉ាំងការសង្រួមនោះ ឲ្យប្រព្រឹត្តទៅបានដោយប្រពៃ មិនភ្លាំងភ្លាត់ ។

កាលបើភិក្ខុនឹករំពឹងដល់ព្រះបរមពុទ្ធោវាទយ៉ាងនេះរឿយ ៗ ហើយ ក៏ជាហេតុឲ្យហិរិឱត្តប្បៈ និងសំវរៈក្នុងបាតិមោក្ខនោះកាន់តែលូតលាស់ដុះដាលចម្រើនឡើងជាលំដាប់ ៗ មិនអាក់ខាន មិនធូរថយឡើយ ។

# សីលឧត្តមជាងជីវិត

បាតិមោក្ខសំវរសីលនេះ ជាសីលសំខាន់បំផុត ជាកិច្ចដែលភិក្ខុត្រូវប្រតិបត្តិតាមជានិច្ច ខានមិនបាន, ទោះបីមានហេតុត្រូវអន្តរាយជីវិត ក៏កុំលះបង់សីលនេះឡើយ ព្រោះសីលនេះជាគុណធម៌ដ៏ឧត្តមជាងជីវិត គួរតែខំជំនះចិត្តប្រព្រឹត្តតាមភាសិតដែលពោលថា ៖

**បាតិមោក្ខំ វិសោធេន្តោ អប្បេវ ជីវិតំ ជហេ**
**បញ្ញត្តំ លោកនាថេន ន ភិន្ទេ សីលសំវរំ ។**

សេចក្តីថា **កល្យាណភិក្ខុកាលដែលនឹងជម្រះបាតិមោក្ខ - សំវរសីលឲ្យបរិសុទ្ធ បើទុកជាមានហេតុត្រូវអន្តរាយជីវិតក៏ត្រូវតែស៊ូលះបង់ មិនគប្បីទំលាយសីលសំវរៈឡើយ គឺត្រូវតែសង្រួមក្នុងសីលដែលព្រះលោកនាថជាម្ចាស់ទ្រង់ត្រាស់បញ្ញត្តទុកមកនោះឲ្យខាងតែបាន ។**

# បាតិមោក្ខសំវរសីលបរិសុទ្ធដោយសទ្ធា

ឯបាតិមោក្ខសំវរសីលនេះ រមែងសម្រេចដោយ **សទ្ធា ( សេចក្តីជឿ )** ព្រោះការបញ្ញត្តិសិក្ខាបទនេះ មិនមែនជាវិស័យរបស់សាវ័កទេ ជាពុទ្ធវិស័យ, ហេតុដូច្នោះ ភិក្ខុអ្នកកាន់សិក្ខាបទលុះតែជឿចំពោះពុទ្ធប្បញ្ញត្តិ មិនគិតដល់ជីវិតជាដើម ទើបអាចរក្សាសិក្ខាបទឲ្យគ្រប់គ្រាន់បាន ។ មួយវិញទៀត ភិក្ខុអ្នកមាន

សទ្ធាជាត្រីមុខ ត្រូវបង្អោនចិត្តគិតតាមន័យដែលលោកដាស់តឿនថា ៖

**កិកីវ អណ្ឌំ ចមរីវ វាលធឹ**
**បិយំវ បុត្តំ នយនំវ ឯកកំ**
**តថេវ សីលំ អនុរក្ខមានកា**
**សុបេសលា ហោថ សទា សគារវា ។**

សេចក្តីថា **សត្វត្រដេវរិចរក្សាស៊ុតយ៉ាងណាមិញ, សត្វចាមរីរក្សាកន្ទុយយ៉ាងណាមិញ, មាតាថ្នមបុត្តជាទីស្រឡាញ់យ៉ាងណាមិញ, មនុស្សខ្វាក់ម្ខាងប្រុងរក្សាភ្នែកយ៉ាងណាមិញ, អ្នកទាំងឡាយចូររក្សាសីល ឲ្យដូចយ៉ាងនោះ ; ចូរជាបុគ្គលមានសីលជាទីស្រឡាញ់ល្អ មានសេចក្តីគោរពគ្រប់កាលចុះ ។**

## ត្រូវបង្អោនចិត្តគិតតាមអង្គនៃកណ្តៀរ

ភិក្ខុអ្នកស្រឡាញ់ការសង្រួម គួរតែបង្អោនចិត្តគិតតាមន័យដែលព្រះនាគសេនត្ថេរ ថ្វាយព្រះពរព្រះបាទមិលិន្ទថា ៖

- " បពិត្រមហារាជ ! ភិក្ខុអ្នកខ្លាចភ័យក្នុងវដ្តសង្សារប្រាថ្នានឹងធ្វើសេចក្តីសង្រួមក្នុងបាតិមោក្ខសំវរសីលឲ្យបរិបូណ៌ត្រូវគិតយកទំនងតាមអង្គ ១ របស់កណ្តៀរ ។ បពិត្រមហារាជ ! ធម្មតាកណ្តៀររមែងយកដីមកពូនធ្វើដំបូលខាងលើ ជាដំបូកបិទបាំងខ្លួនសម្ងំនៅខាងក្នុង ហើយត្រេចស្វែងរកអាហារ យ៉ាងណា

មិញ, ព្រះយោគាវចរ ត្រូវយកសីលមកធ្វើជាដំបូលគ្រឿងប្រក់ គ្រឿងបិទបាំង គឺសង្រួមក្នុងសីល បិទបាំងក្នុងចិត្តហើយសឹម ត្រេចទៅរកចង្ហាន់បិណ្ឌបាត យ៉ាងនោះចុះ ។ ព្រោះព្រះយោគាវចររមែងរួចចាកភ័យទាំងពួងដោយសារគ្រឿងប្រក់ គ្រឿងបិទបាំង គឺការសង្រួមក្នុងសីល ដូចជាកណ្ដៀរតែងរួចចាកសេចក្ដីអន្តរាយដោយសារដំបូកដូច្នោះឯង ។

- " បពិត្រមហារាជ ! សេចក្ដីនេះសមដូចភាសិតដែល ព្រះឧបសេនត្ថេរវង្គន្តបុត្រលោកពោលថា ៖

**សីលសំវរឆទនំ យោគី កត្វាន មានសំ**
**អនុបលិត្តោ វិហរតិ ភយា សោ បរិមុច្ចតិ ។**

សេចក្ដីថា **យោគីដែលធ្វើគ្រឿងប្រក់ គ្រឿងបិទបាំង គឺប្រព្រឹត្តសង្រួមក្នុងសីលហើយបិទបាំងចិត្តទុកឲ្យល្អ ជាអ្នកមិនជាប់ដោយកិលេស រមែងរួចស្រឡះចាកភ័យគ្រប់យ៉ាង ។**

# សីលជាខាងដើមនៃធម៌ទាំងពួង

ក្នុងសិក្ខាទាំង ៣ [១] លោកលើកយកសីលសិក្ខា ទុកជាខាងដើម, ក្នុងវិសុទ្ធិទាំង ៧ លោកលើកយកសីលវិសុទ្ធិ ទុកជាខាងដើម, ក្នុងបារិសុទ្ធានិយង្គទាំង ៩ លោកលើកយកសីល-បារិសុទ្ធិទុកជាខាងដើម ។

(១) គឺ អធិសីលសិក្ខា ១, អធិចិត្តសិក្ខា ១, អធិបញ្ញាសិក្ខា ១ ហៅថា ត្រៃសិក្ខា ។

# សីលជាឯកធម៌តែងមានក្នុងនានាស្ថាន

សីលនេះ ជាឯកធម៌តែងមានក្នុងនានាស្ថាន គឺជាធម៌មានឈ្មោះតែ ១ តែព្រះដ៏មានព្រះភាគជាម្ចាស់ទ្រង់រៀបរៀងទុកក្នុងពួកធម៌ផ្សេង ៗ ដូចមានក្នុងចតុបារិសុទ្ធសីលទាំង ៤, មានត្រង់ទី ២ នៃវេសារជ្ជករណធម៌ ៥, ត្រង់ទី ១ នៃអង្គរបស់ភិក្ខុបួសថ្មី ៥, ត្រង់ទី ៥ នៃសារាណីយធម៌ ៦, ត្រង់ទី ២ នៃអរិយទ្រព្យ ៧, ត្រង់ទី ១ នៃនាថករណធម៌ ១០, ត្រង់ទី ៦ នៃកថាវត្ថុ ១០ ។

ព្រោះហេតុនោះ ទើបទ្រង់ប្រទានព្រះបរមពុទ្ធានុសាសនីដាស់តឿនថា ៖

**សម្បន្នសីលា ភិក្ខវេ វិហរថ**

**ម្នាលភិក្ខុទាំងឡាយ ! អ្នកទាំងឡាយចូរជាអ្នកមានសីលបរិបូណ៌ មានបាតិមោក្ខបរិបូណ៌ សង្រួមក្នុងបាតិមោក្ខ សម្បូណ៌ដោយអាចារៈ[១] និងគោចរៈ [២] ខ្លាចទោសគឺអកុសល សូម្បីបន្តិចបន្តួច**

---

(១) ភិក្ខុដែលស្គាល់ជាក់នូវអនាចារផ្សេង ៗ ហៅថា ឈ្លាសវៃក្នុងអាចារៈ គឺមារយាទការប្រព្រឹត្តល្មើសសិក្ខាបទដោយកាយវាចាចិត្ត និងការទ្រុស្តត្រកូលទាំងអស់ មានឲ្យឫស្សី ស្លឹកឈើ ផ្លែឈើ និងផ្កាឈើ ដល់គ្រហស្ថជាដើម ហៅថា អនាចារៈ គឺឥតមារយាទ ឬមារយាទមិនល្អ ។

(២) ភិក្ខុដែលស្គាល់អគោចរដ្ឋាន ៦ ប្រការ ហៅថា ឈ្លាសវៃក្នុងគោចរៈ គឺទីគួរត្រេចទៅដើម្បីស្វែងរកអាហារជាដើម ។ ទីមិនគួរត្រេចទៅ ៦ ប្រការ គឺលំនៅស្រីផ្កាមាស ១, លំនៅស្រីមេម៉ាយ ១, លំនៅស្រីក្រមុំចាស់ ១, លំនៅមនុស្សខ្ទើយ ១, លំនៅភិក្ខុនី ១, ផ្ទះលក់សុរា ១ ហៅថា អគោចរដ្ឋាន ។

## សិក្សាមាំមួនក្នុងសិក្ខាបទទាំងឡាយចុះ ។

ភិក្ខុអ្នកបរិបូណ៌ដោយបាតិមោក្ខសំវរៈ រមែងបានពេញទីជាសមណៈដ៏ល្អ គួរជាទីជ្រះថ្លា ល្មមជាទីក្រាបសំពះបូជារបស់មហាជន ដូចព្រះចេតិយដែលមានព្រះបរមសារីរិកធាតុបញ្ចុះទុកនៅខាងក្នុង ។ ភិក្ខុដែលមិនមានបាតិមោក្ខសំវរៈ មិនមានសេចក្ដីល្អ មិនគួរជាទីជ្រះថ្លា មិនល្មមជាទីក្រាបសំពះបូជារបស់មហាជនឡើយ គឺអ្នកផងក្រឡេកមើលរមែងទាស់ភ្នែក ។

# អានិសង្សសីល

បុគ្គលអ្នកប្រាថ្នាសម្បត្តិសួគ៌ឬព្រះនិព្វាន ដែលនឹងបានសម្រេចដូចបំណង ក៏ព្រោះតែសេចក្ដីប្រតិបត្តិ, មិនសម្រេចព្រោះសេចក្ដីប្រាថ្នា ឬការអង្វរ តែម្យ៉ាងប៉ុណ្ណោះឡើយ ។ ឯសេចក្ដីប្រតិបត្តិនោះដែលជាខាងដើមបំផុត ក៏គឺសីល, សីលទុកដូចជាភូមិផែនដី, គុណធម៌ដទៃទុកដូចជាពូជ, មានផែនដីគឺសីលបរិបូណ៌ហើយ ទើបពូជធារគឺគុណធម៌ដទៃ ៗ លូតលាស់ដុះដាលចម្រើនឡើងជាលំដាប់ទៅបាន ។

ព្រោះហេតុដូច្នេះបានជា លោកសំដែងថា ៖

**សីលបរិភាវិតោ សមាធិ មហប្ផលោ**
**ហោតិ មហានិសំសោ**

**សមាធិដែលសីលផុសខាត់ហើយ ជាគុណជាតិមានផលច្រើន មានអានិសង្សច្រើន,**

**សមាធិបរិភាវិតា បញ្ញា មហប្ផលា**
**ហោតិ មហានិសំសា**

**បញ្ញាដែលសមាធិផុសខាត់ហើយ ជាគុណជាតិមានផលច្រើន មានអានិសង្សច្រើន,**

**បញ្ញាបរិភាវិតំ ចិត្តំ សម្មទេវ អាសវេហិ វិមុច្ចតិ**
**ចិត្តដែលបញ្ញាផុសខាត់ហើយ រួចស្រឡះចាកអាសវៈទាំងឡាយដោយប្រពៃពិត ។**

ភិក្ខុអ្នកសម្បូណ៌ដោយសីល រមែងបានសេចក្តីត្រជាក់ចិត្តឥតក្តៅក្រហាយ ដូចព្រះបរមសាស្តាទ្រង់ទេសនាសរសើរអានិសង្សថា **សីល** មានប្រយោជន៍ឲ្យកើត **សំវរៈការសង្រួម**, **ការសង្រួម** មានប្រយោជន៍មិនឲ្យមាន **វិប្បដិសារៈ** សេចក្តីក្តៅក្រហាយចិត្ត, **ការមិនមានវិប្បដិសារៈ** មានប្រយោជន៍ឲ្យកើត **បាមោជ្ជៈ** សេចក្តីរីករាយចិត្ត, **បាមោជ្ជៈ** មានប្រយោជន៍ឲ្យកើត **បីតិ** សេចក្តីឆ្អែតចិត្ត, **បីតិ** មានប្រយោជន៍ឲ្យកើត **បស្សទ្ធិ** សេចក្តីស្ងប់រម្ងាប់, **បស្សទ្ធិ** មានប្រយោជន៍ឲ្យកើត **សុខៈ** សេចក្តីស្រួលចិត្ត, **សុខៈ** មានប្រយោជន៍ឲ្យកើតឲ្យកើត **សមាធិ** សេចក្តីតម្កល់ចិត្តមាំក្នុងកុសលធម៌, **សមាធិ** មានប្រយោជន៍ឲ្យកើត **យថាភូតញ្ញាណទស្សនៈ** សេចក្តីយល់ឃើញដឹងច្បាស់នូវសភាវ-

ធម៌ទាំងពួងតាមពិត, **យថាភូតញ្ញាណទស្សនៈ** មានប្រយោជន៍ឲ្យកើត **និព្វិទា** សេចក្តីនឿយណាយក្នុងសត្វនិងសង្ខារ, **និព្វិទា** មានប្រយោជន៍ឲ្យកើត **វិរាគៈ** សេចក្តីប្រាសចាកតម្រេក, **វិរាគៈ** មានប្រយោជន៍ឲ្យបាន **វិមុត្តិ** សេចក្តីរួចស្រឡះចាកកិលេស, **វិមុត្តិ** មានប្រយោជន៍ឲ្យបាន **វិមុត្តិញ្ញាណទស្សនៈ** សេចក្តីយល់ឃើញដឹងច្បាស់ថាបានវិមុត្តិ, **វិមុត្តិញ្ញាណទស្សនៈ** មានប្រយោជន៍ឲ្យបាន **អនុបាទាបរិនិព្វាន** គឺការរំលត់ទុក្ខដោយអស់សេចក្តីប្រកាន់មាំ ។

ម្យ៉ាងទៀត ទ្រង់ត្រាស់ថា ៖

**ឥជ្ឈតិ ហិ ភិក្ខវេ សីលវតោ ចេតោបណិធិ**
**ម្នាលភិក្ខុទាំងឡាយ !**
**សេចក្តីប្រាថ្នាដែលតាំងនៅក្នុងចិត្តរបស់អ្នកមានសីល**
**រមែងបានសម្រេចដូចបំណង ។**

ព្រោះហេតុនេះបានជា ក្នុងទីបំផុតនៃការសមាទាន លោកអ្នកឲ្យសីលរមែងសំដែងអានិសង្សប្រាប់ឧបាសក អ្នកសមាទានហើយបង្គាប់ឲ្យដុសខាត់សំអាតសីលដោយគាថា ថា ៖

**សីលេន សុគតឹ យន្តិ សីលេន ភោគសម្បទា**
**សីលេន និព្វុតឹ យន្តិ តស្មា សីលំ វិសោធយេ ។**

សេចក្តីថា **សត្វទាំងឡាយទៅកាន់ស្ថានសួគ៌បានក៏ព្រោះសីល, សត្វទាំងឡាយបរិបូណ៌ដោយភោគៈក៏ព្រោះសីល, សត្វទាំងឡាយបានទៅកាន់ទីរំលត់ទុក្ខគឺព្រះនិព្វានក៏ព្រោះសីល, ព្រោះហេតុនោះ បុគ្គលជាសប្បុរសគប្បីជម្រះនូវសីលឲ្យបរិសុទ្ធ កុំឲ្យសៅហ្មងឡើយ ។**

**ពាក្យ**ដែលបង្គាប់ឲ្យសង្រួមក្នុងបាតិមោក្ខ ដូចពោលមកហើយនេះ រាប់ថាជា **ពុទ្ធសាសនា** ពាក្យប្រដៅរបស់ព្រះពុទ្ធទាំងឡាយ គឺព្រះពុទ្ធរាល់ព្រះអង្គដែលបានត្រាស់ក្នុងកាលទាំងពួង តែងទ្រង់ប្រដៅដូច្នេះ ។

# ចប់កណ្ឌទី ៨

# ឱវាទបាតិមោក្ខ កណ្ឌទី ៩

**លំដាប់នេះ** នឹងអធិប្បាយសេចក្ដីនៃព្រះបរមពុទ្ធោវាទ ក្នុងឱវាទបាតិមោក្ខ ត្រង់បទថា ៖

**មត្តញ្ញុតា ច ភត្តស្មឹ**
**ភាវៈជាអ្នកដឹងប្រមាណក្នុងភត្ត**

នោះ, ឲ្យមានសេចក្ដីពិស្ដារ ដើម្បីជាគ្រឿងប្រដាប់ សតិបញ្ញា និងជាវត្តប្រតិបត្តិរបស់សាធុជនពុទ្ធបរិស័ទ ដូចតទៅនេះ ៖

សភាពជាអ្នកដឹងការល្អ, ការល្មម និងការសមគួរហៅថា **ភាវៈជាអ្នកដឹងប្រមាណ** ; ភាវៈជាអ្នកដឹងប្រមាណនោះ មានប្រការដែលនឹងត្រូវពណ៌នាជាច្រើន ដូចយ៉ាងដឹងប្រមាណក្នុងការប្រើឥរិយាបថទាំង ៤ គឺ ឈរ, ដើរ, អង្គុយ, ដេក ឲ្យប្រព្រឹត្តទៅស្មើ មិនប្រើឲ្យជ្រុលមួយ ៗ; ដឹងប្រមាណក្នុងការធ្វើ, ការនិយាយ និងការគិត ឲ្យមានរបៀបរៀបរយតាមគន្លងធម៌; ឬដឹងប្រមាណក្នុងការប្រើកម្លាំងកាយ, កម្លាំងគំនិត, កម្លាំងទ្រព្យ ឲ្យល្មមសម ; ឬដឹងប្រមាណក្នុងការសូម និងការឲ្យដោយស្រួល អម្បាលនេះជាដើម ។ តែក្នុងទីនេះ នឹងពណ៌នាចំពោះតែការដឹងប្រមាណ ៣ យ៉ាង ។

# ការដឹងប្រមាណ ៣ យ៉ាង

**ក). ដឹងប្រមាណក្នុងការស្វែងរក ;**

**ខ). ដឹងប្រមាណក្នុងការទទួល ;**

**គ). ដឹងប្រមាណក្នុងការបរិភោគ ។**

# អធិប្បាយការដឹងប្រមាណ

**ក). ដឹងប្រមាណក្នុងការស្វែងរក** នោះ, បើជាគ្រហស្ថ ស្វែងរកដោយផ្លូវដែលត្រូវតាមធម៌, វៀរចាកការស្វែងរកក្នុងផ្លូវខុសដូចវៀរចាកមិច្ឆាកម្មន្ត ៣ យ៉ាង គឺ ៖

១. មិនសម្លាប់សត្វ ;

២. មិនលួចទ្រព្យគេ ;

៣. មិនប្រព្រឹត្តខុសក្នុងកាម ;

និងវៀរចាកមិច្ឆាអាជីវៈ ឬមិច្ឆាវាណិជ្ជ ៥ យ៉ាង គឺ ៖

១. មិនរកស៊ីលក់ដូរគ្រឿងប្រដាប់សម្រាប់ប្រហារ ;

២. មិនលក់មនុស្ស ;

៣. មិនលក់ដូរសាច់ គឺមិនចិញ្ចឹមសត្វទាំងឡាយ មានជ្រូកជាដើម ហើយសម្លាប់យកសាច់លក់ ឬក៏មិនទិញដូរមកសម្លាប់យកសាច់លក់ ;

៤. មិនលក់ដូរទឹកស្រវឹង គឺសុរានិងមេរ័យ ;

៥. មិនលក់ដូរថ្នាំពិស ដែលជាគ្រឿងបំពុលមនុស្ស និងសត្វ ។

អម្បាលនេះជាដើម ។

បើជាបព្វជិត ស្វែងរកដោយផ្លូវដែលត្រូវតាមធម៌វិន័យវៀរចាកកុលទូសកៈ អនេសនៈ វេជ្ជកម្ម អម្បាលនេះជាដើម ។

ខ). **ដឹងប្រមាណក្នុងការទទួល** នោះ, បើជាគ្រហស្ថទទួលទិញទទួលបញ្ចាំតែរបស់ត្រជាក់ គឺរបស់ដែលកើតឡើងក្នុងផ្លូវបរិសុទ្ធ, មិនទទួលទិញទទួលបញ្ចាំរបស់ក្តៅ គឺរបស់ដែលកើតអំពីចោរកម្មខុសចាកព្រះរាជបញ្ញត្តិ ; អម្បាលនេះជា-ដើម ។ បើជាបព្វជិត ទទួលតែវត្ថុណាដែលជាកប្បិយៈគួរតាមធម៌វិន័យវៀរចាកវត្ថុដែលជាអកប្បិយៈ មិនគួរតាមធម៌វិន័យ ; អម្បាលនេះជាដើម ។

គ). **ដឹងប្រមាណក្នុងការបរិភោគ** នោះ, បើជាគ្រហស្ថផ្លាស់ប្តូរចាយវាយបរិភោគឲ្យសមគួរតាមកម្លាំងទ្រព្យ មិនរិះពេកមិនកញ្ជះកញ្ជាយពេក; ទាំងបរិភោគទៀតសោត ក៏ដឹងប្រមាណរបស់, ដឹងប្រមាណកាល, ដឹងប្រមាណពោះ មិនបរិភោគរបស់ដែលស្អុយ របស់ដែលខូច ; អម្បាលនេះជាដើម ។ បើជាបព្វជិតវិញសោត ក៏ដឹងប្រមាណរបស់, ប្រមាណកាល, ប្រមាណផ្ទៃ ទាំង ៣ ប្រការនេះដូចគ្នា ។ ព្រះពុទ្ធជាម្ចាស់ដែលទ្រង់បានត្រាស់ក្នុងអតីតកាលក្តី អនាគតកាលក្តី ឬព្រះ

បរមគ្រូរបស់យើងទាំងឡាយក្នុងបច្ចុប្បន្ននេះក្តី ដែលទ្រង់បានតែងតាំងធម៌វិន័យ ចំពោះរឿងនេះ គ្រប់គ្រាន់សម្រាប់ឲ្យពួកបព្វជិតប្រតិបត្តិតាម ដូចទ្រង់ហាមប្រាមមិនឲ្យបរិភោគរបស់ដែលកើតដោយអធម្មកម្ម និងរបស់ដែលកន្លងហួសវេលា ទ្រង់កំណត់កាលវេលាឲ្យបរិភោគដោយស្រួល និងទ្រង់សំដែងបច្ច - វេក្ខណវិធី សម្រាប់ឲ្យពិចារណាក្នុងខណៈដែលទទួល, ដែលកំពុងបរិភោគ, ដែលបរិភោគរួចហើយ ឲ្យឃើញថាគ្រាន់តែជាធាតុឬបដិកូល ដូច្នេះជាដើមនោះ ក៏ដើម្បីឲ្យស្គាល់ប្រមាណនេះឯង ។

ការដឹងប្រមាណនេះ បើសំដែងចំពោះតែការដឹងប្រមាណក្នុងភត្តាហារម្យ៉ាងប៉ុណ្ណោះ ក៏គប្បីជ្រាបតាមន័យដែលមានក្នុងអប្បណ្ណកសូត្រ ថា ៖

**ឥធ ភិក្ខវេ ភិក្ខុ បដិសង្ខា យោនិសោ អាហារំ អាហារេតិ នេវទវាយ នមទាយ នមណ្ឌនាយ នវិភូសនាយ យាវទេវ ឥមស្ស កាយស្សឋិតិយា យាបនាយ វិហឹសុបរតិយា ព្រហ្មចរិយានុគ្គហាយ ឥតិបុរាណញ្ច វេទនំ បដិហង្ខាមិ នវញ្ច វេទនំ ន ឧប្បាទេស្សាមិ យាត្រា ច មេ ភវិស្សតិ អនវជ្ជតា ច ផាសុវិហារោ ចាតិ ។**

សេចក្តីថា **ម្នាលភិក្ខុទាំងឡាយ ! ភិក្ខុក្នុងសាសនានេះពិចារណាដោយយោបល់ហើយទើបឆាន់ចង្ហាន់ មិនឆាន់ដើម្បីនឹង**

លេងដូចក្មេងអ្នកស្រុក, មិនឆាន់ដើម្បីឲ្យកើតបុរិសមានៈស្រវឹងដូចអ្នកចម្បាប់ប្រដាល់, មិនឆាន់ដើម្បីប្រដាប់តាក់តែងរាងកាយដូចស្ត្រីក្នុងបូរី, មិនឆាន់ដើម្បីធ្វើឲ្យផូរផង់ពណ៌សម្បុរដូចអ្នកលេងរបាំ ; ឆាន់ចង្ហាន់នេះ គ្រាន់តែឲ្យតាំងនៅនៃរាងកាយប៉ុណ្ណោះ ដើម្បីញ៉ាំងជីវិតឲ្យប្រព្រឹត្តទៅ, ដើម្បីបំបាត់បង់នូវសេចក្តីលំបាកគឺសេចក្តីស្រេកឃ្លាន ដើម្បីទំនុកបម្រុងនូវព្រហ្មចរិយៈឆាន់ចង្ហាន់ដោយធ្វើទុកក្នុងចិត្តថា " អាត្មាអញនឹងកំចាត់បង់នូវវេទនាចាស់ គឺសេចក្តីឃ្លានដែលមានហើយផង និងមិនញ៉ាំងវេទនាថ្មី គឺឆ្អែតហួសប្រមាណឲ្យកើតឡើងផង កិរិយាប្រព្រឹត្តទៅនៃឥរិយាបថទាំង ៤ ក្តី សេចក្តីមិនមានទោស គឺមិនច្រអូសកាយ ច្រអូសចិត្តជាដើមក្តី កិរិយានៅសប្បាយក្នុងឥរិយាបថទាំង ៤ ក្តី នឹងមានដល់អាត្មាអញដោយបានបរិភោគអាហារនេះមិនខានឡើយ ។

**ឯវំ ខោ ភិក្ខវេ ភិក្ខុ ភោជនេ មត្តញ្ញូ ហោតិ**

ម្នាលភិក្ខុទាំងឡាយ ! យ៉ាងនេះឯង ទើបឈ្មោះថា ភិក្ខុជាអ្នកដឹងប្រមាណក្នុងភោជន ។

# ទោសនិងគុណនៃការបរិភោគ

ការពិចារណាដោយយោបល់ក្នុងវេលាដែលកំពុងបរិភោគភត្តាហារនោះ ជាហេតុមិនឲ្យវង្វេងក្នុងអំណាចតណ្ហា ( សេចក្តីច្រួលច្រាល់ ) បានប្រព្រឹត្តទៅដោយសេចក្តីល្មមល្អ ។ បណ្តា

សត្វទាំងឡាយទាំងពួងក្នុងលោករមែងរស់ដោយសារអាហារ បើមិនបរិភោគអាហារក៏មិនអាចរស់នៅបាន ។ ព្រោះហេតុដូច្នោះបានជា អាហារនេះជាវត្ថុដែលត្រូវបរិភោគខានមិនបាន, ប៉ុន្តែបើបរិភោគមិនដឹងប្រមាណ គឺតិចពេក ច្រើនពេក ឬឥតពិចារណា ក៏ធ្វើឲ្យកើតទុក្ខវេទនាមិនស្រួលដែរ ទាំងជាផ្លូវចម្រើននៃអាសវៈ[១]ផង, កាលបើបរិភោគឲ្យល្មមសមគួរ និងមានសេចក្ដីត្រិះរិះដោយឧបាយនៃប្រាជ្ញាដ៏ប្រពៃ ក៏ប្រព្រឹត្តទៅដើម្បីសេចក្ដីស្រួល រម្ងាប់ទុក្ខវេទនា, ធ្វើរាងកាយឲ្យកើតសេចក្ដីសប្បាយ ; ព្រោះវេទនាជាបច្ច័យឲ្យកើតតណ្ហា, កាលបើទុក្ខវេទនាស្ងប់ហើយ តណ្ហាសេចក្ដីច្រួលច្រាល់ក៏ស្ងប់ទៅផង ។ ហេតុដូច្នោះ ការដឹងប្រមាណក្នុងការបរិភោគទើបប្រព្រឹត្តទៅដើម្បីលះបង់អាសវៈដែលមិនទាន់កើត មិនឲ្យកើត, អាសវៈដែលកើតហើយ ឲ្យសាបសូន្យទៅបាន ។

ការដែលប្រតិបត្តិឲ្យត្រូវតាមសភាវៈជាអ្នកដឹងប្រមាណក្នុងភោជននោះ ជាការប្រតិបត្តិមិនខុស គឺសុទ្ធតែត្រូវ ហើយជាការប្រតិបត្តិមានកម្រៃពេក ។ សេចក្ដីនេះ សមតាមធម្មទេសនាដែលព្រះសម្មាសម្ពុទ្ធទ្រង់សំដែងថា ៖

(១) អាសវ --សៈវ៉ះ កិលេសជាគ្រឿងត្រាំ គឺកិលេសធម៌ដែលត្រាំនៅក្នុងសន្តាន, មាន ៤ យ៉ាងគឺ ១-កាម ហៅថា កាមាសវៈ; ២-ភព ហៅ ភវាសវៈ; ៣-ទិដ្ឋិ ហៅ ទិដ្ឋាសវៈ; ៤- អវិជ្ជា ហៅ អវិជ្ជាសវៈ; (ម. ព. ឱយ ផង) ។ អាសវក្កិលេស កិលេសជាគ្រឿងត្រាំក្នុងសន្តាន ។

# អបណ្ណកប្បដិបទា
# សេចក្ដីប្រតិបត្តិមិនខុស

មាន ៣ យ៉ាង គឺ ៖

**១. ឥន្ទ្រិយសំវរៈ** សង្រួមឥន្ទ្រិយ ៦ គឺ ភ្នែក, ត្រចៀក, ច្រមុះ, អណ្ដាត, កាយ, ចិត្ត មិនឲ្យកើតសោមនស្ស ទោមនស្សក្នុងវេលាដែលឃើញរូប ស្ដាប់សំឡេង ហិតក្លិន ភ្លក្សរស ពាល់ត្រូវផោដ្ឋព្វៈ ដឹងធម្មារម្មណ៍ ;

**២. ភោជនេ មត្តញ្ញុតា** ដឹងប្រមាណក្នុងការបរិភោគ តែសមគួរ មិនច្រើន មិនតិច ;

**៣. ជាគរិយានុយោគ** ប្រកបសេចក្ដីភ្ញាក់រឭករឿយ ៗ គឺដេកតិច ភ្ញាក់រឭកច្រើន, ព្យាយាមជម្រះចិត្តឲ្យជ្រះថ្លាស្អាតផូរផង់ ។

ន័យមួយទៀត សេចក្ដីដឹងប្រមាណក្នុងភោជន ជាគុណធម៌ដ៏ថ្លៃថ្លា អាចស្រង់សត្វដែលលង់នៅក្នុងសមុទ្ទ គឺវដ្ដសង្សារឲ្យអណ្ដែតត្រសែតឡើងដាក់ដល់ត្រើយ គឺព្រះនិព្វានបាន ។ សេចក្ដីនេះ សមដូចន័យដែលព្រះទសពលញ្ញាណទ្រង់សំដែងថា ៖

**ចតូហិ ភិក្ខវេ ធម្មេហិ សមន្នាគតោ ភិក្ខុ**
**អភព្វោ បរិហានាយ និព្វានស្ស សន្តិកេ**

ម្នាលភិក្ខុទាំងឡាយ ! ភិក្ខុដែលប្រកបដោយធម៌ ៤ ប្រការ ជាអ្នកមិនគួរនឹងសាបសូន្យចាកគុណធម៌ទាំងឡាយ មានឈាន ជាដើមរមែងបានឡើងឈ្មោះថា ជាអ្នកឋិតនៅក្នុងទីជិតនៃព្រះនិព្វាន ។

**កតមេហិ ចតូហិ** ធម៌ ៤ ប្រការនោះ តើដូចម្តេចខ្លះ ?

**ឥធ ភិក្ខវេ ភិក្ខុ សីលសម្បន្នោ ហោតិ ឥន្ទ្រិយេសុ គុត្តទ្វារោ ហោតិ, ភោជនេ មត្តញ្ញូ ហោតិ, ជាគរិយំ អនុយុត្តោ ហោតិ**

ម្នាលភិក្ខុទាំងឡាយ ! ( ធម៌ ៤ ប្រការនោះ ) គឺ ភិក្ខុក្នុង សាសនានេះ ជាអ្នកបរិបូណ៌ដោយសីល ១, ជាអ្នកបានគ្រប់គ្រងរក្សាទ្វារក្នុងឥន្ទ្រិយទាំងឡាយ ១, ជាអ្នកដឹងប្រមាណក្នុង ភោជន ១, ជាអ្នកប្រកបសេចក្តីភ្ញាក់រឭករឿយ ៗ គឺដេកតិច ភ្ញាក់រឭកច្រើន ១ ។

ពាក្យដែលពន្យល់ឲ្យស្គាល់ការដឹងប្រមាណក្នុងភោជនដូច ន័យដែលពោលមកហើយនេះ រាប់ថាជា **ពុទ្ធសាសនា** ពាក្យ ប្រដៅរបស់ព្រះពុទ្ធទាំងឡាយ គឺព្រះពុទ្ធជាម្ចាស់រាល់ព្រះអង្គ ដែលទ្រង់បានត្រាស់ក្នុងកាលទាំងពួង រមែងទ្រង់ប្រដៅដូច្នេះ ។

# ចប់កណ្ឌទី ៩

# ឱវាទបាតិមោក្ខ កណ្ឌទី ១០

**លំដាប់នេះ** នឹងអធិប្បាយសេចក្ដីនៃព្រះបរមពុទ្ធោវាទ ក្នុងឱវាទបាតិមោក្ខ ត្រង់បទថា ៖

**បន្តញ្ច សយនាសនំ ទីដេក ទីអង្គុយដ៏ស្ងាត់**

នោះ, ឲ្យមានសេចក្ដីពិស្ដារ ដើម្បីជាគ្រឿងប្រដាប់សតិបញ្ញា និងជាវត្តប្រតិបត្តិរបស់សាធុសប្បុរសពុទ្ធបរិស័ទ ដូចតទៅនេះ ៖

ព្រៃភ្នំ ឬព្រៃឈើដែលផុតពីស្រុកនិងឧបចារនៃស្រុក (១) ដែលប្រកបដោយពួកឈើធំតូច ឬរុក្ខមូល ( គល់ឈើ ) និង សុញ្ញាគារដ្ឋាន ( ផ្ទះទំនេរឥតមនុស្សនៅ ) ដោយហោចទៅសូម្បីតែកុដិ ( ខ្ទម ) តូច ៗ ដែលសង់ក្នុងទីស្ងាត់សម្រាប់ជាទីចម្រើនសមណធម៌ ; ទីអម្បាលនេះជាដើម ហៅថា **ទីដេកទីអង្គុយដ៏ស្ងាត់** ។ ឯលំនៅជាទីអាស្រ័យដេកអង្គុយរបស់យោគីអ្នកប្រាថ្នាសេចក្ដីស្ងប់រម្ងាប់នោះ, គួរឲ្យជាទីស្ងាត់ច្រៀបចាករូបារម្មណ៍និងសទ្ទារម្មណ៍ កុំឲ្យជាទីគឹកកងរំពងឡើយ ; បើច្របូកច្របល់

(១) ទីដែលធ្លាក់ចុះដុំដីរបស់មជ្ឈឹមបុរសឈរប្រែបធរណីទ្វារស្រុកដែលមានរបង ឬកំផែងចោលទៅ ឬទីដែលធ្លាក់ចុះដុំដីរបស់មជ្ឈឹមបុរសឈរប្រែបឧបចារផ្ទះនៃស្រុកដែលឥតរបងឬកំផែងចោលទៅ ហៅថា ឧបចារនៃស្រុក ។ ទីដ៏សេស លើកលែងតែស្រុកនិងឧបចារនៃស្រុកចេញ ហៅថា ព្រៃ ។

ដោយមនុស្សអ៊ូរអរធ្វើម្ដេចនឹងឲ្យជាទីសម្រាន្តចិត្តទៅកើត, មិនងាយនឹងរក្សាចិត្តឲ្យស្ងប់រម្ងាប់បានទេ ; រឹតតែនាំឲ្យកើតអារម្មណ៍ជាគ្រឿងអផ្សុកចិត្តថែមទៀតក៏មាន ។ ព្រោះហេតុនោះបានជាបណ្ឌិតច្រើនតែចូលចិត្តនឹងសេនាសនៈដ៏ស្ងាត់មានព្រៃភ្នំជាដើម។

ធម្មតាព្រៃភ្នំរមែងជាទីស្រួល គួរឲ្យសរសើរច្រើនយ៉ាង, ទើបជាទីត្រេកអររបស់ពួកយោគី ; តែពួកយោគីដែលចូលទៅនៅក្នុងព្រៃនោះ គួរបង្អោនចិត្តគិតប្រៀបធៀបព្រៃហើយនិងចិត្តរបស់ខ្លួន តាមន័យដែលព្រះនាគសេនត្ថេរថ្វាយព្រះពរព្រះបាទមិលិន្ទ ដូចសំដែងតទៅនេះ ៖

# អង្គនៃព្រៃធំមាន ៥

១. ព្រៃធំជាទីបិទបាំងទុកនូវមនុស្សដែលមិនស្អាតបានដូចម្ដេចមិញ, ព្រះយោគាវចរក៏គប្បីបិទបាំងទុកនូវទោសកំហុសសេចក្ដីភ្លាំងភ្លាត់របស់អ្នកដទៃ ឲ្យដូចជាព្រៃធំដែលបិទបាំងទុកនូវមនុស្សមិនស្អាតដូច្នោះ ;

២. ព្រៃធំជាទីសោះសូន្យទទេឥតមនុស្សទៅមក ដូចម្ដេចមិញ, ព្រះយោគាវចរក៏គប្បីជាអ្នកសូន្យចាកកិលេសទាំងពួងគឺ **រាគៈ, ទោសៈ, មោហៈ, មានះ, ទិដ្ឋិ** ដែលជាបណ្ដាញចាក់ស្រែះនៅក្នុងសន្តាន ឲ្យដូចជាព្រៃធំដែលសូន្យចាកមនុស្សដូច្នោះ ;

៣. ព្រៃធំជាទីស្ងាត់ជ្រងំ ដូចម្ដេចមិញ, ព្រះយោគាវចរក៏គប្បីជាអ្នកស្ងាត់ចាកពួកអកុសលធម៌ដ៏លាមក ដែលជាចិត្តរបស់បុថុជ្ជន មិនមែនជាចិត្តព្រះអរិយៈ ឲ្យដូចជាព្រៃធំដែលស្ងាត់ជ្រងំដូច្នោះ ;

៤. ព្រៃធំជាទីស្ងប់រម្ងាប់ជាទីបរិសុទ្ធ ដូចម្ដេចមិញ, ព្រះយោគាវចរក៏គប្បីជាអ្នកមានចិត្តស្ងប់រម្ងាប់បរិសុទ្ធ គប្បីជាអ្នករំលត់នូវ **មានះ** ( សេចក្ដីប្រកាន់ ) **មក្ខៈ** ( សេចក្ដីលុបគុណលោក ) ឲ្យដូចជាព្រៃធំដែលស្ងប់រម្ងាប់បរិសុទ្ធដូច្នោះ ;

៥. ព្រៃធំជាទីសេពគប់របស់ពួកអរិយជន ដូចម្ដេចមិញ, ព្រះយោគាវចរក៏គប្បីធ្វើខ្លួនឲ្យជាទីសេពគប់របស់អរិយជនដូច្នោះ

សេចក្ដីនេះ សមដូចព្រះពុទ្ធដីកាដែលទ្រង់សំដែងទុកក្នុងសំយុត្តនិកាយដ៏ប្រសើរថា ៖

**បវិវិត្តេហិ អរិយេហិ បហិតត្តេហិ ឈាយិហិ**
**និច្ចំ អារទ្ធវីរិយេហិ បណ្ឌិតេហិ សហាសវេ ។**

សេចក្ដីថា **ព្រះយោគាវចរគប្បីនៅរួមជាមួយនឹងពួកបណ្ឌិតអ្នកស្ងាត់ អ្នកឆ្ងាយចាកកិលេស អ្នកបញ្ជូនចិត្តទៅក្នុងសមាធិជាអ្នកប្រាជ្ញប្រារព្ធសេចក្ដីព្យាយាម ជានិច្ចជាកាលចុះ ។**

# អានិសង្សនៃការនៅក្នុងព្រៃ

ការនៅអាស្រ័យក្នុងព្រៃស្ងាត់ រមែងគួរដើម្បីបានសមាធិដែលមិនទាន់បាន នឹងគួរដើម្បីរក្សាទុកនូវសមាធិដែលបានហើយ ។ ព្រោះហេតុនេះ ទើបព្រះអនាវរណញ្ញាណជាម្ចាស់ទ្រង់ត្រាស់សរសើរភិក្ខុអ្នកកាន់អារញ្ញិកធុតង្គ ថា ៖

**ម្នាលភិក្ខុទាំងឡាយ ! តថាគតមានហឫទ័យរីករាយនឹងនាគិតភិក្ខុពន់ពេក ព្រោះនាគិតភិក្ខុនោះជាអ្នកកាន់អារញ្ញិកធុតង្គនៅក្នុងព្រៃ, អារម្មណ៍គឺរូប សំឡេង ក្លិន រស សម្ផស្ស មិនអាចញ៉ាំងចិត្តភិក្ខុ ដែលនៅក្នុងសេនាសនៈដ៏ស្ងាត់ដូច្នោះឲ្យរវើរវាយឡើយ ។ ភិក្ខុដែលនៅក្នុងសេនាសនៈដ៏ស្ងាត់នោះ តែងប្រាសចាកសេចក្ដីរន្ធត់ចិត្ត ហើយរមែងលះបង់នូវអាល័យក្នុងជីវិតបានត្រេកអរតែនឹងរសនៃសេចក្ដីសុខដែលកើតអំពីវិវេក ។ ន័យមួយទៀត សភាវៈដែលទ្រទ្រង់នូវធុតង្គមានបំសុកូលិកធុតង្គជាដើមក៏សមគួរដល់ភិក្ខុជាអ្នកកាន់អារញ្ញិកធុតង្គនោះដែរ ។**

ព្រោះហេតុដូច្នោះបានជា ព្រះពុទ្ធឃោសាចារ្យលោកនិពន្ធគាថាសរសើរអានិសង្សនៃភិក្ខុអ្នកកាន់អារញ្ញិកធុតង្គថា ៖

**បវិវិត្តោ អសំសដ្ឋោ បន្តសេនាសនេ រតោ**
**អារាធយន្តោ នាថស្ស វនវាសេន មានសំ**
**ឯកោ អរញ្ញេ និវសំ យំ សុខំ លភតេ យតិ**
**រសំ តស្ស ន វិន្ទន្តិ អបិ ទេវា សឥន្ទកា ។**

**បំសុកូលញ្ច ឯសោវ កវចំ វិយ ធារយំ**
**អរញ្ញសង្គាមគតោ អវសេសធុតាយុធោ**
**សមត្ថោ នចិរស្សេវ ជេតុំ មារំ សវាហនំ**
**តស្មា អរញ្ញវាសម្ហិ រតឹ កយិរាថ បណ្ឌិតោ ។**

សេចក្តីថា ព្រះយតិយោគីអ្នកកាន់អាញ្ញិកធុតង្គជាប្រក្រតី ត្រេកអរក្នុងទីសេនាសនៈដ៏ស្ងាត់ ដែលមិនបានច្របូកច្របល់ដោយគ្រហស្ថ ឬបព្វជិត ត្រេកអរក្នុងអារញ្ញិកសេនាសនៈ រមែងញុំាងព្រះហឫទ័យនៃព្រះបរមលោកនាថ ឲ្យទ្រង់រីករាយដោយកិរិយានៅក្នុងព្រៃនោះបាន ; មិនតែប៉ុណ្ណោះ ព្រះយោគាវចរណាមួយកាលនៅក្នុងអរញ្ញប្រទេស រមែងបាននូវរសដែលកើតអំពីសេចក្តីសុខឯណា, ទុកជាពួកទេព្តាមានព្រះឥន្ទ្រាធិរាជជាប្រធានក៏មិនបាននូវរសនៃសេចក្តីសុខនោះដូចលោកដែរ ។ ព្រះយោគាវចរនុ៎ះឯង កាលបើលោកទ្រទ្រង់នូវបំសុកូលិកធុតង្គ ក៏ប្រៀបដូចជាព្រះបរមក្សត្រិយ៍ ទ្រង់គ្រឿងក្រោះឋិតនៅលើផែនដីដែលជាទីធ្វើសង្គ្រាម ព្រះហស្តឆ្វេងស្តាំទ្រង់កាន់នូវអាវុធធ្វើយុទ្ធនាការពោលគឺទ្រទ្រង់នូវធុតង្គក្រៅពីនោះ, មិនយូរប៉ុន្មានក៏អាចផ្ចាញ់មារព្រមទាំងពលពាហនៈ គឺកិលេសទាំងធំទាំងតូចបាន ។

## គុណនៃរុក្ខមូលមាន ១០ យ៉ាង

១. **អប្បសារម្ភតា** មានសេចក្តីប្រុងប្រៀបតិច ;

**២. អបរិគ្គហតា** មិនបាច់ថែទាំទីលំនៅ ( ព្រោះអាស្រ័យនៅតែមួយគ្រា ) ;

**៣. អនុដ្ឋាបនិយតាវោ** មិនបាច់រវល់ទទួលភ្ញៀវ ;

**៤. គរហាយ អប្បដិច្ឆាទតាវោ** មិនលាក់បំពួននូវគ្រឿងដែលគួរតិះដៀល គឺមិនមាននរណាធ្វើអាក្រក់ក្នុងទីដែលបើកឱកាសដូច្នោះបាន ;

**៥. ភាយស្ស អស្សុណ្ណម្ពនតាវោ** មិនបាច់រវាំងខ្លួនក្រែងអន្តរាយ ( ដូចនៅកណ្តាលវាល ) ឡើយ ;

**៦. បរិគ្គហករណតាវោ** មិនបាច់ធ្វើសេចក្តីគ្រប់គ្រង គឺមិនបាច់រវល់ហួងហែង ឬឃាត់មនុស្សដែលនឹងមកអាស្រ័យ ;

**៧. គេហាយ បដិក្ខេបោ** បោះបង់សេចក្តីអាល័យក្នុងទីលំនៅបាន ;

**៨. នីហរណតាវោ** មិនមាននរណាមកបណ្តេញឬដណ្តើមយកទី ;

**៩. វស្សន្តស្ស សប្បីតិកតាវោ** ចង់នៅក៏នៅសប្បាយតាមសេចក្តីពេញចិត្ត ;

**១០. អនបេក្ខតាវោ** មិនបាច់ស្តាយ ( ព្រោះទៅទីណាក៏រកសេនាសនៈគល់ឈើបានដោយងាយ ) ។

# អានិសង្សនៃការនៅទៀបគល់ឈើ

ការនៅទៀបគល់ឈើ ជាសេចក្តីប្រតិបត្តិដ៏សមគួរដល់និស្ស័យ ព្រោះព្រះដ៏មានព្រះភាគជាម្ចាស់ទ្រង់ត្រាស់ថា ៖

**រុក្ខមូលសេនាសនំ និស្សាយ បព្វជ្ជា**
**អ្នកបួសត្រូវអាស្រ័យនៅទៀបគល់ឈើជាសេនាសនៈ ។**

មួយវិញទៀត ភិក្ខុអ្នកទ្រទ្រង់រុក្ខមូលិកធុតង្គ ជាហេតុឲ្យព្រះដ៏មានបុណ្យជាម្ចាស់ត្រាស់សរសើរថា បច្ច័យនឹងកើតដល់ភិក្ខុនោះតិច តែបច្ច័យនោះបានដោយងាយ ឥតមានទោសជាទំនងឲ្យកើតអប្បិច្ឆតាគុណ ។ មិនតែប៉ុណ្ណោះ អនិច្ចសញ្ញានឹងកើតឡើងដល់ព្រះយោគាវចរភិក្ខុនោះ ព្រោះហេតុប្រទះនូវវិការៈនៃដើមឈើរឿយ ៗ នឹងប្រាសចាកសេចក្តីកំណាញ់ក្នុងសេនាសនៈ ប្រាសចាកសេចក្តីត្រេកអរក្នុងនវកម្ម ( ការងារថ្មី ), នៅជាមួយនឹងរុក្ខទេវតា ហើយប្រព្រឹត្តទៅតាមគុណទាំងឡាយមានអប្បិច្ឆតាគុណជាប្រមាណ ។ ព្រោះហេតុនោះបានជាព្រះពុទ្ធឃោសាចារ្យលោកនិពន្ធគាថា សរសើរអានិសង្សនៃភិក្ខុអ្នកកាន់រុក្ខមូលិកធុតង្គថា ៖

**វណ្ណិតោ ពុទ្ធសេដ្ឋេន និស្សយោតិ ច ភាសិតោ**
**និវាសោ បវិវិត្តស្ស រុក្ខមូលសមោ កុតោ**
**អាវាសមច្ឆេរហរេ ទេវតាបរិបាលិតេ**
**បវិវិត្តេ វសន្តោហិ រុក្ខមូលម្ហិ សុព្វតោ**

**អតិរត្តានិ សីលានិ បណ្ណានិ បតិតានិ ច**
**បស្សន្តោ តរុបណ្ណានិ និច្ចសញ្ញំ បនូទតិ**
**តស្មា ហិ ពុទ្ធទាយជ្ជំ ភាវនាភិរតាលយំ**
**វិវិត្តំ នាតិមញ្ញេយ្យ រុក្ខមូលំ វិចក្ខណោ ។**

សេចក្តីថា **លំនៅនៃបុគ្គលអ្នកស្ងាត់ ព្រះសម្មាសម្ពុទ្ធទ្រង់ពោលសរសើរថាជាទីសមគួរដល់និស្ស័យ, បណ្តាទីស្ងាត់រកទីណាឲ្យស្មើនឹងរុក្ខមូលនេះគ្មាន, ភិក្ខុដែលទ្រទ្រង់រុក្ខមូលិកធុតង្គជាប្រក្រតី រមែងនាំបង់នូវអាវាសមច្ឆរិយៈ ( សេចក្តីកំណាញ់ក្នុងអាវាស ) បាន ; ធម្មតាភិក្ខុដែលមានវត្តប្រតិបត្តិល្អ កាលបើនៅក្នុងទីស្ងាត់ គឺរុក្ខមូលដែលទេវតារក្សាហើយ បានទស្សនាការឃើញដើមឈើមានស្លឹកខៀវខ្ចី និងទុំក្រហមដែលជ្រុះចាកទងរមែងបន្ទោបង់នូវនិច្ចសញ្ញា ( សេចក្តីសំគាល់ថាទៀង ) ចេញបាន ; ព្រោះហេតុនោះបានជា ភិក្ខុដែលប្រកបដោយវិចារណប្បញ្ញាត្រេកអរក្នុងការភាវនា មិនត្រូវមើលងាយរុក្ខមូលសេនាសនៈដ៏ស្ងាត់ ដែលជាទ្រព្យមត៌ករបស់ព្រះអរហន្តសម្មាសម្ពុទ្ធបរមគ្រូ ទ្រង់ប្រទានទុកឲ្យនេះឡើយ ។**

ព្រោះការនៅអាស្រ័យក្នុងទីសេនាសនៈដ៏ស្ងាត់ទាំងឡាយមាន រុក្ខមូលជាដើម ជាទីប្រកបដោយប្រយោជន៍ច្រើនដូចពណ៌នាមកនេះ បានជាមានក្នុងអនុសាសនវិធី ( ដែលធ្លាប់ហៅថាផ្តាំនាគ ) ព្រះដ៏មានព្រះភាគជាម្ចាស់ទ្រង់ត្រាស់បង្គាប់ឲ្យភិក្ខុប្រៀនប្រដៅភិក្ខុបួសថ្មីក្នុងវេលាចប់ញត្តិចតុត្ថកម្មវាចាថ្មី ៗ ថា ៖

## រុក្ខមូលសេនាសនំ និស្សាយ បព្វជ្ជា តត្ថ តេ យាវជីវំ ឧស្សាហោ ករណីយោ

## អ្នកបួសត្រូវអាស្រ័យនៅទៀបគល់ឈើជាសេនាសនៈ ( ទីដេក ទីអង្គុយ ) , សេចក្តីព្យាយាមក្នុងការអាស្រ័យនៅដោយរុក្ខមូលសេនាសនៈនោះអ្នកគប្បីធ្វើដរាបដល់អស់ជីវិត ដូច្នេះ ។

រុក្ខមូលសេនាសនៈ រមែងជាទីអភិរម្យរបស់ព្រះយោគីអ្នកប្រាថ្នាសេចក្តីស្ងប់រម្ងាប់ជាធម្មតា, ព្រោះហេតុនេះបានជា ព្រះសម្ពុទ្ធជាបរមសាស្តារបស់យើង ទ្រង់ប្រសូតក្នុងលុម្ពិនីវនឧទ្យាន, ទ្រង់ត្រាស់អនុត្តរសម្មោធិញាណនារុក្ខមូល គឺទៀបគល់ពោធិព្រឹក្ស ទ្រង់រំលត់ខន្ធបរិនិព្វានក្នុងសាលវនោទ្យានក្រោមលង្វែកមែករាំងទាំងគូ ។ ទីដែលព្រះបរមគ្រូទ្រង់ប្រសូត, ទ្រង់ត្រាស់ដឹង, ទ្រង់បរិនិព្វាន សុទ្ធតែក្នុងព្រៃជាសេនាសនៈដ៏ស្ងាត់ទាំងអស់ ។

ការអាស្រ័យសេនាសនៈដ៏ស្ងាត់ដូច្នោះ ហើយព្យាយាមចម្រើនសមណធម៌ ក៏ជាឧបការៈឲ្យបន្ទោបង់សេចក្តីប្រមាទបាន ។ ព្រោះហេតុនោះ បានជាព្រះយោគីអ្នកប្រាថ្នាសេចក្តីស្ងប់ ច្រើនតែគាប់ចិត្តអាស្រ័យនៅក្នុងព្រៃជាទីស្ងាត់ គួរដល់កាយវិវេក ( សេចក្តីស្ងាត់កាយ ) ដែលជាបច្ច័យឲ្យកើតចិត្តវិវេក ( សេចក្តីស្ងាត់ចិត្ត ) និងឧបធិវិវេក ( សេចក្តីស្ងាត់ចាកកិលេស ) ដូច្នេះហើយ, បើនៅព្រៃ កុំគ្រាន់តែស្ងាត់កាយប៉ុណ្ណោះ គួរឲ្យ

ស្ងាត់ទាំងចិត្តនិងកិលេសផង ទើបឃើញថាការនៅក្នុងព្រៃសម្រេចប្រយោជន៍ល្អមែន ; ដូចភិក្ខុ ១ រូបដែលទៅចម្រើនសមណធម៌ក្នុងព្រៃស្ងាត់ ទោះបីឃើញវិសភាគារម្មណ៍ ក៏លោកខំសង្រួមចម្រើនសមណធម៌ដរាបដល់បានសម្រេចព្រះអរហត្តក្នុងទីនោះឯង ។ សូមនាំរឿងនោះមកសំដែងជាឧទាហរណ៍ដូចតទៅនេះ ៖

# រឿង ភិក្ខុមួយរូបចម្រើនធម៌ក្នុងព្រៃ

ភិក្ខុ ១ រូបកំពុងអង្គុយចម្រើនធម៌ក្នុងព្រៃ, គ្រានោះ មានស្ត្រីម្នាក់មត់នឹងបុរសម្នាក់ថានឹងមកជួបគ្នាក្នុងទីនោះ កាលបុរសនោះមិនមក, ស្ត្រីនោះក៏ធ្វើកលមាយាប៉ងនឹងធ្វើឲ្យភិក្ខុនោះខូចសីល ; តែលោកមានសតិសម្បជញ្ញៈល្អ ក៏នឹកសង្វេគខំធ្មេចភ្នែកចម្រើនធម៌ មិនរំភើបឡើយ ។ វេលានោះ ព្រះបរមគ្រូទ្រង់គង់ក្នុងគន្ធកុដិ ទ្រង់ផ្សាយព្រះរស្មីទៅប្រោសប្រាណដូចជាទ្រង់ប្រថាប់ក្នុងទីចំពោះមុខភិក្ខុនោះ ហើយត្រាស់ថា ៖

**រមណីយានិ អរញ្ញានិ យត្ថ ន រមតិ ជនោ**
**វីតរាគា រមេស្សន្តិ ន តេ កាមគវេសិនោ ។**

សេចក្ដីថា **បណ្ឌិតទាំងឡាយជាអ្នកប្រាសចាករាគៈ មិនស្វែងរកកាម រមែងត្រេកអរក្នុងព្រៃជាទីគួររីករាយ ដែលមិនជាទីត្រេកអររបស់មហាជន ។**

នាំរឿងនេះមក ដើម្បីបញ្ជាក់សេចក្ដីឲ្យឃើញច្បាស់ថា ព្រះយោគាវចរដែលនៅអាស្រ័យក្នុងទីសេនាសនៈដ៏ស្ងាត់ គប្បីជាអ្នកស្ងាត់កាយស្ងាត់ចិត្ត និងស្ងាត់ទាំងកិលេសផង ទើបឈ្មោះថា បានសម្រេចប្រយោជន៍តាមអរិយប្បវេណី ។ បើកាយនៅក្នុងព្រៃ តែចិត្តត្រេចទៅស្វែងរកកាមឯក្នុងស្រុក ក៏មិនសម្រេចប្រយោជន៍ ។

ព្រោះហេតុនោះ ព្រះយោគាចវរគប្បីបង្អោនចិត្តគិតរំពឹងតាមន័យដែលព្រះបរមសាស្ដាចារ្យរបស់យើង កាលដែលទ្រង់កំពុងធ្វើទុក្ករកិរិយានៅឡើយ ទ្រង់រំពឹងឃើញច្បាស់ដោយសេចក្ដីឧបមា ៣ យ៉ាង នោះចុះ ។

# សេចក្ដីឧបមា ៣ យ៉ាង

១. សមណព្រាហ្មណ៍ពួកណាមួយ ដែលមានកាយមិនបានចៀសចេញចាកកាម នៅមានសេចក្ដីស្រឡាញ់ពេញចិត្តក្នុងកាម មិនទាន់លះឲ្យស្ងប់រម្ងាប់បានដោយល្អនៅឡើយ, សមណព្រាហ្មណ៍អម្បាលនោះ ទោះបីបានសោយទុក្ខវេទនាដ៏រឹងក្លាផ្សាក្ដៅ ដែលកើតអំពីសេចក្ដីព្យាយាមក្ដី មិនបានសោយក្ដី ក៏មិនគួរនឹងត្រាស់ដឹង ; ដូចឈើស្រស់ដែលជោកដោយជ័រ ហើយបុគ្គលត្រាំទុកក្នុងទឹកថែមទៀត, បុរសឯណាមានសេចក្ដីត្រូវការដោយភ្លើង ក៏កាន់យកឈើពំនួតទៅពួត ដោយសង្ឃឹមថានឹង

កើតភ្លើង បុរសនោះមិនអាចនឹងធ្វើភ្លើងឲ្យកើតឡើងបានឡើយ, បើចេះតែខំពួត មុខជានឿយហត់ឥតអំពើ ព្រោះឈើនោះនៅស្រស់មានជ័រ ហើយថែមទាំងត្រាំទឹកទៀតផង ;

២. សមណព្រាហ្មណ៍ពួកណាមួយ ទោះបីមានកាយចៀសចេញចាកកាមហើយ តែនៅមានសេចក្ដីស្រឡាញ់ពេញចិត្តក្នុងកាមនៅឡើយ មិនទាន់លះឲ្យស្ងប់រម្ងាប់បានដោយល្អ, សមណព្រាហ្មណ៍អម្បាលនោះ ទោះបីបានសោយទុក្ខវេទនាដូច្នោះ ដែលកើតអំពីសេចក្ដីព្យាយាមក្ដី មិនបានសោយក្ដី ក៏មិនគួរនឹងត្រាស់ដឹងទេ ; ដូចឈើស្រស់ដែលជោកដោយជ័រស្ងួម្បីបុគ្គលតម្កល់ទុកលើគោកឲ្យឃ្លាតឆ្ងាយពីទឹកហើយ ក៏បុរសមិនអាចពួតឲ្យកើតភ្លើងបានឡើយ, បើចេះតែខំពួត មុខជានឿយហត់ឥតអំពើ ព្រោះឈើនោះតម្កល់នៅលើគោកក៏ពិតហើយប៉ុន្តែនៅជារបស់ស្រស់ ជោកដោយជ័រនៅឡើយ ;

៣. សមណព្រាហ្មណ៍ពួកណាមួយ មានកាយចៀសចេញចាកកាមហើយ ទាំងសេចក្ដីស្រឡាញ់ពេញចិត្តក្នុងកាមក៏លះបង់ឲ្យស្ងប់រម្ងាប់ល្អហើយ, សមណព្រាហ្មណ៍អម្បាលនោះ ទោះបីបានសោយទុក្ខវេទនាដូច្នោះ ដែលកើតអំពីសេចក្ដីព្យាយាមក្ដី មិនបានសោយក្ដី ក៏គួរនឹងត្រាស់ដឹងបាន ; ដូចឈើក្រៀមដែលឃ្លាតឆ្ងាយចាកទឹក បុគ្គលតម្កល់លើគោកទើបបុរសអាចពួតឲ្យកើតភ្លើងឡើងបាន ព្រោះជារបស់ស្ងួតហើយថែមទាំងនៅលើគោកទៀតផង ។

កាលបើព្រះយោគាវចរបានបង្អោនចិត្តគិតរំពឹងតាមសេចក្ដីឧបមាដែលព្រះបរមត្រៃលោកាចារ្យទ្រង់បានធ្លាប់ពិចារណាដូចថាមកនេះហើយ, មុខជានឹងឃើញថា ការដែលនៅអាស្រ័យក្នុងព្រៃស្ងាត់នោះ លុះតែស្ងាត់ទាំងកាយទាំងចិត្ត និងស្ងាត់ចាកកិលេស ទើបវិសេសតាមអរិយប្បវេណីមែន ។

## នៅព្រៃតែមិនស្ងាត់ចាកកាម

ព្រះយោគាវចរណាមួយ ដែលមានកាយចៀសចេញចាកវត្ថុកាម ទៅនៅអាស្រ័យក្នុងព្រៃជាទីស្ងាត់ហើយ, ប៉ុន្តែមិនហាមឃាត់ចិត្តឲ្យស្ងាត់ចាកកិលេសកាម បណ្ដោយឲ្យចិត្តប្រព្រឹត្តទៅតាមអំណាចវិតក្កៈទាំង ៣ គឺ **កាមវិតក្កៈ** ( សេចក្ដីត្រិះរិះស្វែងរកកាម ) **ព្យាបាទវិតក្កៈ** (សេចក្ដីត្រិះរិះចងគំនុំនឹងអ្នកដទៃ ) **វិហឹសា - វិតក្កៈ** ( សេចក្ដីត្រិះរិះប៉ងនឹងបៀតបៀនអ្នកដទៃ ) ក៏មិនវិសេសជាងអ្នកនៅចម្រើនសមណធម៌ក្នុងស្រុក ដែលស្ងាត់ចាកកាមនោះប៉ុន្មានទេ ; ដូចព្រះថេរៈ ១ រូបឈ្មោះ **មេឃិយៈ** ដែលទៅនៅក្នុងព្រៃមិនបានសម្រេចគុណវិសេសអ្វីឡើយ ព្រោះតែលុះអំណាចវិតក្កៈទាំង ៣ នោះ លុះត្រឡប់មកនៅស្រុកវិញ បានស្ដាប់ធម្មីកថា ដែលព្រះបរមសាស្ដាទ្រង់សំដែងក្នុងវត្តជេតពនទើបបានសម្រេចព្រះអរហត្តក្នុងទីនោះឯង ។ សូមនាំរឿងនោះមកសំដែងជាឧទាហរណ៍ដូចតទៅនេះ ៖

# រឿង ព្រះមេឃិយត្ថេរ

កាលដែលព្រះអានន្ទត្ថេរមិនទាន់ទទួលនាទីជាពុទ្ធុបដ្ឋាកនៅឡើយ ។ គ្រានោះ ព្រះមេឃីយត្ថេរលោកជាពុទ្ធុបដ្ឋាកកំពុងតែបម្រើព្រះដ៏មានព្រះភាគតែសព្វថ្ងៃ ។ វេលាមួយលោកបានទៅឃើញអម្ពវន ( ព្រៃស្វាយ ) ជាទីរមណីយដ្ឋាន ក៏ក្រាបបង្គំលាព្រះបរមសាស្តាបម្រុងនឹងទៅបំពេញព្យាយាមក្នុងទីនោះ ។ ព្រះបរមសាស្តាទ្រង់ឃាត់ថា ចូរអ្នកបង្អង់សិន ទម្រាំបានភិក្ខុដទៃមកជាឧបដ្ឋាកតថាគតសិន សឹមទៅចុះ ។ ព្រះមេឃិយៈមិនស្តាប់ ក្រាបបង្គំទូលទាស់ដោយប្រការផ្សេង ៗ ថា ៖

- " ចំណែកព្រះអង្គបានសម្រេចកិច្ចហើយ, ខ្ញុំព្រះអង្គមានកិច្ចត្រូវធ្វើតទៅទៀត មិនទាន់ស្រេច ",

ក្រាបបង្គំទូលដូច្នេះហើយ ក៏ចៀសចេញទៅ ។ លុះទៅនៅក្នុងទីនោះត្រូវអកុសលវិតក្កៈគ្របសង្កត់ អផ្សុកនៅមិនបានក៏ត្រឡប់មកគាល់ព្រះបរមគ្រូវិញ ហើយក្រាបបង្គំទូលសេចក្តីនុ៎ះឲ្យទ្រង់ជ្រាប ។ ព្រះអង្គត្រាស់ព្រះគាថានេះថា ៖

**ផន្ទនំ ចបលំ ចិត្តំ ទុរក្ខំ ទុន្និវារយំ**
**ឧជុំ ករោតិ មេធាវី ឧសុការោវ តេជនំ**
**វារិជោវ ថលេ ខិត្តោ ឱកមោកតឧព្ភតោ**
**បរិផន្ទតិទំ ចិត្តំ មារធេយ្យំ បហាតវេ ។**

សេចក្ដីថា **អ្នកមានប្រាជ្ញាតែងពត់ចិត្ត ដែលញាប់ញ័រឃ្លេងឃ្លោង ដែលរក្សាបានដោយកម្រ ឃាត់បានដោយកម្រឲ្យជាចិត្តត្រង់ទៅបាន ; ដូចជាងធ្វើព្រួញពត់ព្រួញឲ្យត្រង់នោះឯង ។ ធម្មតាវារិជាតិ ( សត្វកើតក្នុងទឹកមានត្រីជាដើម ) ដែលបុគ្គលស្រង់ឡើងផុតពីទឹកហើយគ្រវែងទៅលើគោក តែងបម្រះនឿលយ៉ាងណាមិញ ; ចិត្តនេះដែលយោគាវចរលើកឲ្យផុតពីទីធ្លាប់នៅគឺកាមគុណប្រាំ ហើយបោះទៅលើគោក គឺវិបស្សនាកម្មដ្ឋានបម្រុងនឹងលះចំណងមារក៏រមែងញាប់ញ័រដូច្នោះដែរ ។**

នាំរឿងនេះមក ដើម្បីបញ្ជាក់សេចក្ដីឲ្យឃើញច្បាស់ថា ការដែលព្រះយោគីនៅអាស្រ័យក្នុងព្រៃជាទីសេនាសនៈដ៏ស្ងាត់គួរឲ្យស្ងាត់ទាំងកាយទាំងចិត្ត និងស្ងាត់ចាកឧបធិ ទើបឈ្មោះថាបានទទួលមតិក គឺការនៅក្នុងទីសេនាសនៈដ៏ស្ងាត់ ដែលព្រះអរហន្តសម្មាសម្ពុទ្ធជាបរមគ្រូទ្រង់ប្រទានទុកឲ្យនោះ ដោយប្រពៃ ។

**ពាក្យ**ដែលពោលសរសើរសេនាសនៈដ៏ស្ងាត់ ដូចពោលមកហើយនេះ រាប់ថាជា **ពុទ្ធសាសនា** ពាក្យប្រដៅរបស់ព្រះពុទ្ធទាំងឡាយ គឺព្រះពុទ្ធរាល់ព្រះអង្គដែលបានត្រាស់ក្នុងកាលទាំងពួង តែងប្រដៅដូច្នេះ ។

# ចប់កណ្ឌទី ១០



# ឱវាទបាតិមោក្ខ កណ្ឌទី ១១

**លំដាប់នេះ** នឹងអធិប្បាយសេចក្តីនៃព្រះបរមពុទ្ធោវាទ ក្នុងឱវាទបាតិមោក្ខ ត្រង់បទថា ៖

**អធិចិត្តេ ច អាយោគោ**
**ការបំពេញព្យាយាមក្នុងអធិចិត្ត**

នោះ, ឲ្យមានសេចក្តីពិស្តារ ដើម្បីជាគ្រឿងប្រដាប់សតិបញ្ញា និងជាវត្តប្រតិបត្តិរបស់សាធុជនពុទ្ធបរិស័ទ ដូចតទៅនេះ ៖

ចិត្តដែលបានសម្រេចសមាបត្តិ ៨ មានវិបស្សនាជាបាទ ឬ ចិត្តដែលបានសម្រេចមគ្គផល ហៅថា **អធិចិត្ត**, ការដែលប្រឹង ប្រកបធ្វើអធិចិត្តឲ្យកើតឲ្យមានឡើង ហៅថា **បំពេញព្យាយាម ក្នុងអធិចិត្ត** ។

សមាបត្តិ ៨ នោះ លោកចែកជា ២ ផ្នែក គឺ ៖

១. **រូបសមាបត្តិ** ឬហៅថា **រូបជ្ឈាន** ក៏បាន

២. **អរូបសមាបត្តិ** ឬហៅថា **អរូបជ្ឈាន** ក៏បាន

**រូបសមាបត្តិ** បានខាងឈាន ៤ គឺ ៖

១. **បឋមជ្ឈាន** ឈានទី ១ ;

២. **ទុតិយជ្ឈាន** ឈានទី ២ ;

៣. **តតិយជ្ឈាន** ឈានទី ៣ ;
៤. **ចតុត្ថជ្ឈាន** ឈានទី ៤ ;

## នីវរណៈ ៥

ធម៌ដែលរាំងរាចិត្តមិនឲ្យសម្រេចឈានសមាបត្តិ ហៅថា នីវរណៈ ។ នោះ មាន ៥ យ៉ាង គឺ ៖

១. **កាមឆន្ទ** សេចក្ដីត្រេកត្រអាលក្នុងកាមគុណ ;
២. **ព្យាបាទ** សេចក្ដីព្យាបាទគុំកួន ;
៣. **ថីនមិទ្ធ** សេចក្ដីច្រអូសកាយច្រអូសចិត្ត ងោកងុយដេក ;
៤. **ឧទ្ធច្ចកុក្កុច្ច** សេចក្ដីរវើរវាយអន្ទះអន្ទែង ;
៥. **វិចិកិច្ឆា** សេចក្ដីសង្ស័យមិនដាច់ស្រេច ។

## កំណើតនីវរណៈ ៥

១. **កាមឆន្ទ** កើតអំពីសុភនិមិត្ត សម្គាល់ថាល្អថាស្អាត ;

២. **ព្យាបាទ** កើតអំពីបដិឃនិមិត្ត សម្គាល់ក្នុងសេចក្ដីចង្អៀតចង្អល់ថ្នាំងថ្នាក់ចិត្ត ;

៣. **ថីនមិទ្ធ** កើតអំពីអរតិ សេចក្ដីមិនត្រេកអរ, សេចក្ដី

ខ្ជិលច្រអូសធុញទ្រាន់ និងសេចក្ដីស្រវឹងព្រោះឆ្អែតអាហារ ;

**៤. ឧទ្ធច្ចកុក្កុច្ច** កើតអំពីចេតសោអវូបសម សេចក្ដីមិនស្ងប់ចិត្ត ;

**៥. វិចិកិច្ឆា** កើតអំពីអយោនិសោមនសិការ សេចក្ដីមិនធ្វើទុកក្នុងចិត្តដោយយោបល់ ។

នីវរណៈទាំង ៥ នេះ ទុកជាបុគ្គលមិនមានចេតនាប្រាថ្នាចង់ឲ្យកើត ក៏អាចកើតឡើងបាន ព្រោះធ្លាប់ស្និទ្ធស្នាលមកយូរហើយ ។

# ធម៌ជាគ្រឿងកំចាត់នីវរណៈ ៥

**១. កាមឆន្ទនីវរណៈ** កំចាត់ដោយអសុភនិមិត្ត សេចក្ដីសម្គាល់ថា មិនល្អមិនស្អាត ។

ម្យ៉ាងទៀត ធម៌ ៦ ប្រការ លោកពោលថាជាធម៌សម្រាប់លះកាមឆន្ទនីវរណៈ គឺ ៖

**ក). អសុភនិមិត្ត ឧគ្គហោ** រៀននិមិត្តក្នុងអសុភ - កម្មដ្ឋាន ;

**ខ). អសុភភាវនានុយោគោ** ខំចម្រើនអសុភកម្មដ្ឋាន;

**គ). ឥន្ទ្រិយេសុ គុត្តទ្វារតា** សង្រួមទ្វារក្នុងឥន្ទ្រិយទាំង ៦ ;

**ឃ). ភោជនេ មត្តញ្ញុតា** ដឹងប្រមាណក្នុងភោជន ;

ង). **កល្យាណមិត្តា** គប់ប្រសព្វនឹងកល្យាណមិត្ត ;

ច). **សប្បាយកថា** និយាយសំដីដែលជាទីសប្បាយ គឺពាក្យដែលគួរនិយាយ ;

**២. ព្យាបាទនីវរណៈ** កំចាត់ដោយមេត្តាភាវនាការចម្រើនមេត្រីចិត្តទៅរកសត្វទាំងឡាយទាំងពួង ។

ម្យ៉ាងទៀត ធម៌ ៦ ប្រការ លោកពោលថាជាធម៌សម្រាប់លះព្យាបាទនីវរណៈ គឺ ៖

ក). **មេត្តានិមិត្តស្ស ឧគ្គហោ** រៀននិមិត្តក្នុងមេត្តា ;

ខ). **មេត្តាភាវនានុយោគោ** ខំចម្រើនមេត្តាភាវនា ;

គ). **កម្មស្សកតាបច្ចវេក្ខណា** ពិចារណាសេចក្ដីដែលសត្វមានកម្មជារបស់ ៗ ខ្លួន ;

ឃ). **បដិសង្ខាពហុលតា** ខំរំពឹងពិចារណាច្រើនដង ;

ង). **កល្យាណមិត្តតា** គប់ប្រសព្វនឹងកល្យាណមិត្ត ;

ច). **សប្បាយកថា** និយាយតែសម្ដីដែលជាទីសប្បាយគឺពាក្យដែលគួរនិយាយ ;

**៣. ថីនមិទ្ធនីវរណៈ** កំចាត់បង់ដោយបណ្ដុះសេចក្ដីព្យាយាមឲ្យមានឡើង ។

ម្យ៉ាងទៀត លោកពោលថាធម៌ ៦ ប្រការជាធម៌សម្រាប់លះថីនមិទ្ធនីវរណៈ គឺ ៖

**ក). អតិភោជនេ និមិត្តគ្គាហោ** កាន់យកនិមិត្ត គឺនឹកសង្កេតក្នុងការបរិភោគច្រើនពេក ;

**ខ). ឥរិយាបថសម្បរិវត្តនតា** ខំផ្លាស់ប្តូរឥរិយាបថឲ្យបានស្រួល ;

**គ). អលោកសញ្ញាមនសិការោ** មនសិការៈអលោក-សញ្ញា គឺខំធ្វើចិត្តឲ្យស្វាង ;

**ឃ). អព្ភោកាសវាសោ** នៅតែក្នុងទីវាល ទីទំនេរ ;

**ង). កល្យាណមិត្តតា** គប់ប្រសព្វតែនឹងកល្យាណមិត្ត ;

**ច). សប្បាយកថា** និយាយតែសម្តីដែលជាទីសប្បាយ គឺពាក្យដែលគួរនិយាយ ។

**៤. ឧទ្ធច្ចកុក្កុច្ចនីវរណៈ** កំចាត់បង់ដោយធ្វើចិត្តឲ្យស្ងប់ ។

ម្យ៉ាងទៀត ធម៌ ៦ ប្រការ លោកពោលថាជាធម៌សម្រាប់លះឧទ្ធច្ចកុក្កុច្ចនីវរណៈ គឺ ៖

**ក). ពហុស្សុតតា** សភាពជាបុគ្គលបានស្តាប់ បានរៀនច្រើន ;

**ខ). បរិបុច្ឆកតា** ប្រឹងសាកសួរនូវកិច្ចដែលគួរ និងមិនគួរ ;

**គ). វិនយេ បកតញ្ញុតា** ចេះដឹងស្ទាត់ក្នុងវិន័យ ;

**ឃ). វុឌ្ឍសេវតា** ចូលទៅរកលោកអ្នកចាស់ព្រឹទ្ធាចារ្យ ឬលោកអ្នកចម្រើនដោយគុណ ;

ង). **កល្យាណមិត្តតា** ភប់ប្រសព្វតែនឹងកល្យាណមិត្ត ;

ច). **សប្បាយកថា** និយាយតែសម្ដីដែលជាទីសប្បាយ គឺពាក្យដែលគួរនិយាយ ។

៥. **វិចិកិច្ឆានីវរណៈ** កំចាត់បង់ដោយយោនិសោមនសិការៈ ធ្វើទុកក្នុងចិត្តដោយយោបល់ ។

ម្យ៉ាងទៀត ធម៌ ៦ ប្រការ លោកពោលថាជាធម៌សម្រាប់ លះវិចិកិច្ឆានីវរណៈ គឺ ៖

ក). **ពហុស្សុតតា** សភាពជាបុគ្គលបានស្ដាប់ បានរៀន ច្រើន ;

ខ). **បរិបុច្ឆកតា** ប្រឹងសាកសួរនូវកិច្ចដែលគួរ និងមិន គួរ ;

គ). **វិនយេ បកតញ្ញុតា** ចេះដឹងស្ទាត់ក្នុងវិន័យ ;

ឃ). **អធិមោក្ខពហុលតា** ច្រើនដោយការបង្អោនចិត្តជឿ;

ង). **កល្យាណមិត្តតា** ភប់ប្រសព្វតែនឹងកល្យាណមិត្ត ;

ច). **សប្បាយកថា** និយាយតែសម្ដីដែលជាទីសប្បាយ គឺពាក្យដែលគួរនិយាយ ។

# ប្រៀបនីវរណៈធម៌ ៥ នឹងទឹក ៥ យ៉ាង

នីវរណៈធម៌ទាំង ៥ នេះជាគ្រឿងរាំងរាចិត្តមិនឲ្យបានឈាន លោកសម្ដែងដោយសេចក្ដីប្រៀបធៀប ដូច្នេះ ថា ៖

១. **កាមឆន្ទ** ដូចទឹកដែលលាយដោយពណ៌ផ្សេង ៗ ;

២. **ព្យាបាទ** ដូចទឹកក្ដៅដែលកំពុងពុះកញ្ជ្រោល ;

៣. **ថីនមិទ្ធ** ដូចទឹកដែលចកនិងសារាយបិទបាំង ;

៤. **ឧទ្ធច្ចកុក្កុច្ច** ដូចទឹកដែលខ្យល់កួចឲ្យខ្ទាយឡើងជានិច្ច ;

៥. **វិចិកិច្ឆា** ដូចទឹកដែលល្អក់ហើយទុកក្នុងទីងងឹត ;

កាលបើទឹកប្រែប្រួលទៅផ្សេង ៗ ដូច្នេះហើយ, បុគ្គលមិនអាចឆ្លុះមើលស្រមោលមុខបាន យ៉ាងណាមិញ ; នីវរណៈក៏ជាគ្រឿងរាំងរាចិត្តមិនឲ្យឃើញសេចក្ដីល្អ យ៉ាងនោះដែរ ។

# រូបសមាបត្តិ ឬរូបជ្ឈាន

រូបសមាបត្តិ ឬរូបជ្ឈាននោះ ចែកជា ៤ គឺ ៖

១. ការដែលបុគ្គលព្យាយាមកំចាត់នីវរណៈទាំង ៥ នោះឲ្យប្រាសចាកសន្ដានទៅបានហើយធ្វើចិត្តឲ្យតិចចុះ បើយ៉ាងច្រើនត្រឹម ៥ គឺ ៖

**ក**). **វិតក្ក** សេចក្ដីត្រិះរិះរំពឹង ;

**ខ). វិចារ** សេចក្តីពិចារណា ;

**គ). បីតិ** សេចក្តីពេញចិត្ត ឆ្អែតចិត្តក្នុងអារម្មណ៍ ;

**ឃ). សុខ** សេចក្តីសុខស្រួល ;

**ង). ឯកគ្គតា** ចិត្តមានអារម្មណ៍តែមួយ ;

ដូច្នេះ ហៅថា បឋមជ្ឈាន ។

២. ធ្វើចិត្តឲ្យមានអារម្មណ៍ថយតិចចុះមកទៀត លះវិតក្កៈនិងវិចារៈចេញ នៅសល់តែ ៣ យ៉ាង គឺ **បីតិ សុខ** និង ឯកគ្គតា ;

ដូច្នេះ ហៅថា ទុតិយជ្ឈាន ។

៣. ធ្វើចិត្តឲ្យមានអារម្មណ៍ថយតិចចុះមកទៀត លះបីតិចេញ នៅសល់តែ ២ យ៉ាង គឺ **សុខ** និង **ឯកគ្គតា** ;

ដូច្នេះ ហៅថា តតិយជ្ឈាន ។

៤. ធ្វើចិត្តឲ្យមានអារម្មណ៍ថយតិចចុះមកទៀត លះសុខចេញ នៅសល់តែ ២ យ៉ាង គឺ **ឯកគ្គតា** និង **ឧបេក្ខា** ;

ដូច្នេះ ហៅថា ចតុត្ថជ្ឈាន ។

# អធិប្បាយអំពីរូបជ្ឈាន

មុនដែលនឹងពិចារណាដល់រឿងឈាននោះ ត្រូវធ្វើសេចក្តីចូលចិត្តទុកជាមុនថា " ចិត្តរបស់មនុស្សយើងរមែងមានធម្មជាតិច្រើនយ៉ាង ល្អខ្លះ អាក្រក់ខ្លះ លាយឡំគ្នា ជាធម្មតា " ។ ឯសេចក្តីអាក្រក់នោះ បើពោលដោយច្រើនបំផុត មានដល់

១៥០០ ដែលហៅថា កិលេស ; តែក្នុងទីនេះ មិនបានចែកឲ្យច្រើនដល់ទៅប៉ុណ្ណោះទេ, នឹងស្រង់យកតែត្រឹម ១០ គឺខាងល្អ ៥ ខាងអាក្រក់ ៥ មកត្រដាងទុកក្នុងទីនេះ ដើម្បីឲ្យឃើញថាល្អ, អាក្រក់ ដាច់ដោយឡែកពីគ្នា ; ខាងល្អសំដៅយកអង្គឈាន, ខាងអាក្រក់សំដៅយកនីវរណៈ មករៀបរៀងជាជួរ ៗ , ចំណែកល្អ ១ ជួរ, ចំណែកអាក្រក់ ១ ជួរ ដូច្នេះគឺ ៖

| **ចំណែកល្អ** | **ចំណែកអាក្រក់** |
|---|---|
| **១. សមាធិ** | **៦. កាមឆន្ទ** |
| **២. បីតិ** | **៧. ព្យាបាទ** |
| **៣. វិតក្ក** | **៨. ថីនមិទ្ធ** |
| **៤. សុខ** | **៩. ឧទ្ធច្ចកុក្កុច្ច** |
| **៥. វិចារ** | **១០. វិចិកិច្ឆា** |

នេះជាលក្ខណៈដួងចិត្តរបស់មនុស្សធម្មតា គឺដួងចិត្តរបស់មនុស្សរមែងជាសមាធិតម្កល់ខ្ជាប់បានខ្លះដោយពេល, តែបើកើតកាមឆន្ទៈស្រឡាញ់ក្នុងអារម្មណ៍ណាមួយឡើង ក្នុងកាលណា, សមាធិក៏ខូចទៅកាលនោះ ; ចិត្តក៏អណ្ដែតទៅដោយរហ័សតាមប្រក្រតី, ចិត្តរបស់មនុស្សយើងរមែងមានបីតិរីករាយ តែបើងាកទៅនឹកដល់អារម្មណ៍ដែលគេធ្វើមិនគាប់ចិត្តឡើងកាលណា, បីតិក៏បាត់ទៅកាលនោះ ; ត្រឡប់ក្លាយទៅជាព្យាបាទវិញ ។ មនុស្សយើងរមែងមានចិត្តសម្រាប់នឹក សម្រាប់គិតដល់អារម្មណ៍

ជាធម្មតា ដែលហៅថាត្រិះរិះ ឬហៅថាវិតក្កៈ, ប៉ុន្តែមានវេលាខ្លះ ក៏លើកគំនិតចោលទៅ លែងនឹកលែងគិត ព្រោះចិត្តងោកងុយដេក ដែលជាថីនមិទ្ធៈចូលមកគ្របសង្កត់ ។ តាមធម្មជាតិដែលបង្កើតមនុស្សយើងឲ្យកើតមកមានសេចក្ដីសុខ, ទាំងមនុស្សយើងសោតក៏ត្រូវការសេចក្ដីសុខគ្រប់គ្នាទាំងអស់ ; តែចួនកាលកើតឧទ្ធច្ចៈសេចក្ដីរាយមាយ និងកុក្កុច្ចៈអន្ទះអន្ទែងចិត្តឡើងមកក៏ដាច់សេចក្ដីសុខទៅ ។ ធម្មតាមនុស្សយើងរមែងមានវិចារ-បញ្ញាសម្រាប់ពិចារណារកផ្លូវដែលជាប្រយោជន៍របស់ខ្លួន, តែបើវិចិកិច្ឆាកើតឡើង, វិចារៈក៏បាត់ទៅ ត្រឡប់ជាងឿងឆ្ងល់មិនដាច់ស្រេចទៅខាងណា គិតអ្វីក៏មិនសម្រេច ។

កាលបើសាធុជនជាអ្នកមើលនិងជាអ្នកស្ដាប់ ចូលចិត្តសេចក្ដីអធិប្បាយដូចខាងនេះដោយល្អហើយ, ការដែលនឹងចូលចិត្តដល់ឈាននោះក៏នឹងងាយឡើងជាលំដាប់ដូចតទៅនេះ គឺ ៖

១. អ្នកដែលសម្រេចបឋមជ្ឈាននោះ អាចកាត់នីវរណៈទាំង ៥ ដែលជាចំណែកអាក្រក់នោះចេញបាន, នៅសល់តែចំណែកល្អទាំង ៥ គឺ សមាធិ បីតិ វិតក្កៈ សុខៈ និងវិចារៈ ។

២. តែថា ធម្មជាតិដែលជាចំណែកល្អទាំង ៥ នេះ, វិតក្កៈ និងវិចារៈ នៅជារបស់គ្រោតគ្រាត ជាហេតុធ្វើចិត្តឲ្យរោយរាយនៅឡើយ ។ ហេតុនោះបានជា ត្រូវព្យាយាមរំលត់វិតក្កៈ និងវិចារៈចេញ, ឲ្យនៅសល់តែសមាធិ បីតិ និងសុខៈ ។ អ្នក

ដែលធ្វើឲ្យសម្រេចដូច្នេះ ហៅថា បានទុតិយជ្ឈាន ។

៣. បីតិ សេចក្តីឆ្អែតចិត្តនោះ ក៏ជាធម្មជាតិនៅទ្រេតទ្រោតនៅឡើយ គួរខ្លាចដែរ ក្រែងលោនឹកនាំយកធម្មជាតិចំណែកខាងអាក្រក់ត្រឡប់ចូលមកវិញ ។ ហេតុនេះបានជាត្រូវព្យាយាមកំចាត់បីតិចោលចេញទៀត, ឲ្យនៅសល់តែសមាធិ និងសុខ: ។ អ្នកដែលធ្វើឲ្យសម្រេចដូច្នេះ ហៅថា បានតតិយជ្ឈាន ។

៤. ប៉ុន្តែបើទុកជាដូច្នោះ សេចក្តីសុខក៏នៅជាធម្មជាតិគ្រោតគ្រៀតទៀត, កំពុងតែមានសុខ សេចក្តីទុក្ខក៏រមែងកើតឡើងក្នុងវេលាណាមួយ ដ្បិតជាគូនឹងគ្នា ។ ព្រោះហេតុនេះបានជា ត្រូវតែលះសុខចេញទៀត, ឲ្យនៅសល់តែសមាធិមួយ ; កាលបើដូច្នោះ ចិត្តក៏រមែងជាឧបេក្ខា គឺព្រងើយមិននាំពាអ្វី ៗ ទាំងអស់ មានដួងចិត្តមូលតែមួយយ៉ាងស៊ប់ ដែលហៅថា **ឯកគ្គតា** ។ យ៉ាងនេះ ហៅថា បានសម្រេចចតុត្ថជ្ឈាន ។

តាមន័យដែលពោលមកហើយខាងដើមនេះ ក៏ឃើញថាពាក្យដែលហៅថាឈាន ៗ នោះ ទោះបីនឹងធ្វើបានដោយកម្រក្រៃពេកក៏មែនពិតហើយ, តែការដែលនឹងចូលចិត្ត ឬនឹងយល់លក្ខណៈរបស់ឈាននោះ មិនក្រដូចជាយើងធ្លាប់នឹកខ្លាចមកពីដើមនោះទេ ។

ដោយមានប្រាថ្នាចង់ឲ្យស្រួលដល់លោកអ្នកសិក្សា បាន

ជាធ្វើផែនទីឬតារាង ដើម្បីត្រដាងឲ្យឃើញលក្ខណៈចិត្តរបស់អ្នកដែលបានឈានទាំង ៤ នេះដោយច្បាស់លាស់នឹងដើម្បីឲ្យបានជ្រាបថា ៖ " ការដែលធ្វើចិត្តឲ្យបានសម្រេចឈានជាជាន់ ៗ នោះក៏គឺជជុះរលាស់សន្តានចិត្តដែលអាក្រក់ ៗ ចោលចេញហើយរើសយកតែស្អាត ៗ ល្អ ៗ ជាថ្នាក់ ៗ ដរាបដល់សល់នៅសុទ្ធតែខ្លឹម ៗ ដែលជារបស់ល្អទីបំផុត ទើបយកទុក " ដូចយកទឹកដែលល្អមកត្រងជាលំដាប់ ៗ ឲ្យនៅសល់តែថ្លា ៗ ដូច្នោះ ។

ឯផែនទីឬតារាងនោះ ដូចតទៅនេះ ៖

## ចិត្តមនុស្សធម្មតា

| | |
|---|---|
| ១. សមាធិ | ៦. កាមឆន្ទ |
| ២. បីតិ | ៧. ព្យាបាទ |
| ៣. វិតក្ក | ៨. ថីនមិទ្ធ |
| ៤. សុខ | ៩. ឧទ្ធច្ចកុក្កុច្ច |
| ៥. វិចារ | ១០. វិចិកិច្ឆា |

## ចិត្តអ្នកបានបឋមជ្ឈាន

| | |
|---|---|
| ១. សមាធិ | ៣. វិតក្ក |
| ២. បីតិ | ៤. សុខ |

| | | | |
|---|---|---|---|
| ៥. | វិចារ | ៨. | ..... |
| ៦. | ..... | ៩. | ..... |
| ៧. | ..... | ១០. | ..... |

# ចិត្តអ្នកបានទុតិយជ្ឈាន

| | | | |
|---|---|---|---|
| ១. | សមាធិ | ៦. | ..... |
| ២. | បីតិ | ៧. | ..... |
| ៣. | ..... | ៨. | ..... |
| ៤. | សុខ | ៩. | ..... |
| ៥. | ..... | ១០. | ..... |

# ចិត្តអ្នកបានតតិយជ្ឈាន

| | | | |
|---|---|---|---|
| ១. | សមាធិ | ៦. | ..... |
| ២. | ..... | ៧. | ..... |
| ៣. | ..... | ៨. | ..... |
| ៤. | សុខ | ៩. | ..... |
| ៥. | ..... | ១០. | ..... |

# ចិត្តអ្នកបានចតុត្ថជ្ឈាន

**១. សមាធិ** [១] **៦.** .....
**២.** ..... **៧.** .....
**៣.** ..... **៨.** .....
**៤.** ..... **៩.** .....
**៥.** ..... **១០.** .....

នេះជាសេចក្ដីអធិប្បាយអំពីរូបសមាបត្តិ ឬរូបជ្ឈានទាំង ៤ ។

## អរូបសមាបត្តិ ឬអរូបជ្ឈាន

ឯអរូបសមាបត្តិ ឬអរូបជ្ឈាន នោះ ចែកជា ៤ ដូចគ្នា គឺ ៖

១. ពិចារណាធ្វើបដិភាគនិមិត្តរបស់កសិណអម្បាលនោះ

(១) ក្នុងទីឯទៀត ពោលថា ចតុត្ថជ្ឈាន មានអង្គ ២ គឺ ឯកគ្គតា និងឧបេក្ខា, ក្នុងទីនេះម្ដេចក៏ថាតែសមាធិ ១ ? សេចក្ដីនេះ សូមលោកអ្នកធម៌ សន្និដ្ឋានថា ការតម្កល់ចិត្តនឹងក្នុងអារម្មណ៍តែមួយ ហៅថា សមាធិ, ចិត្តមានអារម្មណ៍មូលតែមួយ ហៅថា ឯកគ្គតា ទាំង ២ បទនេះ បើសំឡឹងតាមរូបព្យញ្ជនៈ ឃើញថាប្លែកគ្នា តែរូបសេចក្ដីជាមួយគ្នាទេ បានជាចូនកាលលោកហៅថា ឯកគ្គតាសមាធិ រូបគ្នាតែម្ដង ។ កាលបើចិត្តជាឯកគ្គតា ឬសមាធិវេលាណា ទៀងតែជាឧបេក្ខាវេលានោះ ។ ព្រោះហេតុដូច្នោះបានជា ក្នុងទីនេះសំដៅយកតែសមាធិ ១ មកពោលជាការស្រេចតែម្ដង មិនបាច់និយាយដល់ឯកគ្គតា និងឧបេក្ខាឡើយ ។

ដរាបជារបស់ទទេ ដែលហៅថា **បើកកសិណ** ហើយយកអាកាសជាអារម្មណ៍ បរិកម្មថា ៖ " **អនន្តោ អាកាសោ ៗ អាកាសឥតទីបំផុត ៗ** " ; បរិកម្មតទៅដរាបដល់កើតអប្បនាចិត្តហើយលះសេចក្តីសម្គាល់ក្នុងសេចក្តីថ្នាំងថ្នាក់, លះសេចក្តីសម្គាល់ក្នុងសភាពផ្សេង ៗ បាន ;

យ៉ាងនេះ ហៅថា អាកាសានញ្ចាយតនជ្ឈាន ។

២. យកវិញ្ញាណជាអារម្មណ៍ បរិកម្មថា ៖ " **អនន្តំ វិញ្ញាណំ ៗ វិញ្ញាណមិនមានទីបំផុត ៗ** " ; បរិកម្មទៅដរាបដល់កើតអប្បនាចិត្តហើយលះសេចក្តីសម្គាល់ក្នុងអាកាសានញ្ចាយតនចេញបាន ;

យ៉ាងនេះ ហៅថា វិញ្ញាណញ្ចាយតនជ្ឈាន ។

៣. ឥតមានយកអ្វីជាអារម្មណ៍ទេ បរិកម្មថា ៖ " **នត្ថិ កិញ្ចិ ៗ របស់អ្វីបន្តិចបន្តួចក៏មិនមាន ៗ** " ; បរិកម្មទៅដរាបដល់កើតអប្បនាចិត្ត ហើយលះសេចក្តីសម្គាល់ក្នុងវិញ្ញាណញ្ចាយតនចេញបាន ;

យ៉ាងនេះ ហៅថា អាកិញ្ចញ្ញាយតនជ្ឈាន ។

៤. ឥតមានយកអ្វីជាអារម្មណ៍ឡើយ ហើយនឹងវិសេសជាងនោះទៅទៀត បរិកម្មថា ៖ " **សន្តមេតំ បណីតមេតំ ធម្មជាតិនុ៎ះ ល្អិតណាស់ ធម្មជាតិនុ៎ះ ឧត្តមក្រៃពេក** " បរិកម្មទៅដរាបដល់កើតអប្បនាចិត្ត ហើយលះសេចក្តីសម្គាល់ក្នុងអាកិញ្ចញ្ញាយតនចេញបាន ;

យ៉ាងនេះ ហៅថា នេវសញ្ញានាសញ្ញាយតនជ្ឈាន ។

បុគ្គលដែលសម្រេចឈានទី ៤ នេះ នឹងហៅថាដឹងខ្លួនក៏មិនមែន ឬនឹងថាមិនដឹងខ្លួនក៏ទេ ។

## សំដែងបញ្ជាក់អំពីរូបជ្ឈាន និងអរូបជ្ឈាន

ឈានទាំង ៤ ដែលពោលមកខាងដើមនោះ បានជាហៅថា **រូបជ្ឈាន** ព្រោះនៅអាស្រ័យវត្ថុដែលមានរូបគឺកសិណឲ្យជួយឧបត្ថម្ភនៅឡើយ ; តែកាលបើអ្នកដែលធ្វើបានហាត់ធ្វើរូបជ្ឈានទាំង ៤ នោះឲ្យច្នឹក ដរាបដល់តាំងផ្ដើមធ្វើវេលាណាក៏សម្រេចវេលានោះដោយរហ័សបាន, ហើយក៏ហាត់ធ្វើវិធីដែលក្រនិងល្អិតល្អជាងនោះឡើងទៅទៀត គឺលើកកសិណចេញដែលហៅថា **បើកកសិណ** ហើយចូលឈានមិនបាច់ប្រើកសិណតទៅ ទើបបានឈ្មោះថា **អរូបជ្ឈាន** ដែលពោលរួចមកហើយថា ៤ នោះឯង ។

សូមសំដែងបញ្ជាក់អំពីអរូបជ្ឈានម្តងទៀត ដូចតទៅនេះ ៖

១. ថ្នាក់ដំបូងបង្អស់ យកអាកាសជាអារម្មណ៍ គឺនឹករំពឹងថា ៖ " អាកាសជាធម្មជាតឥតទីបំផុត " តែម្យ៉ាង, មិននឹកដល់បដិភាគនិមិត្ត មិនយករូបជាអារម្មណ៍ឡើយ ;

យ៉ាងនេះ ហៅថា អាកាសានញ្ចាយតនជ្ឈាន ។

២. ថ្នាក់ទី ២ លើកគំនិតដែលគិតដល់អាកាសនោះចេញ, បែរទៅគិតដល់វិញ្ញាណតែមួយវិញ ថា " វិញ្ញាណជាធម្មជាតិមិនមានទីបំផុត ";

យ៉ាងនេះ ហៅថា វិញ្ញាណញ្ចាយតនជ្ឈាន ។

៣. ថ្នាក់ទី ៣ លើកគំនិតដែលគិតដល់វិញ្ញាណចោលចេញទៀត ឥតមាននឹកដល់អ្វីឡើយ គឺធ្វើដួងចិត្តឲ្យសម្ងំនៅតែមួយឥតមានអ្វីមកជាប់ជំពាក់ ;

យ៉ាងនេះ ហៅថា អាកិញ្ចញ្ញាយតនជ្ឈាន ។

៤. កាលបើដួងចិត្តចូលស៊ប់ នៅក្នុងឈានជាន់ខ្ពស់ដែលល្អិតជាទីបំផុតដូច្នេះហើយ, បុគ្គលអ្នកចម្រើនឈាននោះក៏រាប់ថាជាអ្នកវិសេសមួយ ពោលគឺមានសេចក្តីដឹងខ្លួនតិចជាទីបំផុតស្ទើរតែនឹងហៅថាមិនដឹងខ្លួនក៏សឹងបាន, ទោះបីមាននរណាមកទះតប់ឬវាយក៏មិនដឹងទាំងអស់, តែមានជីវិតរស់នៅបាន ។

ព្រោះហេតុដូច្នេះបានជាលោកហៅឈានជាន់ខ្ពស់បែបនេះថា នេវសញ្ញានាសញ្ញាយតនជ្ឈាន គឺនឹងថា មានសញ្ញាក៏មិនមែន ឬនឹងថា មិនមានសញ្ញាក៏មិនមែន ។

នេះ ជាសេចក្តីអធិប្បាយអំពីអរូបសមាបត្តិ ឬអរូបជ្ឈានទាំង ៤ ។

រូបជ្ឈាន ៤ និងអរូបជ្ឈាន ៤ រួមជា ៨ ហៅថា **អដ្ឋ - សមាបត្តិ ៗ** នេះតែងប្រព្រឹត្តទូទៅសព្វកាលទាំងពួង គឺមានទាំងខាងក្រៅពុទ្ធកាល និងខាងក្នុងពុទ្ធកាល, តែខាងក្រៅពុទ្ធកាលមិនប្រព្រឹត្តទៅដើម្បីរំលត់កិលេស និងកងទុក្ខបានឡើយ គ្រាន់តែជាទិដ្ឋធម្មសុខវិហារ គឺនៅជាសុខក្នុងធម៌ដែលឃើញហើយ នឹងបានទៅកើតក្នុងព្រហ្មលោកប៉ុណ្ណោះ, ដូចយ៉ាងសមាបត្តិរបស់អាឡារតាបស និងឧទ្ទកតាបសជាដើម ។ សមាបត្តិដែលប្រព្រឹត្តទៅខាងក្នុងពុទ្ធកាល គឺកាលដែលព្រះសម្មាសម្ពុទ្ធជាម្ចាស់បានត្រាស់ហើយនោះ ទើបរំលត់កិលេស និងកងទុក្ខបាន ហៅថា ផលសមាបត្តិ ។ បើថែមបំពេញសញ្ញាវេទយិតនិរោធទៀតផង រួមជា ៩ ហៅថា **អនុបុព្វី - និរោធសមាបត្តិ** ។

នេះ ជាសេចក្តីអធិប្បាយក្នុងអដ្ឋសមាបត្តិ ។

# អធិប្បាយអំពីបញ្ញា

ធម្មជាតិ ដែលមានសេចក្តីឈ្លាសវៃ ស្គាល់ហេតុស្គាល់ផល ឈ្មោះថា **បញ្ញា**, បញ្ញាដែលចេះរក្សាខ្លួនបានដោយស្រួលនៅក្នុងលោក ចាត់ជាលោកិយប្បញ្ញា, បញ្ញាដែលឆ្លងចាកលោកបានដល់មគ្គផលនិព្វាន ចាត់ជាលោកុត្តរប្បញ្ញា ។ ឯផ្លូវប្រតិបត្តិរបស់បញ្ញាដែលជាពហុលានុសាសនី គឺដែលព្រះសម្មាសម្ពុទ្ធជាម្ចាស់ ទ្រង់ត្រាស់ប្រដៅដោយច្រើននោះ បាន

ខាងបញ្ញាដែលដឹងច្បាស់ក្នុងលក្ខណៈទាំង ៣ គឺ ៖

១. **អនិច្ចតា** សភាពជារបស់មិនទៀង ;

២. **ទុក្ខតា** សភាពជាទុក្ខ ;

៣. **អនត្តតា** សភាពជាអនត្តាមិនមែនខ្លួន ។

សេចក្តីនេះ អ្នកប្រាជ្ញគប្បីកំណត់តាមពុទ្ធភាសិតដែលព្រះអរហំសម្មាសម្ពុទ្ធទ្រង់សម្តែង ថា ៖

១. **សព្វេ សង្ខារា អនិច្ចាតិ យទា បញ្ញាយ បស្សតិ**
**អថ និព្វិន្ទតិ ទុក្ខេ ឯស មគ្គោ វិសុទ្ធិយា ។**
២. **សព្វេ សង្ខារា ទុក្ខាតិ យទា បញ្ញាយ បស្សតិ**
**អថ និព្វិន្ទតិ ទុក្ខេ ឯស មគ្គោ វិសុទ្ធិយា ។**
៣. **សព្វេ ធម្មា អនត្តាតិ យទា បញ្ញាយ បស្សតិ**
**អថ និព្វិន្ទតិ ទុក្ខេ ឯស មគ្គោ វិសុទ្ធិយា ។**

សេចក្តីថា **កាលបើបុគ្គលរំពឹងពិចារណាឃើញច្បាស់ដោយបញ្ញាថា ៖**

**១. សង្ខារទាំងឡាយទាំងពួង មិនទៀងមិនឋិតថេរ ...**

**២. សង្ខារទាំងឡាយទាំងពួង ជាទុក្ខព្រួយលំបាក ...**

**៣. សង្ខារទាំងឡាយទាំងពួង ជាអនត្តាមិនមែនខ្លួន ក្នុងកាលណា រមែងមានចិត្តនឿយណាយនឹងកងទុក្ខ ក្នុងកាលនោះ, សេចក្តីដែលបានពិចារណាឃើញថាមិនទៀង ជាទុក្ខ និងជា**

**អនត្តានេះ ជាផ្លូវនៃសេចក្ដីបរិសុទ្ធស្អាត ។**

ដែលហៅថា **សង្ខារ ៗ** នោះ, ក្នុងទីនេះ លោកសំគាល់ថា របស់គ្រប់ចំពូកដែលបច្ច័យតាក់តែងឡើង ទាំងអតីត អនាគត បច្ចុប្បន្ន សុទ្ធតែមិនទៀង ជាទុក្ខ ទាំងអស់មានតែព្រះនិព្វានមួយប៉ុណ្ណោះទើបទៀងទើបសុខ ព្រោះព្រះនិព្វានជាវិសង្ខារផុតចាកបច្ច័យតាក់តែង ជាអសង្ខតៈគឺមិនមានបច្ច័យតាក់តែង, ធម៌ទាំងឡាយទាំងពួងទោះបីជាសង្ខតៈ ឬអសង្ខតៈសុទ្ធតែជាអនត្តាទាំងអស់ ; សូម្បីព្រះនិព្វានក៏រាប់បញ្ចូលក្នុងចំនួនអនត្តាផង ព្រោះមិនមែនខ្លួនដែរ ។

**ឧប្បជ្ជន្តិ និរុជ្ឈន្តិ ឯវំ ហុត្វា អភាវតោ**

**ដែលថាមិនទៀងនោះ ព្រោះកើតឡើងហើយ រលត់ទៅ ៗ បើជាយ៉ាងនេះហើយ ទោះបីនរណា ៗ ក៏បង្វែរឲ្យទៅជាយ៉ាងនោះវិញមិនបាន, គួរនាដូចរបស់ដែលខ្ចីគេមកប្រើមួយសំណើរ ។**

**មុនប្បុនំ បីឡិតត្តា ឧបាទេន វយេន ច**

**ដែលថាជាទុក្ខនោះ ព្រោះសេចក្ដីកើតឡើងនឹងសេចក្ដីសូន្យទៅចេះតែបៀតបៀនញាំញីជាញឹកញយ និងជាទោសព្រោះមានសេចក្ដីក្ដៅក្រហាយដោយភ្លើងទុក្ខ និងភ្លើងកិលេសជានិច្ចជាកាល**

**វសេ អវត្តនាយេវ អត្តវិបក្ខភាវតោ**

**ដែលថាជាអនត្តានោះ ព្រោះមិនប្រព្រឹត្តតាមអំណាចបង្គាប់**

## បញ្ញារបស់នរណា មិនមាននរណាជាម្ចាស់ ជារបស់ទទេ មិនមែនខ្លួន ជារបស់ផ្សេងអំពីខ្លួន ។

បញ្ញាដែលពិចារណាឃើញច្បាស់ក្នុងលក្ខណៈទាំង ៣ មានសេចក្តីដូចសំដែងមកនេះ ជាផ្លូវនៃមគ្គផលព្រះនិព្វាន ។

ចិត្តដែលប្រព្រឹត្តទៅក្នុងធម៌ តាំងអំពីអដ្ឋសមាបត្តិជាដើម ដរាបដល់មគ្គ ផល ព្រះនិព្វាន លោកហៅថា **អធិចិត្ត** ។

ការបំពេញព្យាយាមក្នុងអធិចិត្ត ក៏គឺធ្វើអធិចិត្តឲ្យកើតឲ្យមានឡើងដោយលំដាប់នោះឯង ។

**ពាក្យ**ដែលប្រដៅឲ្យបំពេញព្យាយាមក្នុងអធិចិត្ត ដូចពោលមកហើយនេះ រាប់ថាជា **ពុទ្ធសាសនា** ពាក្យប្រដៅរបស់ព្រះពុទ្ធទាំងឡាយ គឺព្រះពុទ្ធរាល់ព្រះអង្គដែលទ្រង់បានត្រាស់ក្នុងកាលទាំងពួងតែងប្រដៅដូច្នេះ ។

# ចប់កណ្ឌទី ១១

**ចម្លងចប់នៅទីក្រុងម៉ុងរេអាល, ថ្ងៃទី ១០ ខែ វិច្ឆិកា ២០១១*
*ត្រូវនឹងថ្ងៃ ១៥ កើត ខែ កត្តិក ព.ស. ២៥៥៥*
*វ៉ាត ភិរក្ស*

# សមាសភាពចូលរួម

១. ព្រះតិក្ខុ ធីង ធីម (ចន្ទត្ថេរ)

២. ព្រះតិក្ខុ សុំ ប៊ុនធឿម (សុវណ្ណត្ថេរោ)

៣. ឧបាសក ឡាវ លាងថេង

៤. ឧបាសក ម៉ិញ សាវ៉ាន

៥. លោក វ៉ាត សុគន្ធ

៦. លោក វ៉ាត តារា ( ទីទី )

៧. លោក វ៉ាត ម៉ូលីវណ្ណ

៨. កញ្ញា វ៉ាត វារីយ៉ា



# នាមពុទ្ធបរិស័ទ

## មានសទ្ធាជ្រះថ្លាបានបរិច្ចាគបច្ច័យដើម្បីបោះពុម្ព

## សៀវភៅ " ឱវាទបាតិមោក្ខ " ជាធម្មទាន ៖

. ព្រះភិក្ខុ **ធឹង ធីម** (**ចន្ទត្ថេរ**) ចៅអធិការវត្ត **ធម្មិការាម** ............ ១០០ ដុល្លារ
. ព្រះភិក្ខុ **ហ៊ុន ឃួយ** វត្ត **ធម្មិការាម** ............................................ ៦០ ដុល្លារ
. ព្រះភិក្ខុ **សុំ ម៉ុនធៀម** (**សុវណ្ណត្ថេរោ**) វត្ត **ពុទ្ធសុទ្ធារាម** ....... ១៥០ ដុល្លារ
. ព្រះភិក្ខុ **ពិន ហោ** (**ធម្មសារោ** ) ................................................ ៣០ ដុល្លារ
. ព្រះភិក្ខុ **ប៉ាវ សែន** វត្ត **ពុទ្ធស្ថានខ្មែរម៉ុងរអោល** ........................ ២០ ដុល្លារ
. ព្រះអង្គ **ច័ន្ទរាជា** ..................................................................... ៣០ ដុល្លារ
. ឧបាសក **ឡៅ លាងថេង** និងឧបាសិកា **ពឹង ឈីវអ៊ាន** ............. ២៦០ ដុល្លារ
. ឧបាសក **ផាន សុផុន** និងឧបាសិកា **ឈឿង យ៉ាវ** ព្រមទាំងបុត្រ ......... ១២៦ ដុល្លារ
. លោក **តិប វិបុល** និងអ្នកស្រី **ស៊ុំ សោភ័ណ្ឌ** ........................ ១០០ ដុល្លារ
. លោក **កែវ ម៉ុនហាន** និងអ្នកស្រី **លី ឆេងលន់** ................... ១០០ ដុល្លារ
. លោក **តុប រិទ្ធថា** និងអ្នកស្រី **មាស ស៊ីណា** ព្រមទាំងបុត្រ ............. ១០០ ដុល្លារ
. លោក **គិម សុខុម** និងអ្នកស្រី **សែម ខេន** ................................ ៨០ ដុល្លារ
. លោក **នូ ស៊ីយឿន** និងអ្នកស្រី **លី សុភី** ............................... ៨០ ដុល្លារ
. ឧបាសក **ម៉ិញ សាវ៉ាន** និងឧបាសិកា **សិម ចាន់ធូរ៉ា** ................... ៦៥ ដុល្លារ
. ឧបាសក **លឹម ឆេងហ៊ន** និងឧបាសិកា **ឈឿង សុខចេង** ព្រមទាំងបុត្រ ... ៦០ ដុល្លារ
. ឧបាសិកា **ទី ភាយ៉ាន** ................................................................ ៦០ ដុល្លារ
. ឧបាសិកា **គីម មួយហៀង** ........................................................ ៦០ ដុល្លារ
. ឧបាសិកា **ថ្លាង ធុច** ................................................................. ៦០ ដុល្លារ
. ឧបាសិកា **បេ ឡៀង** ................................................................. ៥០ ដុល្លារ
. លោក **សួស ប៉ុណ្ណាវុធ** និងអ្នកស្រី **សិម វិច្ឆិកា** ........................ ៥០ ដុល្លារ

. លោក **តាយ ល័ក្ខ** និងអ្នកស្រី **តាយ តិរម្យ** ............................ ៥០ ដុល្លារ

. លោក **ហួត គិមគាង** និងអ្នកស្រី **តិច ស៊ីន្នួន** ........................ ៥០ ដុល្លារ

. លោក **ឱប ច័ន្ថា** និងអ្នកស្រី **លៀម សុភាព** .......................... ៥០ ដុល្លារ

. លោកយាយ **ឡុត យឿម** ..................................................... ៥០ ដុល្លារ

. លោក **សេក សារុន** ........................................................ ៥០ ដុល្លារ

. ឧបាសក **ហ៊ុន លិមហៀង** ................................................. ៥០ ដុល្លារ

. អ្នកស្រី **ហ៊ុន ម៉ារ៉ានី** .................................................... ៥០ ដុល្លារ

. អ្នកស្រី **អ៊ិន ភាន់យ៉ា** .................................................... ៥០ ដុល្លារ

. ឧបាសក **ហ៊ុន ហេង** និងឧបាសិកា **ឆាង វ៉ែម** ............................ ៥០ ដុល្លារ

. អ្នកស្រី **យឹម ច័ន្ទឌី** ...................................................... ៥០ ដុល្លារ

. លោក **ឡាំ ស្ទីស** និងអ្នកស្រី **តិប សិរីសោភា** ........................ ៥០ ដុល្លារ

. ឧបាសិកា **ស៊ុំ យ៉ាង** ....................................................... ៥០ ដុល្លារ

. អ្នកស្រី **ហ៊ុន ហ៊ាង** ....................................................... ៥០ ដុល្លារ

. លោក **សិម សទ្ធា** និងអ្នកស្រី **ពេជ្រ រីលីន** ............................ ៤០ ដុល្លារ

. លោក **សិម សុមេរ៉ា** និងអ្នកស្រី **ជា ពិសី** ............................... ៤០ ដុល្លារ

. អ្នកស្រី **សក់ សូនី** ព្រមទាំងបុត្រ ............................................ ៤០ ដុល្លារ

. លោក **ផាន ប៊ិត** និងអ្នកស្រី **លឹម ហូង** .................................. ៤០ ដុល្លារ

. លោក **ម៉ី រុណា** និងអ្នកស្រី **ឈឿប ឡាពីន** ព្រមទាំងបុត្រ ...... ៤០ ដុល្លារ

. អ្នកស្រី **សិម ចាន់ណារី** .................................................... ៣៥ ដុល្លារ

. លោក **យន់ សាវុធ** និងអ្នកស្រី **ណាម នី** ................................ ៣០ ដុល្លារ

. លោក **ឌី ស៊ុនហេង** និងអ្នកស្រី **អាង ពៅ** ........................... ៣០ ដុល្លារ

. ឧបាសក **ប៉ែន សារឿន** និងឧបាសិកា **ឡាំ ឈួម** ......................... ៣០ ដុល្លារ

. ឧបាសក **ស សុន** និងឧបាសិកា **អេ វ៉ាន** ................................. ៣០ ដុល្លារ

. ឧបាសក **អ៊ុំម សាម៉ៃ** និងឧបាសិកា **ភួង នាង** ........................... ៣០ ដុល្លារ

---

. ឧបាសិកា **ហេង គិមធី** ព្រមទាំងបុត្រ ............................................. ៣០ ដុល្លារ
. លោក **ខៃ យុនហៃ** និងអ្នកស្រី **សិម ចាន់ធូរ៉ាណា** ............. ៣០ ដុល្លារ
. លោក **តាយ យ៉ន** និងអ្នកស្រី **សឹម ចាន់នី** .............................. ២៥ ដុល្លារ
. កញ្ញា **តាយ តាវី** ......................................................................... ២៥ ដុល្លារ
. លោក **តាន់ ប៊ុនតិក** និងអ្នកស្រី **តាន់ ថានី** ............................. ២០ ដុល្លារ
. លោក **សក្តិ ផល្លា** និងអ្នកស្រី **ចាន់ សុម៉ាលី** ........................... ២០ ដុល្លារ
. លោក **លី គាង** និងអ្នកស្រី **អ៊ុក គិមហ៊ាង** ........................... ២០ ដុល្លារ
. លោក **អៀម រឿន** និងអ្នកស្រី **គី រិម** ........................................ ២០ ដុល្លារ
. លោក **ហ្កេច ហួរ** ......................................................................... ២០ ដុល្លារ
. លោក **ចៅ សុខ** និងអ្នកស្រី **ឈឹម សុនី** ...................................... ២០ ដុល្លារ
. ឧបាសិកា **ណាវ ວ៉ាន់នី** ................................................................ ២០ ដុល្លារ
. លោក **ពេជ្រ តាញ** និងអ្នកស្រី **អ៊ុច ផល្លា** ................................ ២០ ដុល្លារ
. លោក **សឹម មុនី** និងអ្នកស្រី **ស៊ី នួន** ........................................ ២០ ដុល្លារ
. ឧបាសក **ម៉ុម ទុយ** និងឧបាសិកា **ស ស៊ុម** ...................................... ២០ ដុល្លារ
. ឧបាសិកា **តាំង មួយផាង** និងគ្រួសារ .............................................. ២០ ដុល្លារ
. លោក **ប្រាង សន** និងអ្នកស្រី **ទួន សុធីណា** ................................ ២០ ដុល្លារ
. ឧបាសិកា **ជា នាង** ...................................................................... ២០ ដុល្លារ
. ឧបាសិកា **ជា ស្រីយុទ្ធថូ** ............................................................... ២០ ដុល្លារ
. លោក **ស្ងួន ច័ន្ទវេហា** ................................................................... ២០ ដុល្លារ
. លោក **មាស ឧត្តរោ** និងអ្នកស្រី **ជិន ចន្ថា** ................................. ២០ ដុល្លារ
. លោក **នុន ស្បៃ** និងអ្នកស្រី **នុន ណាន់ថា** ................................. ២០ ដុល្លារ
. ឧបាសក **អ៊ូ សុផុន** និងឧបាសិកា **អ៊ូ សុខន** ................................. ២០ ដុល្លារ
. កញ្ញា **វ៉ាត វារីយ៉ា** ........................................................................ ២០ ដុល្លារ
. លោក **វ៉ាត តិរក្ស** និងអ្នកស្រី **មៀច វណ្ណា** ................................. ២០ ដុល្លារ
. អ្នកស្រី **ហ៊ីង យូណា** ...................................................................... ២០ ដុល្លារ

. ឧបាសិកា **ម៉ៅ ទេខ** ........................................................... ២០ ដុល្លារ

. ឧបាសិកា **សេខ សុធានី** ........................................................ ២០ ដុល្លារ

. លោក **ស៊ុំ សើ** និងអ្នកស្រី **អិន ស៊ុំ** ........................................ ២០ ដុល្លារ

. អ្នកស្រី **ស៊ុយ សាម៉ន** ព្រមទាំងគ្រួសារ ........................................ ២០ ដុល្លារ

. ឧបាសក **ឆៅ អុន** និងគ្រួសារ .................................................... ២០ ដុល្លារ

. ឧបាសក **ទិ សៀន** និងឧបាសិកា **នូ** ............................................ ២០ ដុល្លារ

. ឧបាសក **ខាំ មី** និងឧបាសិកា **ប្ល ផាន់**(ប្រទេសស្វីស) ................ ២០ ដុល្លារ

. លោក **ចាន់ អឿន** និងអ្នកស្រី **សឿ សុខុម** .................................. ១៥ ដុល្លារ

. អ្នកស្រី **លី ដែន** ........................................................... ១៥ ដុល្លារ

. អ្នកស្រី **សិម ទេវី** ........................................................... ១៥ ដុល្លារ

. ឧបាសក **ហ៊ិម ឆាន់** និងឧបាសិកា **សាមិត សុវណ្ណ** ......................... ១៥ ដុល្លារ

. ឧបាសិកា **ពឹង ឈីវអ៊ាន** ........................................................ ១២ ដុល្លារ

. ឧបាសក **ម៉ែន សារ៉ាវៃ** និងឧបាសិកា **អ៊ឹម គឹមរ៉ុង** ......................... ១២ ដុល្លារ

. លោកយាយ **ឡេង ឈីន** ........................................................ ១២ ដុល្លារ

. ឧបាសិកា **ត្រឹង រ៉ែន** ........................................................... ១០ ដុល្លារ

. ឧបាសិកា **អ៊ុន យូឡេង** ........................................................ ១០ ដុល្លារ

. ឧបាសិកា **គង់ ញ៉ូ** ........................................................... ១០ ដុល្លារ

. លោក **អ៊ុង ហុកខេង** និងអ្នកស្រី **តៃ អូន** ..................................... ១០ ដុល្លារ

. លោកយាយ **សាមិត** ........................................................... ១០ ដុល្លារ

. លោក **ផាត់ សុភឡិត** និងអ្នកស្រី **ឆៃ សុភិន** ................................ ១០ ដុល្លារ

. អ្នកស្រី **ឡាយ ហេង** ........................................................... ១០ ដុល្លារ

. ឧបាសក **ឈិត ឈាង** ( **យឹម ឈិត** )និងគ្រួសារ ............................. ១០ ដុល្លារ

. លោក **អ៊ុក ចាប** និងអ្នកស្រី **ហ៊ុន ផលរ័ត្ន** ..................................... ១០ ដុល្លារ

. លោក **ឱក សូវៀត** និងអ្នកស្រី **ទេព វណ្ណា** ព្រមទាំងបុត្រ .... ១០ ដុល្លារ

. លោកយាយ **នូ លឹម** ........................................................... ១០ ដុល្លារ

. ឧបាសិកា **លឹម ស៊ីវអេង** ........................................................ ១០ ដុល្លារ

**ឱវាទបាតិមោក្ខ**

---

. ឧបាសិកា **ស៊ីវ គិមសឹង** ............................................................ ១០ ដុល្លារ

. ឧបាសិកា **តែ ធឹងអ៊ី** ព្រមទាំងបុត្រ ............................................. ១០ ដុល្លារ

. ឧបាសក **អ៊ឹម កុសល** និងឧបាសិកា **តែ ធឹងលាភ** ព្រមទាំងបុត្រ.. ១០ ដុល្លារ

. ឧបាសិកា **តែ ចិន្តា** ព្រមទាំងបុត្រ ............................................... ១០ ដុល្លារ

. អ្នកស្រី **ថាច់ ធីនី** ............................................................. ១០ ដុល្លារ

. ឧបាសិកា **ភូ អេងលី** ........................................................... ១០ ដុល្លារ

. អ្នកស្រី **រុន សាវត្ថី** ............................................................ ១០ ដុល្លារ

. អ្នកស្រី **យាន គិត្យា** ............................................................ ១០ ដុល្លារ

. លោក **អ៊ួង ហ៊ាង** និងអ្នកស្រី **វ៉ែន យិម** ..................................... ១០ ដុល្លារ

. លោកយាយ ?????? ................................................................... ១០ ដុល្លារ

. ឧបាសិកា **ម៉េង គិមណាំ** ....................................................... ១០ ដុល្លារ

. អ្នកស្រី **អ៊ុន យូសេង** ............................................................ ៦ ដុល្លារ

. ឧបាសិកា **ស៊ិន ថន** ................................................................ ៦ ដុល្លារ

. ឧបាសិកា **នួវ សេង** ............................................................... ៥ ដុល្លារ

. ឧបាសិកា **យូរ ម្លិះ** ................................................................ ៥ ដុល្លារ

. ឧបាសិកា **សំ ហៀង** ............................................................... ៥ ដុល្លារ

. ឧបាសក **ឡុង** និងឧបាសិកា **ឆៅ ម៉ុន** .......................................... ៥ ដុល្លារ

*សូមប្រគេន និងជម្រាបព្រះតេជព្រះគុណគ្រប់រូប ព្រមទាំងពុទ្ធបរិស័ទទាំងអស់ថា

បច្ច័យដែលបានពីការចូលបោះពុម្ពសៀវភៅ "**ឱវាទបាតិមោក្ខ**"

បានរំលែក ៣៥០ ដុល្លារ ជូនទៅខាងឧបាសក **ហ៊ិម ឆាន់**

ក្នុងការធ្វើថាស CD, DVD ជាធម្មទាន

សូមអនុមោទនា !!!

*សូមពុទ្ធបរិស័ទដែលបានចូលរួមបោះពុម្ពសៀវភៅ, ធ្វើជាថាស
ជាធម្មទាន បានសម្រេចនូវសម្មាទិដ្ឋិគ្រប់ៗជាតិ
និងបានឧបនិស្ស័យរួចផុតចាកទុក្ខទាំងពួង
កុំបីឃ្លៀងឃ្លាតឡើយ !

**សូមអនុមោទនាធម្មទាន** !!!

# ជូនពរព្រះពុទ្ធសាសនា



សូមឲ្យព្រះពុទ្ធសាសនារុងរឿងចំរើន

សូមឲ្យព្រះពុទ្ធសាសនាផ្សាយទូទៅពេញពិភពលោក

សូមឲ្យលោកទាំងមូលបានប្រកបដោយសន្តិភាព

ព្រះសក្យមុនីសម្ពុទ្ធទ្រង់ត្រាស់ថា **នត្ថិ សន្តិ បរំ សុខំ**

ពុំមានសេចក្តីសុខដទៃក្រៅពីសេចក្តីស្ងប់ឡើយ ។

# ឱវាទបាតិមោក្ខ...

ព្រះពុទ្ធបរមគ្រូជាម្ចាស់ទ្រង់រំពឹងឃើញថា ឱកាសនេះជាឱកាសមួយដ៏សមគួរល្មមនឹងសំដែងធម៌, ដូច្នេះ ព្រះអង្គទ្រង់ប្រមូលភិក្ខុសាវ័កទាំងអស់ ឲ្យមកប្រជុំគ្នានៅក្នុងវត្តវេឡុវ័ន ហើយទ្រង់បានសំដែងឱវាទបាតិមោក្ខទូន្មានប្រៀនប្រដៅភិក្ខុទាំងនោះឲ្យប្រតិបត្តិ និងប្រកាន់ខ្ជាប់នូវគោលការណ៍ចំបង ៗ ដូច ៗ គ្នា ។ ខ្លឹមសារនៃព្រះឱវាទនោះគឺ ៖

១. កុំធ្វើអំពើបាបគ្រប់យ៉ាង ;

២. ចូរធ្វើអំពើកុសលទាំងពួង ;

៣. ចូរសំអាតចិត្តឲ្យបរិសុទ្ធប្រាសចាកកិលេសទាំងឡាយ ។

មានរឿងសំខាន់ ៗ ទាំងឡាយ ៤ យ៉ាងទៀតដែលត្រូវចងចាំអំពីសម័យប្រជុំនោះគឺ ...

*** ចម្លងតាមច្បាប់ដើមដោយខ្ញុំព្រះករុណា ខ្ញុំបាទ ទ៉ាត ទិវត្ស**

**សម្រាប់ជាធម្មទាន**

